# សៀវភៅធម៌

ស្រង់ពីព្រះរាជនិពន្ធរបស់ព្រះបាហាអ៊ុលឡាហ៍ ព្រះបប
អង្គពិសិដ្ឋអាប់ឌុលបាហា

បកប្រែចេញមកពីសៀវភៅធម៌ភាសាអង់គ្លេស

បោះពុម្ពលើកទី២

ខែមេសា ឆ្នាំ២០១១នៅកម្ពុជា

ដោយ

សហាគមន៍សាសនាបាហៃប្រចាំកម្ពុជា

បាហៃសករាជ ១៦៨

# សេចក្ដីផ្ដើម

សៀវភៅធម៌នេះមានគោលបំណងដើម្បី ជួយដល់អ្នកទាំងឡាយណាដែលមានចិត្តចង់សូត្រធម៌សុំសេចក្ដីសុខ និងសព្ទសាធុការពរពីព្រះដល់ខ្លួនឯង ក្រុមគ្រួសារ មិត្តភក្ដិនិងសហាគមន៍។ ការសូត្រធម៌គឺជាការធ្វើឲ្យចិត្តគំនិតនិងស្មារតីរបស់យើងភ្លឺស្វាង ស្រស់ស្រាយបរិសុទ្ធ។ អ្នកទាំងឡាយណាដែលមានបំណងចង់អានឬសូត្រធម៌នោះ ពួកគេអាចអានឬសូត្របាន ព្រោះធម៌នេះគឺសម្រាប់មនុស្សគ្រប់រូប។ ដូចដែលព្រះបរមគ្រូបានមានព្រះបន្ទូលថា:

ការសូត្រធម៌គឺជាការសន្ទនាជាមួយនឹងព្រះ។

ការសូត្រធម៌គឺជាជណ្ដើរតភ្ជាប់ពីផែនដីទៅកាន់ឋានសួគ៌។

ការសូត្រធម៌គឺជារងើកភ្លើង សំរាប់ដុតបំផ្លាញរបាំងទាំងឡាយដែលរាំងយើងពីសោភ័ណភាពរបស់ព្រះ។

ការសូត្រធម៌គឺជាពន្លឺមួយ ដែលនឹងនាំយើងឲ្យបានដល់មហាសមុទ្រនៃព្រះវត្តមានរបស់ព្រះ។

ឱម្នាលនៃមនុស្សលោកអើយ សព្ទសាធុការពរដែលបានមកពីព្រះគឺជាទីកន្លែង ជាផ្ទះសំបែង ជាទីជំរក ជាទីក្រុង ជាដួងចិត្ត ជាព្រៃភ្នំក្រំថ្ម ជាទីជំរកជ្រកពួន ជារូងភ្នំជ្រោះជ្រលងដងអូរ ជាទឹកដី ជាសមុទ្រ ជាកោះនិងជាវាលស្មៅដែលព្រះបានបង្កើតមកនិងជាសេចក្ដីសរសើរដ៏រុងរឿងរបស់ទ្រង់។

# មាតិកា

ធម៌សូត្រសម្រាប់សាសនាបាហៃ..........................................
ធម៌កាតព្វកិច្ចបទខ្លី...........................................................
ធម៌កាតព្វកិច្ចបទមធ្យម.......................................................
ធម៌កាតព្វបទវែង...............................................................
ធម៌អធិដ្ឋានសុំការជួយទ្រទ្រង់និងសង្គហៈ............................
ធម៌សម្រាប់កុមារ...............................................................
ធម៌សម្រាប់ទារក...............................................................
ធម៌មរណភាព.....................................................................
ធម៌ទូទៅសម្រាប់មរណភាព..................................................
ធម៌សម្រាប់ស្ត្រី................................................................
ធម៌សម្រាប់ស្វាមី..............................................................
ការលះបង់ចិត្តឬការមិនជាប់ជំពាក់ចិត្ត.................................
ធម៌សូត្រសម្រាប់ភាពរឹងមាំចំពោះកិច្ចព្រមព្រៀង..................
ធម៌សូត្រសម្រាប់ការនៅជិតព្រះ..........................................
ធម៌សូត្រលើកតម្កើងនិងការដឹងគុណព្រះ..............................
ធម៌សូត្រសុំឲ្យព្រះឃុំគ្រង...................................................
ធម៌សូត្រសុំការលើកលែងទោស.........................................
ធម៌សូត្រពេលព្រឹក...........................................................
ធម៌សូត្រពេលល្ងាច..........................................................

ធម៌សូត្រពេលពាក់កណ្ដាលអាធ្រាត....................................

ធម៌សូត្រសម្រាប់គ្រួសារ.....................................................

ធម៌សូត្រសម្រាប់មាតាបិតា.................................................

ធម៌សូត្រពេលធ្វើដំណើរ.....................................................

មូនិធិឬការចូលបច្ច័យនិងគ្រឿងបរិក្ខាធ្វើបុណ្យ........................

ធម៌សូត្រនាពេលបុណ្យ១៩ថ្ងៃ..............................................

ការជួបជុំគ្នា.........................................................................

ធម៌សូត្រព្យាបាលជម្ងឺ..........................................................

ធម៌សូត្រសម្រាប់មនុស្សជាតិ................................................

ធម៌អធិដ្ឋានសម្រាប់ផ្សព្វផ្សាយសាសនា...............................

ធម៌អាពាហ៍ពិពាហ៍...........................................................

ធម៌សូត្រសម្រាប់ការបម្រើ...................................................

ធម៌សូត្រសម្រាប់ការលូតលាស់ផ្នែកខាងស្មារតី......................

ធម៌សូត្រសម្រាប់អង្គប្រជុំសភា............................................

ធម៌សាមគ្គី...........................................................................

ធម៌សូត្រតមអាហារ.............................................................

ធម៌សូត្រសម្រាប់ថ្ងៃបុណ្យអាយ៉ាំអ៊ីហា...................................

ធម៌សូត្រនាឱកាសបុណ្យចូលឆ្នាំថ្មី.......................................

កថាខណ្ឌរបស់អាម៉ាត់........................................................

កថាខណ្ឌសម្រាប់ការចូលគាល់ព្រះបាហាអ៊ុលឡាហ៍.............

# ធម៌សូត្រសម្រាប់សាសនាបាហៃ

ជម្រើសធម៌សូត្រដែលត្រាស់បញ្ចេញដោយព្រះបាហាអ៊ុលឡាហ៍,
ព្រះបប, ហើយនិងអង្គពិសិដ្ឋអាប់ឌុលបាហា។

ឱម្ចាលនៃមនុស្សលោកអើយ សព្វសាធុការពរដែលបានមកពីព្រះ គឺជាទីកន្លែង ជាផ្ទះ សំបែង ជាទីជម្រក ជាទីក្រុង ជាដួងចិត្ត ជាព្រៃភ្នំក្រំថ្ម ជាទីជម្រកជ្រកពួន ជារូងភ្នំជ្រោះជ្រលងដងអូរ ជាទឹកដី ជាសមុទ្រ ជាកោះ និងជាវាលស្មៅដែលព្រះបានបង្កើតមកនិងជាសេចក្តីសរសើរដ៏រុងរឿងរបស់ទ្រង់” ។

ឱអ្នកបម្រើរបស់អង្គអញអើយ! ចូរអ្នកសូត្រធ្វើបទកំណាព្យរបស់ព្រះអាទិទេពជាម្ចាស់ដែលអ្នកបានទទួលពួកវានោះ ព្រោះការសូត្រធ្វើបទដល់កំណាព្យទាំងនោះ វាអាចនាំខ្លួនអ្នកឲ្យខិតជិតព្រះអាទិទេពជាម្ចាស់បាន។

ឱអ្នកបម្រើរបស់អង្គអញអើយ! ចូរអ្នកសូត្រធ្វើបទកំណាព្យរបស់ព្រះអាទិទេពជាម្ចាស់ ដែលអ្នកបានទទួលពួកវានោះឡើង ព្រោះការសូត្រធ្វើបទដល់កំណាព្យទាំងនោះ វាអាចនាំខ្លួនអ្នកខិតជិតនឹងព្រះអាទិទេពជាម្ចាស់បាន ព្រោះភាពពិរោះរងំរណ្តំដែលកើតមកពីបទដែលអ្នកបានធ្វើនោះ ប្រាកដជាអាចលួងលោមដល់វិញ្ញាណក្ខន្ធរបស់អ្នកខ្លួនឯង ហើយនិងធ្វើឲ្យទាក់ចិត្តជិតអារម្មណ៍ដល់ដួងចិត្តរបស់មនុស្សទាំងអស់ផងដែរ។

នរណាដែលបានសូត្រកំណាព្យ ដែលបានត្រាស់បញ្ចេញដោយព្រះអាទិទេពជាម្ចាស់នៅក្នុងបន្ទប់របស់គាត់ដែលដាច់ដោយឡែកពីគេនោះ ទេវតារបស់ព្រះអាទិទេពដែល បានពង្រាយនូវពាក្យដ៏ក្រអូបសុសសាយនៅគ្រប់ទីកន្លែង ដែលបានបន្លឺឡើងពីមាត់របស់អ្នកនោះ ហើយព្រមទាំងញ៉ាំងឲ្យបេះដូងមនុស្សគ្រប់រូបដើរបានត្រឹមត្រូវទៀតផង។ ថ្វីត្បិតតែគ្រាដំបូង គាត់នៅមិនទាន់ដឹងពីឥទ្ធិពលរបស់វាក៏ដោយ ក៏គុណធម៌ដែលកើតមកពីសិរីល្អរបស់ព្រះបានកើតមានដល់គាត់ហើយដែរ ហើយនៅពេលក្រោយឥទ្ធិពលនោះ នឹងបានហ្វឹកហាត់ដល់វិញ្ញាណក្ខន្ធរបស់គាត់ទៀតផង។ ពិតណាស់អាថ៌កំបាំងនៃការត្រាស់ដឹងរបស់ព្រះត្រូវបានគេចេញក្រិត្យឲ្យដោយគុណធម៌នៃឆន្ទៈរបស់ទ្រង់ ដែលជាប្រភពអំណាចហើយនិងគតិបណ្ឌិត។

# ធម៌ភាគព្វកិច្ចបទខ្លី

*ធម៌កាតព្វកិច្ចប្រចាំថ្ងៃមានចំនួនបី...អ៊ីចឹងអ្នកជំនឿអាចជ្រើសរើសធម៌មួយក្នុងចំណោមធម៌ទាំងបីមកសូត្របាន ប៉ុន្តែក្នុង១ថ្ងៃត្រូវតែសូត្រមួយក្នុងចំណោមទាំងបីនោះ ហើយក៏ត្រូវតែអនុលោមទៅតាមទិសមួយនៅតាមតំបន់ដែលអ្នកសូត្រនោះ។*

*-ដកស្រង់ពីលិខិតមួយច្បាប់ក្នុងនាមលោកស្ហ៊ូហ្គីអែហ្វិនឌី-*

*រយៈពេលធម៌កាតព្វកិច្ចដែលត្រូវបានគេសូត្រគឺមានពេលព្រឹក ថ្ងៃត្រង់ហើយនិងពេលល្ងាច នោះមានន័យថាចន្លោះពេលថ្ងៃរះ ហើយនិងថ្ងៃលិចជាពេលល្ងាច ហើយរហូតទៅដល់លិចបានពីរម៉ោងហើយរយៈពេលនេះក៏ជាពេលល្ងាចដែរ។*

*-សេចក្តីសង្ខេបនិងការដកស្រង់មកពីគីតាបអ៊ីអាកដាស-*

*ធម៌នេះក្នុង២៤ម៉ោងសូត្រម្តង គឺសូត្រនៅចន្លោះថ្ងៃត្រង់និងពេលល្ងាច។*

បពិត្រព្រះ អាទិទេពជាម្ចាស់ ទូលបង្គំសូមធ្វើជាសក្ខីភាពថាព្រះអង្គបានបង្កើតទូលព្រះបង្គំមក ដើម្បីឲ្យទូលព្រះបង្គំបានស្គាល់និងបូជាសក្ការៈចំពោះព្រះអង្គ។ ក្នុងខណៈនេះទូលព្រះបង្គំ បាន

ជ្រាបហើយ នូវភាពទន់ខ្សោយរបស់ទូលព្រះបង្គំទៅនឹងបារមីដ៏បវរ របស់ព្រះអង្គ និងភាពក្រខ្សត់របស់ទូលបង្គំទៅនឹងទ្រព្យសម្បត្តិ ដ៏ធំធេងរបស់ព្រះអង្គ។ ពុំមានព្រះដទៃណាទៀតឡើយក្រៅពីព្រះអង្គ ព្រះអង្គទ្រង់ជួយរំដោះទុក្ខភ័យនៃសត្វលោក ព្រះអង្គគង់នៅជានិច្ចដោយបារមីនៃព្រះអង្គឯង។

-ព្រះបាហាអ៊ុលឡាហ៍-

# ធម៌ភាគព្វកិច្ចមធ្យម

*ធម៌នេះសូត្របីដងក្នុងមួយថ្ងៃ គឺសូត្រនៅ ពេលព្រឹក ថ្ងៃត្រង់ ហើយនិងពេលល្ងាច។*

*នរណាមានចិត្តចង់សូត្រធម៌នេះ ចូរលាងដៃឲ្យបានស្អាតល្អ ហើយនៅពេលលាងដៃនោះ ចូរសូត្រធម៌ដូចតទៅនេះ (ធម៌សំរាប់លាងដៃ)*

“ ឱព្រះលោកអើយ សូមព្រះអង្គពង្រឹងដៃរបស់ទូលព្រះបង្គំឲ្យមានកម្លាំងរឹងមាំឡើងផង ដើម្បីឲ្យវាមានកម្លាំងក្នុងការកាន់ទ្រនូវគម្ពីររបស់ព្រះអង្គដោយភាពនឹងធឹងដើម្បីកុំឲ្យអំណាចលោកិយណាមួយស្ថិតនៅលើវាបានឡើយ។ ហើយក៏សូមព្រះអង្គការពារវាកុំឲ្យមានអ្វីមួយដែលមិនមែនជាកម្មសិទ្ធិរបស់វាមកជ្រៀតជ្រែកវាបានឡើយ។ ពិតណាស់ ព្រះអង្គគឺជាព្រះអាទិទេព ដែលប្រកបដោយអានុភាពដ៏ខ្លាំងក្លាបំផុត។

*លាងដៃរួចហើយត្រូវលាងមុខមាត់ឲ្យស្អាតល្អដូចលាងដៃដែរ ហើយនៅពេលលុបលាងមុខត្រូវសូត្រធម៌ដូចតទៅ(ធម៌លុបលាងមុខ)*

ឱព្រះអាទិទេពជាម្ចាស់លោកអើយ ទូលបង្គំបានងាកមុខមករកព្រះអង្គហើយ សូមព្រះអង្គឆ្លុះបញ្ចាំងពន្លឺនៃព្រះភក្ត្ររបស់ព្រះអង្គមករកមុខរបស់ទូលព្រះបង្គំផង។ ហើយសូមព្រះអង្គការពារមុខរបស់ទូលព្រះបង្គំ កុំឲ្យវាងាកទៅរកនរណាក្រៅពីព្រះអង្គឡើយ” ។

*បន្ទាប់ពីលាងដៃនិងមុខរួចហើយ ចូរងើបឈរឡើងហើយបែរមុខទៅកាន់ទិស(ហ្គិបលី) គឺបែរមុខទៅរកទីសក្ការៈវិមានបាជី នៅទីក្រុងអាកា ហើយចូរសូត្រធម៌ដូចតទៅ:*

“ ព្រះអាទិទេពជាម្ចាស់បានមានបន្ទូលធ្វើជាសក្ខីភាពថា ពុំមានព្រះដទៃទៀតណាក្រៅពីព្រះអង្គឡើយ។ រាជាណាចក្រនៃការត្រាស់ដឹងហើយនិងរាជាណាចក្រនៃមាបនកម្មទាំងអស់ គឺជារបស់ព្រះអង្គ។ ពិតណាស់ ព្រះអង្គដែលជាព្រះអាទិទេពជាម្ចាស់បានបង្ហាញឲ្យគេឃើញនូវព្រះសាស្តាមួយអង្គ ដែលជាប្រភពនៃការត្រាស់ដឹងដែលជាអ្នកសន្ទនានឹងព្រះអង្គនៅលើកំពូលភ្នំស៊ីណាអ៊ី ហើយព្រះអង្គក៏ជានភាល័យដ៏ឧត្តម ត្រូវបានគេធ្វើឲ្យមានពន្លឺរស្មីចិញ្ចែងចិញ្ចាចឡើង តាមរយៈនភាល័យនោះហើយព្រះអង្គក៏ជាដើមឈើបរលោកជាអានន្ត ដែលព្រះសាស្តាអង្គមុនបានមានបន្ទូលដល់គ្រប់ព្រះអង្គ ហើយតាមរយៈព្រះអង្គនេះទ្រង់ក៏ជាអ្នកដែលគេបានប្រកាសឲ្យមនុស្សគ្រប់គ្នា ដែលនៅក្នុងឋានសួគ៌

ហើយនិងផែនដីនេះបានដឹងផងដែរថា “ ចូរក្រលេកមើលចុះគ្រប់ភោគទ្រព្យកំពុងតែកើតមានឡើង ហើយផែនដីនិងឋានសួគ៌ ភាពរុងរឿងនិងវិជិតរាជ្យទាំងអស់នេះជារបស់ព្រះ ដែលជាព្រះអាទិទេពរបស់មនុស្សគ្រប់គ្នា ហើយក៏ជាម្ចាស់រាជបល្ល័ង្កនៅលើឋានសួគ៌និងផែនដីនេះផងដែរ!។

*បន្ទាប់មកទៀតចូរឈរឱនដោយដាក់ដៃ ទាំងពីរលើជង្គង់ទាំងទ្វេហើយសូត្រធម៌ខាងក្រោមនេះ៖*

“ ព្រះអង្គជាព្រះដ៏ប្រសើរលើសលុប ហួសពីការសរសើររបស់ទូលព្រះបង្គំ ហើយនិងការសរសើររបស់អ្នកដទៃក្រៅពីទូលបង្គំ ព្រះអង្គគឺជាព្រះដ៏ប្រសើរលើសលុបហួសពីការពិពណ៌នារបស់អ្នកទាំងអស់គ្នាដែលនៅលើឋានសួគ៌ ហើយនិងអ្នកទាំងអស់គ្នាដែលនៅលើផែនដីនេះ! ”

*បន្ទាប់មកទៀតឈរជងខ្លួនឲ្យត្រង់ ដោយលាតបាតដៃទាំងពីរហើយបោះដៃទាំងពីរទៅមុខលើកឡើង ហើយងើបមុខឡើងដោយសូត្រធម៌ខាងក្រោមនេះ៖*

ឱព្រះអាទិទេពជាម្ចាស់របស់ទូលព្រះបង្គំអើយ សូមព្រះអង្គកុំធ្វើឲ្យមនុស្សណាដែលបានតោងទៅនឹងជាយនៃមេត្តាធម៌ ហើយនិងសិរីល្អរបស់ទ្រង់ ដោយម្រាមដៃអង្វរកររបស់គេទាំងអស់

សង្ឃឹមឡើយព្រោះអ្នកទាំងនោះ ជាអ្នកបង្ហាញនូវមេត្តាធម៌របស់ព្រះអង្គ ដែលជាព្រះប្រកបដោយមេត្តាធម៌ដ៏ខ្ពង់ខ្ពស់បំផុត!”

*បន្ទាប់មកទៀតចូរអង្គុយចុះហើយសូត្រធម៌ខាងក្រោមនេះ៖*

ទូលព្រះបង្គំ សូមធ្វើជាសក្ខីភាពដល់សាមគ្គីភាព ហើយនិងភាពតែមួយរបស់ទ្រង់ ហើយព្រមទាំងសូមធ្វើជាសក្ខីភាពថាព្រះអង្គគឺជាព្រះអាទិទេពដែលគ្មានព្រះអាទិទេពណាផ្សេងទៀតឡើយក្រៅពីព្រះអង្គ។ ពិតណាស់ ព្រះអង្គបានបញ្ចេញឲ្យឃើញនូវបុព្វហេតុសាសនានិងបានបំពេញនូវកិច្ចព្រមព្រៀងរបស់ព្រះអង្គ ព្រមទាំងបានបើកចំហទ្វារនៃសិរីល្អរបស់ទ្រង់ ដ៏ធំទូលាយសម្រាប់អ្នកទាំងអស់គ្នាដែលរស់នៅក្នុងឋានសួគ៌ហើយនិងផែនដីនេះផងដែរ។ សព្វសាធុការពរ សុខសន្តិភាព សេចក្តីគោរពស្រឡាញ់ ហើយនិងភាពរុងរឿងគឺស្ថិតនៅលើអ្នកជាទីស្រលាញ់របស់ទ្រង់ ដែលជាអ្នកផ្លាស់ប្តូរហើយជាវាសនារបស់ពិភពលោកនាំទៅរកព្រះអង្គ ហើយក៏ជាអ្នកផ្តល់នូវគ្រប់សេចក្តីសង្ឃឹមរបស់ពួកគេឲ្យស្ថិតនៅជាមួយនឹងព្រះអង្គជានិច្ច។ ពិតណាស់ ព្រះអង្គគឺជាអ្នកផ្តល់នូវការលើកលែងទោសជានិច្ច ហើយក៏ជាព្រះដែលប្រកបដោយសប្បុរសធម៌គ្រប់យ៉ាងដែរ។

*ពាក្យទាំងនេះគឺជាពាក្យសំរាប់សូត្រជំនួសធម៌កាតព្វកិច្ចបទវែង បើនរណាម្នាក់មិនចង់សូត្រធម៌កាតព្វកិច្ចបទវែងទេ អាចជ្រើសរើសពាក្យទាំងនេះដើម្បីសូត្រៈ*

ព្រះអាទិទេពជាម្ចាស់បានធ្វើជាសក្ខីភាពថា គ្មានព្រះណាក្រៅពីព្រះអង្គឡើយ ព្រះអង្គគឺជាព្រះជួយរំដោះទុក្ខដល់មនុស្សលោក ហើយក៏ជាព្រះដែលគង់នូវដោយអង្គឯង។”

*ព្រះធម៌នេះមានសក្តានុភាពស្មើនឹងសូត្រធម៌បទកាតព្វកិច្ចទាំងស្រុង។ ហើយម្យ៉ាងវិញទៀតនៅពេលអង្គុយត្រូវសូត្រនូវធម៌ទាំងនេះ ហើយធម៌ទាំងនេះគឺស្មើនឹងធម៌បទវែងត្រង់វគ្គអង្គុយះ*

ទូលព្រះបង្គំសូមធ្វើជាសក្ខីភាពដល់សាមគ្គីភាព ហើយនិងភាពតែមួយរបស់ព្រះអង្គហើយទូលព្រះបង្គំក៏សូមធ្វើជាសក្ខីភាពថាព្រះអង្គគឺជាព្រះអាទិទេពជាម្ចាស់ដែលគ្មានព្រះអាទិទេពណាក្រៅពីព្រះអង្គឡើយ។

-ព្រះបាហាអ៊ុលឡាហ៍-

# ធម៌ភាគព្វកិច្ចបទវែង

*ធម៌នេះគឺត្រូវជ្រើសរើសសូត្រក្នុង២៤ម៉ោងម្តង នរណាជ្រើសរើសសូត្រធម៌នេះ ចូរក្រោកឈរឡើង ហើយបែរមុខឆ្ពោះទៅរកព្រះអាទិទេពជាម្ចាស់ នៅពេលដែលឈរនៅក្នុងទីកន្លែងនោះ ចូរសម្លឹងទៅខាងស្តាំហើយខាងឆ្វេង ធ្វើដូចជាកំពុងតែរង់ចាំមេត្តាធម៌ពីព្រះអាទិទេពជាម្ចាស់ដែលជាព្រះប្រកបដោយមេត្តាធម៌ ហើយក៏ជាព្រះប្រកបដោយក្តីករុណាធម៌ដ៏ខ្ពស់បំផុត បន្ទាប់មកចូរសូត្រធម៌នៅខាងក្រោមនេះ៖*

ឱព្រះអាទិទេពជាម្ចាស់នៃគ្រប់រូបក្ខន្ធ ហើយនិងជាអ្នកបង្កើតឋានសួគ៌អើយ! ទូលព្រះបង្គំសូមអង្វរដល់ទ្រង់ ដែលជាប្រភពនៃសិរីល្អរបស់ព្រះអង្គ ដែលជាព្រះគួរឲ្យសរសើរបំផុត ហើយក៏ជាព្រះដែលប្រកបដោយភាពសំបូររុងរឿងគ្រប់យ៉ាងជំនួសពួកគេ សូមឲ្យព្រះអង្គធ្វើឲ្យការអធិដ្ឋានរបស់ទូលព្រះបង្គំ បានក្លាយទៅជាភ្លើងដើម្បីដុតកំទេចចោលនូវស្បៃឧបសគ្គដែលបានបិទបាំងរូបទូលព្រះបង្គំពីសិរីល្អរបស់ព្រះអង្គ ហើយនិងដើម្បីធ្វើឲ្យការអធិដ្ឋានរបស់ទូលបង្គំនឹងក្លាយជាពន្លឺដើម្បីដឹកនាំទូលព្រះបង្គំ ឲ្យបានទៅដល់មហាសាគរនៃព្រះវត្តមានរបស់ព្រះអង្គផង។

*បន្ទាប់មកចូរលើកដៃទាំងពីរទៅមុខដែលជាការអង្វរករដល់ព្រះអាទិទេពជាម្ចាស់- ដែលជាព្រះគួរឲ្យសរសើរ ហើយនិងជាព្រះដែលនាំមកនូវសេចក្តីសុខ រួចហើយសូត្រថា:*

ឱព្រះអង្គដែលជាទីប្រាថ្នារបស់ពិភពលោក ហើយនិងអ្នកជាទីស្រឡាញ់របស់មនុស្សគ្រប់ជាតិសាសន៍អើយ! សូមព្រះអង្គទតតម្រង់ទូលព្រះបង្គំឲ្យទូលព្រះបង្គំ បានងាកឆ្ពោះទៅរកព្រះអង្គតែមួយអង្គឯង ហើយសូមព្រះអង្គកំចាត់ចោលនូវគ្រប់ការជំពាក់ចិត្តរបស់ទូលព្រះបង្គំទៅនឹងនរណាដែលមិនមែនជាព្រះអង្គ ហើយក៏សូមព្រះអង្គចងភ្ជាប់ទូលព្រះបង្គំទៅនឹងខ្សែពួររបស់ព្រះអង្គ តាមរយៈសកម្មភាពរបស់មាបនកម្មទាំងមូល ដែលត្រូវបានគេធ្វើឲ្យសាយភាយឡើងផង។ ឱព្រះអាទិទេពជាម្ចាស់នៃទូលបង្គំអើយ ទូលបង្គំជាអ្នកបម្រើរបស់ព្រះអង្គ ហើយក៏ជាបុត្ររបស់អ្នកបម្រើរបស់ព្រះអង្គដែរ។ សូមព្រះអង្គការពារទូលព្រះបង្គំ ដើម្បីឲ្យទូលព្រះបង្គំបានឈរយ៉ាងរឹងមាំដើម្បីធ្វើតាមឆន្ទៈ ហើយនិងសេចក្តីប្រាថ្នារបស់ព្រះអង្គ ហើយសូមព្រះអង្គការពារទូលព្រះបង្គំកុំឲ្យទូលបង្គំមានសេចក្តីប្រាថ្នាអ្វីក្រៅពីសិរីល្អរបស់ព្រះអង្គឡើយ។ ទូលព្រះបង្គំសូមអង្វរដល់ព្រះអង្គ តាមរយៈមហាសាគរនៃក្តីមេត្តារបស់ព្រះអង្គ ហើយនិងសូមអង្វរព្រះអង្គតាមរយៈតារាពេលថ្ងៃ (ព្រះបាហាអ៊ុលឡាហ៍) នៃភាពសមរម្យរបស់ព្រះអង្គ ដើម្បីឲ្យទូលបង្គំបានបម្រើព្រះអង្គជាមួយនឹងអ្នកបម្រើរបស់ព្រះអង្គតាមឆន្ទៈ

ហើយនិងហាឫទ័យរបស់ព្រះអង្គផង។ ពិតណាស់កំលាំងអានុភាពរបស់ព្រះអង្គមានកំលាំងខ្លាំងណាស់មិនអាចរៀបរាប់ ហើយនិងមិនអាចរកអ្វីមកប្រៀបផ្ទឹមបានឡើយ! អ្វីដែលត្រូវបានគេបញ្ចេញឲ្យឃើញតាមរយៈព្រះអង្គ គឺជាសេចក្ដីប្រាថ្នានៃដួងចិត្តរបស់ទូលព្រះបង្គំ ហើយក៏ជាទីស្រឡាញ់នៃវិញ្ញាណក្ខន្ធរបស់ទូលព្រះបង្គំដែរ។ ឱព្រះដែលជាព្រះអាទិទេពរបស់ទូលព្រះបង្គំអើយ! សូមកុំឲ្យទូលព្រះបង្គំមើលឃើញអ្វី ដែលជាសេចក្ដីប្រាថ្នារបស់ទូលបង្គំ ហើយនិងកុំឲ្យទូលព្រះបង្គំមើលឃើញអ្វី ដែលជាទង្វើរបស់ទូលព្រះបង្គំក្រៅពីឆន្ទៈរបស់ព្រះអង្គដែលបានហ៊ុមព័ទ្ធឋានសួគ៌ ហើយនិងផែនដីនេះឡើយ។ ឱព្រះអាទិទេពជាម្ចាស់លោកអើយ! តាមរយៈព្រះនាមដ៏រុងរឿងដែលបានហ៊ុមព័ទ្ធឋានសួគ៌ ហើយនិងផែនដីនេះឡើយ។ ឱព្រះអាទិទេពជាម្ចាស់លោកអើយ តាមរយៈព្រះនាមដ៏រុងរឿងបំផុតរបស់ព្រះអង្គ ទ្រង់គឺជាព្រះរបស់មនុស្សគ្រប់ជាតិសាសន៍! ទូលព្រះបង្គំសូមប្រាថ្នាអ្វីតែជាសេចក្ដីប្រាថ្នារបស់ព្រះអង្គ ហើយទូលព្រះបង្គំសូមស្រលាញ់អ្វីដែលជាសេចក្ដីស្រលាញ់របស់ព្រះអង្គ។

*បន្ទាប់មកទៀតចូរលត់ជង្គង់ទាំងទ្វេរហើយឱនក្បាល (ថ្ងាស់) ទៅនឹងកំរាល(ដី)ហើយសូត្រនូវធម៌ខាងក្រោម នេះ៖*

ព្រះអង្គគឺជាព្រះដ៏ខ្ពង់ខ្ពស់ហួសពីការពិពណ៌នារបស់មនុស្សគ្រប់គ្នាលើកលែងតែខ្លួនព្រះអង្គឯង ហើយក៏ជាព្រះដ៏ខ្ពង់ខ្ពស់ហួសពីការយល់ដឹងរបស់មនុស្សសត្វផ្សេងទៀត លើកលែងតែព្រះអង្គដែលជាព្រះអាទិទេពជាម្ចាស់ដោយអង្គឯង។

*បន្ទាប់មកទៀតចូរឈរហើយសូត្រនូវធម៌ខាងក្រោមនេះ៖*

"ឱព្រះអាទិទេពជាម្ចាស់របស់ទូលព្រះបង្គំលោកអើយ សូមព្រះអង្គញ៉ាំងឱ្យការអធិដ្ឋានបួងសួងរបស់ទូលព្រះបង្គំបានក្លាយជាប្រភពទឹករស់ដែលធ្វើឱ្យទូលព្រះបង្គំយើងខ្ញុំបានរស់នៅក្រោមអធិបតេយ្យភាពរបស់ព្រះអង្គជានិរន្តរ៍ដរាបតទៅ ហើយក៏សូមព្រះអង្គញ៉ាំងឱ្យទូលព្រះបង្គំយើងខ្ញុំបាននិយាយពីព្រះអង្គ នៅគ្រប់ពិភពដែលជាពិភពរបស់ព្រះអង្គផង"។

*បន្ទាប់មកចូរលើកដៃហើយសូត្រអង្វរករម្តងទៀតថា*

"ឱព្រះអង្គជាអ្នកញែកបំបែកបេះដូង ហើយនិងវិញ្ញាណក្ខន្ធដែលបានរលាយចេញពីទ្រង់ដោយភ្លើងនៃសេចក្តីស្រលាញ់របស់ព្រះអង្គ ត្រូវបានគេដុតបំភ្លឺឱ្យឆេះសន្ធោសន្ធៅដល់ពិភពលោកទាំងមូលអើយ! ឱព្រះអង្គដែលជាអ្នកគ្រប់គ្រងលើមនុស្សគ្រប់គ្នាអើយ! ទូលព្រះបង្គំសូមអង្វរព្រះអង្គតាមរយៈព្រះនាមទ្រង់ ព្រោះព្រះអង្គជាអ្នកដឹកនាំមាបនកម្មទាំងអស់តាមរយៈព្រះនាមរបស់ព្រះ

អង្គ សូមព្រះ អង្គយល់ព្រមឱ្យទូលព្រះបង្គំបាននៅជាមួយព្រះអង្គផង។ ឱព្រះអង្គដែលជាព្រះអាទិទេពរបស់ទូលព្រះបង្គំអើយសូមព្រះអង្គទតមើលចុះ មនុស្សចំលែកម្នាក់នេះកំពុងតែប្រញាប់ប្រញាល់ទៅកាន់គេហដ្ឋានដ៏ប្រសើររបស់គាត់ ដែលស្ថិតនៅក្រោមបុស្បុក(ពាងជាអសនៈ) នៃព្រះករុណាជីវិតលើត្បូងដែលប្រកបដោយមេត្តាធម៌របស់ព្រះអង្គ ហើយក៏សូមព្រះអង្គទតមើលចុះបាបជនម្នាក់នេះ កំពុងតែស្វែងរកមហាសាគរនៃការលើកលែងទោសរបស់ទ្រង់ ចំណែកឯអ្នកទន់ទាបម្នាក់នេះវិញ កំពុងតែស្វែងរកព្រះរាជវាំងនៃភាពរុងរឿងរបស់ព្រះអង្គ ហើយក៏សូមព្រះអង្គទតមើលចុះ មនុស្សលោកដែលមានភាពក្រីក្រម្នាក់នេះ កំពុងតែងាកបែរកទិសឆ្ពោះទៅកាន់ទ្រព្យសម្បត្តិមហាសាលរបស់ព្រះអង្គហើយ។ ព្រះអង្គមានអំណាចអាចបញ្ជាអ្វីគ្រប់យ៉ាងបាន តាមព្រះទ័យពេញចិត្តរបស់ព្រះអង្គ។ ទូលព្រះបង្គំសូមធ្វើជាសក្ខីភាពថា ព្រះអង្គគឺជាអ្នកដែលគេសរសើរទៅតាមទង្វើរបស់ព្រះអង្គ ជាអ្នកដែលគេប្រតិបត្តិទៅតាមបញ្ជារបស់ព្រះអង្គ ហើយក៏ជាអ្នកដែលមានសេរីភាពទៅតាមច្បាប់បញ្ញត្តិរបស់ព្រះអង្គផងដែរ”។

*បន្ទាប់មកចូរលើកដៃហើយសូត្រថា*“អាឡ្ឡាហ៊ុអាប់ផា” *បីដង។*

*បន្ទាប់មកឱនដោយដៃទាំងពីរដាក់លើជង្គង់ទាំងសងខាងនូវចំពោះព្រះភក្ត្ររបស់ព្រះអាទិទេពជាម្ចាស់ ដែលជាព្រះប្រកប*

*ដោយសព្វសាធុការពរដ៏ប្រសើរ ហើយសូត្រថាៈ*

"ឱព្រះអាទិទេពជាម្ចាស់របស់ទូលព្រះបង្គំអើយ ព្រះអង្គបានទតឃើញហើយពីចិត្តរបស់ទូលព្រះបង្គំ កំពុងត្រូវបានគេធ្វើឱ្យមានបញ្ហាដល់អង្គអវយវៈរបស់ទូលព្រះបង្គំ ចិត្តរបស់ទូលព្រះបង្គំកំពុងត្រូវបានគេធ្វើឱ្យមានបញ្ហាដល់ការធ្វើសក្ការៈដល់ទ្រង់ ហើយនិងចំណង់ចងចាំនិងលើកតំកើនដល់ទ្រង់។ បពិត្រព្រះអង្គព្រះអាទិទេពជាម្ចាស់ ព្រះអង្គក៏បានទតឃើញផងដែរថា ចិត្តរបស់ទូលព្រះបង្គំបានធ្វើជាសក្ខីភាពដល់បន្ទូលបទបញ្ជារបស់ទ្រង់ ដែលបានបញ្ជាក់នៅក្នុងរាជាណាចក្រនៃសំនៀងរបស់ទ្រង់ ហើយនិងឋានសួគ៌នៃចំណេះដឹងរបស់ព្រះអង្គ។ ឱព្រះអង្គព្រះអាទិទេពជាម្ចាស់ នៅពេលនេះ ទូលព្រះបង្គំសូមអង្វរសុំនូវរបស់គ្រប់យ៉ាងដែលព្រះអង្គមាន ដើម្បីឱ្យទូលព្រះបង្គំបានចាកផុតពីភាពក្រីក្ររបស់ទូលព្រះបង្គំដើម្បីឱ្យទូលព្រះបង្គំបានពង្រីក នូវភាពសម្បូរនិងភាពមានទ្រព្យរបស់ព្រះអង្គ ដើម្បីឱ្យទូលព្រះបង្គំបានចាកផុតពីភាពទន់ខ្សោយរបស់ទូលព្រះបង្គំ ដើម្បីចាប់យកអានុភាពនិងតេជានុភាពរបស់ទ្រង់វិញ"។

*បន្ទាប់មកចូរងើបឈរ ហើយលើកដៃទាំងពីរធ្វើការអង្វរពីរដងដោយសូត្រថាៈ*

"គ្មានព្រះណាក្រៅពីព្រះអង្គឡើយ ព្រះអង្គគឺជាព្រះប្រកបដោយតេជានុភាព និងជាព្រះប្រកបដោយភាពសម្បូរគ្រប់យ៉ាង។ គ្មានព្រះណាក្រៅពីព្រះអង្គឡើយ ព្រះអង្គគឺជាអ្នកកំណត់ទាំងការចាប់ផ្ដើមនិងទីបញ្ចប់។ ឱព្រះអាទិទេពជាម្ចាស់របស់ទូលព្រះបង្គំលោកអើយ! ការលើកលែងទោសរបស់ព្រះអង្គបានធ្វើឱ្យទូលព្រះបង្គំមានភាពក្លាហានឡើង មេត្តាធម៌របស់ព្រះអង្គបានធ្វើឱ្យទូលព្រះបង្គំមានភាពរឹងមាំឡើង ការស្រែកហៅរបស់ព្រះអង្គបានធ្វើឱ្យទូលបង្គំបានភ្ញាក់ឡើងភាពសមរម្យរបស់ព្រះអង្គបានលើកឱ្យទូលព្រះបង្គំមានភាពស្អឹមស្អែឡើង ហើយព្រមទាំងបាននាំឱ្យទូលព្រះបង្គំបានទៅដល់ព្រះអង្គផង។ ម៉្យាងវិញទៀតអ្នកដែលទូលព្រះបង្គំគួរតែហ៊ានឈរ នៅឯក្លោងទ្វារទីក្រុងនៃភាពកៀកជិតរបស់ព្រះអង្គ ហើយនិងមុខរបស់ទូលព្រះបង្គំ សម្លឹងឆ្ពោះទៅរកពន្លឺដែលកំពុងបញ្ចេញរស្មីយ៉ាងត្រចះត្រចង់ពីឋានសួគ៌នៃឆន្ទៈរបស់ព្រះអង្គនោះជានរណា? ឱព្រះអាទិទេពជាម្ចាស់របស់ទូលព្រះបង្គំលោកអើយ សូមព្រះអង្គទតមើលចុះមនុស្សទុគ៌តម្នាក់នេះកំពុងតែគោះទ្វារនៃមនុញ្ញភាពរបស់ព្រះអង្គ ហើយមនុស្សអនត្ដាម្នាក់នេះកំពុងតែស្វែងរកជលសីមា(ស្ទឹង)នៃជីវិតអនន្តពីព្រះហស្តនៃភាពសម្បូររបស់ព្រះអង្គហើយ។ ឱព្រះអាទិទេពជាម្ចាស់ដែលជាព្រះនៃគ្រប់នាមរូបអើយ ព្រះអង្គជាអ្នកត្រួតត្រាលើគ្រប់នាមរូបគ្រប់ពេល ឱព្រះអា

ទិទេពជាអ្នកបង្កើតឋានសួគ៌អើយ ទូលព្រះបង្គំសុខចិត្តចូលជ្រកក្រោមឧត្តមឆន្ទៈរបស់ព្រះអង្គហើយ!

*បន្ទាប់មកទៀតចូរលើកដៃឡើងលើបីដងហើយសូត្រថា:*

"ព្រះអាទិទេពជាម្ចាស់អស្ចារ្យជាងអ្នកដែលអស្ចារ្យគ្រប់គ្នា!"

*បន្ទាប់មកលុតជង្គង់ហើយឱនក្បាលទៅនឹងកម្រាល ហើយសូត្រថា៖*

"ព្រះអង្គគឺជាភាពខ្ពង់ខ្ពស់ ដែលគួរឱ្យសរសើររបស់អ្នកទាំងឡាយណាដែលនៅជិតព្រះអង្គដើម្បីឡើងទៅកាន់ឋានសួគ៌នៃភាពនៅជិតរបស់ព្រះអង្គ ព្រះអង្គជាព្រះដ៏ខ្ពង់ខ្ពស់ដែលគួរឱ្យសរសើររបស់បក្សាបក្សីនៃបេះដូងរបស់អ្នកទាំងឡាយ ដែលមានភក្តីភាពចំពោះទ្រង់ ដើម្បីឱ្យពួកគេទាំងនោះបានទៅដល់ទ្វារនៃក្លោងទ្វាររបស់ព្រះអង្គ។ ទូលព្រះបង្គំសូមធ្វើជាសក្ខីភាពថាព្រះអង្គគឺជាព្រះដ៏ពិសិដ្ឋលើសគ្រប់កេតណភ័ណ្ឌ ហើយនិងជាព្រះដ៏ពិសិដ្ឋលើសអស់ព្រះនាមរូប។ គ្មានព្រះណាក្រៅពីព្រះអង្គឡើយ ព្រះអង្គគឺជាព្រះដ៏ខ្ពង់ខ្ពស់បំផុត ហើយនិងជាព្រះដែលប្រកបដោយភាពសម្បូររុងរឿងគ្រប់យ៉ាង"។

*បន្ទាប់មកចូរអង្គុយហើយសូត្រថា:*

‟ទូលព្រះបង្គំសូមបញ្ជាក់ចំពោះរឿងនេះថា ទូលព្រះបង្គំបានធ្វើជាសាក្សីដល់គ្រប់វត្ថុដែលបានបង្កើតមក បានធ្វើជាសាក្សីដល់ទីជំនុំដ៏ខ្ពស់ បានធ្វើជាសាក្សីដល់មនុស្សរបស់ឋានសួគ៌ដ៏ខ្ពស់ទាំងអស់ បានធ្វើជាសាក្សីដល់ភាពដ៏ខ្ពស់លើសពួកគេនោះគឺជាបន្ទូលនៃភាពរុងរឿងដែលកើតមកពីនភាល័យនៃភាពរុងរឿងគ្រប់យ៉ាងដោយខ្លួនឯង ហើយទូលព្រះបង្គំសូមធ្វើជាសក្ខីភាពថា ព្រះអង្គគឺជាព្រះអាទិទេពជាម្ចាស់ ដែលគ្មានព្រះណាក្រៅពីព្រះអង្គឡើយ ហើយទូលបង្គំសូមធ្វើជាសក្ខីភាពថា ព្រះអង្គដែលជាអ្នកត្រូវបានគេបង្ហាញឱ្យឃើញនោះ គឺជាអាថ៌កំបាំងដែលបានលាក់ទុកគឺជានិមិត្តរូបនៃរតនសម្បត្តិ តាមរយៈអ្នកដែលបានចងភ្ជាប់អក្សរ‟B,បី″ ហើយនិង‟E,អ៊ី″ឱ្យនៅជុំគ្នាកើតបានជា‟BE″ (កើតមានឡើង.ជប់)។ ទូលព្រះបង្គំសូមធ្វើជាសក្ខីភាពថា និមិត្តរូបដែលជារតនសម្បត្តិនោះគឺជានាមរបស់ព្រះអង្គ ដែលត្រូវបានគេសរសេរចុះដោយប៉ាកានៃឋានសួគ៌ដ៏ខ្ពស់បំផុត ហើយព្រះអង្គត្រូវបានគេពិពណ៌នានៅក្នុងគម្ពីររបស់ព្រះអាទិទេពជាម្ចាស់ដែលជាស្តេចនៃរាជបល្ល័ង្កនៅលើឋានសួគ៌ហើយនិងនៅលើផែនដីនេះ។

*បន្ទាប់មកចូរឈរឱ្យត្រង់ខ្លួនហើយសូត្រថា:*

ឱព្រះអាទិទេពជាម្ចាស់នៃមនុស្សលោកគ្រប់គ្នាហើយ និងជាម្ចាស់នៃគ្រប់វត្ថុទាំងមើលឃើញ ហើយនិងទាំងមើលមិនឃើញ

អើយ! ព្រះអង្គទ្រង់ញាណដល់សេចក្ដីទុក្ខសោក ហើយនិងការដកដង្ហើមធំរបស់ទូលព្រះបង្គំ ដែលទូលព្រះបង្គំបន្លឺឡើង ព្រះអង្គទ្រង់ព្រះសណ្ដាប់ឮដល់ការថ្ងូរ ហើយនិងការទ្រហោយំរបស់ទូលព្រះបង្គំដែលបេះដូងរបស់ទូលព្រះបង្គំមានការបរិទេវៈ"ការសោកស្ដាយ"។ ឱព្រះអង្គដែលប្រកបដោយអានុភាពអើយ! បាបកម្មរបស់ទូលព្រះបង្គំបានរាំងខ្ទប់ មិនឱ្យទូលព្រះបង្គំចូលទៅជិតព្រះអង្គបានឡើយ។ ហើយអំពើបាបរបស់ទូលព្រះបង្គំបានរារាំងឱ្យទូលព្រះបង្គំ នៅឃ្លាតឆ្ងាយពីព្រះរាជវាំងនៃសន្តភាព"ភាពពិសិដ្ឋ" របស់ព្រះអង្គ ហើយសូមព្រះអង្គជួយទូលព្រះបង្គំផង។ ឱព្រះអង្គព្រះអាទិទេពជាម្ចាស់លោកអើយ សេចក្ដីស្រឡាញ់របស់ព្រះអង្គបានធ្វើឱ្យទូលព្រះបង្គំមានន័យខ្លឹមសារឡើង ការបែកចេញពីព្រះអង្គបានធ្វើឱ្យទូលព្រះបង្គំវិនាសអស់ ចំណែកឯការឃ្លាតឆ្ងាយពីព្រះអង្គបានធ្វើឱ្យទូលព្រះបង្គំហិនហោចអស់។ ទូលព្រះបង្គំសូមអង្វរព្រះអង្គ ដើម្បីឱ្យទូលព្រះបង្គំបានដើរតាមជំហានរបស់ព្រះអង្គដែលមាននៅក្នុងទីរហោដ្ឋាននេះ ហើយនិងតាមបន្ទូលរបស់ព្រះអង្គផង "នេះគឺជាទូលព្រះបង្គំ។ ទូលព្រះបង្គំនៅទីនេះ" សូមព្រះអង្គធ្វើឱ្យទូលព្រះបង្គំបានក្លាយជាអ្នកដែលព្រះអង្គបាន ជ្រើសរើសឱ្យបន្លឺសូរសំលេង នៅក្នុងភាពមហិមានេះផង ហើយទូលព្រះបង្គំសូមដើរតាមដង្ហើមនៃការត្រាស់ដឹងរបស់ព្រះអង្គ ហើយនិងវាយោស្លូតបូតរបស់អារុណនៃព្រះសាស្ដារបស់ព្រះអង្គ ដើម្បីឱ្យទូលព្រះ

បង្គំបានមើលឃើញសោភណ្ឌភាពរបស់ព្រះអង្គ ហើយនិងបាន សង្កេតឃើញអ្វីៗ ដែលមាននៅក្នុងគម្ពីររបស់ព្រះអង្គផង។

*បន្ទាប់មកទៀតចូរសូត្រឡើងវិញនូវពាក្យ "អាឡាអ៊ុអាប់ផា" បីដង ហើយបង្អោនខ្លួនដោយដាក់ដៃនៅលើជង្គង់ទាំងសងខាង ហើយសូត្រថា:*

ឱព្រះអង្គ ព្រះអាទិទេពដែលគួរឱ្យសរសើរអើយ ព្រះអង្គជាអ្នកជួយឱ្យទូលព្រះបង្គំបានចងចាំដល់ទ្រង់ ដើម្បីឱ្យទូលព្រះបង្គំបានលើកតម្កើងដល់ទ្រង់ ព្រះអង្គជាអ្នកធ្វើឱ្យទូលព្រះបង្គំបានស្គាល់ដល់ព្រះអង្គ(ព្រះបាហាអ៊ុលឡាហ៍) ដែលជាប្រភពនៃសញ្ញារបស់ព្រះអង្គ ព្រះអង្គបានញ៉ាំងឱ្យទូលព្រះបង្គំបង្អោនខ្លួននៅចំពោះមុខអ្នកតំណាងរបស់ទ្រង់(ព្រះបាហាអ៊ុលឡាហ៍) ព្រះអង្គបានញ៉ាំងឱ្យទូលព្រះបង្គំបានបន្ទាបខ្លួនរបស់ទូលព្រះបង្គំ នៅចំពោះមុខគុណធមិរបស់ព្រះអង្គ ហើយព្រមទាំងបានញ៉ាំងឱ្យទូលព្រះបង្គំបានទទួលយកនូវអ្វីៗដែលត្រូវបានគេបញ្ចេញដោយបន្ទូលនៃភាពរុងរឿងរបស់ព្រះអង្គផងដែរ។

*បន្ទាប់មកចូរងើបមុខឡើងហើយសូត្រថា:*

ឱព្រះអាទិទេពដែលជាព្រះរបស់ទូលព្រះបង្គំអើយ! ខ្នងរបស់ទូលព្រះបង្គំត្រូវបានគេធ្វើឱ្យកោងដោយសារតែបន្ទុកធ្ងន់នៃអំពើ

បាបរបស់ទូលព្រះបង្គំ។ ហើយការធ្វេសប្រហែសរបស់ទូលព្រះបង្គំបានធ្វើឱ្យទូលព្រះបង្គំវិនាសអស់។ នៅគ្រប់ពេលដែលទូលព្រះបង្គំសញ្ជឹងគិតពីអំពើអាក្រក់របស់ទូលព្រះបង្គំទៅនឹងព្រះទ័យមេត្តារបស់ព្រះអង្គនោះ ចិត្តរបស់ទូលព្រះបង្គំបានរលាយនៅក្នុងខ្លួនរបស់ទូលព្រះបង្គំអស់ ហើយលោហិតរបស់ទូលព្រះបង្គំបានពុះកញ្ជ្រោលនៅក្នុងសរសៃឈាមរបស់ទូលព្រះបង្គំទាំងអស់។ ឱព្រះអង្គដែលជាសេចក្តីប្រាថ្នារបស់ពិភពលោកអើយ! តាមរយៈសោភ័ណភាពរបស់ព្រះអង្គ ទូលព្រះបង្គំពិបាកនឹងងើបមុខរបស់ទូលព្រះបង្គំទៅរកព្រះអង្គណាស់ ចំណែកឯហត្ថា(ដៃ)ចំណង់របស់ទូលព្រះបង្គំវិញ មានសេចក្តីខ្មាស់អៀនណាស់មិនហ៊ានលូកទៅរកឋានសួគ៌នៃសេចក្តីសម្បូររុងរឿងរបស់ព្រះអង្គឡើយ។ ឱព្រះអង្គព្រះអាទិទេពជាម្ចាស់របស់ទូលព្រះបង្គំអើយ ព្រះអង្គទតមើលចុះសេចក្តីទុក្ខសោករបស់ទូលព្រះបង្គំបានរារាំងទូលព្រះបង្គំ មិនឱ្យទូលព្រះបង្គំចងចាំព្រះអង្គឡើយ ហើយរារាំងទូលព្រះបង្គំមិនឱ្យសរសើរដល់គុណធម៌របស់ព្រះអង្គទៀតផង ឱព្រះអង្គដែលជាម្ចាស់នៃរាជបល្លង្ក៍ទាំងនៅលើឋានសួគ៌ដ៏ខ្ពស់ ហើយនិងនៅលើផែនដីនេះអើយ! ទូលព្រះបង្គំសូមអង្វរដល់ព្រះអង្គ តាមរយៈសញ្ញានៃរាជាណាចក្ររបស់ព្រះអង្គ ហើយនិងតាមរយៈអាថ៌កំបាំងនៃជីវិតរាជរបស់ព្រះអង្គ សូមឱ្យទូលព្រះបង្គំបានធ្វើអំពើល្អជាមួយនឹងអ្នកដែលជាទីស្រលាញ់របស់ព្រះអង្គដើម្បីឱ្យទូលព្រះបង្គំបាន

ក្លាយខ្លួនជាភាពសម្បូររបស់ព្រះអង្គម្នាក់ផង។ ឱព្រះអាទិទេពជាម្ចាស់នៃគ្រប់សត្វលោក ហើយនិងជាស្តេចនៃនាមរូបទាំងមើលឃើញហើយនិងមើលមិនឃើញអើយ ព្រះអង្គមានតម្លៃខ្ពង់ខ្ពស់ព្រោះតែភាពសមរម្យរបស់ព្រះអង្គ(បារមី)!

*បន្ទាប់មកចូរសូត្រពាក្យថា "អាឡ្លាហ៊ុអាប់ជា" បីដង ហើយលុតជង្គង់ដោយឱនក្បាល(ថ្ងាស់)ផ្ទាល់ទៅនឹងកំរាលហើយសូត្រថា:*

ឱព្រះអាទិទេពជាម្ចាស់ របស់ពួកយើងខ្ញុំទាំងអស់គ្នាអើយ យើងខ្ញុំទាំងអស់គ្នាសូមធ្វើឧក្កុំសនា(កោតសរសើរ) ចំពោះព្រះអង្គដែលទ្រង់បានបញ្ជូនមកឱ្យពួកយើងនូវគុណធម៌ដែលនាំពួកយើងឱ្យមកជិតព្រះអង្គ ហើយទូលព្រះបង្គំក៏សូមធ្វើឧក្កុំសនាចំពោះព្រះអង្គផងដែរ ដែលទ្រង់បានប្រទានមកឱ្យពួកយើងនូវគុណធម៌ដ៏បវរដែលបានបញ្ជូនចុះមកដោយព្រះអង្គផ្ទាល់ ដែលមាននៅក្នុងក្បួននិងក្នុងគម្ពីររបស់ព្រះអង្គ។ ឱព្រះអង្គព្រះអាទិទេពជាម្ចាស់លោកអើយ ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នាសូមបួងសួងសុំអង្វរដល់ព្រះអង្គ សូមទ្រង់ការពារទូលព្រះបង្គំយើងខ្ញុំឱ្យបានចាកផុតពីបាហានិក (សត្វដែលសត្វដទៃទៀតមកតោងរស់ដោយសារឬភ្ញៀវ ឧទាហរណ៍ក្បាលមនុស្សមានសត្វចៃជាអ្នកតោងរស់ដោយសារ) នៃការគិតរវើរវាយឥតបានការនិងគំនិតឥតប្រយោជន៍ផង។ ពិត

ប្រាកដណាស់ព្រះអង្គគឺជាព្រះប្រកបដោយអានុភាព និងជាព្រះទ្រង់ញាណគ្រប់យ៉ាង។

*បន្ទាប់មកចូរងើបមុខឡើង ហើយអង្គុយឱ្យបានសមរម្យ ហើយសូត្រថា:*

ឱព្រះអាទិទេពជាម្ចាស់របស់ទូលព្រះបង្គំលោកអើយ ទូលព្រះបង្គំសូមបញ្ជាក់ចំពោះអ្នកដែលជាជំរើសរបស់ព្រះអង្គ បានធ្វើជាសាក្សីឱ្យទូលព្រះបង្គំផង ហើយទូលព្រះបង្គំសូមទទួលស្គាល់ថាអ្នកដែលព្រះអង្គបានជ្រើសរើសនោះ គឺជាមនុស្សដែលមកពីឋានសួគ៌ដ៏ខ្ពស់ហើយអ្នកទាំងនោះ គឺជាអ្នកដែលជារាជបល្លង្ក័ប្រកបដោយអានុភាពរបស់ព្រះបានទទួលស្គាល់។ ឱព្រះអាទិទេពជាម្ចាស់នៃគ្រប់ពិភពអើយ រាជាណាចក្ររបស់ផែនដីនេះហើយនិងឋានសួគ៌គឺជារបស់ព្រះអង្គទាំងអស់!

# ធម៌សូត្រជាទូទៅ

*ធម៌អធិដ្ឋានសុំការជួយទ្រទ្រង់និងសង្គហៈ "ការសង្គ្រោះ"*

ឱព្រះអង្គ ព្រះអាទិទេពជាម្ចាស់លោកអើយ ព្រះភក្ត្ររបស់ព្រះអង្គគឺជាវត្ថុបំណងនៃការធ្វើសក្ការៈរបស់ទូលព្រះបង្គំ សោភណ៍ភាពរបស់ព្រះអង្គគឺជាបដិសរណដ្ឋាន(ទីជំរក) របស់ទូលព្រះបង្គំ លំនៅដ្ឋានរបស់ព្រះអង្គគឺជាគោលបំណងរបស់ទូលព្រះបង្គំ ការលើកតម្កើងរបស់ព្រះអង្គគឺជាសេចក្ដីសង្ឃឹមរបស់ទូលព្រះបង្គំ ទិព្វញាណរបស់ព្រះអង្គគឺជាមិត្តរបស់ទូលព្រះបង្គំ សេចក្ដីស្រឡាញ់របស់ព្រះអង្គគឺជាហេតុដែលនាំឱ្យទូលព្រះបង្គំបានរស់រាន និទ្ទេសរបស់ព្រះអង្គគឺជាសេចក្ដីផុតទុក្ខរបស់ទូលព្រះបង្គំ ការនៅជិតព្រះអង្គគឺជាសេចក្ដីប្រាថ្នារបស់ទូលព្រះបង្គំ វត្តមានរបស់ព្រះអង្គគឺជាសេចក្ដីប្រាថ្នាជាទីពេញចិត្ត ហើយនិងជាទីប្រាថ្នាដ៏ខ្ពង់ខ្ពស់របស់ទូលព្រះបង្គំ ទូលព្រះបង្គំសូមអង្វរដល់ព្រះអង្គ សូមទ្រង់កុំដកហូតពីទូលព្រះបង្គំនូវរបស់ទាំងឡាយ ដែលព្រះអង្គបានកំណត់សំរាប់អ្នកជំរើសទាំងឡាយ ដែលមាននៅក្នុងចំណោមអ្នកបំរើទាំងឡាយរបស់ព្រះអង្គនោះ បន្ទាប់មកសូមព្រះអង្គប្រទានឱ្យទូលព្រះបង្គំនូវសិរីល្អរបស់ពិភពនេះនិងពិភពបន្ទាប់មកទៀតផង។

ពិតណាស់ព្រះអង្គគឺជាស្ដេចរបស់មនុស្សគ្រប់រូប។ ពុំមានព្រះណាក្រៅពីព្រះអង្គឡើយ ព្រះអង្គគឺជាព្រះលើកលែងទោសជានិច្ចហើយក៏ជាព្រះប្រកបដោយព្រះទ័យសប្បុរសធម៌បំផុតផងដែរ។

-ព្រះបាហាអ៊ុលឡាហ៍-

ឱព្រះអង្គ ព្រះអាទិទេពជាម្ចាស់របស់ទូលព្រះបង្គំ ជាព្រះដ៏ជាទីសក្ការៈរបស់ទូលព្រះបង្គំ ជាស្ដេចរបស់ទូលព្រះបង្គំ ជាសេចក្ដីប្រាថ្នារបស់ទូលព្រះបង្គំអើយ! តើអណ្ដាតមួយណាដែលអាចបញ្ចេញសម្លេងនូវពាក្យអរគុណ របស់ទូលព្រះបង្គំចំពោះព្រះអង្គបាន? ទូលព្រះបង្គំជាមនុស្សធ្វេសប្រហែសណាស់ សូមព្រះអង្គដាស់ឱ្យអារម្មណ៍របស់ទូលព្រះបង្គំបានភ្ញាក់ឡើងផង។ ទូលព្រះបង្គំជាមនុស្សដែលបានងាកចេញពីព្រះអង្គ សូមទ្រង់ជួយប្រជុំងប្រជាដោយព្រះទ័យសប្បុរសធម៌របស់ព្រះអង្គឱ្យទូលព្រះបង្គំ បានងាកឆ្ពោះទៅរកព្រះអង្គវិញផង។ ទូលព្រះបង្គំជាមនុស្សស្លាប់ សូមព្រះអង្គធ្វើឱ្យទូលព្រះបង្គំបានរស់ឡើងវិញ ដោយទឹកជីវិតរស់របស់ព្រះអង្គវិញផង។ ទូលព្រះបង្គំជាមនុស្សក្រៀមស្វិត សូមព្រះអង្គធ្វើឱ្យទូលព្រះបង្គំ ស្រស់ស្រាយដោយចរន្តទឹកឋានសួគ៌នៃសំនៀងរបស់ព្រះអង្គ ដែលបានហូរចេញមកពីប៉ាកាដែលប្រកបដោយមេត្តាធម៌គ្រប់យ៉ាងរបស់ព្រះអង្គផង។

ឱព្រះអាទិទេពជាស្តេចទិព្វញាណអើយ! គ្រប់ជីវិតគឺត្រូវបានគេបង្កើតឡើងដោយភាពសម្បូររបស់ព្រះអង្គ សូមព្រះអង្គកុំបង្អត់ទឹកនៃភាពសប្បុរសរបស់ព្រះអង្គ ចំពោះជីវិតទាំងនោះឡើយ ហើយក៏សូមព្រះអង្គកុំផ្តាច់ពួកវា ពីមហាសាគរនៃមេត្តាធម៌របស់ព្រះអង្គផងដែរ។ ទូលព្រះបង្គំ សូមអង្វរសុំឱ្យទ្រង់ជួយប្រដុងប្រជាដល់ទូលព្រះបង្គំគ្រប់ពេលនិងគ្រប់ស្ថានភាព ហើយនិងសូមឱ្យមនុញ្ញភាពរបស់ព្រះអង្គ ដែលជាការអនុគ្រោះរបស់ទ្រង់តាំងពីបុរាណមកកើតមានដល់ទូលព្រះបង្គំផង។ ពិតណាស់ព្រះអង្គគឺជាព្រះអាទិទេពជាម្ចាស់ដែលប្រកបដោយភាពសម្បូររុងរឿង ហើយនិងជាព្រះប្រកបដោយអធិបតេយ្យភាព នៃរាជាណាចក្រជាអនន្តភាពផងដែរ។

-ព្រះបាហាអ៊ុលឡាហ៍-

ឱព្រះអាទិទេពជាម្ចាស់របស់ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នាអើយ ព្រះនាមរបស់ព្រះអង្គគួរឱ្យសរសើរខ្លាំងណាស់! ពិតណាស់ ព្រះអង្គគឺជាព្រះទ្រង់ញាណដល់វត្ថុគ្រប់យ៉ាងដែលគ្មានភ្នែកណាមួយអាចមើលឃើញបានឡើយ។ សូមព្រះអង្គធ្វើឱ្យទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នាមានចំណេះដឹងល្អដូចគ្នានឹងចំណេះដឹងរបស់ព្រះអង្គ ដែលអាចយល់ដឹងពីអ្វីគ្រប់យ៉ាងបានផង។ ព្រះអង្គគឺជាព្រះប្រកបដោយអំណាច ជាព្រះប្រកបដោយអានុភាព ហើយ

និងជាព្រះប្រកបដោយសេចក្តីស្រឡាញ់ដ៏ប្រសើរបំផុត។

ឱព្រះអាទិទេពជាម្ចាស់លោកអើយ ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នាសូមលើកតម្កើងសរសើរចំពោះព្រះអង្គ! និងសូមស្វែងរកមនុញ្ញភាពរបស់ព្រះអង្គតាមសម័យកាល ដែលបានកំណត់ដោយព្រះអង្គ ហើយនិងសូមពឹងពាក់សេចក្តីសង្ឃឹមរបស់ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នាទាំងស្រុង ចំពោះព្រះអង្គដែលជាព្រះអាទិទេពជាម្ចាស់របស់ទូលព្រះបង្គំយើងខ្ញុំ។ ឱព្រះអាទិទេពជាម្ចាស់លោកអើយ! ព្រះ អង្គគឺជាព្រះប្រកបដោយភាពសម្បូររុងរឿងខ្លាំងណាស់! សូមព្រះអង្គប្រទានឱ្យទូលព្រះបង្គំយើងខ្ញុំ នូវសិរីល្អនិងសិរីសួស្តីដើម្បីឱ្យទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នាអាចមានលទ្ធភាពដើម្បីកំចាត់ចោលនូវរបស់គ្រប់យ៉ាងលើកលែងតែព្រះអង្គចេញ។ ពិតណាស់ព្រះអង្គគឺជាព្រះអាទិទេពជាម្ចាស់ដែលមាននៅគ្រប់ពិភព។

ឱព្រះអាទិទេពជាម្ចាស់លោកអើយ! សូមព្រះអង្គ ប្រទានពរឱ្យដល់អ្នកទាំងឡាយណា ដែលបានអត់ធន់ដោយខន្តីនៅក្នុងសម័យកាលរបស់ព្រះអង្គ ហើយក៏សូមព្រះអង្គពង្រឹងដួងចិត្តរបស់ពួកគេ ដើម្បីឱ្យពួកគេបានដើរតាមខ្សែបន្ទាត់នៅក្នុងមាគ៌ានៃសច្ចភាពរបស់ព្រះអង្គផង។ ឱព្រះអាទិទេពជាម្ចាស់លោកអើយ នៅពេលនេះសូមព្រះអង្គប្រទានអំណោយដែលជាអំណោយដ៏ល្អទាំងនេះឱ្យដល់ពួកគេដើម្បីឱ្យពួកគេបានទទួលការអនុញ្ញាត្តិឱ្យទៅកាន់

ឋានសួគ៌បរមសុខរបស់ព្រះអង្គផង។ ពិតណាស់ ព្រះអង្គគឺជាព្រះអាទិទេពជាម្ចាស់ដែលគួរឱ្យសរសើរបំផុត។ សូមព្រះអង្គប្រទានពរឋានសួគ៌របស់ព្រះអង្គឱ្យជ្រាលចុះមកកាន់គេហដ្ឋាន របស់មនុស្សទាំងឡាយណាដែលបានជឿចំពោះព្រះអង្គផង។ ពិតណាស់ ព្រះអង្គគឺជាព្រះដ៏សមគួរក្នុងការបញ្ជូនចុះមកនូវសព្ទសាធុការពរដ៏ល្អប្រសើរបំផុតនេះ។ឱព្រះអាទិទេពជាម្ចាស់លោកអើយ សូមព្រះអង្គបញ្ជូនសព្ទសាធុការពរទៅឱ្យបាហានិក ដែលជាអ្នកធ្វើឱ្យអ្នកបំរើដែលមានការជឿជាក់របស់ព្រះអង្គបានជ័យជំនះផង។ ព្រះអង្គអាចធ្វើឱ្យវត្ថុគ្រប់យ៉ាងដែលបានបង្កើតមកនេះ ធ្វើតាមអំណាចក្រិត្យរបស់ព្រះអង្គទៅតាមព្រះអង្គសព្វព្រះហរទ័យ។ ពិតណាស់ ព្រះអង្គប្រកបដោយអធិបតេយ្យភាពជាអ្នកបង្កើតអ្វីៗគ្រប់យ៉ាង ជាព្រះប្រកបដោយគតិបណ្ឌិតគ្រប់យ៉ាង។

មានព្រះតម្រាស់ថា តាមពិតព្រះអាទិទេពជាម្ចាស់គឺជាអ្នកគ្រប់នាមរូបដែលមើលឃើញ ហើយនិងមើលមិនឃើញទាំងមានជីវិតហើយនិងទាំងគ្មានជីវិត។ ព្រះអង្គបានប្រទានចំណីអាហារឱ្យមនុស្សគ្រប់គ្នាដោយបរិបូរណ៍តាមព្រះទ័យរបស់ព្រះអង្គ។ ព្រះអង្គជាអ្នកបង្កើតអ្វីៗគ្រប់យ៉ាង ជាប្រភពកំនើតរបស់សត្វលោកគ្រប់យ៉ាង ជាអ្នកកៃច្នៃ ជាអ្នកមានអានុភាព ជាអ្នកបង្កើត ហើយនិងជាអ្នកមានគតិបណ្ឌិតគ្រប់យ៉ាង។ ព្រះអង្គជាអ្នកទៅរកឋានៈដ៏ប្រពៃបំផុតដែលមានពាសពេញទាំងឋានសួគ៌និងផែនដី ហើយនិងអ្វីៗ

ដែលមានជាប់និងពួកវានោះផង។ អ្នកទាំងអស់គ្នាជាអ្នកធ្វើតាមច្បាប់របស់ព្រះអង្គ ហើយនិងជាអ្នករស់នៅលើផែនដី និងឋានសួគ៌ ចូរអបអរនិងឧក្កិសនា(លើកតម្កើង)ដល់ព្រះអង្គឡើង ដើម្បីឱ្យអ្នកទាំងគ្នានឹងបានវិលត្រឡប់ទៅកាន់ព្រះអង្គវិញ។ ឱព្រះដែលជាព្រះអាទិទេពជាម្ចាស់របស់ទូលព្រះបង្គំលោកអើយ! ទូលព្រះបង្គំបានកាត់ផ្ដាច់ខ្លួនទូលព្រះបង្គំពីញាតិសន្តានរបស់ទូលព្រះបង្គំរួចហើយ ហើយក៏បានប្រឹងប្រែងស្វែងរកឯករាជ្យភាពពីរបស់គ្រប់យ៉ាងដែលមាននៅលើផែនដីនេះ តាមរយៈព្រះអង្គព្រមទាំងបានត្រៀមខ្លួនរួចជាស្រេចដើម្បីទទួលយកនូវអ្វី ដែលជាសម្បត្តិសួគ៌នៅក្នុងព្រះនេត្ររបស់ព្រះអង្គរួចហើយផងដែរ។ ដូច្នេះសូមព្រះអង្គប្រទានឱ្យទូលព្រះបង្គំនូវសម្បត្តិសួគ៌ទាំងនេះ ដើម្បីឱ្យទូលព្រះបង្គំមានឯករាជ្យភាពពីរបស់ផ្សេងៗលើកលែងតែព្រះអង្គចេញ ហើយក៏សូមឱ្យព្រះអង្គប្រទានឱ្យទូលព្រះបង្គំនូវចំណែកដ៏ធំនៃការអនុគ្រោះឥតកំណត់របស់ព្រះអង្គដល់ទូលព្រះបង្គំផង។ ពិតណាស់ព្រះអង្គគឺជាព្រះប្រកបដោយមនុញ្ញភាពដ៏សម្បូរ។

-ព្រះបប-

ឱព្រះលោកអើយ! ទូលព្រះបង្គំយើងខ្ញុំជាមនុស្សគួរឱ្យអាណិតខ្លាំងណាស់សូមព្រះអង្គប្រទានការអនុគ្រោះរបស់ព្រះអង្គឱ្យទូលព្រះបង្គំយើងខ្ញុំផង។ ទូលព្រះបង្គំយើងខ្ញុំជាមនុស្សទុគ៌ត សូម

ព្រះអង្គប្រទានចំណែកពីមហាសាគរ នៃទ្រព្យសម្បត្តិមហាសាលរបស់ព្រះអង្គឱ្យបានដល់ទូលព្រះបង្គំយើងខ្ញុំផង។ ទូលព្រះបង្គំយើងខ្ញុំជាមនុស្សក្រខ្សត់ខ្វះមុខខ្វះក្រោយ សូមព្រះអង្គបំពេញឱ្យទូលព្រះបង្គំយើងខ្ញុំបានស្កប់ចិត្តផង។ ទូលព្រះបង្គំយើងខ្ញុំជាមនុស្សខ្មាស់អៀន សូមព្រះអង្គប្រទានភាពរុងរឿងរបស់ព្រះអង្គឱ្យទូលព្រះបង្គំយើងខ្ញុំផង។ សត្វហើរលើអាកាស ហើយនិងសត្វដើរលើដីទទួលបានចំណីរបស់ពួកវាពីព្រះអង្គតែមួយថ្ងៃសម្រាប់មួយថ្ងៃ ចំណែកឯមនុស្សលោកវិញសេព(ស៊ីឬផឹក) អាហាររបស់ពួកគេដោយការផ្គត់ផ្គង់ ហើយនិងដោយព្រះទ័យសប្បុរសធម៌ដែលជាក្ដីស្រលាញ់របស់ព្រះអង្គ។ សូមព្រះអង្គកុំដកហូតមនុញ្ញភាពដ៏អស្ចារ្យរបស់ព្រះអង្គពីមនុស្សដ៏កំសោយម្នាក់នេះឡើយ ហើយផ្ទុយទៅវិញសូមព្រះអង្គធានាសុវត្ថិភាព ចំពោះមនុស្សតែលតោលម្នាក់នេះ ដោយអានុភាពរបស់ព្រះអង្គឱ្យបានទទួលភាពសម្បូររុងរឿងរបស់ព្រះអង្គផង។

សូមព្រះអង្គផ្ដល់ចំណីអាហារឱ្យពួកយើងជារៀងរាល់ថ្ងៃផង ហើយសូមទ្រង់ប្រទានភាពរីកចម្រើនរបស់ព្រះអង្គ ឱ្យមាននៅក្នុងជីវិតចាំបាច់ ដើម្បីឱ្យយើងទាំងអស់គ្នាអាចរួចផុតពីការពឹងពាក់អ្នកផ្សេងក្រៅពីព្រះអង្គ សូមព្រះអង្គប្រទានភាពរីកចំរើនរបស់ព្រះអង្គឱ្យមាននៅក្នុងជីវិតចាំបាច់របស់យើងខ្ញុំទាំងអស់គ្នា ដើម្បីឱ្យយើងខ្ញុំទាំងអស់គ្នាអាចទាក់ទងជាមួយនឹងព្រះអង្គបានទាំងស្រុង ហើយ

និងដើម្បីឱ្យយើងទាំងអស់គ្នា អាចដើរនៅក្នុងមាគ៌ារបស់ព្រះអង្គ ហើយនិងអាចប្រកាសពីអាថ៌កំបាំងរបស់ព្រះអង្គបានផង។ ពិតណាស់ព្រះអង្គគឺជាព្រះដែលមានមហិទ្ធិឫទ្ធិដ៏លើសលប់ ជាព្រះប្រកបដោយក្ដីស្រលាញ់ ហើយនិងជាអ្នកប្រទានអ្វីៗគ្រប់យ៉ាងឱ្យដល់មនុស្សលោកគ្រប់គ្នា។

-អង្គពិសិដ្ឋអាប់ឌុលបាហា-

បពិត្រព្រះអាទិទេពជាម្ចាស់ ដែលប្រកបដោយព្រះទ័យសប្បុរសធម៌អើយ! ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នាគឺជាអ្នកបម្រើនៃទ្វារឋានសួគ៌របស់ព្រះអង្គ ដែលកំពុងតែប្រើទីជម្រកនៅឯទ្វារពិសិដ្ឋរបស់ព្រះអង្គ។ យើងខ្ញុំទាំងអស់គ្នានឹងមិនខំប្រឹងប្រែងស្វែងរកទីជម្រកណាមួយ ក្រៅពីទីជម្រកដែលមានសសរដ៏រឹងមាំនេះឡើយ ហើយក៏មិនងាករកទីសុំចតណាមួយក្រៅពីទីសុំចតដែលព្រះអង្គបានថែរក្សាទុកឡើយ។ សូមព្រះអង្គការពារយើងខ្ញុំទាំងអស់គ្នា ប្រទានពរឱ្យពួកយើងទាំងអស់គ្នា ទ្រទ្រង់យើងខ្ញុំទាំងអស់គ្នា និងធ្វើឱ្យយើងខ្ញុំទាំងអស់គ្នាមានសេចក្ដីស្រលាញ់តែសិរីល្អរបស់ព្រះអង្គ បញ្ចេញសម្លេងលើកតម្កើងតែព្រះអង្គ ធ្វើតាមតែមាគ៌ានៃសច្ចធម៌របស់ព្រះអង្គ ដើម្បីឱ្យយើងខ្ញុំទាំងអស់គ្នាអាច

មានទ្រព្យជាប់ខ្លួនគ្រប់គ្រាន់ ដើម្បីចែកជាមួយនឹងអ្នកទាំងអស់គ្នា បានលើកលែងតែព្រះអង្គ ហើយនិងដើម្បីឱ្យយើងខ្ញុំទាំងអស់គ្នា អាចទទួលបាននូវអំណោយរបស់ពួកយើងពីមហាសាគរនៃអំពើល្អ របស់ព្រះអង្គ និងដើម្បីឱ្យយើងអាចប្រឹងប្រែងយ៉ាងខ្លាំងដើម្បី លើកតម្កើងបុព្វហេតុសាសនារបស់ព្រះអង្គ ហើយនិងដើម្បីពង្រីក ក្លិនដ៏ក្រអូបផ្អែមស្អិតរបស់ព្រះអង្គ ឱ្យបានពាសពេញពិភពលោក ហើយនិងដើម្បីឱ្យយើងអាចចៀសផុតពីអាត្មានិយម ហើយនិង បានរស់នៅជាមួយតែនឹងព្រះអង្គ ហើយឈប់ទទួលស្គាល់របស់ គ្រប់យ៉ាងផ្សេងទៀត ដែលជាប់ចិត្តតែនឹងព្រះអង្គមួយអង្គគត់។

ឱព្រះអង្គព្រះអាទិទេពជាអ្នកប្រទាន និងជាអ្នកលើកលែង ទោសអើយ! សូមព្រះអង្គប្រទានមនុញ្ញភាព ព្រះទ័យសប្បុរសធម៌ ជាទីស្រលាញ់ ជំនូនហើយនិងអំណោយរបស់ព្រះអង្គដល់ទូល ព្រះបង្គំយើងខ្ញុំផង ហើយសូមព្រះអង្គទ្រទ្រង់ដល់ពួកយើង ដើម្បី ឱ្យពួកយើងអាចបានទៅដល់គោលដៅរបស់ពួកយើងផង។ ព្រះ អង្គជាព្រះប្រកបដោយអានុភាព ជាព្រះប្រកបដោយសមត្ថភាព ជាអ្នកឈ្វេងយល់ ជាអ្នកមានព្រះនេត្រទិព្វ ពិតណាស់ព្រះអង្គគឺ ជាព្រះប្រកបដោយព្រះទ័យសប្បុរសធម៌ ពិតណាស់ព្រះអង្គគឺជា ព្រះប្រកបដោយមេត្តាធម៌គ្រប់យ៉ាង ពិតណាស់ព្រះអង្គគឺជាព្រះ លើកលែងទោសចំពោះអ្នកដែលបានធ្វើខុសចំពោះព្រះអង្គ ព្រះ

អង្គជាអ្នកលើកលែងទោស បើទោះជាសេចក្តីទុក្ខព្រួយនៃអំពើបាប នោះមានទម្ងំប៉ុណ្ណាក៏ដោយ។

-អង្គពិសិដ្ឋអាប់ឌុលបាហា-

ឱព្រះអាទិទេពជាម្ចាស់លោកអើយ សូមព្រះអង្គកុំបំបាត់គម្រោងរៀបចំដ៏សប្បាយអ៊ឹកធឹក ដែលត្រូវបានលាតត្រដាងតាមរយៈព្រះនាមរបស់ព្រះអង្គ ហើយសូមទ្រង់កុំពន្លត់អណ្ដាតភ្លើងដែលត្រូវបានគេបង្កាត់ឱ្យឆេះ ដោយភ្លើងអមតៈរបស់ព្រះអង្គនេះឡើយ។ សូមព្រះអង្គអនុញ្ញាតឱ្យទឹករស់ ដែលហូរចេញពីទឹករស់របស់ព្រះអង្គបានហូរចេញទៅដោយមានសំនៀងបទភ្លេង នៃភាពរុងរឿងរបស់ព្រះអង្គ និងការចងចាំរបស់ព្រះអង្គផង ហើយសូមទ្រង់កុំដកហូតអ្នកបម្រើរបស់ព្រះអង្គឱ្យចេញផុតពីក្លិនក្រអូបពិដោររបស់ព្រះអង្គដែលកំពុងតែស្រូបយកនូវគន្ធរសនៃសេចក្តីស្រលាញ់របស់ព្រះអង្គឡើយ។

ឱព្រះអាទិទេពជាម្ចាស់លោកអើយ! សូមព្រះអង្គបង្វែរសេចក្ដីកង្វល់ទុក្ខព្រួយរបស់អ្នកពិសិដ្ឋរបស់ព្រះអង្គ ឱ្យទៅជាអស់កង្វល់វិញផង សូមព្រះអង្គបង្វែរសេចក្ដីលំបាករបស់ពួកគេឱ្យទៅជាសេចក្ដីសុខស្រួលវិញផង សូមព្រះអង្គបង្វែរសេចក្ដីអាម៉ាស់របស់ពួកគេឱ្យទៅជាសេចក្ដីរុងរឿងផង សូមព្រះអង្គបង្វែរសេចក្ដីទុក្ខរបស់ពួក

គេឱ្យទៅជាសេចក្តីរីករាយប្រកបដោយបរមសុខផង ឱព្រះអាទិទេពជាម្ចាស់ ដែលជាអ្នកអនុគ្រោះដល់មនុស្សជាតិគ្រប់គ្នាអើយ! ពិតណាស់ ព្រះអង្គគឺជាព្រះមួយអង្គឯកគ្មានពីរ ជាព្រះប្រកបដោយអានុភាព ជាព្រះទ្រង់ញាណគ្រប់យ៉ាង និងជាព្រះប្រកបដោយគតិបណ្ឌិតគ្រប់យ៉ាង។

-អង្គពិសិដ្ឋអាប់ឌុលបាហា-

# ធម៌សម្រាប់កុមារ

ឱព្រះអាទិទេពជាម្ចាស់របស់ទូលព្រះបង្គំលោកអើយ! នេះគឺជាក្មេងដែលបានកើតមក ពីអង្គជាតិរបស់អ្នកបម្រើរបស់ព្រះអង្គម្នាក់ក្នុងចំណោមអ្នកបម្រើរបស់ព្រះអង្គទាំងឡាយ ដែលព្រះអង្គបានប្រទានឋានៈដ៏ថ្លៃថ្នូរមួយ ឱ្យទៅគាត់ដែលមាននៅក្នុងកថាខណ្ឌនៃក្រិត្យដែលបានកំណត់ឱ្យ មាននៅក្នុងគម្ពីរនៃបទបញ្ជារបស់ព្រះអង្គ។

ទូលព្រះបង្គំបួងសួងអង្វរសុំទ្រង់ តាមរយៈព្រះនាមរបស់ព្រះអង្គ សុំទ្រង់ធ្វើឱ្យគេជួយមនុស្សរាល់គ្នាដើម្បីឱ្យពួកគេជួយឱ្យក្មេងម្នាក់នេះ បានទទួលនូវគោលបំណងនៃសេចក្តីប្រាថ្នារបស់គាត់ផង ដើម្បីឱ្យមនុស្សគ្រប់គ្នាទទួលស្គាល់ថា ក្មេងម្នាក់នេះនឹងអាចក្លាយជាមនុស្សពេញវ័យម្នាក់ដែលបរិបូរណ៍ ដោយចិត្តវិញ្ញាណច្រើនក្នុងចំណោមអ្នកបម្រើរបស់ព្រះអង្គផង ហើយសូមទ្រង់ញ៉ាំងឱ្យគាត់មានពន្លឺឆ្ពោះទៅមុខតាមរយៈអំណាចនៃព្រះនាមរបស់ព្រះអង្គ និងសូមទ្រង់ធ្វើឱ្យគាត់បន្លឺសូរធ្វើឧក្កុំសនា (ការលើកសរសើរ) របស់ព្រះអង្គ និងសូមទ្រង់ញ៉ាំងឱ្យគាត់បានរៀបមុខរបស់គាត់ឆ្ពោះទៅកាន់ព្រះអង្គ និងបានខិតជិតនឹងព្រះអង្គផង។ ពិតណាស់ព្រះអង្គគឺជាព្រះអមតៈ ជាព្រះដែលមានអានុភាពអាចធ្វើអ្វីៗបានតាមព្រះទ័យរបស់ព្រះអង្គ ជាព្រះដែលមានកម្លាំងទេព ជាអនន្តភាព

អាចធ្វើអ្វីៗតាមព្រះអង្គពេញព្រះហឫទ័យ។ គ្មានព្រះណាក្រៅពីព្រះអង្គទ្បើយ ព្រះអង្គគឺជាព្រះដ៏ខ្ពង់ខ្ពស់ ជាព្រះដ៏គួរឱ្យគោរពបំផុត ជាអ្នកបង្ក្រាប ជាអ្នកមានអានុភាព និងជាអ្នកមានបញ្ញាដ៏លើសលុបបំផុតគ្រប់យ៉ាង។

-ព្រះបាហាអ៊ុលឡាហ៍ -

ឱព្រះអាទិទេពជាម្ចាស់លោកអើយ! សូមព្រះអង្គអប់រំបណ្តុះបណ្តាលក្មេងទាំងនេះផងចុះ។ ព្រោះក្មេងទាំងនេះគឺជាព្រឹក្សានៃផល្លារាមរបស់ព្រះអង្គ ជាបុប្ផានៃចំការរបស់ព្រះអង្គនិងជាកុលាបនៃសួនឧទ្យានរបស់ព្រះអង្គ។ សូមព្រះអង្គញ៉ាំងឱ្យទឹកភ្លៀងរបស់ព្រះអង្គបង្អុរចុះមកលើពួកគេ និងសូមព្រះអង្គញ៉ាំងឱ្យព្រះអាទិត្យសច្ចភាពបញ្ចេញរស្មីត្រចះត្រចង់មកលើពួកគេ ដោយក្តីស្រលាញ់របស់ព្រះអង្គផង។ សូមព្រះអង្គញ៉ាំងឱ្យវាយោដ៏ត្រជាក់របស់ព្រះអង្គផាត់បបោសអង្អែលពួកគេ ដើម្បីឱ្យពួកគេអាចត្រូវបានគេហ្វឹកហ្វឺនហាត់ពត់លត់ដំឱ្យរីកចម្រើននិងអភិវឌ្ឍ ហើយនិងដើម្បីឱ្យគេអាចបង្ហាញខ្លួននៅក្នុងសោភ័ណភាពដ៏ស្រស់ត្រកាលឡើងផងចុះ។ ពិតណាស់ព្រះអង្គគឺជាអ្នកប្រទានឱ្យអ្វីៗគ្រប់យ៉ាង។ ព្រះអង្គជាអ្នកមានព្រះទ័យមេត្តាករុណាបំផុត។

-អង្គពិសិដ្ឋអាប់ឌុលបាហា-

ឱព្រះអង្គព្រះអាទិទេព ដែលប្រកបដោយព្រះទ័យសប្បុរសធម៌អើយ! ក្មេងជាទីស្រលាញ់ទាំងនេះ គឺជាសិប្បកម្មដែលកើតមកពីម្រាមព្រះហស្តនៃអានុភាពរបស់ព្រះអង្គ ហើយនិងជាសញ្ញាដ៏អស្ចារ្យដែលកើតមកពីភាពអស្ចារ្យរបស់ព្រះអង្គ។ ឱព្រះលោកអើយ! សូមព្រះអង្គការពារក្មេងទាំងនេះ និងជួយពួកគេដោយមនុញ្ញភាពដើម្បីឱ្យពួកគេបានទទួលការអប់រំ និងដើម្បីឱ្យពួកគេបានទទួលនូវការបម្រើទៅដល់ពិភពរបស់មនុស្សជាតិនេះផង។ ឱព្រះលោកអើយ! ក្មេងទាំងនេះគឺជាមុក្តា(គុជខ្យង) ដ៏មានតម្លៃបំផុត សូមព្រះអង្គញ៉ាំងឱ្យពួកគេបានទទួលការអប់រំដែលស្ថិតនៅក្នុងកំណារការពារ នៃព្រះទ័យសប្បុរសធម៌ដែលប្រកបដោយសេចក្តីស្រលាញ់របស់ព្រះអង្គផង។

ព្រះអង្គគឺជាព្រះប្រកបដោយភាពរុងរឿង និងជាព្រះប្រកបដោយក្តីស្រលាញ់គ្រប់យ៉ាង។

-អង្គពិសិដ្ឋអាប់ឌុលបាហា-

ឱព្រះអាទិទេពជាម្ចាស់លោកអើយ! សូមព្រះអង្គធ្វើឱ្យក្មេងទាំងនេះប្រៀបដូចជារុក្ខជាតិដ៏ស្រស់ត្រកាលយ៉ាងប្រពៃផង។ សូមព្រះអង្គញ៉ាំងឱ្យពួកគេរីកធំធាត់ និងអភិវឌ្ឍន៍នៅក្នុងសួននៃកិច្ចព្រមព្រៀងរបស់ព្រះអង្គ និងសូមទ្រង់ប្រទានភាពស្រស់បស់ និង

ភាពស្រស់ស្អាតតាមរយៈការបង្អុរទឹកភ្លៀងពីពពកនៃរាជាណាចក្រុងរឿងគ្រប់យ៉ាងឱ្យដល់ពួកគេផង។

ឱព្រះអាទិទេពជាម្ចាស់ ប្រកបដោយព្រះទ័យសប្បុរសធម៌អើយ! ទូលព្រះបង្គំគឺជាក្មេងតូចអាយុវ័យខ្ចីម្នាក់ សូមព្រះអង្គលើកតម្កើងទូលព្រះបង្គំ ដោយអនុញ្ញាតឱ្យទូលព្រះបង្គំបានទៅកាន់រាជាណាចក្ររបស់ព្រះអង្គផង។ ទូលព្រះបង្គំជាមនុស្សលោកិយ សូមព្រះអង្គធ្វើឱ្យទូលព្រះបង្គំក្លាយជាមនុស្សឋានសួគ៌ ទូលព្រះបង្គំជាមនុស្សរបស់ពិភពទាប សូមព្រះអង្គធ្វើឱ្យទូលព្រះបង្គំក្លាយជាមនុស្សរបស់ពិភពខ្ពស់ ទូលព្រះបង្គំជាមនុស្សស្រអាប់ស្រពាប់ស្រពោន សូមព្រះអង្គអនុញ្ញាតឱ្យទូលព្រះបង្គំបានក្លាយជាមនុស្សរួសរាយប្រិមប្រិយ ទូលព្រះបង្គំជាមនុស្សជំពាក់ចិត្តនឹងសម្ភារ សូមព្រះអង្គធ្វើឱ្យទូលព្រះបង្គំក្លាយជាមនុស្សជំពាក់ចិត្តនឹងចិត្ត វិញ្ញាណ ហើយសូមព្រះអង្គប្រទានឱ្យទូលព្រះបង្គំ តាមការបួងសួងសុំរបស់ទូលព្រះបង្គំផង ដើម្បីឱ្យទូលព្រះបង្គំអាចបញ្ចេញឱ្យឃើញនូវភាពសម្បូរជាអនន្តរបស់ព្រះអង្គបាន។

ព្រះអង្គគឺជាព្រះប្រកបដោយសព្វានុភាពជាព្រះប្រកបដោយក្តីស្រលាញ់គ្រប់យ៉ាង។

-អង្គពិសិដ្ឋអាប់ឌុលបាហា-

ព្រះអង្គគឺជាព្រះអាទិទេពជាម្ចាស់! ឱព្រះអាទិទេពជាម្ចាស់របស់ទូលព្រះបង្គំអើយ! សូមព្រះអង្គប្រទានបេះដូងបរិសុទ្ធដែលមានតម្លៃដូចគ្នានឹងមុក្តាដល់ទូលព្រះបង្គំផង។

-អង្គពិសិដ្ឋអាប់ឌុលបាហា-

ឱព្រះអាទិទេពជាម្ចាស់លោកអើយ! សូមព្រះអង្គនាំផ្លូវទូលព្រះបង្គំការពារទូលព្រះបង្គំ ធ្វើឱ្យទូលព្រះបង្គំប្រៀបដូចជាដួងប្រទីបដែលមានពន្លឺចែងចាំងរស្មី និងជាដួងតារាមួយដួងដែលមានពន្លឺប្រិមប្រិយត្រចះត្រចង់ផង ព្រះអង្គជាព្រះប្រកបដោយអានុភាព និងពលានុភាពក្រៃលែង។

-អង្គពិសិដ្ឋអាប់ឌុលបាហា-

ឱព្រះរបស់ទូលព្រះបង្គំលោកអើយ! ពិតណាស់ព្រះអង្គគឺជាព្រះអាទិទេពរបស់ទូលព្រះបង្គំ! ទូលព្រះបង្គំគឺជាមនុស្សក្មេងខ្ចីម្នាក់។ សូមព្រះអង្គចិញ្ចឹមទូលព្រះបង្គំដោយខីររសដែលកើតមកពីកន្សោមទ្រូងនៃមេត្តាធម៌របស់ព្រះអង្គ អប់រំទូលព្រះបង្គំនៅក្នុងព្រះទ័យនៃក្តីស្រលាញ់របស់ព្រះអង្គ បណ្តុះបណ្តាលទូលព្រះបង្គំនៅក្នុងសាលានៃការដឹកនាំផ្លូវរបស់ព្រះអង្គ និងសូមទ្រង់អភិវឌ្ឍន៍ទូល

ព្រះបង្គំនៅក្រោមម្លប់នៃភាពសម្បូររុងរឿងរបស់ព្រះអង្គផង។ សូមព្រះអង្គដឹកនាំទូលព្រះបង្គំឱ្យចាកផុតពីភាពងងឹត សូមព្រះអង្គធ្វើឱ្យទូលព្រះបង្គំមានពន្លឺដ៏ប្រិមប្រិយសូមព្រះអង្គធ្វើឱ្យទូលព្រះបង្គំគេចផុតពីភាពអពមង្គល សូមព្រះអង្គធ្វើឱ្យទូលព្រះបង្គំប្រៀបដូចជាផ្កាកុឡាបនៃសួនតែមួយ សូមព្រះអង្គអនុញ្ញាតឱ្យទូលព្រះបង្គំបានក្លាយជាអ្នកបម្រើនៃទ្វារឋានសួគ៌របស់ព្រះអង្គ និងសូមព្រះអង្គផ្តល់ក្តីអធ្យាស្រ័យនិងនិស្ស័យចរឹតត្រឹមត្រូវឱ្យទូលព្រះបង្គំផង ហើយសូមព្រះអង្គញ៉ាំងឱ្យទូលព្រះបង្គំ បានក្លាយជាប្រភពនៃភាពសម្បូរដល់ពិភពមនុស្ស ហើយនិងសូមព្រះអង្គបំពាក់មកុដឱ្យក្បាលរបស់ទូលព្រះបង្គំជាមួយនឹងមកុដនៃជីវិតអនន្តផង។ ពិតណាស់ព្រះអង្គគឺជាព្រះប្រកបដោយសព្វានុភាព ជាព្រះប្រកបដោយពលានុភាព ជាអ្នកមានចក្ខុវិញ្ញាណទិព្វ ជាអ្នកមានសោតវិញ្ញាណទិព្វ។

-អង្គពិសិដ្ឋអាប់ឌុលបាហា-

ឱព្រះអាទិទេពជាម្ចាស់ដែលគ្មានគូប្រៀបអើយ! ព្រះអង្គគឺជាទីជម្រកសម្រាប់ក្មេងដ៏កំសត់នេះ ហើយក៏ជាព្រះដែលមានព្រះទ័យសប្បុរសធម៌ និងការលើកលែងទោសចំពោះមនុស្សដែលប្រព្រឹត្តិខុសគន្លង ហើយនិងមនុស្សដែលមិនសប្បាយចិត្តនេះ។ ឱព្រះអាទិទេពជាម្ចាស់លោកអើយ! បើទោះជាពួកយើងគឺជារុក្ខជាតិដែលឥតតម្លៃក៏ដោយក៏ពួកយើងនៅតែជាកុលាបនៃសួនរបស់ព្រះអង្គ

ដែរ។ បើទោះបីពួកយើងជាកូនឈើដែលឥតមានស្លឹកហើយនិងផ្កាក៏ដោយក៏ពួកយើងនៅតែជាផ្នែកមួយនៃចំការរបស់ព្រះអង្គដែរ។ ដូច្នេះសូមព្រះអង្គចិញ្ចឹមរុក្ខជាតិនេះ តាមរយៈការបង្អុរទឹកភ្លៀងដែលកើតមកពីពពកនៃមេត្តាធម៌ដ៏ស្រទន់របស់ព្រះអង្គ និងធ្វើឱ្យកូនឈើនេះមានសង្ឃឹម និងស្រស់ស្រាយតាមរយៈដង្ហើមរស់នៃនិទាឃរដូវនៃចិត្តវិញ្ញាណរបស់ព្រះអង្គផង។ ហើយក៏សូមព្រះអង្គញ៉ាំងឱ្យក្មេងម្នាក់នេះបានក្លាយជាមនុស្សដែលចេះយកចិត្តទុកដាក់ជាមនុស្សដែលចេះត្រិះរិះពិចារណា ហើយនិងជាមនុស្សថ្លៃថ្នូរ ព្រមទាំងសូមឱ្យព្រះអង្គញ៉ាំងឱ្យគាត់ទទួលបាននូវជីវិតអនន្ត និងបានរស់នៅក្នុងរាជាណាចក្ររបស់ព្រះអង្គជារៀងរហូតទៅហោង។

-អង្គពិសិដ្ឋអាប់ឌុលបាហា-

បពិត្រព្រះអង្គជាព្រះអាទិទេពរបស់ទូលព្រះបង្គំលោកអើយ! ព្រះអង្គគឺជាអ្នកទតមើលក្មេងៗ ដែលជាមែកឈើនៃជីវិតគឺជាសកុណជាតិ(បក្សាបក្សី)នៃវាលសង្គ្រោះ ជាគុជនៃសមុទ្រមនុញ្ញភាពរបស់ព្រះអង្គ ហើយនិងជាកុលាបនៃសួនការណែនាំបង្ហាញផ្លូវរបស់ទ្រង់។

ឱព្រះអាទិទេពដែលជាព្រះរបស់ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នាអើយ! យើងទាំងអស់គ្នានឹងច្រៀងសរសើរដល់ភាពខ្ពង់ខ្ពស់របស់ព្រះអង្គ និងធ្វើជាសាក្សីសក្ខីភាពដល់សន្តិភាពរបស់ព្រះអង្គ ហើយសូមអង្វរដោយចិត្តស្មោះសរដល់ឋានសួគ៌ដែលជាមេត្តាធម៌របស់ព្រះអង្គ ដើម្បីសុំឱ្យទ្រង់ធ្វើឱ្យទូលព្រះបង្គំយើងខ្ញុំបានក្លាយជាពន្លឺនៃការដឹកនាំ បានក្លាយជាតារាដែលមានពន្លឺរស្មីចិញ្ចែងចិញ្ចាចនៅលើនភាល័យនៃភាពរុងរឿងជាអនន្ត នៅក្នុងចំណោមមនុស្សជាតិ ហើយនិងសូមអង្វរដោយចិត្តក្លៀវក្លាដល់ឋានសួគ៌ដែលជាមេត្តាធម៌របស់ព្រះអង្គ ដើម្បីសុំឱ្យទ្រង់បង្រៀនពួកយើងនូវចំណេះដឹងដែលកើតមកពីព្រះអង្គ។ យ៉ាបាហាអ៊ុលឡាអាប់ហា!

-អង្គពិសិដ្ឋអាប់ឌុលបាហា-

ឱសម្មិត្តិទេពម្ចាស់លោកអើយ! ទូលព្រះបង្គំគឺជាកុមារដែលមានអាយុវ័យខ្ចីណាស់ សូមព្រះអង្គញ៉ាំងឱ្យទូលព្រះបង្គំបានធំធាត់ដោយនៅក្រោមម្លប់នៃព្រះទ័យសប្បុរសធម៌ដែលប្រកបដោយសេចក្តីស្រលាញ់របស់ព្រះអង្គផង។ ទូលព្រះបង្គំគឺជារុក្ខជាតិនៅវ័យខ្ចីណាស់ សូមព្រះអង្គញ៉ាំងឱ្យទូលព្រះបង្គំបានរីកដុះដាលតាមរយៈការបង្អុរទឹកភ្លៀងពីពពក នៃភាពសម្បូរហូរហៀររបស់ព្រះអង្គផង។ ទូលព្រះបង្គំគឺជាកូនឈើវ័យខ្ចីនៃសួនសេចក្តីស្រលាញ់ សូម

ព្រះអង្គញ៉ាំងឱ្យទូលព្រះបង្គំ បានក្លាយទៅជាដើមឈើមួយដើម ដែលប្រកបដោយផ្កាផ្លែផង។

ពិតណាស់ព្រះអង្គគឺជាព្រះដែលមានអានុភាព និងសព្វានុភាព ព្រះអង្គគឺជាព្រះប្រកបដោយសេចក្តីស្រលាញ់គ្រប់យ៉ាង ជាព្រះមានញាណទិព្វនិងជាព្រះមានចក្ខុញាណទិព្វ។

-អង្គពិសិដ្ឋអាប់ឌុលបាហា-

ឱព្រះអាទិទេពជាម្ចាស់ ដែលប្រកបដោយភាពសម្បូររុងរឿងបំផុតអើយ! សូមព្រះអង្គធ្វើឱ្យអ្នកបម្រើរបស់ព្រះអង្គដ៏តូចម្នាក់នេះបានទទួលនូវសព្វសាធុការពរ ហើយនិងមានសុភមង្គលផង សូមព្រះអង្គញ៉ាំងឱ្យនាងបានទទួលនូវក្តីស្រលាញ់បំផុត ពីទ្វារឋានសួគ៌នៃភាពតែមួយរបស់ព្រះអង្គ ហើយក៏សូមឱ្យព្រះអង្គអនុញ្ញាតឱ្យនាងបានក្រេបរសជាតិទឹកនៃក្តីស្រលាញ់ដ៏ជ្រាលជ្រៅ ពីពែងរបស់ព្រះអង្គដើម្បីឱ្យនាងអាចត្រូវបានគេបំពេញឱ្យដោយភាពអណ្តែតអណ្តូងនិងបីតិ(ការអណ្តែតអណ្តូង) ហើយនិងមានក្លិនពិដោរដ៏ក្រអូបសាយផង។ ពិតណាស់ព្រះអង្គគឺជាព្រះប្រកបដោយអានុភាពនិងសព្វានុភាព ព្រះអង្គគឺជាព្រះទ្រង់ញាណ និងជាអ្នកមានញាណទិព្វគ្រប់យ៉ាង។

-អង្គពិសិដ្ឋអាប់ឌុលបាហា-

# ធម៌សម្រាប់ទារក

ឱព្រះអាទិទេពជាម្ចាស់របស់ទូលព្រះបង្គំលោកអើយ! ព្រះអង្គគឺជាព្រះដែលមានភាពខ្ពង់ខ្ពស់បំផុត សូមព្រះអង្គយល់ព្រមដោយមនុញ្ញភាពឱ្យទារកម្នាក់នេះ បានបឺតយកខីររសពីកន្សោមទ្រូងនៃមេត្តាធម៌ដ៏ស្រទន់ និងទិព្វញាណដែលប្រកបដោយក្ដីស្រលាញ់របស់ព្រះអង្គ ហើយនិងបានគេចិញ្ចឹមដោយផល្លានុផលពីដើមឈើទិព្វរបស់ព្រះអង្គផង។ សូមព្រះអង្គបញ្ចៀសទារកម្នាក់នេះឱ្យបានចាកផុតពីការបង្ខាំងទុក ដែលជាការកង្វល់របស់មនុស្សណាម្នាក់ក្រៅពីព្រះអង្គផង ព្រោះថាមានតែព្រះអង្គទេដែលតាមរយៈសក្កានុពលនៃអធិបតេយ្យភាព ហើយនិងអំណាចរបស់ព្រះអង្គផ្ទាល់នឹងបង្កើតគាត់ ហើយនិងធ្វើឱ្យគាត់រស់រានមានជីវិតដែលប្រកបដោយមនុស្សលោកបាន។ គ្មានព្រះណាក្រៅពីព្រះអង្គឡើយព្រះអង្គគឺជាព្រះប្រកបដោយអំណាច និងជាព្រះទ្រង់ញាណគ្រប់យ៉ាង។ ឱព្រះអង្គដែលជាទីស្រលាញ់បំផុតរបស់ទូលព្រះបង្គំលោកអើយ ព្រះអង្គគឺជាព្រះគួរឱ្យសរសើរខ្លាំងណាស់ សូមព្រះអង្គបង្ហើរក្លិនក្រអូបនៃភាពសម្បូរហូរហៀរ ដ៏សំខាន់បំផុតរបស់ព្រះអង្គហើយនិងក្លិនពិដោរនៃអំណោយពិសិដ្ឋរបស់ព្រះអង្គ ឱ្យបានដល់ទារកម្នាក់នេះផង។ ឱព្រះអង្គដែលជាអ្នកកាន់កាប់រាជាណាចក្រនៃនាមរូប ហើយនិងកេតណភ័ណ្ឌនៅក្នុងកណ្ដាប់ព្រះហស្ថរបស់

ព្រះអង្គលោកអើយ សូមព្រះអង្គញ៉ាំងឱ្យទារកម្នាក់នេះស្វែងរកទីជម្រកនៅក្រោមម្លប់នៃព្រះនាមដ៏ខ្ពង់ខ្ពស់របស់ព្រះអង្គបានសម្រេចផង។ ពិតណាស់ព្រះអង្គមានសក្ដានុពលអាចធ្វើអ្វីៗបានតាមព្រះអង្គសព្វព្រះហឫទ័យ ហើយតាមពិតព្រះអង្គក៏ជាព្រះដែលប្រកបដោយអានុភាព ជាព្រះប្រកបដោយភាពខ្ពង់ខ្ពស់ជាព្រះលើកលែងទោស ជាព្រះប្រកបដោយសប្បុរធម៌ និងជាព្រះប្រកបដោយមេត្តាធម៌ផងដែរ។

អង្គពិសិដ្ឋអាប់ឌុលបាហា-

ឱព្រះអង្គដែលជាព្រះអាទិទេពជាម្ចាស់ ដែលមានឋានៈដ៏ខ្ពង់ខ្ពស់គ្មានគូប្រៀបស្មើអើយ! សូមព្រះអង្គញ៉ាំងឱ្យទារកដែលមិនទាន់ផ្ដាច់ដោះនេះត្រូវបានគេចិញ្ចឹមដោយខីររសពីកន្សោមទ្រូងនៃព្រះទ័យសប្បុរសធម៌ដ៏ជាទីស្រលាញ់របស់ព្រះអង្គ ហើយសូមព្រះអង្គរក្សាការពារក្មេងម្នាក់នេះ ឱ្យស្ថិតនៅក្នុងអម្រឹងសុវត្ថិភាពហើយនិងកំណារការពាររបស់ព្រះអង្គហើយក៏សូមព្រះអង្គញ៉ាំងឱ្យគេថ្នាក់ថ្នមបមបីទារកម្នាក់នេះ នៅក្នុងព្រះហស្ថនៃក្ដីស្រលាញ់ដ៏ស្រទន់របស់ព្រះអង្គផង។

-អង្គពិសិដ្ឋអាប់ឌុលបាហា-

ឱព្រះអាទិទេពជាម្ចាស់លោកអើយ! សូមព្រះអង្គថ្នាក់ថ្នមបម បីទារកដ៏តូចម្នាក់នេះ នៅក្នុងព្រះឱរានៃក្ដីស្រលាញ់របស់ព្រះអង្គ ហើយសូមព្រះអង្គផ្ដល់ខីររសពីកន្សោមទ្រូងនៃទិព្វញាណរបស់ព្រះ អង្គដល់ទារកម្នាក់នេះផង។ សូមព្រះអង្គដាំបណ្ដុះរុក្ខជាតិដ៏ស្រស់ខ្ចី នេះនៅក្នុងសួនកុលាបនៃក្ដីស្រលាញ់ និងការឧបត្ថម្ភរបស់ព្រះអង្គ ដល់វា ដើម្បីឱ្យវាលូតលាស់តាមរយៈទឹកភ្លៀងនៃភាពសម្បូរហូរ ហៀររបស់ព្រះអង្គផង។ សូមព្រះអង្គធ្វើឱ្យវាក្លាយជាក្មេងរាជាណា ចក្រម្នាក់ ហើយនិងនាំវាឆ្ពោះទៅកាន់រាជាណាចក្រឋានសួគ៌របស់ ព្រះអង្គផង។ ព្រះអង្គគឺជាព្រះប្រកបដោយសព្វានុភាពនិងសប្បុ រសធម៌ ព្រះអង្គជាអ្នកប្រទាន ជាអ្នកមានសប្បុរស ជាព្រះប្រកប ដោយភាពសម្បូររុងរឿងដ៏លើសលុប។

-អង្គពិសិដ្ឋអាប់ឌុលបាហា-

# ធម៌មរណៈភាព

(ធម៌សូត្រនាពេលមរណៈភាព)

*(ធម៌នេះ សូត្រនាពេលមាននរណាម្នាក់ទទួលមរណៈភាព គឺជាធម៌កាតព្វកិច្ច ដែលមានតែបាហៃប៉ុណ្ណោះដែលអាចសូត្រនៅក្នុងក្រុមជំនុំ វានឹងត្រូវបានគេសូត្រដោយអ្នកជំនឿម្នាក់ នាពេលដែលអ្នកជំនឿទាំងអស់ដែលមានវត្តមាននៅក្នុងជំហរ ដោយភាពស្ងៀមស្ងាត់។ ព្រះបាហាអ៊ុលឡាហ៍បានពន្យល់យ៉ាងច្បាស់ថា ធម៌នេះតម្រូវឱ្យគេសូត្រ នៅពេលណាតែអ្នកដែលបានទទួលមរណៈភាពនោះ មានអាយុចាប់ពី១៥ឆ្នាំឡើងទៅ ហើយការសូត្រធម៌នេះត្រូវតែធ្វើមុនពេលបញ្ចុះសព ហើយក៏មិនចាំបាច់តម្រូវឱ្យបែរមុខទៅរកទិសគីបលី(ទឹកដីសក្តិសិទ្ធ)នាពេលសូត្រនោះដែរ។ ពាក្យ "អាឡាអ៊ុអាប់ផា,Allá'h-ú-Abhá" ត្រូវបានគេសូត្រតែមួយដង ហើយបន្ទាប់មកធម៌ទីមួយក្នុងចំណោមធម៌ទាំង៦ ត្រូវបានគេសូត្រ១៩ដង។ បន្ទាប់ពីនោះមកពាក្យ "អាឡាអ៊ុអាប់ផា" ត្រូវបានគេសូត្រម្តងទៀតដែលអមទៅដោយធម៌ទីពីរដែលត្រូវបានគេសូត្រ១៩ដងដូចធម៌ទីមួយដែរ ។ល។*

ឱព្រះអាទិទេពជាម្ចាស់លោកអើយ! នេះគឺជាអ្នកបម្រើរបស់ព្រះអង្គ ហើយក៏ជាបុត្រានៃអ្នកបម្រើរបស់ព្រះអង្គដែលបានជឿ

ចំពោះព្រះអង្គ ហើយនិងចំពោះសញ្ញារបស់ព្រះអង្គដែរ គាត់បានងើបមុខរបស់គាត់ឆ្ពោះទៅរកព្រះអង្គ ព្រមទាំងបានកាត់ផ្តាច់ចោលនូវអ្វីៗគ្រប់យ៉ាងទាំងអស់លើកលែងតែព្រះអង្គ។ ពិតណាស់ព្រះអង្គគឺជាអ្នកបង្ហាញមេត្តាធម៌ម្នាក់ ក្នុងចំណោមអ្នកបង្ហាញមេត្តាធម៌ដែលប្រកបដោយក្តីករុណាបំផុត។ ឱព្រះអង្គដែលជាអ្នកលើកលែងទោសដល់សេចក្តីបាបរបស់មនុស្ស ហើយនិងជាអ្នកលាក់បំបាំងនូវទោសកំហុសរបស់ពួកគេលោកអើយ សូមព្រះអង្គលើកលែងទោសឱ្យគាត់ម្នាក់នេះ ដោយភាពសមគួរនៃភាពសម្បូររបស់ព្រះអង្គ ហើយនិងមហាសាគរនៃមនុញ្ញភាពរបស់ព្រះអង្គផង។ សូមព្រះអង្គ អនុញ្ញាតឱ្យគាត់ស្ថិតនៅក្នុងបរិវេណនៃមេត្តាធម៌ដ៏ឧត្តមរបស់ព្រះអង្គដែលជាគ្រឹះមុនគេនៃផែនដីនិងឋានសួគ៌ផង។ គ្មានព្រះណាក្រៅពីព្រះអង្គឡើយ ព្រះអង្គជាអ្នកលើកលែងទោសជាព្រះប្រកបដោយព្រះទ័យសប្បុរសធម៌បំផុត។

*បន្ទាប់មកចូរសូត្រពាក្យ"អាឡាអ៊ុអាប់ផា" ៦ដង ហើយបន្ទាប់មកទៀតចូរសូត្រធម៌និមួយៗខាងក្រោមនេះ ចំនួនដប់ប្រាំបួនដង:*

1. ពិតណាស់យើងទាំងអស់គ្នា សូមធ្វើសក្ការៈចំពោះព្រះអង្គព្រះអាទិទេពជាម្ចាស់។
2. ពិតណាស់យើងទាំងអស់គ្នាសូមលំឱនកាយនៅចំពោះព្រះភក្ត្រព្រះអង្គព្រះអាទិទេពជាម្ចាស់។

3. ពិតណាស់យើងទាំងអស់គ្នា ជាអ្នកដែលមានភក្តីភាពចំពោះព្រះអង្គព្រះអាទិទេពជាម្ចាស់។
4. ពិតណាស់យើងទាំងអស់គ្នា សូមសរសើរចំពោះព្រះអង្គព្រះអាទិទេពជាម្ចាស់។
5. ពិតណាស់យើងទាំងអស់គ្នា សូមថ្លែងអំណរគុណចំពោះព្រះ អង្គព្រះអាទិទេពជាម្ចាស់។
6. ពិតណាស់យើងទាំងអស់គ្នា ជាអ្នកមានចិត្តខន្តីតាមព្រះអង្គព្រះអាទិទេពជាម្ចាស់។

(បើអ្នកទទួលមរណភាពជាស្ត្រីចូរសូត្រថា៖ នេះគឺជាអ្នកបម្រើស្រី ហើយក៏ជាបុត្រីនៃអ្នកបម្រើរបស់ព្រះអង្គ។ល។)

-ព្រះបាហាអ៊ុលឡាហ៍-

# ធម៌ទូនៅសម្រាប់មរណភាព

ឱព្រះអាទិទេពជាម្ចាស់របស់ទូលព្រះបង្គំលោកអើយ! ព្រះអង្គជាអ្នកមានភាពរុងរឿងដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គកុំធ្វើឱ្យអ្នកដែលព្រះអង្គបានលើកតម្កើង តាមរយៈអំណាចនៃអធិបតេយ្យភាពជាអមតៈរបស់ព្រះអង្គម្នាក់នេះធ្លាក់ចុះថោកទាបឡើយ ហើយក៏សូមព្រះអង្គកុំធ្វើឱ្យអ្នកដែលព្រះអង្គ បានញ៉ាំងឱ្យចូលទៅកាន់ទីសក្ការៈអនន្តភាពរបស់ព្រះអង្គម្នាក់នេះ ឃ្លាតឆ្ងាយពីព្រះអង្គឡើយ។ ឱព្រះអាទិទេពជាម្ចាស់ដែលជាទីប្រាថ្នារបស់ទូលព្រះបង្គំអើយ តើព្រះអង្គនឹងបោះបង់ចោលអ្នកដែលព្រះអង្គបានយកភាពជាម្ចាស់របស់ព្រះអង្គមកធ្វើជាម្លប់គ្របលើគាត់ហើយ តើព្រះអង្គនឹងដាកចេញពីទីជំរកដែលព្រះអង្គ បានធ្វើជាទីជម្រកសម្រាប់គាត់ឬ? តើព្រះអង្គដាច់ព្រះទ័យបន្ទោកអ្នកដែលព្រះអង្គបានលើកតម្កើងឬក៏តើព្រះអង្គអាចបំភ្លេចអ្នកដែលបានចងចាំព្រះអង្គបានដែរឬទេ?

ព្រះអង្គគឺជាព្រះប្រកបដោយភាពរុងរឿងដ៏ធំស្កឹមស្កៃ! ព្រះអង្គគឺជាស្តេចអនន្តភាពរបស់មាបនកម្មទាំងមូល ហើយក៏ជាអ្នកបំបាត់សេចក្តីទុក្ខដ៏ធំជាងគេរបស់មាបនកម្ម ព្រមទាំងជាព្រះរបស់វត្ថុគ្រប់យ៉ាងដែលបានបង្កើត ហើយនិងជាអ្នកកំណត់វាសនារបស់ពួកគេជាអនន្តផងដែរ។ ឱព្រះអង្គជាព្រះអាទិទេពជាម្ចាស់របស់

ទូលព្រះបង្គំអើយ! ព្រះអង្គគឺជាព្រះដែលប្រកបដោយភាពរុងរឿង! បើនៅពេលនេះព្រះអង្គអស់មេត្តាធម៌ចំពោះអ្នកបម្រើរបស់ព្រះអង្គ អ៊ីចឹងតើបាននរណានឹងបង្ហាញពីមេត្តាធម៌ចំពោះពួកគេ ហើយបើព្រះអង្គឈប់សង្គ្រោះអ្នកដែលជាទីស្រលាញ់របស់ព្រះអង្គ អ៊ីចឹងតើនរណាអាចសង្គ្រោះពួកគេបាន?

ឱព្រះអង្គដែលជាអ្នកមានកិត្តិគុណដែលប្រកប ដោយភាពសម្បូររុងរឿងដែលមិនមានអ្វីអាចវាស់ស្ទង់បានអើយ! យើងស្រលាញ់ព្រះអង្គព្រោះតែសច្ចធម៌របស់ព្រះអង្គ។ ពិតណាស់យើងទាំងអស់គ្នាសូមលំអោនកាយថ្វាយបង្គំចំពោះព្រះអង្គ ព្រះអង្គជាអ្នកស្តែងចេញនូវយុត្តិធម៌របស់ព្រះអង្គ ពិតណាស់យើងទាំងអស់គ្នាសូមធ្វើជាសាក្សីចំពោះព្រះអង្គ។ ពិតណាស់ព្រះអង្គគឺជាព្រះជាទីស្រលាញ់របស់ពួកយើងតាមរយៈមនុញ្ញភាពរបស់ព្រះអង្គ។ គ្មានព្រះណាក្រៅពីព្រះអង្គឡើយ ព្រះអង្គជាអ្នកសង្គ្រោះឱ្យផុតពីសេចក្តីទុក្ខ ព្រះអង្គគង់នៅដោយអង្គឯង។

-ព្រះបាហាអ៊ុលឡាហ៍-

ព្រះអង្គគឺជាព្រះអាទិទេពជាម្ចាស់ ព្រះអង្គគឺជាព្រះដ៏ខ្ពង់ខ្ពស់ជាព្រះមានព្រះទ័យសប្បុរសដែលប្រកបដោយក្តីស្រលាញ់ហើយនិងភាពសម្បូររុងរឿង! ឱព្រះអាទិទេពជាម្ចាស់របស់ទូលព្រះបង្គំ

ព្រះអង្គជាព្រះប្រកបដោយភាពរុងរឿង ជាព្រះប្រកបដោយវិជិតរាជ្យដ៏ខ្ពង់ខ្ពស់។ ទូលព្រះបង្គំសូមធ្វើជាសក្ខីភាពចំពោះវិជិតរាជ្យរបស់ព្រះអង្គនិងអានុភាពរបស់ព្រះអង្គ។ ទូលព្រះបង្គំសូមធ្វើជាសក្ខីភាពចំពោះអធិបតេយ្យភាពរបស់ព្រះអង្គនិងព្រះទ័យសប្បុរសធម៌ដែលប្រកបដោយក្តីស្រលាញ់របស់ព្រះអង្គ ទូលព្រះបង្គំសូមធ្វើជាសក្ខីភាពចំពោះមនុញ្ញភាពរបស់ព្រះអង្គ និងសញ្ញានុភាពរបស់ព្រះអង្គ ទូលព្រះបង្គំសូមធ្វើជាសក្ខីភាពចំពោះភាពតែមួយ ដែលកើតមកពីមនុស្សអាទិទេពរបស់ព្រះអង្គ និងសាមគ្គីភាពដែលកើតមកពីភាពសំខាន់របស់ព្រះអង្គ ទូលព្រះបង្គំសូមធ្វើជាសក្ខីភាពចំពោះសន្តភាព(ភាពពិសិដ្ឋ)និងភាពខ្ពង់ខ្ពស់របស់ព្រះអង្គ ដែលខ្ពស់លើសពិភពរបស់មនុស្ស ហើយនិងរបស់គ្រប់យ៉ាងដែលនៅក្នុងពិភពនោះ។

ឱព្រះអង្គព្រះអាទិទេពរបស់ទូលព្រះបង្គំលោកអើយ! សូមព្រះអង្គញ៉ាំងឱ្យទូលព្រះបង្គំបានកាត់ផ្តាច់ចេញពីរបស់ គ្រប់យ៉ាងលើកលែងតែព្រះអង្គ សូមព្រះអង្គញ៉ាំងឱ្យទូលព្រះបង្គំបានតោងនឹងព្រះអង្គ ហើយសូមព្រះអង្គញ៉ាំងឱ្យទូលព្រះបង្គំបានងាកទៅកាន់មហាសាគរនៃភាពសម្បូររបស់ព្រះអង្គ សូមព្រះអង្គញ៉ាំងឱ្យទូលព្រះបង្គំបានងាកទៅកាន់ឋានសួគ៌នៃក្តីសង្គ្រោះរបស់ព្រះអង្គ សូមព្រះអង្គញ៉ាំងឱ្យទូលព្រះបង្គំ បានងាកទៅកាន់តារាពេលថ្ងៃនៃមនុញ្ញភាពរបស់ព្រះអង្គផង។

ឱព្រះអាទិទេពជាម្ចាស់លោកអើយ! ទូលព្រះបង្គំ សូមធ្វើជាសក្ខីភាពថា ព្រះអង្គគឺជាអ្នកប្រទាននូវរបស់ជាទីពឹងរបស់ព្រះអង្គឱ្យដល់អ្នកបំរើរបស់ព្រះអង្គហើយរបស់ជាទីពឹងដែលព្រះអង្គបានប្រទានឱ្យនោះគឺជាចិត្តវិញ្ញាណដែលមានមកពីព្រះអង្គ ជាអ្នកប្រទានជីវិតឱ្យមកកាន់ភពផែនដីនេះ។ ទូលព្រះបង្គំសូមអង្វរសុំឱ្យព្រះអង្គមេត្តាទទួលយកពីគាត់ម្នាក់នេះនូវអ្វីដែលគាត់បានបំពេញនៅក្នុងយុគសម័យរបស់ព្រះអង្គតាមរយៈភាពរុងរឿងដែលកើតមកពីគន្លងនៃការត្រាស់ដឹងរបស់ព្រះអង្គ។ នៅពេលនេះ សូមព្រះអង្គញ៉ាំងឱ្យគាត់បានទទួលនូវភាពសម្បូររុងរឿង ដែលកើតមកពីសេចក្តីរីករាយជាសុភមង្គលរបស់ព្រះអង្គ ហើយសូមព្រះអង្គញ៉ាំងឱ្យគាត់បានតុបតែងខ្លួនគាត់ជាមួយនឹងការទទួលស្គាល់របស់ព្រះអង្គផង។

ឱព្រះរបស់ទូលព្រះបង្គំលោកអើយ! ទូលព្រះបង្គំខ្លួនឯងផ្ទាល់ ហើយនិងវត្ថុដែលបានបង្កើតមកគ្រប់យ៉ាងនេះ សូមធ្វើជាសក្ខីភាពចំពោះអានុភាពរបស់ព្រះអង្គ ហើយទូលព្រះបង្គំក៏សូមបួងសួងដល់ព្រះអង្គ សូមកុំឱ្យទូលព្រះបង្គំឃ្លាតចេញពីវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គ ព្រោះវិញ្ញាណបរិសុទ្ធនេះហើយ ដែលបាននាំឱ្យទូលព្រះបង្គំបានទៅដល់ព្រះអង្គ បានទៅដល់ទីកន្លែងដ៏ជាទីសប្បាយរីករាយរបស់ព្រះអង្គ បានទៅដល់ឋានសួគ៌ដ៏ខ្ពង់ខ្ពស់

របស់ព្រះអង្គ ហើយនិងបាននៅជិតព្រះអង្គ ពិតណាស់ព្រះអង្គគឺជាព្រះរបស់មនុស្សគ្រប់គ្នា!

ឱព្រះរបស់ទូលព្រះបង្គំលោកអើយ! នៅពេលនេះ សូមព្រះអង្គញ៉ាំងឱ្យអ្នកបំរើរបស់ព្រះអង្គម្នាក់នោះ បានសេពគប់នឹងអ្នកជម្រើសរបស់ព្រះអង្គ បានសេពគប់នឹងអ្នកមានបុណ្យរបស់ព្រះអង្គ ហើយនិងបានសេពគប់នឹងអ្នកនាំសាររបស់ព្រះអង្គ នៅក្នុងទីស្ថានដ៏ជាទីរីករាយដែលគ្មានប៉ាកាឬអណ្តាតណាអាចរ៉ាយរ៉ាប់បានឡើយ។

ឱព្រះរបស់ទូលព្រះបង្គំលោកអើយ! ពិតណាស់អ្នកក្រម្នាក់នេះបានប្រញាប់ប្រញាល់ទៅកាន់ រាជាណាចក្រនៃទ្រព្យសម្បត្តិរបស់ព្រះអង្គ ហើយចំណែកឯអ្នកចម្លែកម្នាក់នេះក៏ប្រញាប់ប្រញាល់ចូលទៅកាន់ផ្ទះរបស់គាត់ ដែលនៅក្នុងទីកន្លែងដ៏ជិតរបស់ព្រះអង្គផងដែរ គាត់ម្នាក់នេះហើយ ដែលជាអ្នកស្រេកឃ្លានចំពោះទឹកស្ទឹងសួគ៌នៃបុណ្យរបស់ព្រះអង្គនោះ។ ឱព្រះលោកអើយ សូមព្រះអង្គកុំដកហូតចំណែកអាហារនៃមនុញ្ញភាពរបស់ព្រះអង្គចេញពីគាត់ឡើយ ហើយក៏សូមព្រះអង្គកុំដកហូតគុណប្រយោជន៍នៃបុណ្យរបស់ព្រះអង្គចេញពីគាត់ផងដែរ។ ពិតណាស់ ព្រះអង្គគឺជាព្រះប្រកបដោយសព្វានុភាព ជាព្រះប្រកបដោយមនុញ្ញភាព និងជាព្រះប្រកបដោយបុណ្យគ្រប់យ៉ាង។

ឱព្រះរបស់ទូលព្រះបង្គំលោកអើយទំនុកចិត្តដល់ព្រះអង្គបាន ញ៉ាំងឱ្យទូលព្រះបង្គំបានវិលត្រឡប់ទៅកាន់ព្រះអង្គវិញហើយ។ វាជាការល្អប្រសើរណាស់ដែលមនុញ្ញភាពរបស់ព្រះអង្គ ហើយនិងបុណ្យរបស់ព្រះអង្គដែលបានរួមបញ្ចូលគ្នានឹងអំណាចរបស់ព្រះអង្គនៅលើផែនដី ហើយនិងនៅក្នុងឋានសួគ៌នោះ ដើម្បីធានាសុវត្ថិភាពដល់អ្នកដែលគេបានស្វាគមន៍ថ្មីៗដែលជាអំណោយរបស់ព្រះអង្គ និងជាការប្រទានរបស់ព្រះអង្គ ហើយក៏ជាផលានុផលដែលចេញមកពីដើមនៃមនុញ្ញភាពរបស់ព្រះអង្គ! ព្រះអង្គប្រកបដោយសព្វានុភាព ព្រះអង្គអាចធ្វើអ្វីៗបានតាមព្រះទ័យរបស់ព្រះអង្គ គ្មានព្រះណាក្រៅពីព្រះអង្គឡើយ ព្រះអង្គគឺជាព្រះប្រកបដោយមនុញ្ញភាព ជាព្រះប្រកបដោយបុណ្យខ្ពង់ខ្ពស់បំផុត ជាព្រះប្រកបដោយក្តីអាសូរ ជាអ្នកប្រទានអ្វីៗគ្រប់យ៉ាង ជាអ្នកលើកលែងទោស ជាព្រះប្រកបដោយក្តីស្រលាញ់ ជាព្រះទ្រង់ញាណគ្រប់យ៉ាង។

ឱព្រះរបស់ទូលព្រះបង្គំខ្ញុំអើយ ទូលបង្គំសូមធ្វើជាសក្ខីភាពថា ព្រះអង្គបានបង្គាប់ឱ្យមនុស្សគ្រប់គ្នាគោរពដល់ភ្ញៀវរបស់ពួកគេ ហើយភ្ញៀវរបស់ពួកគេម្នាក់នោះ ហើយជាអ្នកដែលបានឡើងទៅកាន់ព្រះអង្គ ជាអ្នកដែលបានទៅដល់ព្រះអង្គពិតៗហើយនិងជាអ្នកដែលបានទទួលព្រះវត្តមានរបស់ព្រះអង្គ។ ចូរទាក់ទងជាមួយគាត់ បន្ទាប់មកធ្វើតាមមនុញ្ញភាព ហើយនិងបុណ្យរបស់ព្រះអង្គចុះ! តាមរយៈភាពរុងរឿងរបស់ព្រះអង្គ ទូលព្រះបង្គំដឹងយ៉ាង

ប្រាកដថា ព្រះនឹងមិនបានដកហូតពីអ្វីដែលព្រះអង្គបានបញ្ជាដោយអង្គឯងផ្ទាល់ដល់អ្នកបម្រើរបស់ព្រះអង្គឡើយ ហើយព្រះអង្គក៏មិនបានបង្អត់អ្នកដែលបានតោងទៅនឹងខ្សែ ដែលជាបុណ្យរបស់ព្រះអង្គ ព្រមទាំងជាអ្នកដែលបានឡើងទៅកាន់ភាពសប្បាយរីករាយនៃភោគទ្រព្យរបស់ព្រះអង្គនោះដែរ។

ពិតណាស់គ្មានព្រះណាក្រៅពីព្រះអង្គឡើយ ព្រះអង្គគឺជាព្រះតែមួយអង្គគត់ ជាព្រះគ្មានពីរ ជាព្រះប្រកបដោយសព្វានុភាព ជាព្រះប្រកបដោយសព្វញ្ញូភាព ជាព្រះប្រកបដោយបុណ្យខ្ពស់បំផុតគ្មានគូប្រៀប។

-ព្រះបាហាអ៊ុលឡាហ៍-

ឱព្រះរបស់ទូលព្រះបង្គំខ្ញុំអើយ! ព្រះអង្គនេះហើយជាអ្នកលើកលែងទោសលោះនៃអំពើបាប ជាអ្នកប្រទានអំណោយ ជាអ្នកកំចាត់នូវសេចក្តីឈឺចាប់! ពិតណាស់ទូលព្រះបង្គំ សូមអង្វរដល់ព្រះអង្គ សុំឱ្យទ្រង់លើកលែងទោសលោះបាបកម្មរបស់អ្នកដែលបានបោះបង់ចោលនូវសម្លៀកបំពាក់លោកិយហើយបានងើបឡើងទៅកាន់ពិភពស្មារតីនោះផង។

ឱព្រះរបស់ទូលព្រះបង្គំខ្ញុំអើយ! សូមព្រះអង្គបន្សុទ្ធពួកគេពីកំហុសខុសឆ្គងទាំងឡាយ ដែលពួកគេបានប្រព្រឹត្ត សូមព្រះអង្គកំចាត់ទុក្ខកង្វល់របស់ពួកគេហើយ សូមព្រះអង្គផ្លាស់ប្តូរស្បែងងឹតរបស់ពួកគេឱ្យប្រែក្លាយទៅជាពន្លឺភ្លឺស្វាងផង។ សូមព្រះអង្គញ៉ាំងឱ្យពួកគេបានចូលទៅកាន់សួននៃភាពរីករាយ សូមព្រះអង្គលាងជម្រះពួកគេដោយទឹកដ៏បរិសុទ្ធហើយនិងសូមព្រះអង្គញ៉ាំងឱ្យពួកគេបានឃើញនូវភាពរុងរឿងនៅលើភ្នំដ៏ខ្ពង់ខ្ពស់របស់ព្រះអង្គផង។

-អង្គពិសិដ្ឋអាប់ឌុលបាហា-

ឱព្រះរបស់ទូលព្រះបង្គំខ្ញុំអើយ! ឱព្រះរបស់ទូលបង្គំលោកអើយ! ទូលព្រះបង្គំសូមបង្អោនខ្លួនចំពោះឫទ្ធិចេស្តានៃបរមានុភាព (ភាពដាច់គេ)ដ៏ល្អឥតខ្ចោះរបស់ព្រះអង្គ សូមបន្ទាបខ្លួននៅនឹងទ្វារនៃភាពតែមួយរបស់ព្រះអង្គ ពិតណាស់អ្នកបម្រើរបស់ព្រះអង្គម្នាក់នេះបានជឿចំពោះព្រះអង្គ ហើយព្រមទាំងជឿចំពោះបទកំណាព្យរបស់ព្រះអង្គផងដែរ គេក៏បានធ្វើជាសក្ខីភាពចំពោះបន្ទូលរបស់ព្រះអង្គទៀតផងគេក៏បានបង្កឱ្យគាត់មានភ្លើងនៃសេចក្តីស្រលាញ់របស់ទ្រង់ គេបានត្រាំគាត់ឱ្យនៅក្នុងទីជម្រៅនៃសាគរនៃចំណេះដឹង គេបានធ្វើឱ្យគាត់ទាក់ចិត្តជិតអារម្មណ៍ដោយវាយោរំភើយៗរបស់ព្រះអង្គបានពឹងលើព្រះអង្គ បានងាកមុខរបស់គាត់ទៅរកព្រះអង្គបានអង្វរករដល់ព្រះអង្គ ហើយព្រមទាំងទុកចិត្តដល់

ការអភ័យទោស និងលើកលែងទោសរបស់ព្រះអង្គផងដែរ។ គាត់បានលះបង់ជីវិតអនត្តានេះចោលហើយ ហើយបានហូរទៅកាន់រាជាណាចក្រនៃអនន្តភាពដែលជាចំណង់ជួបជុំនឹងព្រះអង្គវិញ។

ឱព្រះអាទិទេពលោកអើយ សូមព្រះអង្គលើកតម្កើងឋានៈរបស់គាត់ សូមឱ្យគាត់បានជ្រកកោនក្រោមព្រះពន្លានៃមេត្តាធម៌ដ៏ឧត្តុង្គឧត្តមរបស់ព្រះអង្គ សូមព្រះអង្គញ៉ាំងឱ្យគាត់បានចូលទៅកាន់ឋានសួគ៌ដែលជាភាពរុងរឿងរបស់ព្រះអង្គ ហើយនិងសូមព្រះអង្គធ្វើឱ្យជីវិតរបស់គាត់បាននៅក្នុងសួនកុលាបដ៏ខ្ពង់ខ្ពស់របស់ព្រះអង្គជារៀងរហូត ដើម្បីឱ្យគាត់អាចបានត្រាំនៅក្នុងមហាសាគរនៃពន្លឺចំណេះដឹងនៅក្នុងពិភពនៃអាថ៌កំបាំងនេះជារៀងរហូតផង។

ពិតណាស់ព្រះអង្គគឺជាព្រះប្រកបដោយភាពរុងរឿង ជាព្រះប្រកបដោយអំណាចចេស្ដា និងជាអ្នកលើកលែងទោស ហើយនិងជាអ្នកប្រទាននូវអ្វីៗគ្រប់យ៉ាង។

-អង្គពិសិដ្ឋអាប់ឌុលបាហា-

ឱព្រះអាទិទេពជាអ្នកលើកលែងទោសលោកអើយ! ថ្វីត្បិតតែអ្នកខ្លះ បានចំណាយពេលនៃការរស់នៅរបស់ពួកគេក្នុងសភាពល្ងង់ខ្លៅ ហើយនិងជាអ្នកដែលឃ្លាតឆ្ងាយពីព្រះអង្គ និងជាអ្នកចចេសរឹងរូសក៏ដោយ ប៉ុន្តែដោយមានរលកដែលកើតចេញមក

ពីមហាសាគរ នៃការលើកលែងទោសរបស់ព្រះអង្គតែមួយពួកគេទាំងនោះក៏បានប្រាស់ចាកផុតពីអំពើបាបទាំងពួង។ នរណាក៏ដោយឱ្យតែព្រះអង្គសព្វព្រះហឫទ័យ ព្រះអង្គនឹងយកអ្នកនោះធ្វើជាអ្នកជំនិតរបស់ព្រះអង្គ ហើយនរណាក៏ដោយឱ្យតែមិនមែនជាវត្ថុបំណងនៃជម្រើសរបស់ព្រះអង្គអ្នកនោះត្រូវបានគេចាត់ទុកថាជាបាបជន។ ព្រះអង្គជាអ្នកដោះស្រាយឱ្យយើងដោយភាពយុត្តិធម៌របស់ព្រះអង្គ ចំណែកឯយើងទាំងអស់គ្នាវិញគ្មានយុត្តិធម៌អ្វីបន្តិចសោះឡើយ ក្រៅពីជាអ្នកមានបាបនិងសមតែគេបំបិទមិនឱ្យចូលទៅកាន់ព្រះអង្គ ប៉ុន្តែដោយសារតែព្រះអង្គ ជាអ្នកមានធម៌មេត្តាទើបធ្វើឱ្យអ្នកបាបទាំងអស់គ្នា បានក្លាយជាអ្នកមានចិត្តបរិសុទ្ធហើយអ្នកចម្លែកគ្រប់គ្នាបានក្លាយជាមិត្តនឹងគ្នា។ អ៊ីចឹងនៅខណៈនេះសូមព្រះអង្គប្រទាននូវការលើកលែងទោស និងការអភ័យទោសរបស់ព្រះអង្គ ហើយនិងសូមព្រះអង្គប្រទាននូវមេត្តាធម៌របស់ព្រះអង្គបានដល់ពួកគេគ្រប់ៗគ្នាផង។

ពិតណាស់ព្រះអង្គជាអ្នកលើកលែងទោស ជាអ្នកប្រទាននូវពន្លឺចំណេះដឹងហើយនិងជាអ្នកប្រកបដោយឫទ្ធិចេស្ដា។

-អង្គពិសិដ្ឋអាប់ឌុលបាហា-

# ធម៌សម្រាប់ស្ត្រី

ឱព្រះរបស់ទូលព្រះបង្គំ ឱព្រះជាអ្នកលោះបាបហើយនិងជាអ្នកកំចាត់នៃសេចក្តីទុក្ខវេទនាអើយ! ឱព្រះអង្គដែលជាអ្នកកំពុងតែលើកលែងទោសនិងជាអ្នកមានមេត្តាអើយ! ទូលព្រះបង្គំសូមលើកហត្ថាឡើង ប្រណម្យអង្វរដល់ទ្រង់ទាំងទឹកភ្នែកហូររហាមសុំឱ្យព្រះអង្គនិងព្រះរាជបរិពារជាន់ខ្ពស់របស់ព្រះអង្គសុំឱ្យលើកលែងទោសដល់ពួកគេ តាមរយៈមេត្តាធម៌ហើយនិងការអភ័យទោសរបស់ព្រះអង្គនោះបានធ្វើឱ្យទាសីស្រីបំរើរបស់ព្រះអង្គម្នាក់នេះបានឡើងទៅកាន់កៅអីនៃសច្ចភាពហើយ។ ឱព្រះលោកអើយ សូមព្រះអង្គញ៉ាំងឱ្យទាសីស្រីបម្រើម្នាក់នេះ បានស្ថិតនៅក្រោមម្លប់ដោយពពកនៃបុណ្យបារមីរបស់ព្រះអង្គ សូមព្រះអង្គឱ្យនាងត្រាំនៅក្នុងមហាសាគរនៃការលើកលែងទោស និងការត្រាប្រណីរបស់ព្រះអង្គហើយនិងសូមព្រះអង្គញ៉ាំងឱ្យនាង បានចូលទៅដល់ទីលំនៅដ៏ពិសិដ្ឋដែលជាឋានសួគ៌ដ៏ជាទីរីករាយ របស់ព្រះអង្គផង។

ពិតណាស់ព្រះអង្គជាព្រះប្រកបដោយឫទ្ធានុភាព ជាព្រះប្រកបដោយក្តីអាណិតអាសូរ ជាព្រះប្រកបដោយព្រះទ័យសប្បុរស ជាព្រះប្រកបដោយមេត្តាធម៌។

-អង្គពិសិដ្ឋអាប់ឌុលបាហា-

ឱព្រះលោកអើយ ឱព្រះអង្គអើយមេត្តាធម៌របស់ព្រះអង្គបានបញ្ចូលដល់អ្នកទាំងអស់គ្នាហើយ ការលើកលែងទោសរបស់ព្រះអង្គសំខាន់ខ្លាំងណាស់ បុណ្យរបស់ព្រះអង្គមហាប្រសើរណាស់ ការអភ័យទោសនិងសប្បុរសធម៌របស់ព្រះអង្គកំពុងតែអោបរឹតអ្នកទាំងអស់គ្នាហើយ ហើយពន្លឺនៃការលើកលែងទោសរបស់ព្រះអង្គក៏ត្រូវបានគេធ្វើឱ្យសាយភាយដល់ពិភពលោកសព្វទីកន្លែងផងដែរ! ឱព្រះនៃភាពរុងរឿងអើយ! ទូលព្រះបង្គំសូមអង្វរទ្រង់ដោយចិត្តក្លៀវក្លានិងទឹកភ្នែក សូមព្រះអង្គចោលកន្ទុយភ្នែកនៃក្ដីមេត្តារបស់ព្រះអង្គឱ្យដល់ទាសីស្រីបម្រើរបស់ព្រះអង្គដែលជាអ្នកបានឡើងទៅកាន់ព្រះអង្គម្នាក់នេះផង។ សូមព្រះអង្គរុំស្រោបនាងនៅក្នុងអាវធំនៃមនុញ្ញភាពរបស់ព្រះអង្គ សូមព្រះអង្គបំភ្លឺរស្មីឱ្យនាងដោយអលង្ការនៃឋានសួគ៌ទិព្វ សូមព្រះអង្គឆ្លុះបំភ្លឺភក្ត្រារបស់នាងដោយពន្លឺនៃមេត្តាធម៌និងករុណាទិភាពរបស់ព្រះអង្គ ហើយនិងសូមព្រះអង្គឱ្យនាងបានជ្រកនៅក្រោមដើមឈើនៃភាពតែមួយរបស់ព្រះអង្គផង។ ឱព្រះអាទិទេពលោកអើយ សូមព្រះអង្គប្រទានកំណើតក្លិនពិដោរសក្តិសិទ្ធិនៃវិញ្ញាណបរិសុទ្ធនៃការលើកលែងទោសរបស់ព្រះអង្គឱ្យបានដល់ទាសីស្រីបម្រើសួគ៌របស់ព្រះអង្គម្នាក់នេះផង។ សូមព្រះអង្គញ៉ាំងឱ្យនាងបានរស់នៅក្នុងគេហដ្ឋានបរមសុខ សូមព្រះអង្គព្យាបាលសេចក្តីទុក្ខឱ្យនាង ដោយថ្នាំនៃការរួបរួមគ្នារបស់ព្រះអង្គដោយអនុលោមទៅតាមឆន្ទៈរបស់ព្រះអង្គ ហើយនិងសូមព្រះ

អង្គអនុញ្ញាតឱ្យនាង បានចូលទៅកាន់ឋានសួគ៌សក្តិសិទ្ធិរបស់ព្រះអង្គផង។ សូមព្រះអង្គញ៉ាំងឱ្យទេវតានៃភាពសប្បុរសជាទីស្រលាញ់របស់ព្រះអង្គបានជ្រាលចុះមករកនាងតាមលំដាប់ ហើយនិងសូមឱ្យនាងបានជ្រកក្រោមដើមឈើសព្វសាធុការពររបស់ព្រះអង្គផង។ ពិតណាស់ព្រះអង្គគឺជាព្រះលើកលែងទោសជាអនន្ត ជាព្រះប្រកបដោយសប្បុរសធម៌បំផុត ជាព្រះប្រកបដោយបុណ្យគ្រប់យ៉ាង។

-អង្គពិសិដ្ឋអាប់ឌុលបាហា-

ឱព្រះដ៏មានព្រះទ័យសប្បុរសអើយ! ទាសីស្រីបំរើជាទីស្រលាញ់ម្នាក់នេះ ត្រូវបានគេធ្វើឱ្យចាប់អារម្មណ៍ចំពោះ ព្រះអង្គហើយនាងបានធ្វើការសញ្ជឹងគិត ហើយនិងការវិនិច្ឆ័យដោយយកចិត្តទុកដាក់ដ៏យូរដើម្បីឱ្យបានទទួលនូវព្រះវត្តមានរបស់ព្រះអង្គ ហើយនិងដើម្បីឱ្យបានចូលទៅដល់រាជាណាចក្ររបស់ព្រះអង្គ។ នាងបានសម្លឹងផ្តោតភ្នែករបស់នាង ទៅលើរាជាណាចក្រនៃអាថិកំបាំងដោយទឹកភ្នែកហូររហាម។ ក្នុងមួយយប់ៗនាងបានចំណាយពេលជាច្រើនក្នុងការទាក់ទង ជាមួយនឹងព្រះអង្គដោយអារម្មណ៍យ៉ាងជ្រាលជ្រៅ ហើយក្នុងមួយថ្ងៃៗនាងបានរស់នៅដោយក្តីនឹករឭកដល់ព្រះអង្គយ៉ាងច្រើន។ ជារៀងរាល់ព្រឹកនាងបានគិតដល់ព្រះអង្គ ហើយនិងរៀងរាល់ល្ងាចនាងបានផ្តោតអារម្មណ៍គំនិតរបស់

នាងទៅដល់ព្រះអង្គ។ នាងបានសូត្រកំណាព្យពិសិដ្ឋរបស់ព្រះអង្គ ប្រៀបដូចជាសម្លេងច្រៀងរបស់បក្សីត្រាច់ចរនាពេលរាត្រី ហើយ នាងបានខំប្រឹងឆ្លុះយកពន្លឺរបស់ព្រះអង្គប្រៀបដូចជាកញ្ចក់ឆក់យក ពន្លឺអ៊ុចឹងដែរ។

ឱព្រះអង្គ ដែលជាអ្នកលើកលែងទោសដល់អ្នកដែលមានអំពើបាបអើយ! សូមព្រះអង្គបើកចំហផ្លូវឱ្យអ្នកដែលបានភ្ញាក់រលឹកម្នាក់នេះ ឱ្យបានចូលទៅកាន់រាជាណាចក្ររបស់ព្រះអង្គ និងញ៉ាំងឱ្យបក្សីដែលបានបង្វឹកដោយព្រះហស្ដរបស់ព្រះអង្គ ១ក្បាលនេះ បានហើរសំកាំងនៅក្នុងសួនកុលាបជាអន្តនផង។ នាងបានបញ្ឆោះដោយភ្លើងចំណង់ចង់នៅជិតព្រះអង្គ ដូច្នេះសូមព្រះអង្គញ៉ាំងឱ្យនាងបានចូលគាល់ដល់ព្រះវត្តមានរបស់ព្រះអង្គផង។ នាងមានអារម្មណ៍រវើរវាយនិងទុក្ខព្រួយខ្លាំងណាស់ បើនាងឃ្លាតឆ្ងាយពីព្រះអង្គ ដូច្នេះសូមព្រះអង្គអនុញ្ញាតឱ្យនាងបានចូលទៅក្នុងវិមានសួគ៌របស់ព្រះអង្គផង។ ឱព្រះលោកអើយ! ពួកយើងទាំងអស់គ្នាជាអ្នកដែលមានអំពើបាប ចំណែកឯព្រះអង្គគឺជាអ្នកលើកលែងទោសដល់អ្នកដែលមានអំពើបាបដូចជាពួកយើងខ្ញុំនេះ។ យើងខ្ញុំទាំងអស់គ្នាត្រូវបានគេធ្វើឱ្យលិចលង់ ក្នុងមហាសាគរនៃវិបត្តិភ័យ ចំណែកឯព្រះអង្គគឺជាអ្នកអភ័យទោស និងជាអ្នកមានព្រះទ័យល្អជានិច្ច។ សូមព្រះអង្គលោះបាបកម្មរបស់ពួកយើង និងសូមឱ្យពួកយើងបានទទួលសព្ទសាធុការពរ ដោយមនុញ្ញភាពដ៏សម្បូរបែប

របស់ព្រះអង្គផង។ សូមព្រះអង្គប្រទានសិទ្ធិនៃការមើលឃើញនូវភាពប្រសើរខ្ពង់ខ្ពស់របស់ព្រះអង្គឱ្យពួកយើង និងប្រទានឱ្យពួកយើងនូវពែងនៃសេចក្ដីរីករាយនិងបរមសុខផង។ ពួកយើងគឺជាឈ្លើយនៃអំពើបាបផ្ទាល់ខ្លួនឯង រីឯព្រះអង្គវិញគឺជាអធិរាជនៃការអនុគ្រោះដែលប្រកបដោយបុណ្យ។ ពួកយើងត្រូវបានគេធ្វើឱ្យលង់ស្លាប់ក្នុងមហាសាគរនៃអំពើទុច្ចរិត ចំណែកឯព្រះអង្គវិញគឺជាព្រះដែលមានមេត្តាធម៌គ្មានទីបញ្ចប់។ ព្រះអង្គគឺជាព្រះលើកលែងទោស ជាព្រះប្រកបដោយភាពរុងរឿង ជាព្រះមានជីវិតអមតៈ ជាព្រះប្រកបដោយព្រះទ័យសប្បុរស និងជាអ្នកមានមនុញ្ញភាព ជាអ្នកមានមេត្តាធម៌គ្រប់យ៉ាង ជាអ្នកប្រកបដោយសព្វានុភាពព្រះអង្គគឺជាអ្នកប្រទានអំណោយនិងជាអ្នកលើកលែងទោសដល់អ្នកដែលមានអំពើបាប។ ពិតណាស់ ព្រះអង្គគឺជាទ្រង់ដែលយើងងាកទៅកាន់ដើម្បីសុំការអនុគ្រោះពីកំហុសរបស់យើង គឺជាទ្រង់ដែលជាព្រះលើសអស់ព្រះទាំងពួង។

-អង្គពិសិដ្ឋអាប់ឌុលបាហា-

# ធម៌សម្រាប់ស្វាមី

ឱព្រះជាព្រះរបស់ទូលបង្គំអើយ! ទាសីស្រីបម្រើរបស់ព្រះអង្គម្នាក់នេះកំពុងតែបួងសួងដល់ព្រះអង្គ កំពុងតែមានទំនុកចិត្តចំពោះព្រះអង្គ កំពុងតែងាកមុខរបស់នាងទៅរកព្រះអង្គ កំពុងតែអង្វរព្រះអង្គសុំឱ្យព្រះអង្គសម្រក់ឱ្យនាង នូវបុណ្យសួគ៌របស់ព្រះអង្គ ហើយឱ្យព្រះអង្គបង្ហាញអាថ៌កំបាំងផ្នែកស្មារតីរបស់ព្រះអង្គឱ្យនាងបានឃើញ ហើយនិងសូមព្រះអង្គឆ្លុះបំភ្លឺនៃបញ្ញារបស់ព្រះអង្គដែលជាព្រះឱ្យនាងបានឃើញផង។

ឱព្រះរបស់ទូលបង្គំអើយ! សូមព្រះអង្គធ្វើឱ្យចក្ខុស្វាមីរបស់ទូលបង្គំបានមើលឃើញអ្វីៗគ្រប់យ៉ាងផង។ សូមព្រះអង្គញ៉ាំងឱ្យបេះដូងរបស់ស្វាមីទូលបង្គំ បានរីករាយស្រស់ស្រាយជាមួយនឹងពន្លឺនៃចំណេះដឹងរបស់ព្រះអង្គ សូមព្រះអង្គអូសទាញសតិអារម្មណ៍របស់គាត់ឱ្យបានចូលទៅដល់សោភ័ណភាពដែលជាពន្លឺរបស់ព្រះអង្គ សូមព្រះអង្គញ៉ាំងឱ្យចិត្តវិញ្ញាណរបស់គាត់បានអបអរខ្សៀវខ្សាដោយការត្រាស់បញ្ចេញឱ្យគាត់ បានឃើញនូវភាពរុងរឿងដែលបង្ហាញឱ្យឃើញរបស់ព្រះអង្គផង។

ឱព្រះរបស់ទូលបង្គំលោកអើយ! សូមព្រះអង្គបើកស្បៃចេញពីមុខចក្ខុស្វាមីរបស់ទូលបង្គំផង។ សូមព្រះអង្គបង្អុរទឹកភ្លៀងនៃ

បុណ្យបរិបូរណ៍ចុះមកលើរូបគាត់ សូមព្រះអង្គធ្វើឱ្យគាត់ជក់ចិត្ត ជិតអារម្មណ៍ជាប់នឹងទឹកអម្រឹត ដែលកើតមកពីសេចក្តីស្រលាញ់ របស់គាត់ចំពោះព្រះអង្គ សូមព្រះអង្គធ្វើឱ្យគាត់បានក្លាយជាទេវតា មួយអង្គ ក្នុងចំណោមទេវតាទាំងឡាយរបស់ព្រះអង្គ ដែលជើង របស់ពួកគេដើរនៅលើផែនដីនេះតែវិញ្ញាណក្ខន្ធរបស់ពួកគេកំពុង តែហោះកាត់ទៅកាន់ឋានសួគ៌ដ៏ខ្ពង់ខ្ពស់។ សូមព្រះអង្គញ៉ាំងឱ្យ គាត់ បានក្លាយជាប្រទីបមួយដ៏មានពន្លឺចិញ្ចែងចិញ្ចាចនិងបញ្ចេញ រស្មីដោយពន្លឺនៃគតិបណ្ឌិតនៅចំកណ្តាលហ្វូងនៃមនុស្សរបស់ព្រះ អង្គ។

ពិតណាស់ព្រះអង្គគឺជាព្រះជាទីស្រលាញ់ ជាព្រះប្រទានជា អមត ជាព្រះដែលមានព្រះហស្តទូលំទូលាយ។

-អង្គពិសិដ្ឋអាប់ឌុលបាហា-

# ការលះបង់ឬការមិនជំពាក់ចិត្ត

ឱព្រះរបស់ទូលព្រះបង្គំខ្ញុំអើយ សូមព្រះអង្គអនុញ្ញាតឱ្យទូលព្រះបង្គំបានចូលទៅជិតព្រះអង្គ និងឱ្យទូលព្រះបង្គំបាននៅក្នុងបរិវេណនៃព្រះរាជវាំងរបស់ព្រះអង្គផង ព្រោះការនៅឆ្ងាយពីព្រះអង្គបានធ្វើឱ្យទូលបង្គំស្ទើរតែខូចអស់ទៅហើយ។ សូមព្រះអង្គញ៉ាំងឱ្យទូលបង្គំ បានសម្រាកនៅម្លប់នៃស្លាបទាំងទ្វេនៃមនុញ្ញភាពរបស់ព្រះអង្គផង ព្រោះអណ្ដាតភ្លើងនៃការញែកចេញរបស់ទូលព្រះបង្គំពីព្រះអង្គបានរំលាយបេះដូងទូលព្រះបង្គំ ដែលនៅក្នុងទូលបង្គំនេះអស់ហើយ។ សូមព្រះអង្គអូសទាញឱ្យទូលបង្គំបានចូលទៅកាន់តែជិតនឹងស្ទឹងដែលជាជីវិតពិតផង ព្រោះវិញ្ញាណក្ខន្ធរបស់ទូលបង្គំបានឆេះខ្លោចដោយសេចក្ដីស្រេកឃ្លាន ក្នុងការដេញតាមស្វែងយល់ពីក្រោយព្រះអង្គដោយឥតឈប់ឈរ។ ឱព្រះរបស់ទូលបង្គំអើយ ការដកដង្ហើមធំរបស់ទូលបង្គំនេះនឹងលាតត្រដាងពីភាពល្វីងជូរចត់ដែលកើតមកពីការរង្គើះចិត្តរបស់ទូលបង្គំរីឯទឹកភ្នែកដែលទូលបង្គំបានសម្រក់មកនេះ នឹងបង្ហាញពីសេចក្ដីស្រលាញ់របស់ទូលបង្គំចំពោះព្រះអង្គ។

ទូលព្រះបង្គំសូមអង្វរព្រះអង្គ ដោយការគោរពកោតសរសើរជាមួយនឹងអ្វីដែលព្រះអង្គបានលើកតម្កើងដោយអង្គឯង ហើយនិងកិត្តិគុណដែលព្រះអង្គ ធ្វើឱ្យមានភាពរុងរឿងដល់ភាពជាសំខាន់

ផ្ទាល់របស់ព្រះអង្គ សុំឱ្យទ្រង់អនុញ្ញាតឱ្យពួកយើងបាននៅក្នុងលេខរៀងជាមួយនឹងអ្នកដែលបានទទួលស្គាល់ព្រះអង្គ ហើយនិងអ្នកដែលបានទទួលយកអធិបតេយ្យភាពរបស់ព្រះអង្គ ក្នុងយុគសម័យរបស់ព្រះអង្គ។ ឱព្រះអាទិទេពរបស់ទូលព្រះបង្គំលោកអើយ សូមព្រះអង្គជួយឱ្យពួកយើងបានផឹកទឹកដែលមានជីវិតនៃព្រះទ័យសប្បុរសធម៌ជាទីស្រលាញ់ពីម្រាមព្រះហស្ថ ដែលមានមេត្តាធម៌របស់ព្រះអង្គផង ដើម្បីឱ្យយើងអាចបំភ្លេចចោលនូវអ្វីៗគ្រប់យ៉ាងទាំងអស់លើកលែងតែព្រះអង្គ ហើយសូមឱ្យពួកយើងនៅជាប់ជំពាក់តែជាមួយនឹងព្រះអង្គមួយអង្គឯងគត់។ ពិតណាស់ព្រះអង្គគឺជាព្រះប្រកបដោយសព្វានុភាព ព្រះអង្គអាចធ្វើអ្វីៗបានតាមព្រះទ័យចង់របស់ព្រះអង្គ។ ក្រៅពីព្រះអង្គគ្មានព្រះឯណាទៀតឡើយ ព្រះអង្គគឺជាព្រះប្រកបដោយចេស្តាបារមី ជាអ្នកជួយរំដោះគ្រោះភ័យ ជាអ្នកគង់នៅដោយអង្គឯង។ ឱព្រះអង្គដែលជាអធិរាជលើអធិរាជទាំងអស់អើយ ទូលបង្គំសូមគោរពកោតសរសើរព្រះអង្គតាមព្រះនាមរបស់ព្រះអង្គផង!

-ព្រះបាហាអ៊ុលឡាហ៍-

ឱព្រះរបស់ទូលព្រះបង្គំលោកអើយ ព្រះអង្គគឺជាអ្នកមានភាពរុងរឿងខ្ពង់ខ្ពស់បំផុត! ទូលព្រះបង្គំសូមថ្លែងនូវអំណរអរព្រះគុណចំពោះព្រះអង្គយ៉ាងអនេក ដែលព្រះអង្គបានធ្វើឱ្យទូលព្រះបង្គំ

បានស្គាល់ដល់ព្រះអង្គដែលជាថ្ងៃរីករាយនៃមេត្តាធម៌របស់ព្រះអង្គ និងជាទីកន្លែងដើមកំណើតនៃមនុញ្ញភាពរបស់ព្រះអង្គព្រមទាំងជាទីកន្លែងដាក់ទុកនៃបុព្វហេតុសាសនារបស់ព្រះអង្គផងដែរ។ តាមរយៈការជូសមុខឱ្យពួកគេដែលជាអ្នកខិតទៅជិតព្រះអង្គដោយទឹកមុខស្លេកស្លាំង និងជូសឱ្យបេះដូងរបស់អ្នកដែលមានចិត្តភក្តីចំពោះព្រះអង្គដែលបានហោះឡើងឆ្ពោះទៅកាន់ព្រះអង្គនោះ ទូលព្រះបង្គំសូមអង្វរព្រះអង្គដោយព្រះនាមរបស់ព្រះអង្គ សូមទ្រង់ប្រទានឱ្យទូលព្រះបង្គំនូវអ្វីដែលអាចធ្វើឱ្យទូលបង្គំតោងជាប់ទៅនឹងខ្សែរបស់ព្រះអង្គ ហើយសូមព្រះអង្គកំចាត់នូវការជំពាក់ចិត្តគ្រប់យ៉ាងរបស់ទូលព្រះបង្គំ ទៅនឹងនរណាម្នាក់ក្រៅពីព្រះអង្គ ហើយសូមឱ្យចក្ខុរបស់ទូលព្រះបង្គំបន្តបាញ់ឆ្ពោះទៅរកនភាល័យនៃការត្រាស់ដឹងរបស់ព្រះអង្គ ហើយនិងសូមឱ្យទូលព្រះបង្គំអនុវត្តន៍តាមតែអ្វីដែលព្រះអង្គបានបញ្ញត្តិឱ្យទូលព្រះបង្គំធ្វើតាមកថាខណ្ឌ របស់ព្រះអង្គគ្រប់ពេលនិងគ្រប់ស្ថានភាពទាំងអស់។

ឱព្រះនៃទូលព្រះបង្គំលោកអើយ សូមព្រះអង្គតែងលំអប្រាណឱ្យទូលបង្គំបានល្អទាំងចិត្តទាំងកាយ ដោយសំលៀកបំពាក់នៃការអនុគ្រោះរបស់ព្រះអង្គ និងសម្លៀកបំពាក់នៃសប្បុរសធម៌ជាទីស្រលាញ់របស់ព្រះអង្គ នៅពេលនេះសូមព្រះអង្គថែរក្សាការពារឱ្យទូលបង្គំមានសុវត្ថិភាព ពីអ្វីដែលជាទីស្អប់ខ្ពើមចំពោះព្រះអង្គ ហើយសូមព្រះអង្គជួយទូលបង្គំ និងពូជញាតិទូលបង្គំបានគោរព

តាមព្រះអង្គដោយមេត្តា និងបានគេចផុតពីអ្វីដែលអាចបង្កឱ្យមាន សេចក្តីប្រាថ្នាអាក្រក់ ឬកំហុចដែលមាននៅក្នុងចិត្តរបស់ទូលបង្គំផង។

ពិតណាស់ព្រះអង្គគឺជាព្រះរបស់មនុស្សគ្រប់គ្នា ហើយក៏ជាម្ចាស់នៃភពនេះនិងភពបន្ទាប់ផងដែរ។ គ្មានព្រះឯណាទៀតឡើយក្រៅពីព្រះអង្គ ព្រះអង្គគឺជាព្រះទ្រង់ញាណ និងមានបញ្ញាញាណគ្រប់យ៉ាង។

-ព្រះបាហាអ៊ុលឡាហ៍-

ព្រះនាមរបស់ព្រះអង្គគួរឱ្យគេសរសើរខ្លាំងណាស់ ឱព្រះរបស់ទូលបង្គំលោកអើយ! ទូលបង្គំអង្វរទ្រង់ដោយគន្ធាពិដោរនៃសម្លៀកបំពាក់នៃមនុញ្ញភាពរបស់ព្រះអង្គ ដែលនៅនឹងបទបញ្ញត្តិរបស់ព្រះអង្គ និងការអនុលោមតាមក្តីប្រាថ្នារបស់ព្រះអង្គត្រូវបានគេបំភាយពាសពេញអស់ទាំងមាបនកម្មទាំងមូល ហើយនិងដោយសារតារាប្រចាំភព(ព្រះសាស្តា) នៃឆន្ទៈរបស់ព្រះអង្គបានបញ្ចេញរស្មីយ៉ាងត្រចះត្រចង់ នៅលើនភាល័យនៃមេត្តាធម៌របស់ព្រះអង្គតាមរយៈអំណាចនៃឫទ្ធានុភាពរបស់ព្រះអង្គ ហើយនិងអំណាចនៃអធិបតេយ្យភាពរបស់ព្រះអង្គដើម្បីបំបាត់ចោល នូវគ្រប់គំនិតឥត

បានការ និងការស្រមើស្រមៃឥតប្រយោជន៍ពីចិត្តរបស់ទូលបង្គំ ឱព្រះអង្គដែលជាព្រះរបស់មនុស្សលោកគ្រប់គ្នាអើយ ទូលបង្គំសូមងាកទៅរកព្រះអង្គដោយសុច្ចចិត្តហើយ! ឱព្រះអង្គដែលជាព្រះរបស់ទូលបង្គំអើយ ទូលបង្គំជាអ្នកបម្រើរបស់ព្រះអង្គ ហើយក៏ជាបុត្រារបស់អ្នកបម្រើរបស់ព្រះអង្គផងដែរ! ទូលបង្គំបានប្រទានឋានៈនៃមនុញ្ញភាពរបស់ព្រះអង្គ ហើយក៏បានតោងទៅនឹងខ្សែនៃមេត្តាធម៌ជាទីស្រលាញ់របស់ព្រះអង្គហើយដែរ។ សូមព្រះអង្គកំណត់វត្ថុល្អៗដែលនៅជាមួយនឹងព្រះអង្គឱ្យទូលបង្គំ ហើយសូមព្រះអង្គប្រទានអាហារឱ្យទូលបង្គំពីតុដែលព្រះអង្គបានធ្វើ បញ្ជូនចុះចេញមកពីពពកនៃបុណ្យរបស់ព្រះអង្គ ហើយនិងចេញមកពីឋានសួគ៌នៃក្ដីអនុគ្រោះរបស់ព្រះអង្គផង។ ពិត ណាស់ព្រះអង្គគឺជាព្រះគ្រប់ពិភព ហើយក៏ជាព្រះរបស់មនុស្សគ្រប់គ្នាដែលនៅក្នុងឋានសួគ៌ ហើយនិងគ្រប់មនុស្សដែលនៅលើផែនដីនេះផងដែរ។

-ព្រះបាហាអ៊ុលឡាហ៍-

ឱព្រះរបស់ទូលព្រះបង្គំលោកអើយ បេះដូងជាច្រើនក្នុងចំណោមបេះដូងនិមួយៗដែលខ្វះភាពកក់ក្ដៅពីមុនមកនោះ ឥឡូវនេះត្រូវបានគេធ្វើឱ្យមានភាពកក់ក្ដៅដោយភ្លើងនៃបុព្វហេតុសាសនា ហើយនិងអ្នកដែលបានដេកលង់លក់ជាច្រើនក្នុងចំណោមអ្នកដែលបានដេកលង់លក់ម្នាក់ៗ ត្រូវបានគេធ្វើឱ្យភ្ញាក់ដោយភាព

ពិរោះនៃព្រះសូរសៀងរបស់ព្រះអង្គហើយ។ យ៉ាងដូចម្ដេចបានជាសម្បុរអ្នកប្លែកមុខរុករកទីជម្រកក្រោមម្លប់ឈើ នៃភាពតែមួយ ហើយនិងសម្បុរអ្នកស្រេកឃ្លាន បានជង្ហក់ចង់បានប្រភពទឹករស់ក្នុងយុគសម័យរបស់ព្រះអង្គច្រើនម្លេះន៎! បុណ្យនឹងកើតមានដល់នរណាដែលបានបូជាខ្លួនគាត់ចំពោះព្រះអង្គ ហើយនិងកើតមានដល់នរណាដែលប្រញាប់ទទួលយកតារាពន្លឺថ្មី (ព្រះបាហាអ៊ុលឡាហ៍)នៃព្រះភក្ត្ររបស់ព្រះអង្គ។ បុណ្យនឹងកើតមានដល់នរណាដែលបានងាកគ្រប់មេត្រីភាពរបស់គាត់ ឆ្ពោះទៅកាន់ទីកន្លែងអរុណោភាសនៃការត្រាស់ដឹងរបស់ព្រះអង្គ ហើយនិងប្រភពនៃសេចក្ដីប្រាថ្នារបស់ព្រះអង្គ។ បុណ្យនឹងកើតមានដល់នរណាដែលបានពង្រីកតាមមាគ៌ារបស់ព្រះអង្គ តាមអ្វីដែលព្រះអង្គបានប្រទានឱ្យគាត់តាមរយៈសប្បុរសនិងការអនុគ្រោះរបស់ព្រះអង្គ។ ចំពោះចំណង់របស់គាត់ដែលចង់ឱ្យបានទៅដល់ព្រះអង្គនោះ បុណ្យនឹងកើតមានដល់គាត់ បើគាត់នឹងបោះបង់ចោលនូវអ្វីៗគ្រប់យ៉ាងលើកលែងតែព្រះអង្គ។ បុណ្យនឹងកើតមានដល់នរណាដែលបានពេញចិត្តធ្វើទំនាក់ទំនងយ៉ាងជិតស្និទ្ធិជាមួយនឹងព្រះអង្គ ហើយលះបង់ខ្លួនគាត់ទៅនឹងការជំពាក់ចិត្តទៅនរណាម្នាក់ ក្រៅពីព្រះអង្គ។

ឱព្រះរបស់ទូលព្រះបង្គំលោកអើយ តាមរយៈអំណាចនៃអធិបតេយ្យភាពនិងឬទ្ធានុភាពរបស់ព្រះអង្គ ទូលព្រះបង្គំសូមអង្វរព្រះអង្គតាមរយៈទ្រង់ដែលជាព្រះនាមរបស់ព្រះអង្គ ដែលបានរះ

ឡើងនៅលើនភាល័យនៃពន្ធនាគាររបស់ព្រះអង្គ សូមទ្រង់កំណត់ក្រិត្យឱ្យអ្នករាល់គ្នានូវអ្វីដែលសក្តិសមនឹងព្រះអង្គនិងសមរម្យដល់ភាពខ្ពង់ខ្ពស់របស់ព្រះអង្គ។ ពិតណាស់ឫទ្ធានុភាពរបស់ព្រះអង្គគឺជារបស់គ្រប់យ៉ាង។

-ព្រះបាហាអ៊ុលឡាហ៍-

ឱព្រះរបស់ទូលបង្គំលោកអើយ ព្រះអង្គគួរឱ្យគេសរសើរខ្លាំងណាស់! ទូលបង្គំគឺជាអ្នកបម្រើម្នាក់ក្នុងចំណោមអ្នកបម្រើរបស់ព្រះអង្គទាំងឡាយ ដែលបានជឿចំពោះព្រះអង្គ ហើយនិងសញ្ញារបស់ព្រះអង្គ។ ព្រះអង្គបានទតយល់ពីរបៀបដែលទូលបង្គំបានរៀបខ្លួនរបស់ទូលបង្គំ ឆ្ពោះទៅកាន់ទ្វារនៃមេត្តាធម៌របស់ព្រះអង្គហើយ ហើយព្រះអង្គក៏បានបង្វែរមុខរបស់ទូលបង្គំទៅក្នុងទិសដៅនៃសប្បុរសធម៌ជាទីស្រលាញ់របស់ព្រះអង្គផងដែរ។ តាមរយៈឋានៈដ៏ប្រពៃបំផុតហើយនិងកេតណាភ័ណ្ឌដ៏ប្រសើរបំផុតនោះទូលព្រះ បង្គំសូមអង្វរព្រះអង្គសូមទ្រង់មេត្តាបើកក្លោងទ្វារធំរបស់ព្រះអង្គឱ្យមានដល់មុខរបស់ទូលបង្គំផង។ ព្រះអង្គដែលជាម្ចាស់នៃគ្រប់នាមនិងកេតណាភ័ណ្ឌអើយ នៅពេលនេះសូមព្រះអង្គជួយឱ្យទូលបង្គំបានធ្វើអ្វីដែលជារឿងល្អផង! ឱព្រះលោកអើយ ទូលបង្គំជា

អ្នកក្រខ្សត់ ឯព្រះអង្គវិញគឺជាអ្នកមានអ្វីៗគ្រប់យ៉ាង។ ទូលបង្គំបាន ងាកមុខរបស់ទូលបង្គំឆ្ពោះទៅរកព្រះអង្គ ហើយបានលះបង់ខ្លួន របស់ទូលបង្គំចេញពីរបស់គ្រប់យ៉ាងក្រៅពីព្រះអង្គផងដែរ។ ទូល ព្រះបង្គំសូមអង្វរព្រះអង្គសូមទ្រង់កុំដកហូតវាយោរំភើយៗនៃមេត្តា ធម៌ជាទីស្រលាញ់របស់ព្រះអង្គចេញពីទូលបង្គំ ហើយសូមទ្រង់កុំ ដកយកអ្វីដែលព្រះអង្គ បានកំណត់ក្រិត្យទុកឱ្យនៅនឹងអ្នកបម្រើ ដែលជាជម្រើសរបស់ព្រះអង្គចេញពីទូលបង្គំឡើយ។

ឱព្រះលោកអើយ សូមព្រះអង្គបើកស្បៃពីភ្នែករបស់ទូលបង្គំ ដើម្បីឱ្យទូលបង្គំអាចបានស្គាល់នូវអ្វីៗដែលព្រះអង្គបានប្រាថ្នាចង់ ឱ្យសត្វលោករបស់ព្រះអង្គ ដែលមាននៅក្នុងការបង្ហាញឱ្យឃើញ ទាំងអស់នៃសិប្បកម្មរបស់ព្រះអង្គ និងដើម្បីឱ្យទូលបង្គំបានយល់ពី អំណាចដ៏មានអនុភាពរបស់ព្រះអង្គ។ ឱព្រះលោកអើយ សូមព្រះ អង្គធ្វើឱ្យវិញ្ញាណអារម្មណ៍របស់ទូលបង្គំ អណ្តែតអណ្តូងជាមួយនឹង សញ្ញាដ៏មានអានុភាពបំផុតរបស់ព្រះអង្គ និងសូមព្រះអង្គស្រង់ទូល បង្គំឱ្យបានរួចផុតពីអន្លង់ជ្រៅនៃភាពកំហូច និងសេចក្តីប្រាថ្នា អាក្រក់របស់ទូលព្រះបង្គំផង។ បន្ទាប់មកសូមព្រះអង្គព្រះរាជនិពន្ធ របស់ល្អៗនៃពិភពនេះនិងពិភពបន្ទាប់ពីនេះឱ្យទូលបង្គំផង។ ព្រះ អង្គមានអំណាចខ្លាំងក្លាអស្ចារ្យក្នុងការធ្វើអ្វីៗតាមព្រះអង្គសព្វព្រះ ហឫទ័យ។ គ្មានព្រះឯណាទៀតឡើយក្រៅពីព្រះអង្គ ព្រះអង្គគឺជា ព្រះប្រកបដោយព្រះទ័យសប្បុរសធម៌គ្រប់យ៉ាង ព្រះអង្គគឺជាព្រះ

ដែលមនុស្សគ្រប់រូបស្វែងរកជំនួយពីព្រះអង្គគ្រប់គ្នា។ ឱព្រះរបស់ទូលបង្គំលោកអើយ ទូលបង្គំសូមថ្លែងអំណរគុណដល់ព្រះអង្គ ដែលទ្រង់បានដាស់ឱ្យទូលបង្គំ បានភ្ញាក់ពីដំណេកដ៏លង់លក់របស់ទូលបង្គំ និងធ្វើឱ្យទូលបង្គំបានងើបឡើង ព្រមទាំងបានធ្វើឱ្យទូលបង្គំមានការរឭកដឹងនូវអ្វីៗដែលអ្នកបំរើរបស់ព្រះអង្គ ដ៏ច្រើនមិនបានយល់។ ឱព្រះរបស់ទូលបង្គំលោកអើយដើម្បីសេចក្តីស្រលាញ់របស់ព្រះអង្គនិងដើម្បីសេចក្តីរីករាយរបស់ព្រះអង្គ អ៊ីចឹងសូមព្រះអង្គធ្វើឱ្យទូលបង្គំអាចមានលទ្ធភាពដើម្បីសង្កេតមើលឃើញនូវអ្វីៗដែលព្រះអង្គប្រាថ្នាចង់បានផង។ ព្រះអង្គគឺជាព្រះមួយអង្គដែលមានវត្ថុគ្រប់យ៉ាងធ្វើជាសក្ខីភាពទៅនឹងអំណាចនៃឫទ្ធានុភាព និងអធិបតេយ្យភាពរបស់ព្រះអង្គ។

ក្រៅពីព្រះអង្គគ្មានព្រះឯណាទៀតឡើយ ព្រះអង្គគឺជាព្រះដែលប្រកបដោយឫទ្ធានុភាព ជាព្រះប្រកបដោយសប្បុរសធម៌។

-ព្រះបាហាអ៊ុលឡាហ៍-

ឱព្រះរបស់ទូលបង្គំលោកអើយ ទូលបង្គំមិនដឹងទេថាតើភ្លើងដែលព្រះអង្គបានដុតបំភ្លឺនៅក្នុងដែនដីរបស់ព្រះអង្គនោះគឺជាភ្លើងអ្វីឡើយ។ ភ្លើងនោះផែនដីនេះមិនអាចធ្វើឱ្យមានពពកបិទ

បាំងភាពរុងរឿងរបស់វាបានឡើយ ហើយក៏គ្មានទឹកណាអាចពន្លត់វាបានដែរ។ មនុស្សគ្រប់ជាតិសាសន៍ក្នុងលោកនេះគ្មានអំណាចដើម្បីតតាំងទប់ទល់នឹងកម្លាំងរបស់វាបានឡើយ។ ពិសិដ្ឋពរដ៏អស្ចារ្យបំផុតនឹងកើតមានដល់នរណាដែលបានខិតចូលទៅជិតនឹងវា ហើយនិងបានឮពីសម្លេងរោទ៍របស់វា។

ឱព្រះរបស់ទូលបង្គំលោកអើយ តាមរយៈមនុញ្ញភាពដែលកំពុងតែរឹងមាំដែលព្រះអង្គបានធ្វើនោះ ខ្លះអាចចូលទៅជិតវាបានហើយ ចំណែកឯអ្នកផ្សេងទៀតនៅមិនទាន់ទៅជិតបាន ដោយសារតែដៃរបស់ពួកគេធ្វើឱ្យរំជួលចិត្ត នូវអ្វីដែលព្រះអង្គបានធ្វើនៅក្នុងយុគសម័យរបស់ព្រះអង្គ។ ដោយមាននៅក្នុងចំណង់របស់គាត់ដែលចង់ឃើញសោភ័ណភាពរបស់ព្រះអង្គទើបគាត់ប្រញាប់ឆ្ពោះទៅកាន់វា ហើយទទួលយកវាដោយមាននៅក្នុងចំណង់របស់គាត់ដែលចង់ឃើញសោភ័ណភាពរបស់ព្រះអង្គ ទើបគាត់ប្រគល់ជីវិតរបស់គាត់ក្នុងមាគ៌ារបស់ព្រះអង្គហើយដើរឡើងចូលទៅដល់ព្រះអង្គដោយមាននៅក្នុងចំណង់របស់គាត់ដែលចង់ឃើញសោភ័ណភាពរបស់ព្រះអង្គទើបគាត់ឈប់ជំពាក់ចិត្តនឹងវត្ថុគ្រប់យ៉ាងលើកលែងតែព្រះអង្គ។ ឱព្រះរបស់ទូលបង្គំអើយ ទូលបង្គំសូមអង្វរទ្រង់តាមរយៈភ្លើងដែលឆេះ ហើយជាទីនិយមនៅក្នុងលោកនៃមាបនកម្មនេះ សូមឱ្យព្រះអង្គហែកស្បៃដែលបានរារាំងនៅពីមុខទូលបង្គំមិនឱ្យទូលបង្គំបានមើលឃើញរាជបល្ល័ង្កនៃភាពដ៏សម្បើម

របស់ព្រះអង្គឱ្យទៅជាបំណែកៗ ហើយសូមព្រះអង្គហែកស្បៃដែលឈរបាំងមុខនៅឯទ្វារនៃក្លោងទ្វាររបស់ព្រះអង្គ។ ឱព្រះរបស់ទូលបង្គំលោកអើយ សូមព្រះអង្គដាក់កំណត់ក្រិត្យឱ្យទូលបង្គំនូវរបស់ល្អគ្រប់យ៉ាងដែលព្រះអង្គបានបញ្ជូនចុះមកតាមគម្ពីរស័ក្តិសិទ្ធិរបស់ព្រះអង្គ ហើយសូមព្រះអង្គកុំធ្វើឱ្យទូលបង្គំឈឺចាប់ដោយសារតែធ្វើឱ្យទូលបង្គំឃ្លាតឆ្ងាយពីជម្រកនៃមេត្តាធម៌របស់ព្រះអង្គ។

ព្រះអង្គគឺជាព្រះប្រកបដោយសព្វានុភាព ព្រះអង្គអាចធ្វើអ្វីៗបានតាមព្រះអង្គសព្វព្រះហឫទ័យ។ ពិតណាស់ព្រះអង្គគឺជាព្រះប្រកបដោយសព្វានុភាពគ្រប់យ៉ាង ជាព្រះប្រកបដោយព្រះទ័យសប្បុរសធម៌។

-ព្រះបាហាអ៊ុលឡាហ៍-

ក្នុងនាមព្រះរបស់អ្នកដែលជាអ្នកបង្កើត ជាអ្នកមានអំណាចគ្មានគូប្រៀប ជាអ្នកបង្គ្រប់ឱ្យរបស់គ្រប់យ៉ាង ជាអ្នកមានឋានៈខ្ពង់ខ្ពស់បំផុត ទ្រង់គឺជាព្រះដែលជំនួសរបស់ព្រះអង្គត្រូវបានគេអង្វរករសុំដោយមនុស្សគ្រប់រូប។ ទូលបង្គំសូមសសើរ ឱព្រះរបស់ទូលបង្គំអើយ! ឱព្រះនៃរាជាណាចក្រសួគ៌អើយ! ឱព្រះអង្គដែលជាអ្នកបង្កើតឱ្យមានឋានសួគ៌និងផែនដីអើយ! ព្រះអង្គជាអ្នកដឹងច្បាស់នូវអាថ៌កំបាំងនៃដួងចិត្តរបស់ទូលបង្គំ ក្រៅពីមនុស្សអាទិទេពរបស់

ព្រះអង្គ គ្មាននរណាអាចយល់ពីរឿងរ៉ាវទាំងអស់នេះបានឡើយ។ អ្វីក៏ដោយឱ្យតែកើតចេញមកពីទូលបង្គំ ព្រះអង្គទតយល់ទាំងអស់ គ្មាននរណាផ្សេងទៀតអាចធ្វើរឿងនេះបានឡើយក្រៅពីព្រះអង្គ។ តាមរយៈមនុញ្ញភាពរបស់ព្រះអង្គ សូមព្រះអង្គប្រទានអភ័យឯកសិទ្ធិឱ្យដល់ទូលបង្គំបានចៀសផុតពីរបស់គ្រប់យ៉ាងលើកលែងតែព្រះអង្គ ហើយសូមព្រះអង្គបម្រុងទុកឱ្យទូលបង្គំនូវអ្វីដែលនឹងធ្វើឱ្យទូលបង្គំមានភាពឯករាជ្យដែលមិនពឹងពាក់អ្នកផ្សេង ក្រៅពីព្រះអង្គ។ សូមព្រះអង្គប្រទានឱ្យទូលបង្គំនូវអ្វីដែលអាចឱ្យទូលបង្គំបានទទួលអត្ថប្រយោជន៍ពីជីវិតរបស់ទូលបង្គំទាំងនៅក្នុងជាតិនេះ និងជាតិខាងមុខផង។ សូមព្រះអង្គបើកក្លោងទ្វារធំនៃមនុញ្ញភាពរបស់ព្រះអង្គឱ្យបានដល់ភក្ត្ររបស់ទូលបង្គំ ហើយនិងសូមព្រះអង្គប្រទានមេត្តាធម៌ និងអំណោយជាទីស្រលាញ់របស់ព្រះអង្គដល់ទូលបង្គំផង។

ឱព្រះអង្គដែលជាព្រះប្រកបដោយ មនុញ្ញភាពដ៏ឧត្តមអើយ សូមព្រះអង្គអនុញ្ញាតឱ្យជំនួយទិព្វរបស់ព្រះអង្គ ឡោមពទ្ធ័អ្នកទាំងឡាយណាដែលស្រលាញ់ព្រះអង្គ ហើយសូមព្រះអង្គប្រទានអំណោយ ហើយនិងបុណ្យដែលព្រះអង្គមានឱ្យបានដល់ពួកយើងផង។ ព្រះអង្គជាអ្នកប្រទានរបស់គ្រប់យ៉ាងឱ្យដល់ពួកយើងបានគ្រប់គ្រាន់ ព្រះអង្គជាអ្នកលើកលែងទោសឱ្យពួកយើង និងជាអ្នកមានមេត្តាធម៌ចំពោះពួកយើង។ ព្រះអង្គគឺជាព្រះរបស់ពួកយើងនិង

ជាព្រះរបស់វត្ថុគ្រប់យ៉ាងដែលបានបង្កើតមកនេះផងដែរ។ ក្រៅពីព្រះអង្គគ្មានអ្នកផ្សេងឯណាដែលពួកយើងបួងសួងសុំឡើយ ហើយក្រៅពីការអនុគ្រោះរបស់ព្រះអង្គ ពួកយើងមិនអង្វរនរណាទៀតឡើយ។ ព្រះអង្គគឺជាព្រះប្រកបដោយបុណ្យនិងមនុញ្ញភាព ព្រះអង្គជាអ្នកមានអំណាចឫទ្ធីចេស្ដាខ្លាំងក្លាមិនចេះបរាជ័យ និងជាអ្នកមានជំនាញដ៏ច្រើនបំផុតចំពោះគម្រោងប្លង់របស់ព្រះអង្គ។ ក្រៅពីព្រះអង្គគ្មានព្រះឯណាទៀតឡើយ ព្រះអង្គជាអ្នកមានអ្វីៗគ្រប់យ៉ាងជាព្រះគួរឱ្យសរសើរបំផុត។ ឱព្រះរបស់ទូលព្រះបង្គំអើយ សូមព្រះអង្គប្រទានបុណ្យរបស់ព្រះអង្គឱ្យបានដល់អ្នកនាំសាររបស់ព្រះអង្គដែលជាអ្នកពិសិដ្ឋនិងជាអ្នកត្រឹមត្រូវបំផុត។ ពិតណាស់ ព្រះអង្គគឺជាព្រះអាទិទេពដ៏ខ្ពង់ខ្ពស់ ជាព្រះគ្មានគូប្រៀបជាព្រះឈ្នះអស់ទាំងលោកនេះនិងឋានសួគ៌។

-ព្រះបប-

ឱព្រះលោកអើយ! ទូលបង្គំតម្រង់ឆ្ពោះទៅរកទីជម្រកនៅជិតព្រះអង្គហើយទូលបង្គំនឹងផ្ដុំដួងចិត្តរបស់ទូលបង្គំ ឆ្ពោះទៅរកគ្រប់សញ្ញារបស់ព្រះអង្គហើយ។ ឱព្រះលោកអើយ! ឱព្រះលោកអើយ! ទោះជានៅពេលធ្វើដំណើរឬនៅផ្ទះ ហើយនិងទោះជានៅក្នុង<u>ជាជីព</u>របស់ទូលបង្គំឬនៅក្នុងកន្លែងការងាររបស់ទូលព្រះបង្គំក៏ដោយទូលបង្គំនឹងប្រគល់សេចក្ដីទុកចិត្តទាំងស្រុងរបស់ទូលព្រះបង្គំ ចំពោះ

ព្រះអង្គហើយ។ ឱព្រះអង្គដែលជាព្រះមានមេត្តាធម៌របស់ព្រះអង្គ ដ៏លើសលុបអើយ នៅពេលនេះសូមព្រះអង្គប្រទានជំនួយឱ្យទូល បង្គំបានគ្រប់ដើម្បីធ្វើឱ្យទូលបង្គំមានឯករាជ្យពីវត្ថុគ្រប់យ៉ាងផង!

ឱព្រះលោកអើយ សូមព្រះអង្គប្រទានចំណែករបស់ទូលបង្គំ ឱ្យបានដល់ទូលបង្គំតាមព្រះអង្គសព្វព្រះហឫទ័យ ហើយសូមព្រះ អង្គញ៉ាំងឱ្យទូលបង្គំបានពេញចិត្តនឹងអ្វី ដែលព្រះអង្គបានកំណត់ ក្រិត្រឱ្យទូលបង្គំផង។ អំណាចរបស់ព្រះអង្គគឺជាអំណាចពិតដើម្បី បញ្ជាអ្វីៗគ្រប់យ៉ាង។ មើលនេះនែ! ព្រះបានបំពេញសេចក្តីត្រូវការ គ្រប់វត្ថុលើវត្ថុគ្រប់យ៉ាង នៅក្នុងឋានសួគ៌ឬក្នុងផែនដីនេះ ព្រះបាន បំពេញសេចក្តីត្រូវការគ្មានខ្វះចន្លោះអ្វីទៀតឡើយ។ ពិតណាស់ ព្រះអង្គគង់នៅដោយអង្គឯង ព្រះអង្គជាព្រះទ្រង់ញាណ ជាអ្នកទ្រ ទ្រង់ ជាព្រះប្រកបដោយវិជិតរាជ្យ។

-ព្រះបប-

ព្រះជាព្រះទូលបង្គំអើយ! ព្រះអង្គគឺជាសេចក្តីសង្ឃឹមរបស់ ទូលបង្គំនិងជាទីស្រលាញ់របស់ទូលបង្គំ ព្រះអង្គគឺជាបំណង គោលដៅនិងជាទីប្រាថ្នាដ៏ខ្ពស់បំផុតរបស់ទូលបង្គំ! ទូលបង្គំសូម លំឱនកាយដោយចិត្តស្មោះអស់ពីដួងចិត្តដើម្បី សូត្រធម៌បួងសួង ទៅកាន់ព្រះអង្គ សូមទ្រង់ញ៉ាំងឱ្យទូលបង្គំបានក្លាយជាព្រះវិហារ

នៃក្ដីស្រលាញ់របស់ព្រះអង្គនៅក្នុងផែនដីរបស់ព្រះអង្គ សូមព្រះអង្គញ៉ាំងឱ្យទូលបង្គំបានក្លាយ ជាប្រទីបនៃចំណោះនៅក្នុងចំណោមសត្វលោករបស់ព្រះអង្គ ហើយសូមព្រះអង្គញ៉ាំងឱ្យទូលបង្គំបានក្លាយជាទង់នៃបុណ្យកុសលដ៏ល្អឥតខ្ចោះ នៅក្នុងតំបន់ត្រួតត្រាដោយអំណាចរបស់ព្រះអង្គ។

សូមព្រះអង្គដាក់តម្រៀបលេខរៀងឱ្យទូលបង្គំ ទៅជាមួយនឹងអ្នកបម្រើរបស់ព្រះអង្គដែលបានលះបង់ខ្លួនគេ ចេញពីរបស់គ្រប់យ៉ាងក្រៅពីព្រះអង្គ និងជាអ្នកដែលបានធ្វើឱ្យខ្លួនរបស់ពួកគេបានពិសិដ្ឋចេញផុតពីរបស់អនិច្ចាមិនទៀងនៃភពនេះ ហើយនិងជាអ្នកដែលបានធ្វើឱ្យខ្លួនគេមានសេរីភាព គេចផុតពីការទូន្មានរបស់អ្នកដែលមានសូរសៀងគំនិតរវើរវាយឥតបានការ។

សូមព្រះញ៉ាំងឱ្យបេះដូងរបស់ទូលព្រះបង្គំ បានរីករាយដោយសេចក្ដីពេញចិត្ត តាមរយៈចិត្តវិញ្ញាណអំណះអំណាងពីរាជាណាចក្ររបស់ព្រះអង្គ ហើយនិងសូមព្រះអង្គញ៉ាំងឱ្យចក្ខុរបស់ទូលបង្គំទាំងទ្វេរបានភ្លឺថ្លាត្រចះត្រចង់ ដោយការសម្លឹងមើលបាហានិកជំនួយរបស់ព្រះដែលកំពុងជ្រោលចុះមកពីរាជាណាក្រនៃភាពរុងរឿងដែលប្រកបដោយអំណាចរបស់ព្រះអង្គមកលើទូលបង្គំជាហូរហែរផង។

ពិតណាស់ ព្រះអង្គគឺជាព្រះមានបុណ្យ ជាព្រះប្រកបដោយព្រះទ័យសប្បុរសធម៌ ជាព្រះប្រកបដោយសព្វានុភាពគ្រប់យ៉ាង។

-អង្គពិសិដ្ឋអាប់ឌុលបាហា-

ឱព្រះជាព្រះរបស់ទូលបង្គំអើយ! សូមព្រះអង្គបំពេញពែងនៃការមិនជំពាក់ចិត្តនឹងវត្ថុគ្រប់យ៉ាងឱ្យទូលបង្គំ ហើយសូមព្រះអង្គធ្វើឱ្យទូលបង្គំបានរីករាយជាមួយនឹងទឹកអម្រឹតនៃការស្រលាញ់ព្រះអង្គ នៅក្នុងសភានៃភាពរុងរឿងនិងអំណោយរបស់ព្រះអង្គផង។ សូមព្រះអង្គធ្វើឱ្យទូលបង្គំបានរួចផុតពីការរំលោភបំពានរបស់ចំណង់តណ្ហា និងការលោភលន់ សូមព្រះអង្គកាត់ផ្ដាច់ទូលបង្គំពីខ្នោះរបស់ពិភពលោកដែលទាបនេះ សូមព្រះអង្គអូសទាញទូលបង្គំឱ្យបានចូលទៅកាន់រាជាណាចក្រដ៏ខ្ពង់ខ្ពស់របស់ព្រះអង្គដោយភាពរីករាយនិងសូមឱ្យព្រះអង្គញ៉ាំងឱ្យទូលបង្គំបានស្រស់ស្រាយ នៅក្នុងចំណោមអ្នកបម្រើដោយដង្ហើមនៃភាពពិសិដ្ឋរបស់ព្រះអង្គផង។

ឱព្រះលោកអើយ សូមព្រះអង្គបញ្ចេញរស្មីត្រចះត្រចង់ឱ្យដល់ភក្ត្ររបស់ទូលបង្គំជាមួយនឹងពន្លឺនៃអំណាចរបស់ព្រះអង្គ សូមព្រះអង្គបំភ្លឺចក្ខុទូលបង្គំដើម្បីឱ្យទូលបង្គំបានមើលឃើញ

សញ្ញានៃអំណាចរបស់ព្រះអង្គ ដែលកំពុងតែបង្ក្រាបរបស់គ្រប់យ៉ាង សូមព្រះអង្គញុំាងឱ្យបេះដូងរបស់ទូលបង្គំបានរីកស្រស់ស្រាយជាមួយនឹងភាពរុងរឿងនៃចំណេះដឹងរបស់ព្រះអង្គដែលបានបញ្ចូលរបស់គ្រប់យ៉ាងទៅក្នុងវា សូមព្រះអង្គញុំាងឱ្យវិញ្ញាណក្ខន្ធរបស់ទូលបង្គំបានរីករាយជាមួយនឹងដំណឹងរីករាយដ៏អស្ចារ្យរបស់ព្រះអង្គ ដែលកំពុងធ្វើឱ្យវិញ្ញាណក្ខន្ធមានជីវិតរស់ឡើងវិញ។ ឱព្រះអង្គដែលជាស្ដេចនៃពិភពនេះ ហើយនិងជារាជាណាចក្រដ៏ខ្ពង់ខ្ពស់ ឱព្រះអង្គដែលជាព្រះនៃអំណាចនិងសព្វានុភាពអើយ ទូលបង្គំពង្រីកសញ្ញានិងនិមិត្តរូបរបស់ទូលព្រះបង្គំ ទូលបង្គំសូមប្រកាសពីបុព្វហេតុសាសនារបស់ព្រះអង្គ ទូលបង្គំសូមផ្សព្វផ្សាយពីការបង្ហាត់បង្រៀនរបស់ព្រះអង្គហើយ ទូលបង្គំក៏សូមបម្រើដល់ច្បាប់របស់ព្រះអង្គ និងសូមលើកតម្កើងបន្ទូលរបស់ព្រះអង្គផង។

ពិតណាស់ព្រះអង្គគឺជាព្រះប្រកបដោយសព្វានុភាព ជាព្រះលើកលែងទោសជាអមត ជាព្រះពោរពេញដោយលទ្ធភាព និងជាព្រះប្រកបដោយអំណាច។

- អង្គពិសិដ្ឋអាប់ឌុលបាហា-

# ធម៌សូត្រសម្រាប់ភាពរឹងមាំចំពោះកិច្ចព្រមព្រៀង

ឱស្ដេចនៃអមតភាពអើយ ព្រះអង្គគឺជាព្រះដែលមានភាពរុងរឿងជាអ្នកបង្កើតមនុស្សគ្រប់ជាតិសាសន៍ ជាអ្នករចនានៃឆ្អឹងគ្រោងគ្រប់ផ្នែក! ទូលបង្គំសូមបួងសួងដល់ព្រះអង្គ តាមព្រះនាមរបស់ព្រះអង្គ សូមព្រះអង្គស្រែកហៅឱ្យមនុស្សជាតិគ្រប់គ្នាចូលទៅកាន់នភាល័យនៃព្រះករុណាធិគុណ និងភាពរុងរឿងរបស់ព្រះអង្គ ហើយសូមព្រះអង្គដឹកនាំបង្ហាញផ្លូវឱ្យអ្នកបម្រើរបស់ព្រះអង្គទៅកាន់ព្រះរាជវាំងនៃមនុញ្ញភាព និងការអនុគ្រោះរបស់ព្រះអង្គ សូមព្រះអង្គដាក់លេខរៀង ឱ្យទូលបង្គំបាននៅជាមួយនឹងអ្នកបម្រើរបស់ព្រះអង្គដែលបានលះបង់ខ្លួនគេពីវត្ថុគ្រប់យ៉ាងលើកលែងតែជារបស់ព្រះអង្គ និងសូមព្រះអង្គដាក់ឱ្យទូលបង្គំបាននៅជាមួយនឹងអ្នកបម្រើដែលបានភ្ជាប់ខ្លួនគេឆ្ពោះទៅកាន់ព្រះអង្គ សូមព្រះអង្គដាក់ឱ្យទូលបង្គំបាននៅជាមួយនឹងអ្នកបម្រើដែលត្រូវបានគេធ្វើឱ្យវិលត្រឡប់ទៅកាន់ភាពអកុសលដែលខុសពីក្រិត្យដែលព្រះអង្គបានចេញនោះឡើយ ហើយក៏សូមព្រះអង្គការពារទូលបង្គំបាននៅក្នុងទិសដៅនៃអំណាចរបស់ព្រះអង្គផងជារៀងរហូត។

ព្រះរបស់ទូលបង្គំលោកអើយ ទូលបង្គំបានកាន់ដងបុណ្យរបស់ព្រះអង្គ ហើយបានតោងយ៉ាងខ្ជាប់ទៅនឹងជាយសំពត់នៃការអនុគ្រោះរបស់ព្រះអង្គ។ អ៊ីចឹងនៅពេលនេះ សូមព្រះអង្គបញ្ជូន

បុណ្យរបស់ព្រះអង្គ ឱ្យចុះមកកាត់តាមពពកនៃសប្បុរសធម៌របស់ព្រះអង្គឱ្យបានដល់ទូលបង្គំ ហើយអ្វីដែលធ្វើឱ្យទូលបង្គំចងចាំនរណាក្រៅពីព្រះអង្គនោះសូមព្រះអង្គបន្សុទ្ធឱ្យទូលបង្គំផង សូមព្រះអង្គធ្វើឱ្យទូលបង្គំបានវិលទៅកាន់ទ្រង់ ដែលជាវត្ថុបំណងនៃសក្ការៈរបស់មនុស្សជាតិគ្រប់គ្នា សូមព្រះអង្គធ្វើឱ្យទូលបង្គំហ៊ានប្រឆាំងនឹងអ្នកដែលប្រឆាំងនឹងព្រះអង្គហ៊ានប្រឆាំងនឹងអ្នក ដែលបានបំបែកបំបាក់កិច្ចព្រមព្រៀងរបស់ព្រះអង្គ និងអ្នកដែលមិនជឿចំពោះព្រះអង្គ ហើយនិងអ្នកដែលមិនជឿចំពោះសញ្ញារបស់ព្រះអង្គ។

ឱព្រះរបស់ទូលបង្គំលោកអើយ សូមព្រះអង្គអនុញ្ញាតឱ្យទូលបង្គំបានទទួលនូវក្លិនពិដោរសម្លៀកបំពាក់របស់ព្រះអង្គនៅក្នុងយុគសម័យរបស់ព្រះអង្គ ហើយសូមព្រះអង្គកុំផ្តាច់ដង្ហើមនៃការត្រាស់ដឹងរបស់ព្រះអង្គដែលបានបង្ហាញឱ្យឃើញពីភាពរុងរឿងនៃពន្លឺពីព្រះភក្ត្ររបស់ព្រះអង្គចេញពីទូលបង្គំឡើយ។ ព្រះអង្គគឺជាព្រះប្រកបដោយសព្វានុភាព ដែលព្រះអង្គអាចធ្វើអ្វីៗបានតាមព្រះទ័យរបស់ព្រះអង្គ។ គ្មាននរណាអាចរឹងទទឹងនឹងឆន្ទៈរបស់ព្រះអង្គបានឡើយ ហើយក៏គ្មាននរណាអាចរារាំងនូវអ្វីដែលព្រះអង្គបានមានព្រះរាជបំណងដែលព្រះអង្គប៉ង ដោយអំណាចរបស់ព្រះអង្គបានដែរ។ ពិតណាស់គ្មានព្រះឯណាទៀតឡើយ ក្រៅពីព្រះអង្គព្រះអង្គគឺជាព្រះប្រកបដោយឫទ្ធីចេស្តាជាព្រះប្រកបដោយបញ្ញា

ញាណគ្រប់យ៉ាង។

-ព្រះបាហាអ៊ុលឡាហ៍-

ទ្រង់ជាព្រះអង្គដែលមានឫទ្ធីចេស្តាជាអ្នកអភ័យទោស ឱ្យជាព្រះមានក្តីអាណិតដល់មនុស្សគ្រប់គ្នា! ឱព្រះជាព្រះរបស់ទូលបង្គំលោកអើយ! សូមព្រះអង្គទតមើលអ្នកបម្រើរបស់ព្រះអង្គដែលកំពុងធ្លាក់ចុះនៅក្នុងអន្លង់នៃការបំផ្លិចបំផ្លាញនិងការភាន់ច្រឡំផង ឱព្រះអង្គដែលជាទីប្រាថ្នារបស់ពិភពលោកអើយ តើពន្លឺនៃការដឹកនាំបង្ហាញផ្លូវដ៏សុក្រិតរបស់ព្រះអង្គនៅឯណា? ភាពខ្វះជំនួយ និងភាពទន់ខ្សោយរបស់ពួកគេព្រះអង្គបានស្វែងយល់ទាំងអស់ ឱព្រះអង្គដែលមានអំណាចយល់ដឹងនៅក្នុងឋានសួគ៌ និងផែនដីអើយ តើសព្វានុភាពរបស់ព្រះអង្គនៅឯណា?

ឱព្រះម្ចាស់របស់ទូលបង្គំអើយ ទូលបង្គំបួងសួងសុំព្រះអង្គតាមរយៈភាពរុងរឿងនៃពន្លឺដែលកើតចេញមកពីព្រះទ័យសប្បុរសធម៌ជាទីស្រលាញ់របស់ព្រះអង្គ និងជារលកនៃមហាសាគរដែលកើតចេញពីចំណេះដឹង និងគតិបណ្ឌិតរបស់ព្រះអង្គហើយទូលបង្គំក៏សូមបួងសួងសុំព្រះអង្គតាមរយៈបន្ទូល ដែលព្រះអង្គបានចល័តដល់មនុស្សដែលកើតចេញមកពីអំណាចរបស់ព្រះអង្គសូមព្រះអង្គយល់ព្រមឱ្យទូលបង្គំបានក្លាយទៅជាមនុស្សម្នាក់ក្នុងចំណោមពួក

គេដែលបានប្រតិបត្តិតាមបញ្ញត្តិរបស់ព្រះអង្គដែលមាននៅក្នុងគម្ពីរធម៌របស់ព្រះអង្គ។ ហើយសូមព្រះអង្គកំណត់ឱ្យទូលបង្គំនូវអ្វីដែលព្រះអង្គបានកំណត់ឱ្យអ្នកដែលគេទុកចិត្តរបស់ព្រះអង្គនិងសូមព្រះអង្គយល់ព្រមឱ្យទូលបង្គំបានក្លាយទៅជាមនុស្សម្នាក់ក្នុងចំណោមពួកគេដែលបានផឹកទឹកអម្រឹតនៃដង្វើមដ៏សុក្រិត្យដែលចេញមកពីពែងនៃបុណ្យរបស់ព្រះអង្គ និងជាមនុស្សម្នាក់ប្រញាប់ទទួលយកភាពរីករាយរបស់ព្រះអង្គ។ ព្រមទាំងមនុស្សម្នាក់ដែលប្រតិបត្តិតាមកិច្ចព្រមព្រៀងនិងមតិកសាសន៍របស់ព្រះអង្គ។ ព្រះអង្គគឺជាព្រះប្រកបដោយសព្វានុភាពព្រះអង្គអាចធ្វើអ្វីៗ បានតាមព្រះអង្គសព្វព្រះហឫទ័យ។ គ្មានព្រះឯណាទៀតឡើយក្រៅពីព្រះអង្គ ព្រះអង្គជាព្រះទ្រង់ញាណគ្រប់យ៉ាង ជាព្រះប្រកបដោយបញ្ញាញាណគ្រប់យ៉ាង។

ឱព្រះលោកអើយ តាមរយៈបុណ្យរបស់ព្រះអង្គនេះ សូមព្រះអង្គកំណត់ក្រិត្យឱ្យទូលបង្គំនូវអ្វីដែលនឹងធ្វើឱ្យទូលបង្គំបានចម្រើនទាំងក្នុងភពនេះ និងភពបន្ទាប់ទៀតផង ឱព្រះអង្គដែលជាព្រះរបស់មនុស្សគ្រប់គ្នាអើយ សូមព្រះអង្គអូសទាញទូលបង្គំឱ្យបានទៅនៅជិតព្រះអង្គផង។ ក្រៅពីព្រះអង្គគ្មានព្រះឯណាទៀតឡើយព្រះអង្គជាព្រះតែមួយអង្គគត់ ជាព្រះប្រកបដោយឫទ្ធីចេស្ដា និងជាព្រះប្រកបដោយភាពរុងរឿងអស្ចារ្យ។ -ព្រះបាហាអ៊ុលឡាហ៍-

ឱព្រះលោកអើយ សូមព្រះអង្គពង្រឹងជំហាររបស់ពួកយើងឱ្យបាននៅក្នុងមាគ៌ារបស់ព្រះអង្គ និងសូមព្រះអង្គពង្រឹងចិត្តរបស់ពួកយើងឱ្យបាននៅក្នុងការស្តាប់បង្គាប់ តាមការបង្គាប់របស់ព្រះអង្គផង។ សូមព្រះអង្គបង្វែរមុខរបស់ពួកយើងឆ្ពោះទៅកាន់សោភ័ណភាពនៃភាពតែមួយរបស់ព្រះអង្គ និងសូមព្រះអង្គធ្វើឱ្យទ្រូងរបស់ពួកយើងបានរីករាយសប្បាយ ជាមួយនឹងសញ្ញានៃសាមគ្គីភាពដ៏សុក្រិតរបស់ព្រះអង្គ។ សូមព្រះអង្គតុបតែងរាងកាយរបស់ពួកយើងជាមួយនឹងសម្លៀកបំពាក់ នៃបុណ្យកុសលរបស់ព្រះអង្គ សូមព្រះអង្គបកស្បៃ នៃអំពើបាបកម្មចេញពីភ្នែករបស់ពួកយើង និងសូមព្រះអង្គប្រទានពែងនៃមនុញ្ញភាពរបស់ ព្រះអង្គឱ្យបានដល់ពួកយើង ដើម្បីឱ្យមនុស្សគ្រប់គ្នាបានច្រៀងខ្លឹមសាររបស់ចំរៀងលើកតម្កើងរបស់ព្រះអង្គ មុនពេលគេបានឃើញភាពរុងរឿងរបស់ព្រះអង្គ។ ឱព្រះលោកអើយ នៅពេលនេះសូមព្រះអង្គបង្ហាញព្រះកាយរបស់ព្រះអង្គឱ្យបានឃើញតាមរយៈព្រះសូរសៀងដែលប្រកបដោយមេត្តាធម៌របស់ព្រះអង្គ និងដោយមនុស្សអាទិទេពដ៏អាថ៌កំបាំងរបស់ព្រះអង្គដើម្បីឱ្យបីតិ(ការមានសេចក្តីរីករាយ) ដែលកើតមកពីការបួងសួងអធិដ្ឋាននេះ បានបំពេញឱ្យមានដល់វិញ្ញាណក្ខន្ធរបស់ពួកយើង គឺជាធម៌ដែលនឹងបំពេញវិញ្ញាណក្ខន្ធរបស់ពួកយើងដែលនឹងលើកបន្ទូល និងសារលិខិតនិងជាសូរសៀងដែលកើតចេញមកពីព្យាង្គនិងសំនៀងរហឹមៗ ហើយក៏ជាធម៌ដែលត្រូវ

បានគេបញ្ចូលទៅក្នុងអត្ថន័យខ្លឹមសារដែលគ្មានអ្វីក្រៅពីការត្រាស់ដឹងនៃភាពរុងរឿងរបស់ព្រះអង្គឡើយ។ ព្រះលោកអើយ! ទាំងនេះគឺជាអ្នកបម្រើដែលបាននៅជាប់ ហើយរឹងមាំនឹងកិច្ចព្រមព្រៀងរបស់ព្រះអង្គ ហើយនិងមតិកសាសន៍របស់ព្រះអង្គ ហើយក៏ជាអ្នកដែលបានកាន់យ៉ាងជាប់ស្អិតទៅនឹងខ្សែ និរន្តរភាពនៅក្នុងបុព្វហេតុសាសនារបស់ព្រះអង្គ ហើយព្រមទាំងជាអ្នកដែលតោងជាយសម្លៀកបំពាក់រុងរឿងរបស់ព្រះអង្គផងដែរ។ ឱព្រះលោកអើយសូមព្រះអង្គជួយពួកគេ ជាមួយនឹងមនុញ្ញភាពរបស់ព្រះអង្គ សូមព្រះអង្គញ៉ាំងឱ្យពួកគេពោលអះអាង ដោយអំណាចរបស់ព្រះអង្គ និងសូមព្រះអង្គញ៉ាំងឱ្យសាច់ដុំចំឡុករបស់ពួកគេបានរឹងមាំក្នុងការស្ដាប់បង្គាប់តាមព្រះអង្គ។

ព្រះអង្គគឺជាអ្នកអភ័យទោសឱ្យ និងជាព្រះប្រកបដោយមនុញ្ញភាព។

-អង្គពិសិដ្ឋអាប់ឌុលបាហា-

ឱព្រះដែលប្រកបដោយព្រះទ័យអាណិតអាសូរលោកអើយ! ទូលបង្គំមានសេចក្ដីអំណរអរព្រះគុណយ៉ាងអនេក ដល់ព្រះអង្គព្រោះព្រះអង្គបានដាស់និងបានធ្វើឱ្យទូលបង្គំបានដឹងខ្លួនឡើង។ ព្រះអង្គបានប្រទានចក្ខុភ្លឺស្វាង ដែលអាចមើលឃើញឱ្យទូលបង្គំ

ហើយបានប្រទានត្រចៀកដែលចូលចិត្តស្តាប់ឱ្យទូលបង្គំ ព្រមទាំងបាននាំទូលបង្គំឆ្ពោះទៅកាន់រាជាណាចក្ររបស់ព្រះអង្គ និងដឹកនាំបង្ហាញផ្លូវទូលបង្គំឆ្ពោះទៅកាន់មាគ៌ារបស់ព្រះអង្គផង។ ព្រះអង្គបានបង្ហាញផ្លូវត្រឹមត្រូវដល់ទូលបង្គំ និងបានញ៉ាំងឱ្យទូលបង្គំបានចូលទៅកាន់នាវាសង្គ្រោះផងដែរ។ ឱព្រះលោកអើយ! សូមព្រះអង្គការពារ ទូលបង្គំឱ្យបានប្រកាន់ខ្ជាប់នូវព្រះធម៌របស់ព្រះអង្គ ហើយសូមព្រះអង្គធ្វើឱ្យទូលបង្គំបានរឹងប៉ឹងផង។ សូមព្រះអង្គបញ្ចៀសទូលបង្គំ ឱ្យបានគេចផុតពីពិសោធនកម្មដែលប្រកបដោយអំពើហឹង្សា និងសូមព្រះអង្គការពារ និងផ្តល់ទីជម្រកឱ្យទូលបង្គំបាននៅក្នុងបន្ទាយការពារដ៏រឹងមាំនៃកិច្ចព្រមព្រៀងនិងមតិកសាសន៍របស់ព្រះអង្គផង។ ព្រះអង្គគឺជាព្រះប្រកបដោយអំណាចខ្លាំងក្លា។ ព្រះអង្គគឺជាព្រះមានព្រះនេតទិព្វ។ ព្រះអង្គគឺជាព្រះមានសោតវិញ្ញាណទិព្វ។

ឱព្រះអង្គដែលជាព្រះប្រកបដោយព្រះទ័យអាណិតអាសូរលោកអើយ សូមព្រះអង្គប្រទានឱ្យទូលបង្គំនូវបេះដូងដែលប្រៀបដូចជាកញ្ចក់ដែលអាចត្រូវបានគេឆ្លុះបំភ្លឺ ដោយពន្លឺនៃក្តីស្រលាញ់របស់ព្រះអង្គ ហើយសូមព្រះអង្គប្រទានគំនិតដែលអាចផ្លាស់ប្តូរពិភពលោកនេះ ឱ្យក្លាយទៅជាឧទ្យានកុលាបតាមរយៈការបង្អុរមនុញ្ញភាពសួគ៌ឱ្យបានដល់ទូលបង្គំផង។ ព្រះអង្គគឺជាព្រះប្រកបដោយព្រះទ័យអាណិតអាសូរជាព្រះប្រកបដោយមេត្តាធម៌។

ព្រះអង្គជាព្រះប្រកប ដោយព្រះទ័យសប្បុរសដ៏អស្ចារ្យ។

-អង្គពិសិដ្ឋអាប់ឌុលបាហា-

ឱព្រះរបស់ទូលបង្គំ និងជាក្ដីសង្ឃឹមរបស់ទូលបង្គំលោកអើយ! សូមព្រះអង្គជួយឱ្យអ្នកជាទីស្រលាញ់របស់ព្រះអង្គបានប្រកាន់ខ្ជាប់តាមកិច្ចព្រមព្រៀងដ៏មានអំណាចរបស់ព្រះអង្គ សូមព្រះអង្គជួយឱ្យអ្នកដែលជាទីស្រលាញ់របស់ព្រះអង្គទាំងនោះ បាននៅមានជំនឿពិតចំពោះបុព្វហេតុសាសនាដែលបានបង្ហាញឱ្យគេឃើញមកនេះ និងសូមព្រះអង្គជួយឱ្យអ្នកដែលជាទីស្រលាញ់របស់ព្រះអង្គទាំងនោះបានអនុវត្តតាមបញ្ញត្តិដែលព្រះអង្គ បានដាក់ចុះមកឱ្យពួកគេនៅក្នុងគម្ពីររុងរឿងរបស់ព្រះអង្គ ដើម្បីឱ្យពួកគេអាចក្លាយទៅជាទង់នៃការនាំបង្ហាញផ្លូវ និងជាប្រទីបនៃក្រុមជំនុំនាឋានខ្ពង់ខ្ពស់ និងសូមព្រះអង្គធ្វើឱ្យពួកគេបានក្លាយទៅជាប្រភពនៃគតិបណ្ឌិតគ្មានទីបញ្ចប់ និងតារាដែលនាំផ្លូវត្រឹមត្រូវ ហើយក៏ជាតារាដែលបញ្ចេញរស្មីចុះមកពីមេឃដ៏អស្ចារ្យផងដែរ។

ពិតណាស់ ព្រះអង្គគឺជាព្រះឈ្នះអស់គ្មានគូប្រៀប ជាព្រះប្រកបដោយឫទ្ធីចេស្ដាដ៏ខ្លាំងក្លា និងជាព្រះប្រកបដោយសព្វានុភាពគ្រប់យ៉ាង។ -អង្គពិសិដ្ឋអាប់ឌុលបាហា-

# ធម៌សូត្រសម្រាប់ការនៅជិតព្រះ

ឱព្រះម្ចាស់របស់ទូលបង្គំលោកអើយ ព្រះអង្គគឺជាព្រះប្រកបដោយភាពរុងរឿង! សូមព្រះអង្គទ្រង់ព្រះសណ្ដាប់អ្នកជាទីស្រលាញ់របស់ព្រះអង្គកំពុងតែខ្សឹកខ្សួលអួលដើមកដោយសារតែការបំបែកពួកគេឱ្យឃ្លាតឆ្ងាយពីព្រះអង្គចុះ ហើយសូមព្រះអង្គទ្រង់ព្រះសណ្ដាប់អ្នកដែលបានទទួលស្គាល់ព្រះអង្គទាំងនោះ កំពុងតែទ្រហោយំដោយសារតែពួកគេបានឃ្លាតឆ្ងាយពីវត្តមានរបស់ព្រះអង្គ។

ឱព្រះម្ចាស់របស់ទូលបង្គំលោកអើយ សូមព្រះអង្គបើកចំហទ្វារនៃមនុញ្ញភាពរបស់ព្រះអង្គ ទៅកាន់មុខរបស់ពួកគេដើម្បីឱ្យពួកគេបានចូលតាមទ្វារនោះ ដោយការអនុគ្រោះរបស់ព្រះអង្គ និងដោយការអនុលោមទៅតាមឆន្ទៈរបស់ព្រះអង្គផង ហើយនិងដើម្បីឱ្យពួកគេបានឈរនៅចំពីមុខរាជបល្លង្ក៍នៃជីវិតតម្កល់លើត្បូងរបស់ព្រះអង្គហើយនិងដើម្បីឱ្យពួកគេបានឮពីសំនៀងរបស់ព្រះអង្គព្រមទាំងដើម្បីឱ្យពួកគេបានទទួលនូវពន្លឺនៃភាពរុងរឿង ដែលចេញមកពីភក្ត្រប្រិមប្រិយរបស់ព្រះអង្គផង។

ព្រះអង្គគឺជាព្រះប្រកបដោយអំណាចធ្វើអ្វីៗបានតាមប្រាថ្នាព្រះអង្គសព្វព្រះហឫទ័យ។ គ្មាននរណាម្នាក់អាចដកយកអំណាច

ពីអធិបតេយ្យភាពរបស់ព្រះអង្គបានឡើយ។ ព្រះអង្គគឺជាព្រះតែមួយអង្គជារៀងរហូត ជាព្រះដែលគ្មានគូប្រៀប ហើយក៏ជាព្រះដែលមានគំនិតខ្ពង់ខ្ពស់លើសអស់ទាំងគំនិតទាំងឡាយ ហើយក៏គ្មានគំនិតណាអាចពិពណ៌នាពីព្រះអង្គបានឡើយ។ នៅពេលនេះ សូមព្រះអង្គប្រទានមេត្តាធម៌ ឱ្យបានដល់អ្នកបម្រើរបស់ព្រះអង្គ ដោយមនុញ្ញភាពនិងដោយបុណ្យរបស់ព្រះអង្គផង ហើយក៏សូមព្រះអង្គកុំធ្វើឱ្យពួកគេឈឺចាប់ ដោយសារតែការដកពួកគេចេញពីឆ្នេរនៃមហាសាគរនៃភាពនៅជិតរបស់ព្រះអង្គឡើយ។ បើព្រះអង្គបោះបង់ពួកគេចោល ពួកគេគ្មាននរណាជាទីពឹងទៀតឡើយ ហើយបើព្រះអង្គដាក់ពួកគេឱ្យនៅឆ្ងាយពីព្រះអង្គតើគាត់នោះអាចសង្គ្រោះពួកគេបានទេ? ពួកគេទាំងអស់គ្នា គ្មានទទួលស្គាល់ព្រះណាក្រៅពីព្រះអង្គឡើយ ពួកគេគ្មានសេចក្តីស្រលាញ់ឯណាក្រៅពីសេចក្តីស្រលាញ់របស់ព្រះអង្គឡើយ។ សូមព្រះអង្គទាក់ទងពួកគេជាមួយនឹងមនុញ្ញភាព ដែលប្រកបដោយបុណ្យរបស់ព្រះអង្គផង។

ពិតណាស់ព្រះអង្គគឺជាព្រះលើកលែងទោសជាអមត ជាព្រះប្រកបដោយក្តីអាណិតអាសូរបំផុត។

-ព្រះបាហាអ៊ុលឡាហ៍-

# ធម៌ស្មូត្រលើកតម្កើងនិងការដឹងគុណព្រះ

ឱព្រះរបស់ទូលបង្គំលោកអើយ យើងទាំងអស់គ្នាសូម សរសើរចំពោះព្រះអង្គ ដែលជាប្រភពនៃគ្រប់ភាពរុងរឿង និងអំណាចដែលជាប្រភពនៃភាពអស្ចារ្យនិងកិត្តិយស ដែល

ជាប្រភពនៃអធិបតេយ្យភាព និងវិជិតរាជ្យដែលជាប្រភព នៃភាពខ្ពង់ខ្ពស់និងមនុញ្ញភាពដែលជាប្រភពនៃភាពគួរឱ្យ គោរពកោតខ្លាចនិងអំណាច។ ពិតណាស់អ្នកដែលព្រះអង្គ សព្វព្រះហឫទ័យនោះព្រះអង្គបានញ៉ាំងឱ្យបានទៅជិតនឹង មហាសាគរដ៏អស្ចារ្យបំផុតហើយ ហើយចំណែកឯនរណា ដែលព្រះអង្គនឹងពេញព្រះទ័យនោះ ព្រះអង្គនឹងផ្តល់ឱ្យនូវ កិត្តិយសដែលកើតមកពីការទទួលស្គាល់ព្រះនាមដើមដ៏ អស្ចារ្យបំផុតរបស់ព្រះអង្គ។ ទាំងអ្នកនៅក្នុងឋានសួគ៌និង នៅលើផែនដីនេះ គ្មាននរណាម្នាក់អាចស៊ូទ្រាំនឹងអានុភាព នៃឆន្ទៈដ៏ស័ក្តិសិទ្ធរបស់ព្រះអង្គបានឡើយ។ ព្រះអង្គគ្រប់ គ្រងមាបនកម្មទាំងអស់តាំងតែពីដើមរៀងមក ហើយព្រះ អង្គក៏នឹងបន្តប្រើអំណាចរបស់ព្រះអង្គដើម្បីគ្រប់គ្រងលើវត្ថុគ្រប់យ៉ា ងដែលបានបង្កើតមកនេះជារៀងរហូតទៅជាអនន្តភាពផងដែរ។

ក្រៅពីព្រះអង្គគ្មានព្រះណាទៀតឡើយ ព្រះអង្គគឺជាព្រះប្រកបដោយឫទ្ធានុភាព និងជាព្រះប្រកបដោយភាព

ខ្ពង់ខ្ពស់បំផុត ជាព្រះប្រកបដោយសព្វានុភាពគ្រប់យ៉ាងនិងជាព្រះប្រកបដោយបញ្ញាគ្រប់យ៉ាង។

ឱព្រះម្ចាស់លោកអើយ សូមព្រះអង្គឆ្លុះបំភ្លឺភក្ត្រនៃអ្នកបម្រើរបស់ព្រះអង្គគ្រប់គ្នាផងដើម្បីឱ្យពួកគេបានឃើញ ព្រះអង្គសូមព្រះអង្គលាងសម្អាតដួងចិត្តរបស់ពួកគេដើម្បីឱ្យពួកគេបានងាកទៅកាន់ព្រះរាជវាំងនៃការអនុគ្រោះសួគ៌របស់ព្រះអង្គហើយនិងដើម្បីឱ្យពួកគេបានទទួលស្គាល់ទ្រង់

ដែលជាព្រះសាស្តានៃអង្គឯងហើយនិងជាប្រភពរីករាយនៃភាពសំខាន់របស់ព្រះអង្គ។ ពិតណាស់ព្រះអង្គគឺជាព្រះជាម្ចាស់គ្រប់ពិភព។ ក្រៅពីព្រះអង្គគ្មានព្រះណាទៀតឡើយ ព្រះអង្គគឺជាព្រះមានព្រះទ័យទូលំទូលាយ ជាព្រះឈ្នះអស់វត្ថុទាំងពួង។

-ព្រះបាហាអ៊ុលឡាហ៍-

* * * * *

ធម៌សូត្រសុំឱ្យព្រះឃុំគ្រង

ឱព្រះម្ចាស់របស់ទូលបង្គំលោកអើយ ពិតណាស់ព្រះអង្គជាព្រះគួរឱ្យសរសើរ! ព្រះអង្គទ្រង់បានទតឃើញនិងទ្រង់បានជ្រាបហើយថាទូលបង្គំបានអំពាវនាវដល់អ្នកបម្រើរបស់ព្រះអង្គកុំឱ្យពួកគេងាកទៅកាន់ផ្លូវណាឡើយក្រៅពីទិសដៅនៃការប្រទានរបស់ព្រះអង្គ ហើយព្រមទាំងបានបញ្ជាឱ្យគេកុំពិនិត្យមើលរបស់អ្វីក្រៅពីរបស់ព្រះអង្គដែលទ្រង់បានបញ្ញត្តិទុកនៅក្នុងគម្ពីរពិតរបស់ព្រះអង្គដែលត្រូវបានគេបញ្ជូនចុះមកអនុលោមទៅតាមក្រិត្យដែលគ្មាននរណាអាចយល់បាន ហើយនិងតាមគោលបំណងដែលគ្មាន

នរណាអាចកែប្រែពីក្រិត្យនិងគោលបំណងរបស់ព្រះអង្គបានឡើយ។

ឱព្រះម្ចាស់របស់ទូលបង្គំលោកអើយ ទូលបង្គំគ្មានពាក្យណាអាចនិយាយបានឡើយ លុះត្រាណាតែព្រះអង្គអនុញ្ញាតទើបទូលបង្គំអាចនិយាយបាន ហើយទូលបង្គំក៏មិនអាចដើរទៅកាន់ទិសណាបានដែរ បើគ្មានការយល់ព្រមពីព្រះអង្គនោះ។ ឱព្រះម្ចាស់របស់ទូលបង្គំលោកអើយ អ្នកដែលបានអំពាវនាវឱ្យទូលបង្គំចូលទៅកាន់ជីវិតមនុស្សលោកតាមរយៈអំណាចនៃឫទ្ធិរបស់ព្រះអង្គ ហើយនិងអ្នកដែលបានផ្តល់មនុញ្ញភាពរបស់ព្រះអង្គឱ្យទូលបង្គំដើម្បីសម្តែងពីបុព្វហេតុសាសនារបស់ព្រះអង្គនោះ គ្មាននរណាក្រៅពីព្រះអង្គឡើយ។ ព្រោះទូលបង្គំនៅពេលនេះត្រូវបានគេដាក់គំនៀបឱ្យនៅក្រោមភាពទន់ខ្សោយដោយមិនឱ្យអណ្តាតរបស់ទូលបង្គំបានលើកសរសើរព្រះអង្គ និងពង្រីកពីភាពរុងរឿងរបស់ព្រះអង្គបានឡើយ។

ឱព្រះម្ចាស់របស់ទូលបង្គំលោកអើយ ព្រះអង្គគឺជាព្រះគួរឱ្យអ្នកទាំងអស់គ្នាសរសើរខ្លាំងណាស់ ព្រោះវត្ថុគ្រប់យ៉ាងព្រះអង្គបានកំណត់ឱ្យទូលបង្គំតាមរយៈក្រិត្យរបស់

ព្រះអង្គនិងតាមរយៈអំណាចនៃអធិបតេយ្យភាពរបស់ព្រះអង្គរួចហើយ។ ទូលបង្គំសូមអង្វរព្រះអង្គសូមទ្រង់ពង្រឹងទាំងទូលបង្គំទាំងពួកគេដែលស្រលាញ់ទូលបង្គំសូមឱ្យសេចក្ដីស្រលាញ់របស់យើងមានដល់ព្រះអង្គ ហើយនិងសូមព្រះអង្គបន្តពង្រឹងពួកយើងឱ្យបានស្ថិតនៅក្នុងបុព្វហេតុសាសនារបស់ព្រះអង្គផង។ទូលបង្គំទុកចិត្តលើឫទ្ធានុភាពរបស់ព្រះអង្គ! ឱព្រះម្ចាស់របស់ទូលបង្គំលោកអើយ! ភាពអាម៉ាស់របស់អ្នកបម្រើរបស់ព្រះអង្គនឹងត្រូវបានគេបំបិទដោយស្បែពីព្រះអង្គ ហើយចំណែកឯភាពរុងរឿងរបស់គាត់នឹងកើតមានឡើងដោយសារគាត់បានស្គាល់ព្រះអង្គ។ អាវុធដែលបានបំពាក់ដោយអំណាចនៃព្រះនាមរបស់ព្រះអង្គគ្មានអ្វីអាចធ្វើឱ្យទូលបង្គំឈឺចាប់សូម្បីតែបន្តិចឡើយ ហើយដោយមានក្ដីស្រលាញ់របស់ព្រះអង្គនៅក្នុងចិត្តរបស់ទូលបង្គំនោះទើបគ្រប់ការឈឺចាប់របស់ពិភពលោកមិនអាចធ្វើឱ្យទូលបង្គំរន្ធត់ឡើយ។

ឱព្រះម្ចាស់របស់ទូលបង្គំលោកអើយនៅពេលនេះសូម

ព្រះអង្គបញ្ជូនឱ្យទូលបង្គំ និងអ្នកដែលជាទីស្រលាញ់របស់

ទូលបង្គំនូវអ្វីដែលនឹងអាចការពារពួកយើងពីការរំខាន របស់អ្នកដែលមិនទទួលយកសច្ចភាពរបស់ព្រះអង្គ ហើយ និងអ្នកដែលមិនជឿចំពោះសញ្ញារបស់ព្រះអង្គ។

ពិតណាស់ព្រះអង្គគឺជាព្រះប្រកបដោយភាពរុងរឿង

គ្រប់យ៉ាងជាព្រះប្រកបដោយព្រះទ័យសប្បុរសធម៌បំផុត។

-ព្រះបាហាអ៊ុលឡាហ៍-

ឱព្រះម្ចាស់របស់ទូលបង្គំលោកអើយ ព្រះអង្គគឺជា ព្រះគួរឱ្យគេសរសើរ! នេះគឺជាអ្នកបម្រើរបស់ព្រះអង្គដែល

បានក្រេបទឹកអម្រឹតនៃមេត្តាធម៌ដ៏ស្រទន់ពីព្រះហស្តរបស់ ព្រះអង្គហើយក៏ជាអ្នកដែលភ្លក់រសជាតិនៃក្តីស្រលាញ់របស់ ព្រះអង្គនៅក្នុងយុគសម័យរបស់ព្រះអង្គផងដែរ។ ទូលបង្គំ សូមអង្វរព្រះអង្គ តាមរយៈអ្នកតំណាងនៃព្រះនាមរបស់ ព្រះអង្គដែលជាអ្នកគ្មានភាពទុក្ខព្រួយណាមួយអាចរារាំងពីការរីករា យដែលមាននៅក្នុងសេចក្តីស្រលាញ់របស់ព្រះអង្គ ឬពីការសម្លឹងមើលទៅលើព្រះភក្ត្ររបស់ព្រះអង្គបានឡើយ ហើយក៏ជាអ្នកដែលគ្រប់បាបនិកដ៏កំសោយណាមួយអាចញ៉ាំងឱ្យ គាត់ងាកចេញពីមាគ៌ានៃភាពរីករាយរបស់ព្រះអង្គបានឡើយ

ហើយទូលបង្គំក៏សូមអង្វរព្រះអង្គសូមទ្រង់ផ្តត់ផ្គង់គាត់ជាមួយនឹងវត្ថុគាប់ប្រសើរដែលព្រះអង្គមាន ហើយក៏សូមព្រះអង្គលើកតម្កើងគាត់នោះឱ្យបានដល់ទីដ៏ខ្ពង់ខ្ពស់ ដើម្បីឱ្យគាត់នឹងបានការពារពិភពលោកនៅពេលដែលស្រមោលនៃពិភពលោកនោះបានបាត់រហ័សជាងមួយប៉ព្រិចភ្នែកនេះផង។

ឱព្រះម្ចាស់របស់ទូលបង្គំលោកអើយ សូមព្រះអង្គការពារឱ្យគាត់មានសុវត្ថិភាពពីគ្រប់វត្ថុដែលព្រះអង្គស្អប់ខ្ពើមដោយអំណាចដែលមានមហិទ្ធិឫទ្ធិជាអប្បរិមាណ (ដែលមិនអាចវាស់បាន)របស់ព្រះអង្គផង។ ពិតណាស់ព្រះអង្គគឺជាព្រះរបស់គាត់ហើយក៏ជាព្រះគ្រប់ពិភពដែរ។

-ព្រះបាហាអ៊ុលឡាហ៍-

* * * * *

ធម៌សូត្រសុំការលើកលែងទោស

ឱព្រះរបស់ទូលបង្គំលោកអើយ ព្រះអង្គជាព្រះដែលមានភាពរុងរឿង! ទូលបង្គំសូមអង្វរព្រះអង្គតាមរយៈអ្នកជម្រើសរបស់ព្រះអង្គ និងតាមរយៈអ្នកនាំសារដែលជាទីទុកព្រះទ័យរបស់ព្រះអង្គហើយនិងតាមរយៈទ្រង់ដែលព្រះអង្គបានកំណត់ឱ្យទៅជាសង្ហារ(ត្រា)នៃព្យាករណ៍របស់ព្រះអង្គ និងជាព្រះសង្ហារនៃអ្នកនាំសាររបស់ព្រះអង្គ សូមព្រះអង្គញ៉ាំងឱ្យការចងចាំរបស់ព្រះអង្គក្លាយជាគូកនរបស់ទូលបង្គំ សូមឱ្យសេចក្តីស្រលាញ់របស់ព្រះអង្គក្លាយជាគោលបំណងរបស់ទូលបង្គំ សូមឱ្យព្រះភក្ត្ររបស់ព្រះអង្គក្លាយជាគោលដៅរបស់ទូលបង្គំសូមឱ្យព្រះនាមរបស់ព្រះ

អង្គក្លាយជាប្រទីបរបស់ទូលបង្គំ សូមអោយសេចក្តីប្រាថ្នា

របស់ព្រះអង្គក្លាយជាចំណង់របស់ទូលបង្គំ និងសូមឱ្យភាព

រីករាយរបស់ព្រះអង្គក្លាយជាទីមនោរម្យរបស់ទូលបង្គំ។ ឱព្រះរបស់ទូលបង្គំលោកអើយ ទូលបង្គំជាមនុស្សមានបាបចំណែកឯព្រះអង្គគឺជាព្រះលើកលែងទោសជា អមតៈ។ នៅពេលនេះទូលបង្គំបានទទួលស្គាល់ព្រះអង្គ ហើយក៏បានប្រញាប់ទទួលយកព្រះរាជវាំងនៃភាពសប្បុរសជាទី

ស្រលាញ់ដ៏ខ្ពង់ខ្ពស់របស់ព្រះអង្គផងដែរ។ ឱព្រះម្ចាស់របស់ទូលបង្គំលោកអើយ សូមព្រះអង្គលើកលែងទោសឱ្យទូលបង្គំដែលកើតមកពីអំពើបាបរបស់ទូលបង្គំដែលរារាំងទូលបង្គំមិនឱ្យទូលបង្គំបានធ្វើដំណើរតាមគន្លងមាគ៌ានៃភាពសប្បាយរីករាយរបស់ព្រះអង្គ និងរារាំងទូលបង្គំមិនឱ្យទូលបង្គំបានទៅដល់មាត់នៃមហាសាគរនៃភាពតែមួយរបស់ ព្រះអង្គ។

ឱព្រះរបស់ទូលបង្គំលោកអើយ គ្មាននរណាម្នាក់ដែលអាចមានលទ្ធភាពពាក់ព័ន្ធច្រើនជាមួយនឹងទូលបង្គំដើម្បីឱ្យទូលបង្គំអាចងាកមុខរបស់ទូលបង្គំទៅកាន់អ្នកនោះបានឡើយ ហើយក៏គ្មាននរណាម្នាក់ដែលអាចមានសេចក្ដីករុណាមកលើទូលបង្គំដើម្បីឱ្យទូលបង្គំអាចទទួលបានមេត្តារបស់គាត់នោះដែរ។ ទូលបង្គំសូមអង្វរព្រះអង្គសូមព្រះអង្គកុំបោះបង់ទូលបង្គំឱ្យឃ្លាតឆ្ងាយពីព្រះវត្តមាននៃមនុញ្ញភាពរបស់ព្រះអង្គ ហើយក៏សូមព្រះអង្គកុំបង្អាក់ពីការបង្អុរទឹកនៃមេត្តាធម៌និងសប្បុរសធម៌របស់ព្រះអង្គពីទូលបង្គំឡើយ។ ឱព្រះរបស់ទូលបង្គំលោកអើយសូមព្រះអង្គកំណត់ក្រិត្យឱ្យទូលបង្គំឱ្យដូចគ្នានឹងអ្វីដែលព្រះអង្គបានអំណត់ក្រិត្យឱ្យពួកគេដែលនាំឱ្យគេស្រលាញ់ដល់ព្រះអង្គ ហើយសូមព្រះអង្គរាជនិពន្ធចុះមកឱ្យទូលបង្គំឱ្យដូចគ្នានឹងអ្វីដែលព្រះអង្គបានព្រះរាជនិពន្ធចុះមកឱ្យអ្នកជម្រើស

របស់ព្រះអង្គ។ ចក្ខុរបស់ទូលបង្គំបានសម្លឹងផ្តោតទៅលើនភាល័យនៃទិព្វវិញ្ញាណដែលប្រកបដោយមនុញ្ញភាពរបស់ព្រះអង្គគ្រប់ពេល ហើយចក្ខុរបស់ទូលបង្គំក៏បានផ្តោតទៅលើព្រះរាជវាំងនៃមេត្តាធម៌ជាទីស្រលាញ់របស់ព្រះអង្គផងដែរ។ សូមព្រះអង្គធ្វើឱ្យទូលបង្គំបានសមធ្វើជាអ្នកបម្រើរបស់ព្រះអង្គផង។ ក្រៅពីព្រះអង្គគ្មានព្រះឯណាទៀតឡើយ ព្រះអង្គគឺជាព្រះប្រកបដោយអំណាច ជាព្រះនៃភាពរុងរឿង ជាអ្នកដែលជំនួយរបស់ព្រះអង្គ មនុស្សគ្រប់រូបអង្វរសុំឱ្យបានដល់ពួកគេ។

-ព្រះបាហាអ៊ុលឡាហ៍-

ឱព្រះរបស់ទូលបង្គំលោកអើយ ទូលបង្គំគឺ

ជាមនុស្សម្នាក់ដែលភ្ជាប់ភក្ត្ររបស់គាត់ឆ្ពោះទៅរកព្រះអង្គ

ហើយក៏ជាអ្នកដែលបានភ្ជាប់សេចក្តីសង្ឃឹមរបស់គាត់ ទៅលើភាពអស្ចារ្យនៃមនុញ្ញភាពរបស់ព្រះអង្គនិងការបញ្ចេញឱ្យឃើញនៃបុណ្យកុសលរបស់ព្រះអង្គ។ ទូលបង្គំសូមអង្វរ បួងសួងព្រះអង្គសូមព្រះអង្គកុំធ្វើឱ្យទូលបង្គំឈឺចាប់ហើយ

អស់សង្ឃឹមដែលនាំឱ្យងាកចេញឃ្លាតឆ្ងាយពីទ្វារទាំង ឡាយដែលជាសត្វលោករបស់ព្រះអង្គដែលបានបោះបង់ ចោលបុព្វហេតុសាសនារបស់ព្រះអង្គនោះ។

ឱព្រះរបស់ទូលបង្គំលោកអើយ ទូលបង្គំជាអ្នកបំរើ របស់ព្រះអង្គ ហើយក៏ជាបុត្ររបស់អ្នកបម្រើរបស់ព្រះអង្គ ម្នាក់ដែរ។ ទូលបង្គំបានទទួលស្គាល់សច្ចភាពរបស់ព្រះអង្គ នៅក្នុងយុគសម័យរបស់ព្រះអង្គ ហើយទូលបង្គំក៏បាននាំជំ ហានរបស់ទូលបង្គំឆ្ពោះទៅកាន់មាត់នៃមហាសាគរនៃ ភាពតែមួយរបស់ព្រះអង្គ ដែលជាការសារភាពចំពោះភាព ស្មោះត្រង់របស់ព្រះអង្គ ជាការទទួលបាននូវសាមគ្គីភាព របស់ព្រះអង្គ ហើយនិងការមានសង្ឃឹមចំពោះការលើក លែងទោសនិងការអភ័យទោសរបស់ព្រះអង្គ។ ព្រះអង្គគឺ ជាព្រះប្រកបដោយសព្វានុភាព ព្រះអង្គធ្វើអ្វីៗតាមព្រះ អង្គសព្វព្រះហទ្ទ័យ ក្រៅពីព្រះអង្គគ្មានព្រះឯណាទៀត ឡើយព្រះអង្គគឺជាព្រះប្រកបដោយភាពរុងរឿងគ្រប់យ៉ាង ជាព្រះលើកលែងទោសជាអមត។

-ព្រះបាហាអ៊ុលឡាហ៍-

ឱព្រះរបស់ទូលបង្គំលោកអើយ សូមព្រះអង្គទតមើលទូលបង្គំជាមួយនឹងភក្ដ្ររបស់ទូលបង្គំ ដែលបានងាកឆ្ពោះទៅរកឋានសួគ៌នៃបុណ្យកុសលរបស់ព្រះអង្គនិងមហាសាគរនៃក្ដីអនុគ្រោះរបស់ព្រះអង្គដែលព្រះអង្គបានបើករបស់គ្រប់យ៉ាងចោលពីមុខរបស់ទូលបង្គំលើកលែងតែព្រះអង្គ។ទូលបង្គំសូមបួងសួងសុំព្រះអង្គតាមរយៈភាពរុងរឿងដែលកើតចេញពីព្រះអាទិត្យនៃការត្រាស់ដឹងរបស់ព្រះអង្គនៅលើស៊ីណាអ៊ី ហើយនិងពន្លឺប្រិមប្រិយរបស់ភ្ញគោលនៃមនុញ្ញភាពរបស់ព្រះអង្គដែលបានបញ្ចេញរស្មីត្រចះត្រចង់ពីនភាល័យនៃព្រះនាមរបស់ព្រះអង្គដែលជាព្រះនាមលើកលែងទោសជាអមត សូមព្រះអង្គប្រទានការអភ័យទោសរបស់ព្រះអង្គឱ្យទូលបង្គំ និងសូមព្រះអង្គប្រទានមេត្តាធម៌ឱ្យបានដល់ទូលបង្គំផង។ នៅពេលនេះសូមព្រះអង្គព្រះរាជនិពន្ធឱ្យទូលបង្គំជាមួយនឹងប៉ាកានៃភាពរុងរឿងរបស់ព្រះអង្គដែលនឹងលើកស្ទួយទូលបង្គំឱ្យខ្ពស់ត្រដែតឡើងតាមរយៈព្រះនាមរបស់ព្រះអង្គដែលមាននៅក្នុងពិភពមាបន កម្មនេះ។ ឱព្រះរបស់ទូលបង្គំលោកអើយ សូមព្រះអង្គជួយឱ្យទូលបង្គំបានភ្ជាប់ខ្លួនរបស់ទូលបង្គំចំពោះព្រះអង្គនិងសូមព្រះអង្គជួយឱ្យទូលបង្គំបានស្ដាប់សំលេងរបស់អ្នកដែលជាទីស្រលាញ់របស់ព្រះអង្គផង ហើយអ្នកដែលជាទីស្រលាញ់

របស់ព្រះអង្គនោះ អំណាចរបស់លោកិយនេះមិនអាចបន្ទន់គាត់បានឡើយ ហើយអំណាចរបស់មនុស្សក៏មិនអាចដកហូតគាត់ដែលកំពុងតែបោះជំហានទៅរកព្រះអង្គបានដែរ អ្នកជាទីស្រលាញ់របស់ព្រះអង្គនោះបានមានបន្ទូលថា: "ព្រះជាព្រះរបស់ពួកយើង ហើយក៏ជាព្រះរបស់អ្នកទាំងអស់គ្នាដែលនៅក្នុងឋានសួគ៌ហើយនិងអ្នកទាំងអស់គ្នាដែលនៅលើផែនដីនេះផងដែរ ៉។

-ព្រះបាហាអ៊ុលឡាហ៍-

ឱព្រះរបស់ទូលបង្គំលោកអើយ ព្រះអង្គគឺជាព្រះប្រកបដោយភាពរុងរឿង! គ្រប់ពេលដែលទូលបង្គំធ្វើដំណើរផ្សព្វផ្សាយពីព្រះអង្គនោះ ទូលបង្គំត្រូវបានគេរាំងដោយអំណាចអំពើបាប ហើយនិងអំពើបាបកម្មរបស់ទូលបង្គំដែលប្រឆាំងនឹងព្រះអង្គយ៉ាងខ្លាំង ហើយទូលបង្គំខ្លួនឯងក៏បានយល់ទាំងស្រុងដែរថាអំណាចមនុញ្ញភាពរបស់ព្រះអង្គត្រូវបានគេដកហូតយកពីទូលបង្គំទាំងអស់ដែលធ្វើឱ្យទូលបង្គំគ្មានសល់កម្លាំងអំណាចណាមួយ ដើម្បីអបអរលើកតម្កើងអំណាចរបស់ព្រះអង្គបានឡើយ។ ទោះបីជាយ៉ាងនេះក៏ដោយសារតែសេចក្ដីទុកចិត្តរបស់ទូលបង្គំដ៏អស្ចារ្យចំពោះបុណ្យកុសលរបស់ព្រះអង្គទើបធ្វើឱ្យសេចក្ដី

សង្ឃឹមរបស់ទូលបង្គំចំពោះព្រះអង្គបានរស់ឡើងវិញហើយចំណែកឯនិស្ស័យរបស់ទូលបង្គំដែលព្រះអង្គបានភ្ជាប់យ៉ាងក្រាស់ក្រែលជាមួយនឹងទូលបង្គំនោះបានធ្វើឱ្យទូលបង្គំមានចិត្តក្លាហានលើកសរសើរព្រះអង្គហើយព្រមទាំងធ្វើឱ្យទូលបង្គំហ៊ានបួងសួងសុំព្រះអង្គនូវរបស់ដែលព្រះអង្គមាន។

ឱព្រះរបស់ទូលបង្គំលោកអើយ ទូលបង្គំសូមអង្វរព្រះអង្គតាមរយៈមេត្តាធម៌របស់ព្រះអង្គ ដែលព្រះអង្គបានបង្កើតរបស់គ្រប់យ៉ាង ហើយរបស់គ្រប់យ៉ាងទាំងនោះត្រូវបានគេដាក់ត្រាំឱ្យនៅក្រោមមហាសាគររបស់ព្រះអង្គ ជា សក្ខីភាពដូច្នេះសូមព្រះអង្គកុំបោះបង់ទូលបង្គំឱ្យនៅខ្លួនទី ពឹងខ្លួនឯងឡើយព្រោះបេះដូងរបស់ទូលបង្គំឆាប់ទៅរក ផ្លូវខុសងាយណាស់។ នៅពេលនេះសូមព្រះអង្គការពារទូលបង្គំឱ្យស្ថិតនៅក្នុងតំបន់ការពារដ៏រឹងមាំនៃសេចក្តីការពាររបស់ព្រះអង្គ ហើយនិងទីជម្រកនៃសេចក្តីថៃទាំរបស់ព្រះ អង្គផង។ ឱព្រះរបស់ទូលបង្គំលោកអើយ ទូលបង្គំគឺជាមនុស្សម្នាក់ដែលចង់បានរបស់ដែលព្រះអង្គបានឆ្លុះបំភ្លឺដោយកម្លាំងអំណាចនៃបុណ្យបារមីរបស់ព្រះអង្គតែ ប៉ុណ្ណោះ។ របស់គ្រប់យ៉ាងដែលទូលបង្គំបានជ្រើសរើសសម្រាប់ខ្លួនឯងនោះគឺសូមឱ្យគេជួយជ្រោមជ្រែងដោយការចាត់ចែងប្រកបដោយមនុញ្ញភាពរបស់ព្រះអង្គ និងគោរព

តាមឆន្ទៈរបស់ព្រះអង្គ ហើយនិងសូមឱ្យគេជួយឧបត្ថម្ភគាំទ្រដោយភស្តុតាងជានិមិត្តរូបនៃក្រិត្យ និងការវិនិច្ឆ័យរបស់ព្រះអង្គ។

ឱព្រះអង្គដែលជាព្រះជាទីស្រលាញ់របស់បេះដូងមនុស្សដែលត្រូវការព្រះអង្គអើយ ទូលបង្គំសូមអង្វរព្រះអង្គតាមរយៈព្រះសាស្តានៃបុព្វហេតុសាសនានិងប្រភពរីករាយដែលកើតចេញមកពីប្រភពដង្ហើមរបស់ព្រះអង្គនិងតាមរយៈអ្នកពន្យល់ពីភាពសម្ងើមអស្ចារ្យរបស់ព្រះអង្គ ហើយនិងតាមរយៈរតនាគារនៃចំណេះដឹងរបស់ព្រះអង្គ សូមព្រះអង្គកុំឱ្យគេដកហូតយកទីលំនៅស្ថានស័ក្តិសិទ្ធិរបស់ព្រះអង្គ ទីជម្រករបស់ព្រះអង្គ និងអាសនៈរបស់ព្រះអង្គពីទូលបង្គំដែលជាដើមចមធ្វើឱ្យទូលបង្គំឈឺចាប់ឡើយ។ ឱព្រះម្ចាស់របស់ទូលបង្គំលោកអើយ សូមព្រះអង្គជួយឧបត្ថម្ភគាំទ្រឱ្យទូលបង្គំបានទទួលព្រះរាជវាំងស័ក្តសិទ្ធិរបស់ទ្រង់ដែលព្រះសាស្តារបស់ព្រះអង្គនិងបាននៅក្នុងរង្វង់មនុស្សរបស់ទ្រង់ព្រមទាំងបានឈរយ៉ាងបន្ទាបខ្លួនទៅឯទ្វាររបស់ទ្រង់ផងដែរ។ ព្រះអង្គគឺជាទ្រង់ដែលអំណាចរបស់ទ្រង់កើតចេញមកពីអំណាចអមតៈលើអំណាចអមតៈ។របស់គ្រប់យ៉ាងនៅក្រោមការយល់ដឹងរបស់ព្រះអង្គ គ្មានរបស់ណាមួយគេចរួចពីការយល់ដឹងរបស់ព្រះអង្គបានឡើយ។ ពិតណាស់ ព្រះអង្គគឺជា

ព្រះដែលមានអំណាច ជាព្រះដែលមានភាពរុងរឿង និងជាព្រះដែលមានគតិបណ្ឌិតគ្មានគូប្រៀប។ ព្រះអង្គគឺជាព្រះជាម្ចាស់របស់ពិភពគ្រប់ពិភពដ៏ខ្ពង់ខ្ពស់!

-ព្រះបាហាអ៊ុលឡាហ៍-

ឱព្រះរបស់ទូលបង្គំ និងជាព្រះរបស់វត្ថុគ្រប់យ៉ាងជាភាពរុងរឿងរបស់ទូលបង្គំនិងជាភាពរុងរឿងរបស់វត្ថុគ្រប់យ៉ាង ជាទីប្រាថ្នារបស់ទូលបង្គំនិងជាទីប្រាថ្នារបស់វត្ថុគ្រប់ យ៉ាង ជាកម្លាំងរបស់ទូលបង្គំនិងជាកម្លាំងរបស់វត្ថុគ្រប់ យ៉ាង ជាមហារាជរបស់ទូលបង្គំ និងមហារាជរបស់វត្ថុគ្រប់យ៉ាងជាម្ចាស់របស់វត្ថុគ្រប់យ៉ាងជាបំណងរបស់ទូលបង្គំនិងជាបំណងរបស់វត្ថុគ្រប់យ៉ាងជាអ្នកកំចាត់វិបត្តិរបស់ទូលបង្គំ និងជាអ្នកកំចាត់វិបត្តិរបស់វត្ថុគ្រប់យ៉ាងអើយ! ទូលបង្គំអង្វរព្រះអង្គសូមទ្រង់កុំឱ្យទូលបង្គំឈឺចាប់ដែលកើតមកពីការដកមហាសាគរនៃមេត្តាធមិជាទីស្រលាញ់របស់ព្រះអង្គចេញពីទូលបង្គំនិងសូមព្រះអង្គកុំដកទូលបង្គំឱ្យនៅឆ្ងាយពីមហាសមុទ្រនៃភាពនៅជិតនិងព្រះអង្គ។

ឱព្រះរបស់ទូលបង្គំលោកអើយសូមព្រះអង្គកុំឱ្យទូលបង្គំគិតពីអ្វីក្រៅពីព្រះអង្គ និងសូមកុំឱ្យទូលបង្គំទៅជិតនឹងនរណាក្រៅពីព្រះអង្គដែលនាំឱ្យទូលបង្គំខាតបង់ប្រយោជន៍ពីព្រះអង្គ។ ទូលបង្គំអង្វរព្រះអង្គតាមរយៈភាពសម្បូណ៌បែបនៃភោគទ្រព្យរបស់ព្រះអង្គ ដោយហេតុនេះសូមព្រះអង្គកុំឱ្យទូលបង្គំជំពាក់ចិត្តនឹងរបស់ផ្សេងៗក្រៅពីរបស់ព្រះអង្គ សូមព្រះអង្គដាក់ឱ្យទូលបង្គំបាននៅនឹងលេខរៀងជាមួយនឹងអ្នកទាំងឡាយដែលបានភ្ជាប់មុខរបស់ពួកគេឆ្ពោះទៅរកព្រះអង្គព្រមទាំងបានងើបឡើងដើម្បីបំរើព្រះអង្គ។ ឱព្រះរបស់ទូលបង្គំលោកអើយ នៅពេលនេះសូមព្រះអង្គលើកលែងទោសឱ្យអ្នកបម្រើរបស់ព្រះអង្គ និងទាសីស្រីបម្រើរបស់ព្រះអង្គផង។ ពិតណាស់ព្រះអង្គគឺជាព្រះលើកលែងទោសជាអមតៈ និងជាព្រះប្រកបដោយក្តីអាណិត អាសូរ។

-ព្រះបាហាអ៊ុលឡាហ៍-

ឱព្រះរបស់ពួកទូលបង្គំលោកអើយ!សូមព្រះអង្គឃុំគ្រងពួកយើងតាមរយៈមនុញ្ញភាពរបស់ព្រះអង្គ ដើម្បីឱ្យពួកយើងបានរួចផុតពីអ្វីដែលជាទីស្អប់ខ្ពើមចំពោះ ព្រះអង្គ និងសូមព្រះអង្គប្រទានឱ្យពួកយើងនូវអ្វីដែលជាទីគាប់ប្រសើរចំពោះព្រះអង្គ។ សូមព្រះអង្គប្រទានបុណ្យ

កុសលនិងសព្វសាធុការពរឱ្យបានដល់ពួកយើងកាន់តែច្រើនឡើងថែមទៀត។ សូមព្រះអង្គអភ័យទោសឱ្យពួកយើងនូវរឿងរ៉ាវទាំងឡាយដែលពួកយើងបានធ្វើ និងសូមព្រះអង្គលុបលាងបាបរបស់ពួកយើង ព្រមទាំងលើកលែងទោសឱ្យពួកយើងដោយការលើកលែងទោស ដែលប្រកបដោយមនុញ្ញភាពរបស់ព្រះអង្គផង។ ពិតណាស់ព្រះអង្គគឺជាព្រះដ៏ខ្ពង់ខ្ពស់បំផុតនិងជាព្រះគង់នៅដោយអង្គឯង។

ទិព្វវិញ្ញាណជាទីស្រលាញ់របស់ព្រះអង្គបានបញ្ចូលឱ្យមានដល់គ្រប់វត្ថុដែលបានបង្កើតនៅក្នុងឋានសួគ៌ ហើយនិងនៅលើផែនដី ចំណែកឯការលើកលែងទោសរបស់ព្រះអង្គបានធ្វើឱ្យមានលើសលុបដល់មាបនម្មទាំងមូល។ ការលើកលែងទោសរបស់ព្រះអង្គ គឺជាអធិបតេយ្យភាពរបស់ព្រះ អង្គ។ នៅក្នុងព្រះហស្តរបស់ព្រះអង្គគឺជារាជាណាចក្រនៃមាបនកម្មនិងជាការត្រាស់ដឹងរបស់ព្រះអង្គ។ នៅក្នុងព្រះហស្តស្តាំរបស់ព្រះអង្គ ព្រះអង្គបានបង្ហាញរបស់គ្រប់យ៉ាងដែលព្រះអង្គបានបង្កើតហើយនៅក្នុងការយល់ដឹងរបស់ព្រះអង្គគឺជាទំហំនៃការលើកលែងទោសដែលគេបានកំណត់។ នរណាក៏ដោយឱ្យតែនៅក្នុងចំណោមអ្នកបម្រើរបស់ព្រះ

អង្គដែលព្រះអង្គសព្វព្រះហឫទ័យនោះ សូមព្រះអង្គលើកលែងទោសឱ្យពួកគេផង។ ពិតណាស់ព្រះអង្គគឺជាព្រះលើកលែងទោសជាអមតៈ និងជាព្រះប្រកបដោយក្ដីស្រលាញ់គ្រប់យ៉ាង។ គ្មានអ្វីមួយអាចគេចរួចពីការដឹងរបស់ព្រះអង្គបានឡើយ ហើយក៏គ្មានអ្វីដែលត្រូវបានគេលាក់បំបាំងនឹងព្រះអង្គបានដែរ។

ឱព្រះរបស់ពួកទូលបង្គំលោកអើយ!សូមព្រះ អង្គការពារពួកយើងតាមរយៈអំណាចនៃឫទ្ធីចេស្ដារបស់ ព្រះអង្គ សូមព្រះអង្គធ្វើឱ្យទូលបង្គំបានចូលទៅកាន់មហាសាគរដែលកំពុងតែខ្ជោលឡើងដ៏អស្ចារ្យហើយនិងសូមព្រះអង្គប្រទានឱ្យពួកយើងនូវអ្វីដែលល្អសមគាប់ព្រះទ័យព្រះអង្គផង។ព្រះអង្គគឺជាអ្នកគ្រប់គ្រងដែលប្រកបដោយអធិបតេយ្យភាពជាទ្វារដែលប្រកបដោយឫទ្ធីចេស្ដាជាព្រះប្រកបដោយភាពខ្ពង់ខ្ពស់និងជាព្រះប្រកបដោយក្ដីស្រលាញ់គ្រប់យ៉ាង។

-ព្រះបប-

ឱព្រះរបស់ទូលបង្គំលោកអើយ ទូលបង្គំសូមអង្វរឱ្យព្រះអង្គលើកលែងទោសឱ្យទូលបង្គំនូវគ្រប់ការពោលពាក្យក្រៅពីការពោលពីព្រះអង្គ នូវគ្រប់ការលើកតម្កើងក្រៅពីការលើកតម្កើងពីព្រះអង្គ នូវគ្រប់សេចក្តីសប្បាយក្នុងការនៅជិតព្រះអង្គ នូវគ្រប់ការរីករាយក្រៅពីការរីករាយនឹងទំនាក់ទំនងជាមួយនឹងព្រះអង្គ នូវគ្រប់វត្ថុដែលស៊ីគ្នានឹងទូលបង្គំ ប៉ុន្តែមិនមានសម្ព័ន្ធភាពនឹងព្រះអង្គពិតណាស់ព្រះអង្គគឺជាព្រះលើព្រះ ព្រះអង្គគឺជាអ្នកផ្តល់មធ្យោបាយនិងជាអ្នកបើកសោទ្វារ។

-ព្រះបប-

ឱព្រះលោកអើយ ព្រះអង្គជាព្រះប្រកប ដោយភាពរុងរឿង។ តើទូលបង្គំអាចពោលពីព្រះអង្គតាម របៀបណា បើព្រះអង្គមានភាពបរិសុទ្ធពីការលើកតម្កើងពីមនុស្សជាតិគ្រប់គ្នាហើយនោះ។ ឱព្រះលោកអើយ ព្រះនាមរបស់ព្រះអង្គមានភាពប្រសើរលើសលុបណាស់ព្រះអង្គគឺជាស្តេចអធិរាជជាសច្ចភាពជាអនន្តព្រះអង្គស្វែងយល់អ្វីៗគ្រប់យ៉ាងនៅក្នុងឋានសួគ៌និងនៅលើផែនដីហើយរបស់អស់ទាំ

ងនោះត្រូវតែវិលត្រឡប់មករកព្រះអង្គវិញ។ ព្រះអង្គបានបញ្ជាន់ចុះមកនូវការត្រាស់ដឹងដែលបានកំណត់យ៉ាងល្អឥតខ្ចោះដែលអនុលោមទៅតាមវិធានការច្បាស់លាស់ របស់ព្រះអង្គ។ ឱព្រះលោកអើយ ព្រះអង្គជាព្រះ គួរឱ្យគេសរសើរខ្លាំងណាស់! តាមរយៈបាហានិករបស់ឋាន សួគ៌និងផែនដី ហើយនិងអ្វីក៏ដោយឱ្យតែនៅចន្លោះពួកវា នោះបើយោងទៅតាមពាក្យបណ្ដាំរបស់ព្រះអង្គថាព្រះអង្គនឹងប្រទានជ័យជំនះឱ្យវិញ បើទោះអ្នកនោះជានរណាក៏ដោយឱ្យតែព្រះអង្គសព្វព្រះហឫទ័យ។ ពិតណាស់ព្រះអង្គគឺជាព្រះមានអធិបតេយ្យភាពជាសច្ចភាពជាអនន្ត ជាព្រះមានមហិទ្ធីឫទ្ធិមិនចេះចាញ់។

ឱព្រះលោកអើយព្រះអង្គគឺជាព្រះប្រកបដោយភាពរុងរឿង!ព្រះអង្គនឹងលើកលែងទោសគ្រប់ពេលនូវបាបកម្មទាំងឡាយរបស់អ្នកបម្រើរបស់ព្រះអង្គដែលអង្វរសុំការអភ័យទោសរបស់ព្រះអង្គ។ សូមព្រះអង្គលុបលាងបាបកម្មរបស់ទូលបង្គំ និងបាបកម្មរបស់អ្នកទាំងឡាយណាដែលស្វែងរកការលើកលែងទោសរបស់ព្រះអង្គនាគ្រាដំបូង សូមព្រះអង្គលុបលាងបាបកម្មរបស់អ្នកទាំងឡាយណាដែលសូត្រធម៌បួងសួងដល់ព្រះអង្គទាំងយប់ទាំងថ្ងៃ សូមព្រះអង្គលុបលាងបាបកម្មរបស់អ្នកទាំងឡាយណាដែលមិនចង់បា

នអ្វីក្រៅពីព្រះអង្គ សូមព្រះអង្គលុបលាងបាបកម្មរបស់អ្នកទាំងឡាយណាដែលទទួលយកអ្វីគ្រប់យ៉ាងដែលព្រះបានប្រទានមកដល់ពួកគេយ៉ាងទន់ភ្លន់សូមព្រះអង្គលុបលាងបាបកម្មរបស់អ្នកទាំងឡាយណា ដែលប្រារព្ធការលើកតម្កើងរបស់ព្រះអង្គនាពេលព្រឹកនិងល្ងាចហើយនិងសូមព្រះអង្គលុបលាងបាបកម្មរបស់អ្នកទាំងឡាយណាដែលយកចិត្តទុកដាក់ចំពោះករណីយកិច្ចរបស់ពួកគេផង។ -ព្រះបប-

ឱព្រះលោកអើយ ទូលបង្គំដឹងហើយថាការប្រព្រឹត្តិខុសរបស់ទូលបង្គំបានគ្របដណ្តប់មុខរបស់ទូលបង្គំដោយក្តីអាម៉ាស់ចំពោះវត្តមានរបស់ព្រះអង្គ ការប្រព្រឹត្តិខុសរបស់ទូលបង្គំបានដាក់បន្ទុកដ៏ធ្ងន់នៅលើខ្នងរបស់ទូលបង្គំនៅចំពោះព្រះភក្ត្ររបស់ព្រះអង្គ ការប្រព្រឹត្តិខុសរបស់ទូលបង្គំបានធ្វើអន្តរាគមន៍នៅចន្លោះទូលបង្គំ និងការសរសើរកម្លាំងចិត្តដ៏ស្អាតស្អំរបស់ព្រះអង្គ ការប្រព្រឹត្តិខុសរបស់ទូលបង្គំបានរួមបញ្ចូលទូលបង្គំពីគ្រប់ទិសដៅ ហើយការប្រព្រឹត្តិខុសរបស់ទូលបង្គំបានរារាំងទូលបង្គំមិនឱ្យទូលបង្គំបានចូលទៅដល់ការត្រាស់ដឹងពីអំណាចទិព្វរបស់ព្រះអង្គឡើយ

ឱព្រះលោកអើយ! បើព្រះអង្គមិនលើកលែងទោសឱ្យទូលបង្គំទេនោះ តើមាននរណាជាអ្នកប្រទានការអភ័យទោសឱ្យទូលបង្គំបាននៅពេលនេះ ហើយបើព្រះអង្គមិនមានមេត្តាធម៌ចំពោះទូលបង្គំទេនោះ តើនរណាអាចមានលទ្ធភាពបង្ហាញពីសេចក្តីករុណាបាន? ព្រះអង្គជាព្រះមានភាពរុងរឿងព្រះអង្គបានបង្កើតទូលបង្គំកាលដែលទូលបង្គំនៅមិនទាន់មានជីវិត ហើយព្រះអង្គក៏បានចិញ្ចឹមនិងបង្រៀនទូលបង្គំនៅខណៈពេលដែលទូលបង្គំនៅមិនទាន់ដឹងក្តីអ្វីបន្តិចសោះនោះ។ ពិតណាស់ព្រះអង្គជាព្រះគួរឱ្យគេសរសើរខ្លាំងណាស់ គ្រប់សញ្ញាដែលបង្ហាញឱ្យឃើញពីបុណ្យនោះសុទ្ធតែបណ្តាលមកពីព្រះអង្គហើយនិងបណ្តាលមកពីគ្រប់និមិត្តរូបនៃមនុញ្ញភាពដែលភាយចេញមកពីរតនគារនៃក្រិត្យរបស់ព្រះអង្គ។

-ព្រះបប-

ឱព្រះអង្គដែលជាព្រះលើកលែងទោសអើយ!ព្រះអង្គ

គឺជាទីជម្រកគ្រប់អ្នកបម្រើរបស់ព្រះអង្គទាំងអស់នេះ។ ព្រះអង្គទ្រង់ជាអ្នកឈ្វេងយល់ដល់អាថ៌កំបាំងគ្រប់យ៉ាងនិងជាអ្នក

ដឹងពីវត្ថុគ្រប់យ៉ាង។ ពួកយើងទាំងអស់គ្នាជាអ្នកតែលតោលគ្មានលំនឹង ចំណែកឯព្រះអង្គវិញជាព្រះប្រកបដោយឫទ្ធីចេស្តានិងជាព្រះប្រកបដោយអំណាចខ្លាំងអស្ចារ្យ ពួកយើងទាំងអស់គ្នាជាអ្នកមានបាប ចំណែកឯព្រះអង្គវិញជាអ្នកលើកលែងទោសលោះបាបកម្ម ព្រះអង្គគឺជាព្រះប្រកបដោយមេត្តាធម៌ និងជាព្រះប្រកបដោយក្ដីអាណិត អាសូរ។ ឱព្រះម្ចាស់លោកអើយ! សូមព្រះអង្គកុំទតមើលគុណវិបត្តិរបស់ពួកទូលបង្គំ។ សូមព្រះអង្គបង្កើតទំនាក់ទំនងជាមួយនឹងពួកយើងដោយពឹងទៅលើមនុញ្ញភាព និងបុណ្យរបស់ព្រះអង្គ។ ពួកយើងជាអ្នកមានគុណវិបត្តិច្រើន ណាស់ប៉ុន្តែមហាសាគរនៃការលើកលែងទោសរបស់ព្រះអង្គគឺមានច្រើនរាប់មិនអស់។ ពួកយើងជាអ្នកមានភាពទន់ខ្សោយដោយភាពទុក្ខព្រួយប៉ុន្តែជំនួយឧបត្ថម្ភ និងការទ្រទ្រង់របស់ព្រះអង្គបង្ហាញភស្តុតាងយ៉ាងច្បាស់។ ដូច្នេះសូមព្រះអង្គទទួលយកការបួងសួងសុំនិងពង្រឹងឱ្យពួកយើងបានរឹងមាំឡើងផង។ សូមព្រះអង្គញ៉ាំងឱ្យទូលបង្គំយើងខ្ញុំបានធ្វើអ្វីដែលជាទីគាប់ចិត្តដែលមានតម្លៃដល់ធរណីទ្វារសក្តិសិទ្ធិរបស់ព្រះអង្គ។ សូមព្រះអង្គឆ្លុះបំភ្លឺដួងចិត្តរបស់ពួកទូលបង្គំនិងសូមព្រះអង្គប្រទានឱ្យពួកទូលបង្គំនូវចក្ខុដែលយកចិត្តទុដាក់មើលនិងសោតដែលយកចិត្តទុកដាក់

ស្តាប់ផង។ សូមព្រះអង្គប្រោះអ្នកដែលស្លាប់វិញ្ញាណ និង សូមព្រះអង្គព្យាបាលអ្នកដែលមានជម្ងឺវិញ្ញាណឱ្យរស់ និង ជាសះស្បើយឡើងវិញផង។ សូមព្រះអង្គប្រទានទ្រព្យសម្បត្តិមកដល់អ្នកក្រីក្រ និងផ្តល់សន្តិភាពនិងសន្តិសុខឱ្យដល់ពួកគេបាត់ភ័យខ្លាចផង។ សូមព្រះអង្គទទួលពួកយើងឱ្យបាននៅក្នុងរាជាណាចក្ររបស់ព្រះអង្គ និងសូមព្រះអង្គឆ្លុះបំភ្លឺពន្លឺនៃការដឹកនាំបង្ហាញផ្លូវឱ្យដល់ពួកយើងផង។ព្រះអង្គគឺជាព្រះដែលប្រកបដោយសព្វានុភាពនិងអំណាចដ៏ខ្លាំងក្លាអស្ចារ្យ។ ព្រះអង្គគឺជាព្រះប្រកបដោយមនុញ្ញភាព។ ព្រះអង្គជាព្រះប្រកបដោយក្តីត្រាប្រណី។ ព្រះអង្គគឺជាព្រះប្រកបដោយព្រះទ័យល្អគ្មានគូប្រៀប។

-អង្គពិសិដ្ឋអាប់ឌុលបាហា-

* * * * *

ធម៌សូត្រពេលព្រឹក

បពិត្រព្រះរបស់ទូលបង្គំ និងជាម្ចាស់របស់ទូលបង្គំ លោកអើយ! ទូលបង្គំជាអ្នកបម្រើរបស់ព្រះអង្គហើយក៏ជា បុត្រានៃអ្នកបម្រើរបស់ព្រះអង្គដែរ។ ទូលបង្គំបានងើបពីដំណេករបស់ទូលបង្គំនាព្រឹកព្រលឹមនេះ នៅចំពេលដែលតារាប្រចាំភពតែមួយរបស់ទ្រង់បានបញ្ចាំងពីប្រភពរីករាយនៃឆន្ទៈរបស់ព្រះអង្គ ហើយនិងនៅចំពេលដែលទ្រង់បានសំរក់នូវភាពពន្លឺប្រិមប្រិយរបស់វាមកលើពិភពលោកទាំងមូល ដែលអនុលោមទៅតាមអ្វីដែលត្រូវបានគេកំណត់នៅក្នុង គម្ពីរនៃក្រិត្យរបស់ព្រះអង្គ។

ឱព្រះម្ចាស់របស់ទូលបង្គំលោកអើយ ព្រះអង្គគឺជាព្រះគួរឱ្យសរសើរ ចំណែកឯពួកទូលបង្គំទាំងអស់គ្នានេះបាន

ភ្ញាក់ពីដំណេកមកនេះដោយសារតែពន្លឺនៃភាពរុងរឿងនៃ

ចំណេះដឹងរបស់ព្រះអង្គ។ ឱព្រះម្ចាស់របស់ទូលបង្គំលោកអើយនៅពេលនេះសូមព្រះអង្គបញ្ជូនពន្លឺនៃភាពរុងរឿងនៃចំណេះដឹងរបស់ព្រះអង្គឱ្យបានមកដល់ពួកយើងដើម្បីកុំឱ្យ

ពួកយើងត្រូវការនរណាក្រៅពីព្រះអង្គឡើយ ហើយក៏សូមព្រះអង្គកំចាត់គ្រប់វត្ថុលោកិយដែលធ្វើឱ្យពួកយើងជំពាក់ចិត្តនឹងវាលើកលែងតែរបស់ព្រះអង្គ។ ម៉្យាងវិញទៀត សូមព្រះអង្គកត់ត្រាទុកនូវអំពើល្អដែលជាប្រយោជន៍ដល់ពិភពនេះនិងពិភពខាងមុខឱ្យទូលបង្គំនិងអ្នកដែលជាទីស្រលាញ់ចំពោះទូលបង្គំនិងញាតិមិត្តប្រុសស្រីរបស់ទូលបង្គំស្មើៗគ្នាផង។ឱព្រះម្ចាស់លោកអើយព្រះអង្គគឺជាព្រះជាទីស្រលាញ់របស់មាបនម្នទាំងអស់ ហើយនិងជាទីប្រាថ្នារបស់ពិភពលោកទាំងមូលនៅពេលនេះសូមព្រះអង្គបីបាច់រក្សាការពារពួកទូលបង្គំទាំងអស់គ្នាតាមរយៈកំណារការពារដែលមិនចេះចាញ់របស់ព្រះអង្គឱ្យពួកយើងមានសុវត្ថិភាពពីអ្នកទាំងឡាយដែលព្រះអង្គបានបកអាក្រាតពីអ្នករអេចរអូចគ្មានសីលធមិជាអ្នកខ្សឹបខ្សៀវក្នុងចិត្តរបស់មនុស្ស។ ព្រះអង្គគឺជាព្រះប្រកបដោយអំណាចអាចធ្វើឱ្យសេចក្តីរីករាយរបស់ព្រះអង្គកើតមានឡើងគ្រប់ទីកន្លែងបាន។ ពិតណាស់ព្រះអង្គគឺជាព្រះប្រកបដោយមហិទ្ធិឫទ្ធិជាព្រះជួយសង្គ្រោះឱ្យរួចផុតពីគ្រោះថ្នាក់និងជាព្រះគង់នៅដោយអង្គឯង។

ឱព្រះដែលជាម្ចាស់របស់ទូលបង្គំលោកអើយ សូម ព្រះអង្គប្រទានពរឱ្យព្រះសាស្ដាដែលព្រះអង្គបានបំពាក់ ឋានៈដ៏ប្រពៃបំផុតរបស់ព្រះអង្គដែលតាមរយៈព្រះសាស្ដា

អង្គនោះព្រះអង្គបានបែងចែកសម្រាប់អ្នកជំនឿស៊ប់ក្នុង

សាសនានិងអ្នកកំណាចហើយព្រះអង្គបានជួយពួកយើង

ដោយមេត្តាដើម្បីឱ្យពួកយើងធ្វើអ្វីៗដែលព្រះអង្គសព្វព្រះទ័យនិងក្ដី ប្រាថ្នា។ ឱព្រះរបស់ទូលបង្គំលោកអើយ ម៉្យាង វិញទៀត សូមព្រះអង្គប្រទានពរឱ្យដល់អ្នកទាំងឡាយណា ដែលជាអ្នកនាំបន្ទូលរបស់ព្រះអង្គ និងជាអ្នកនាំចុតហ្មាយ របស់ព្រះអង្គ ហើយនិងអ្នកទាំងឡាយណាដែលបានងើប មុខរបស់ពួកគេឆ្ពោះទៅរកព្រះអង្គ និងអ្នកទាំងឡាយណា ដែលបានងាកមុខរបស់ពួកគេឆ្ពោះទៅរកព្រះភក្ត្ររបស់ ព្រះអង្គ ហើយនិងអ្នកទាំងឡាយណាដែលបានស្ដាប់ទៅនឹង ការអំពាវនាវរបស់ព្រះអង្គ។

ពិតណាស់ព្រះអង្គគឺជាព្រះហើយក៏ជាស្ដេចរបស់ មនុស្សគ្រប់គ្នា ហើយក៏ជាព្រះដែលមានអំណាចលើវត្ថុគ្រប់ យ៉ាងផងដែរ។

-ព្រះបាហាអ៊ុលឡាហ៍-

ឱព្រះម្ចាស់របស់ទូលបង្គំលោកអើយ ទូលបង្គំបានភ្ញាក់ពីដំណេកឡើងមកនេះនៅក្នុងទីជម្រករបស់ព្រះអង្គ ហើយវានោះគឺជាទីជម្រកដែលស័ក្តសមនឹងមនុស្សណា ដែលបានស្វែងរកវាដើម្បីរស់នៅក្នុងបដិសរណដ្ឋាននៃកំណាារការពារ

របស់ព្រះអង្គហើយនិងតំបន់ការពារដ៏រឹងមាំនៃការថែរក្សារបស់ព្រះអង្គ។ ឱព្រះម្ចាស់របស់ទូលបង្គំលោកអើយ នៅពេលណាដែលព្រះអង្គបានឆ្លុះបំភ្លឺជីវិតរាងកាយរបស់ទូលបង្គំជាមួយនឹងពន្លឺអារុណនៃការអនុគ្រោះរបស់ព្រះអង្គ នោះសូមព្រះអង្គឆ្លុះបំភ្លឺជីវិតដួងចិត្តរបស់ទូលបង្គំជាមួយនឹងភាពរុងរឿងដែលកើតមកពីប្រភពរីករាយនៃការត្រាស់

ដឹងរបស់ព្រះអង្គផង។

-ព្រះបាហាអ៊ុលឡាហ៍-

* * * * *

ធមិស្ធូត្រពេលល្ងាច

ឱព្រះរបស់ទូលបង្គំជាម្ចាស់របស់ទូលបង្គំនឹងជាគោល
ដៅនៃក្តីប្រាថ្នារបស់ទូលបង្គំអើយ! អ្នកបម្រើរបស់ព្រះអង្គ ម្នាក់នេះ
បានព្យាយាមស្វែងរកដំណោកនៅក្នុងទីជំរកនៃ
មេត្តាធមិរបស់ព្រះអង្គនិងបានព្យាយាមស្វែងរកបង្អែកនៅ
ក្រោមបុស្បុកនៃមនុញ្ញភាពរបស់ព្រះអង្គព្រមទាំងកំពុងតែ
អង្វរករសុំទំហែទាំរបស់ព្រះអង្គនិងកំណាករការពាររបស់ព្រះអង្គ។
ឱព្រះរបស់ទូលបង្គំអើយ ទូលបង្គំសូមអង្វរព្រះអង្គ
តាមរយៈព្រះនេតរបស់ព្រះអង្គដែលមិនចេះដេកលង់លក់
សូមព្រះអង្គថាំឃ្លាំការពារចក្ខុទាំងទ្វេរបស់ទូលបង្គំ កុំឱ្យ
ទូលបង្គំមើលឃើញអ្វីក្រៅពីព្រះអង្គឡើយ។ បន្ទាប់មក
សូមព្រះអង្គពង្រឹងគំហើញរបស់វា ដើម្បីឱ្យពួកវាអាចមើល
ឃើញសញ្ញារបស់ព្រះអង្គ និងមើលឃើញនភាល័យនៃការ
ត្រាស់ដឹងរបស់ព្រះអង្គផង។ ព្រះអង្គគឺជាទ្រង់ដែលបង្ហាញ
ឱ្យឃើញពីខ្លឹមសារដែលមានអំណាចសព្វញ្ញុភាពរបស់ព្រះអង្គបាន
ធ្វើឱ្យញ័ររង្គើរមុនគេ។ ក្រៅពីព្រះអង្គគ្មានព្រះឯ ណាទៀតឡើយ
ព្រះអង្គគឺជាព្រះប្រកបដោយចេស្តាបារមី
ជាព្រះគ្រប់គ្រងលើរបស់គ្រប់យ៉ាងជាព្រះមានអំណាចខ្លាំងក្លាគ្មាន
កំណត់ព្រំដែន។

-ព្រះបាហាអ៊ុលឡាហ៍-

ឱព្រះជាព្រះរបស់ទូលបង្គំអើយតើឱ្យទូលបង្គំដេក
លក់ម្តេចនឹងកើត
បើនៅពេលនេះចក្ខ្ខ្ខ្ខ្ខ្ខ្ខ្ខ្ខ្ខ្ខ្ខ្ខ្ខ្ខ្ខុរបស់អ្នកដែលចង់
ឃើញព្រះអង្គដេកមិនលក់សោះ ព្រោះតែការបែកឃ្លាតរបស់ពួកគេពីព្រះអង្គហើយតើឱ្យទូលបង្គំអាចសម្រាកម្តេចនឹងកើត
បើនៅពេលនេះវិញ្ញាណក្ខន្ធរបស់អ្នកស្រលាញ់
របស់ព្រះអង្គកំពុងតែត្រូវបានគេធ្វើឱ្យរំខានដោយសារការឃ្លាតឆ្ងាយរបស់ពួកគេពីវត្តមានរបស់ព្រះអង្គ?

ឱព្រះរបស់ទូលបង្គំលោកអើយទូលបង្គំបានប្រតិបត្តិ
ចិត្តវិញ្ញាណរបស់ទូលបង្គំនិងរូបកាយទាំងមូលរបស់ទូលបង្គំ
នៅក្នុងព្រះហស្តស្តាំនៃអំណាចនិងកំណារការពាររបស់ព្រះអង្គ
ហើយទូលបង្គំក៏សូមដាក់ក្បាលរបស់ទូលបង្គំនៅលើ
ខ្នើយរបស់ទូលបង្គំតាមរយៈអំណាចរបស់ព្រះអង្គ ហើយទូលបង្គំសូមលើកវាឡើងមកដោយពឹងទៅលើឆន្ទៈ និងសិរីល្អរបស់ព្រះអង្គ។ ពិតណាស់ព្រះអង្គគឺជាអ្នកថែរក្សាជាអ្នក

ថ្ងៃទាំជាអ្នកមានឫទ្ធិអំណាចជាព្រះប្រកបដោយសព្វានុភាពបំផុត។

តាមអំណាចរបស់ព្រះអង្គ!ថាតើត្រូវដេកឬត្រូវភ្ញាក់ ពីដំណេកនោះទូលបង្គំមិនឆ្ងល់ឡើយព្រោះវាជាអ្វីៗដែល ព្រះអង្គបានធ្វើតាមសេចក្តីប្រាថ្នា។ ទូលបង្គំជាអ្នកបម្រើរបស់ព្រះអង្គ និងជាអ្នកនៅក្នុងព្រះហស្តរបស់ព្រះអង្គ។ សូមព្រះអង្គជួយឱ្យទូលបង្គំ ដោយព្រះទ័យមេត្តាដើម្បីឱ្យទូលបង្គំបានធ្វើអ្វីដែលនឹងបានបង្ហូរក្លិនពិដោរនៃសិរីល្អរបស់ព្រះអង្គផង។ ពិតណាស់នេះជាសេចក្តីសង្ឃឹមរបស់ទូលបង្គំ និងសេចក្តីសង្ឃឹមដែលកើតចេញមកពីសេចក្តីសប្បាយ ដែលពួកគេបានចូលទៅជិតព្រះអង្គ។ ឱព្រះរបស់ពិភពទាំងឡាយអើយ ព្រះអង្គគឺជាព្រះដ៏ខ្ពង់ខ្ពស់បំផុត!

-ព្រះបាហាអ៊ុលឡាហ៍-

* * * * *

ធមិសូត្រពេលពាក់កណ្តាលអាធ្រាត

ឱអ្នកស្វែងរកសច្ចធម៌អើយ! បើអ្នកចង់ឱ្យព្រះបើកភ្នែកឱ្យអ្នក អ្នកត្រូវតែធ្វើការអង្វរករចំពោះព្រះដោយ

ស្ងូត្រទៅកាន់និងទាក់ទងវិញ្ញាណជាមួយព្រះអង្គនៅពេល

ពាក់កណ្ដាលរាត្រីដោយពោលថាៈ

ឱព្រះលោកអើយ ទូលបង្គំបានងាកភក្ត្ររបស់ទូលបង្គំឆ្ពោះទៅកាន់រាជាណាចក្រនៃភាពតែមួយរបស់ព្រះអង្គហើយព្រមទាំងត្រូវបានគេឱ្យត្រាំនៅក្នុងមហាសាគរនៃក្ដីមេត្តាធម៌របស់ព្រះអង្គផងដែរ។ ឱព្រះលោកអើយ សូមព្រះអង្គបំភ្លឺចក្ខុវិស័យរបស់ទូលបង្គំឱ្យបានឃើញពន្លឺរបស់ព្រះអង្គនៅក្នុងរាត្រីដ៏ងងឹតនេះ ហើយសូមព្រះអង្គធ្វើឱ្យទូលបង្គំបានសប្បាយ ដោយទឹកអម្រឹតនៃក្ដីស្រលាញ់របស់ព្រះអង្គនៅក្នុងយុគសម័យដ៏អស្ចារ្យនេះផង។ ឱព្រះលោក អើយ សូមព្រះអង្គធ្វើឱ្យទូលបង្គំបានឮការស្រែកហៅរបស់ ព្រះអង្គ និងសូមព្រះអង្គបើកទ្វារឋានសួគ៌របស់ព្រះអង្គ ដែលនៅចំពីមុខរបស់ទូលបង្គំ ដើម្បីឱ្យទូលបង្គំអាចមើលឃើញពន្លឺនៃភាពរុងរឿងរបស់ព្រះអង្គ ហើយនិងដើម្បីឱ្យ

ទូលបង្គំបានទាក់ចិត្តជិតអារម្មណ៍នឹងសោភ័ណភាពរបស់ព្រះអង្គផង។

ពិតណាស់ព្រះអង្គគឺជាព្រះអ្នកប្រទានឱ្យនូវអ្វីៗគ្រប់យ៉ាងជាព្រះប្រកបដោយព្រះទ័យសប្បុរសធម៌ ជាព្រះប្រកបដោយមេត្តាធម៌ ជាព្រះអ្នកលើកលែងទោស។

-អង្គពិសិដ្ឋអាប់ឌុលបាហា-

* * * * *

ធម៌សូត្រសម្រាប់គ្រួសារ

ឱព្រះរបស់ទូលបង្គំអើយ ព្រះអង្គគឺជាព្រះមានភាពរុងរឿង!ទូលបង្គំសូមអង្វរសុំឱ្យព្រះអង្គលើកលែងទោសដល់ទូលបង្គំ និងលើកលែងទោសដល់អ្នកដែលទ្រទ្រង់សាសនារបស់ព្រះអង្គផង។ ពិតណាស់ព្រះអង្គគឺជាព្រះ

ប្រកបដោយអធិបតេយ្យភាព ជាព្រះលើកលែងទោស ជាព្រះប្រកបដោយព្រះទ័យមេត្តាបំផុត។ ឱព្រះរបស់ទូលបង្គំអើយសូមព្រះអង្គអនុញ្ញាតឱ្យអ្នកបម្រើរបស់ព្រះអង្គដែលខ្វះចំណេះដឹងទាំងនេះបានចូលទៅកាន់បុព្វហេតុសាសនារបស់ព្រះអង្គផងបើពួកគេបានរៀនពីព្រះអង្គតែម្តងនោះពួកគេប្រាកដជានឹងធ្វើជាសាក្សីចំពោះការកាត់សេចក្តីពីយុគសម័យសច្ចភាពនេះ ហើយប្រាកដជានឹងមិនប្រឆាំងនឹង

ការត្រាស់បញ្ចេញឱ្យឃើញពីសោភ័ណភាពរបស់ព្រះអង្គ

ឡើយ។ សូមព្រះអង្គបញ្ជូននិមិត្តរូបនៃមនុញ្ញភាពរបស់ព្រះអង្គឱ្យចុះមកដល់ពួកគេ បើទោះជាពួកគេនៅទីណាក៏ ដោយសូមព្រះអង្គប្រទានឱ្យពួកគេនូវចំណែកដ៏សប្បុរសនៃរបស់ដែលព្រះអង្គបានដាក់កំណត់ក្រិត្យឱ្យអ្នកបម្រើដែលមានជំនឿស៊ប់របស់ព្រះអង្គផង។ ពិតណាស់ព្រះអង្គគឺជាព្រះអ្នកគ្រប់គ្រងដ៏ឧត្តម ជាព្រះប្រកបដោយភាពត្រឹមត្រូវនិងជាព្រះប្រកបដោយមេត្តាធម៌បំផុត។

ឱព្រះរបស់ទូលបង្គំអើយ! សូមព្រះអង្គអនុញ្ញាតឱ្យការទោរទន់ចិត្តដែលកើតមកពីព្រះទ័យសប្បុរសធម៌ និង

បុណ្យកុសលរបស់ព្រះអង្គបានជ្រាលចុះមកលើផ្ទះរបស់អ្នកដែលបានទទួលយកជំនឿរបស់ព្រះអង្គដែលចាត់ទុកជានិមិត្តរូបនៃមនុញ្ញភាពរបស់ព្រះអង្គ និងដែលចាត់ទុកជាសញ្ញានៃភាពសប្បុរសជាទីស្រលាញ់ដែលចេញមកពីវត្តមានរបស់ព្រះអង្គផង។ ពិតណាស់ព្រះអង្គគឺជាព្រះអ្នកប្រទាននូវការលើកលែងទោសដ៏ពិតប្រាកដ។ នៅពេលនេះបើផលបុណ្យរបស់ព្រះអង្គត្រូវបានគេដកហូតយកពីនរណាម្នាក់នោះ តើអ្នកនោះអាចត្រូវបានគេចាត់ទុកថាជាសាវកម្នាក់នៅក្នុងចំណោមសាវកទាំងអស់នៃជំនឿសាសនានៅក្នុងយុគសម័យរបស់ព្រះអង្គម្ដេចនឹងកើត។ឱព្រះរបស់ទូលបង្គំអើយសូមព្រះអង្គប្រទានបុណ្យឱ្យទូលបង្គំ និងអ្នកទាំងឡាយណាដែលនឹងជឿចំពោះសញ្ញារបស់ព្រះអង្គនាយុគសម័យដែលបានកំណត់ ហើយនិងអ្នកទាំងឡាយណាដែលបានចាត់ទុកសេចក្ដីស្រលាញ់ជាទីពេញចិត្តរបស់ទូលបង្គំនៅក្នុងដួងចិត្តរបស់ពួកគេដែលចាត់ទុកសេចក្ដីស្រលាញ់នោះថាជាសេចក្ដីស្រលាញ់ដែលព្រះអង្គបានដាំបណ្ដុះចំពោះពួក គេ។ ពិតណាស់ព្រះអង្គគឺជាព្រះនៃភាពត្រឹមត្រូវ ជាព្រះដ៏ខ្ពង់ខ្ពស់បំផុត។

-ព្រះបប-

* * * *

ធម៌សូត្រសម្រាប់មាតាបិតា

ឱព្រះរបស់ទូលបង្គំអើយ ទូលបង្គំអង្វរសុំការលើកលែងទោសរបស់ព្រះអង្គហើយទូលបង្គំក៏សុំអង្វរការអភ័យទោសទៅតាមនិស្ស័យដែលព្រះអង្គសព្វព្រះហឫទ័យប្រាថ្នាចង់ឱ្យអ្នកបម្រើរបស់ព្រះអង្គទាំងអស់ ចេះស្តាប់បង្គាប់ព្រះ

អង្គដោយខ្លួនឯង។ ទូលបង្គំសុំឱ្យព្រះអង្គជម្រះបាបរបស់ពួកយើងទាំងអស់គ្នាឱ្យអស់ស្រឡះពីពួកយើង ដើម្បីឱ្យពួកយើងសមជាអ្នកយកព្រះអង្គធ្វើជាម្ចាស់របស់ពួកយើង ហើយទូលបង្គំក៏សុំឱ្យព្រះអង្គលើកលែងទោសឱ្យទូលបង្គំឱ្យមាតាបិតារបស់ទូលបង្គំហើយនិងឱ្យដល់អ្នកទាំងឡាយណាដែលមានសេចក្តីគោរពចំពោះព្រះអង្គ ដែលបានចូលទៅកាន់ទីលំនៅនៃសេចក្តីស្រលាញ់របស់ព្រះអង្គ ដែលប្រកបដោយឫកពារថ្លៃថ្នូរដែលកើតចេញមកពីអធិតេយ្យភាពដ៏សំខាន់របស់ព្រះអង្គ និងភាពរុងរឿងដែលកើតចេញមកពីអំណាចទិព្វរបស់ព្រះអង្គដ៏ល្អបំផុតផងដែរ។

ឱព្រះរបស់ទូលបង្គំអើយ!សូមព្រះអង្គបំពេញបំណងប្រាថ្នាតាមការអង្វរសុំរបស់ទូលបង្គំចំពោះព្រះអង្គផង ទូលបង្គំមិនមានទីពឹងនរណាក្រៅពីព្រះអង្គឡើយ។ព្រះអង្គគឺជាព្រះគួរឱ្យគេសរសើរ ជាព្រះប្រកបដោយភាពរុងរឿង ទូលបង្គំបានលើកតម្កើងសរសើរព្រះអង្គ ដោយហេតុថាព្រះអង្គបានត្រាស់បញ្ចេញឱ្យទូលបង្គំ បានឃើញដោយអង្គឯងតាំងតែពីទូលបង្គំ បានធ្លាក់ចូលទៅក្នុងវិបត្តិក្នុងករណីយកិច្ចដើម្បីស្គាល់ព្រះអង្គ ហើយតាំងតែពីទូលបង្គំខកខានមិនបាន

ធ្វើដំណើរតាមមាគ៌ានៃក្ដីស្រលាញ់របស់ព្រះអង្គ ដូច្នេះ ហើយទូលបង្គំសុំឱ្យព្រះអង្គលើកលែងទោសឱ្យទូលបង្គំផង

-ព្រះបប-

ឱព្រះលោកអើយ!ចំពោះការលើកលែងទោស ដ៏ធំអស្ចារ្យបំផុតរបស់ព្រះអង្គនេះ សូមព្រះអង្គទទួលយក នូវការសុំទោសរបស់កូនជំនួសមាតាបិតារបស់ពួកគេ។ នេះ គឺជាអំណោយដ៏ធំពិសេសមួយក្នុងចំណោមអំណោយទាំង ឡាយនៃការលើកលែងទោសនេះ។ ឱព្រះអង្គដែលជាព្រះ មានព្រះទ័យសប្បុរសអើយ បើដូច្នេះសូមព្រះអង្គទទួល យកនូវការបួងសួងសុំរបស់អ្នកបម្រើរបស់ព្រះអង្គម្នាក់នេះដែលនៅ ឯធរណីទ្វារនៃភាពស្មោះត្រង់របស់ព្រះអង្គ ហើយ សូមព្រះអង្គដាក់ឱ្យឪពុករបស់គាត់បានត្រាំនៅក្នុងមហាសាគរនៃម នុញ្ញភាពរបស់ព្រះអង្គផង ព្រោះបុត្រាម្នាក់នេះបាន ងើបឡើងបម្រើដល់ព្រះអង្គ និងកំពុងតែខំប្រឹងប្រែងគ្រប់ ពេលក្នុងការដើរតាមមាគ៌ានៃក្ដីស្រលាញ់របស់ព្រះអង្គ ហើយ។ ពិតណាស់ព្រះអង្គគឺជាព្រះប្រទាន ជាព្រះលើក

លែងទោសនិងជាព្រះមានទ័យសប្បុរស!

-អង្គពិសិដ្ឋអាប់ឌុលបាហា-

* * * * *

ធម៌សូត្រនាពេលធ្វើដំណើរ

ឱព្រះម្ចាស់របស់ទូលបង្គំលោកអើយ ទូលបង្គំបាន ងើបឡើងពីដំណេកនាព្រឹកព្រលឹមនេះដោយសារអានុភាព

របស់ព្រះអង្គ ហើយទូលបង្គំបានចាកចេញពីផ្ទះរបស់ទូលបង្គំមកនេះដោយមានការទុកចិត្តចំពោះព្រះអង្គទាំងស្រុង ហើយទូលបង្គំក៏បានផ្ទុកផ្ដាក់ខ្លួនទូលបង្គំទៅនឹងការថែរក្សា

របស់ព្រះអង្គផងដែរ។ នៅពេលនេះសូមព្រះអង្គបញ្ជូនសព្វសាធុការពររបស់ព្រះអង្គចេញពីឋានសួគ៌នៃមេត្តាធម៌របស់ព្រះអង្គឱ្យបានដល់ទូលបង្គំផង ហើយក៏សូមព្រះអង្គញ៉ាំងឱ្យទូលបង្គំបានវិលត្រឡប់មកគេហដ្ឋានវិញដែលប្រកបដោយសុវត្ថិភាពដូចកាលដែលព្រះអង្គបានញ៉ាំងឱ្យទូលបង្គំ

បានចាកចេញពីគេហដ្ឋានមក ដែលស្ថិតនៅក្រោមកំណារ

ការពាររបស់ព្រះអង្គដែលធ្វើឱ្យគំនិតរបស់ទូលបង្គំបាន

ប្រកាន់ខ្ជាប់ចំពោះព្រះអង្គ។ ក្រៅពីព្រះអង្គគ្មានព្រះណា

ទៀតឡើយ ព្រះអង្គគឺជាព្រះតែមួយអង្គគត់ ជាព្រះគ្មានគូ

ប្រៀបជាព្រះទ្រង់ញាណគ្រប់យ៉ាងនិងជាព្រះប្រកបដោយបញ្ញាញាណគ្រប់យ៉ាង។

-ព្រះបាហាអ៊ុលឡាហ៍-

* * * * *

មូលនិធិឬការចូលរួមបច្ច័យនិងបរិក្ខារធ្វើបុណ្យ

គ្រប់មិត្តទាំងឡាយរបស់ព្រះគួរតែចូលរួមទៅតាមចំនួនដែលអាចធ្វើឱ្យបាន បើទោះជាចំនួនបច្ច័យចូលរួមរបស់គេនោះមានចំនួនតិចតួចក៏ដោយ។ ការចូលរួមបច្ច័យធ្វើបុណ្យនេះព្រះមិនកំណត់ឱ្យហួសពីសមត្ថភាពរបស់អ្នកដែលចូលរួ

មធ្វើបុណ្យនេះឡើយ។ ការចូលរួមធ្វើបុណ្យនេះត្រូវតែកើតចេញមកពីគ្រប់មជ្ឈមណ្ឌលនិងគ្រប់អ្នកជំនឿ........ឱមិត្តរបស់ព្រះអើយ! ការចូលរួមធ្វើបុណ្យរបស់អ្នកនោះប្រាកដជានឹងបានតបមកវិញនូវបុណ្យឱ្យដល់មុខរបរកសិកម្មរបស់អ្នក មុខរបរឧស្សាហកម្មរបស់អ្នក ហើយនិងមុខរបរពាណិជ្ជកម្មរបស់អ្នកមួយទ្វេជាដប់ដែលជាអំណោយនិងរង្វាន់ដ៏ច្រើនថែមទៀត។ មនុស្សណាមួយបានធ្វើអំពើល្អណាមួយនោះនឹងបានទទួលបុណ្យមួយទ្វេជាដប់។ ពិតណាស់មិនបាច់សង្ស័យទេថា ព្រះដែលមានជីវិតជាអមតនឹងទទួលខុសត្រូវជាប្រាកដដល់អ្នកទាំងឡាយណា ដែលបានចំណាយទ្រព្យធនរបស់ខ្លួននៅក្នុងមាគ៌ារបស់ព្រះអង្គ។

ឱព្រះជាព្រះរបស់ទូលបង្គំលោកអើយ! សូមព្រះអង្គឆ្លុះបំភ្លឺគំនិតប្រាថ្នារបស់អ្នកស្រលាញ់ពិតរបស់ព្រះអង្គ និងសូមព្រះអង្គទ្រទ្រង់ពួកគេជាមួយនឹងបាហានិកដែលជាទេវតានៃជ័យជំនះពិតផង។ សូមព្រះអង្គពង្រឹងជើងរបស់ពួកគេឱ្យស្ថិតនៅលើមាគ៌ាត្រឹមត្រូវរបស់ព្រះអង្គ ហើយក្រៅពីភាពសម្បូរពីបុរាណរបស់ព្រះអង្គសូមទ្រង់បើកក្លោងទ្វារនៃបុណ្យរបស់ព្រះអង្គនៅចំពោះមុខពួកគេផង ព្រោះពួកគេកំពុងតែដើរនៅលើមាគ៌ារបស់ព្រះអង្គដែលព្រះអង្គបានប្រទានឱ្យដល់ពួកគេ ព្រោះពួកគេកំពុងតែការពារជំនឿ

សាសនារបស់ព្រះអង្គ ព្រោះពួកគេកំពុងតែដាក់សេចក្តីទុកចិត្តរបស់ពួកគេឱ្យនៅក្នុងការចងចាំរបស់ពួកគេដល់ព្រះ អង្គ ព្រោះពួកគេកំពុងតែជូនបេះដូងរបស់ពួកគេដើម្បីសេចក្តីស្រលាញ់ដល់ព្រះអង្គហើយនិងព្រោះពួកគេរក្សាទុកនូវអ្វីដែលពួកគេមានក្នុងការស្រលាញ់ជាទីសក្ការៈចំពោះសោភ័ណភាពរបស់ព្រះអង្គហើយនិងក្នុងការស្វែងរកមាគ៌ាដែលធ្វើឱ្យព្រះអង្គសព្វព្រះហឫទ័យ។

ឱព្រះរបស់ទូលបង្គំលោកអើយ!សូមព្រះអង្គប្រទានចំណែកដ៏ច្រើនដល់ពួកគេសូមព្រះអង្គប្រទានសំណាងឱ្យដល់ពួកគេនិងសូមព្រះអង្គប្រទានរង្វាន់ពិតដល់ពួកគេផង។

ពិតណាស់ព្រះអង្គជាអ្នកទ្រទ្រង់ ជាអ្នកជួយ ជាព្រះប្រកបដោយព្រះទ័យសប្បុរសជាព្រះប្រកបដោយបុណ្យ

និងជាព្រះប្រទានជាអមត។

-អង្គពិសិដ្ឋអាប់ឌុលបាហា-

* * * * *

ធម៌សូត្រនាពេលបុណ្យ១៩ថ្ងៃ

ឱព្រះម្ចាស់លោកអើយ!សូមព្រះអង្គកំចាត់គ្រប់កត្តា
ទាំងឡាយណាដែលជាបុព្វហេតុនាំឱ្យមានភាពជម្រោង
ចម្រាស់កើតឡើងហើយរៀបចំឱ្យពួកយើងវិញនូវរឿងទាំង

ឡាយណាដែលជាបុព្វហេតុនាំឱ្យមានសាមគ្គីភាព និងភាពស្រុះស្រួលគ្នា! ឱព្រះលោកអើយ! សូមព្រះអង្គប្រទានក្លិនពិដោរសួគ៌ឱ្យមកដល់ពួកយើង និងសូមព្រះអង្គបំភ្លៃយការជួបជុំគ្នានេះឱ្យទៅជាការជួបជុំគ្នានៃឋានសួគ៌វិញផង! និងសូមព្រះអង្គប្រទានគ្រប់ប្រយោជន៍និងគ្រប់អាហារឱ្យពួកយើងបានបរិភោគផង។

សូមព្រះអង្គរៀបចំអាហារនៃក្ដីស្រលាញ់ឱ្យពួកយើង!
សូមព្រះអង្គប្រទានអាហារនៃចំណេះដឹងឱ្យដល់ពួកយើង!

សូមព្រះអង្គប្រទានអាហារនៃពន្លឺសួគ៌ឱ្យពួកយើងផង!

-អង្គពិសិដ្ឋអាប់ឌុលបាហា-

* * * * *

## ការជួបជុំគ្នា

ឱព្រះជាព្រះរបស់ទូលបង្គំលោកអើយព្រះអង្គជាព្រះ

ប្រកបដោយភាពរុងរឿង! ទូលបង្គំសូមអង្វរព្រះអង្គតាម

រយៈវាយោផាយផាត់នៃមនុញ្ញភាពរបស់ព្រះអង្គហើយនិង

តាមរយៈវាយោដែលជាប្រភពរីករាយដែលជាព្រះរាជបំ
ណាងរបស់ព្រះអង្គ ហើយនិងជាទីកន្លែងដើមកំណើតសេតា

រុណានៃបំណងប្រាថ្នាដែលជាបំណងប្រាថ្នារបស់ព្រះអង្គសូម ព្រះអង្គបញ្ជូនចុះមកនូវភាពសប្បុរស និងមនុញ្ញភាពដ៏សម្បូរណ៍បែបរបស់ព្រះអង្គ និងសូមព្រះអង្គបញ្ជូនចុះមកនូវអំណោយ និងការអនុគ្រោះដ៏ថ្លៃថ្លាយ៉ាងគាប់ប្រសើរឱ្យបានដល់ទូលបង្គំ និងបានដល់របស់គ្រប់យ៉ាងដែលបានស្វែងរកព្រះភក្ត្ររបស់ព្រះអង្គ។ ឱព្រះរបស់ទូលបង្គំលោកអើយ ទូលបង្គំគឺជាអ្នកក្រខ្សត់និងជាអ្នកស្រេកឃ្លាន ខ្លាំង ណាស់! សូមព្រះអង្គដាក់ត្រាំទូលបង្គំឱ្យបាននៅក្នុងមហាសាគរនៃទ្រព្យសម្បត្តិរបស់ព្រះអង្គ ហើយទូលបង្គំក៏ជាអ្នកស្រេកឃ្លានខ្លាំងណាស់ដែរសូមព្រះអង្គអនុញ្ញាតឱ្យទូលបង្គំបានផឹកទឹករស់ពីព្រះទ័យសប្បុរសធមិដ៏ជាទីស្រលាញ់របស់

ព្រះអង្គផង។

ទូលបង្គំសូមអង្វរព្រះអង្គផ្ទាល់និងតាមរយៈទ្រង់ដែលព្រះអង្គបានចាត់តាំងឱ្យធ្វើជាព្រះសាស្តាដែលកើតមកពីមនុស្សអាទិទេពផ្ទាល់របស់ព្រះអង្គ និងតាមរយៈបន្ទូលស្គាល់ខុសស្គាល់ត្រូវរបស់ព្រះអង្គឱ្យបានទៅដល់របស់គ្រប់យ៉ាងដែលនៅក្នុងឋានសួគ៌និងនៅលើផែនដីនេះសូមឱ្យព្រះអង្គប្រមូលអ្នកបម្រើរបស់ព្រះអង្គឱ្យនៅជួបជុំគ្នាក្រោមម្លប់ឈើនៃទិព្វវិញ្ញាណដែលប្រកបដោយមនុញ្ញភាពរបស់

ព្រះអង្គ។ នៅពេលនេះព្រះអង្គជួយពួកគេឱ្យបានសេព (ញ៉ាំ)ផល្លានុផលពីដើមឈើនោះ សូមព្រះអង្គជួយឱ្យពួកគេបានផ្ទៀងត្រចៀករបស់ពួកគេទៅនឹងសម្លេងលាន់នៃស្លឹករបស់ដើមឈើនោះ និងសូមព្រះអង្គជួយពួកគេឱ្យបានស្តាប់ទៅនឹងភាពពិរោះនៃសម្លេងរបស់បក្សាបក្សី ដែលបានស្មូតនៅលើមែកឈើនោះផង។ ពិតណាស់ព្រះអង្គគឺជាអ្នកជួយឱ្យរួចផុតពីគ្រោះអាសន្ន ជាអ្នកអាចធ្វើអ្វីៗបានតាមបំណងប្រាថ្នាជាព្រះប្រកបដោយឫទ្ធីចេស្តានិងជាព្រះប្រកបដោយភាពសម្បូរណ៍បែបបំផុត។

-ព្រះបាហាអ៊ុលឡាហ៍-

ឱព្រះអង្គដែលជាព្រះប្រកបដោយមេត្តាធម៌អើយ!

ឱព្រះអង្គដែលជាព្រះប្រកបដោយឫទ្ធីចេស្តានិងសព្វានុ

ភាពអើយ! ឱព្រះអង្គជាព្រះវរាជបិតាដែលប្រកបដោយព្រះទ័យដ៏សប្បុរសធម៌បំផុតអើយ! អ្នកបម្រើទាំងនេះបានមកជួបជុំគ្នាកំពុងតែងាកទៅរកព្រះអង្គកំពុងតែអង្វរសុំធរណីទ្វាររបស់ព្រះអង្គកំពុងតែប្រាថ្នាចង់បានភាពសម្បូណ៌

ពីការធានារ៉ាប់រងដ៏ច្រើនរបស់ព្រះអង្គដែលមិនចេះចប់។ ពួកគេគ្មានបំណងអ្វីក្រៅពីភាពសប្បាយរីករាយរបស់ព្រះអង្គឡើយ។ ពួកគេគ្មានចេតនាអ្វីក្រៅពីការបម្រើពិភពរបស់មនុស្សជាតិឡើយ។

ឱព្រះលោកអើយ! សូមព្រះអង្គធ្វើឱ្យក្រុមមនុស្សដែលប្រមូលផ្ដុំគ្នានេះ មានពន្លឺត្រចះត្រចង់ឡើង ផង។ សូមព្រះអង្គធ្វើឱ្យបេះដូងពួកគេប្រកបដោយមេត្តា ធម៌។ សូមព្រះប្រទានបុណ្យពីវិញ្ញាណសក្តិសិទ្ធិឱ្យបានដល់ ពួកគេ។ សូមព្រះអង្គប្រទានអំណាចពីឋានសួគ៌ឱ្យពួកគេ។ សូមព្រះអង្គប្រទានពរសតិសួគ៌ឱ្យពួកគេ។ សូមព្រះអង្គបង្កើនភាពស្មោះត្រង់របស់ពួកគេដើម្បីឱ្យពួកគេអាចងាកទៅកាន់រាជាណាចក្ររបស់ព្រះអង្គដោយភាពបន្ទាបខ្លួននិងដោយចិត្តបុណ្យនិងដើម្បីឱ្យពួកគេបាននៅបម្រើដល់ពិភពរបស់មនុស្ស។ សូមឱ្យពួកគេម្នាក់ៗក្លាយជាទៀនមួយដើមដែលមានពន្លឺ។ សូមឱ្យពួកគេម្នាក់ៗក្លាយជាដួងតារាមួយដួងដែលមានពន្លឺចិញ្ចែងចិញ្ចាច។ សូមឱ្យពួកគេម្នាក់ៗក្លាយជាពណ៌ដែលមានភាពស្រស់ស្អាត ហើយនិងក្លិនពិដោរដ៏ក្រអូបសាយនៅក្នុងរាជាណាចក្ររបស់ព្រះ។ ឱព្រះវរាជបិតាដែលប្រកបដោយព្រះទ័យល្អគ្រប់យ៉ាងអើយ! សូមព្រះអង្គប្រទានពររបស់ព្រះអង្គឱ្យពួកយើងម្នាក់ៗផង។ សូមព្រះ

អង្គកុំមានព្រះរាជតំរិះពីវិបត្តិរបស់ពួកយើង។ សូមព្រះអង្គផ្តល់ទីជម្រកឱ្យពួកយើងបាននៅក្រោមកំណារការពាររបស់ព្រះអង្គផង។ សូមព្រះអង្គបំភ្លេចពីបាបកម្មរបស់ពួកទូល បង្គំផង។ សូមព្រះអង្គព្យាបាលឱ្យពួកយើងដោយមេត្តាធម៌ របស់ព្រះអង្គ។ ពួកទូលបង្គំទន់ខ្សោយខ្លាំងណាស់ ចំណែកព្រះអង្គជាព្រះមានចេស្តាខ្លាំងក្លាណាស់។ ពួកទូលបង្គំជាអ្នកក្រខ្សត់ចំណែកព្រះអង្គជាអ្នកមានភោគទ្រព្យមិនខ្វះ។ ពួកយើងជាអ្នកមានជម្ងឺ ចំណែកព្រះអង្គជាគ្រូពេទ្យដ៏ចំ ណាន។ ពួកយើងជាអ្នកខ្វះខាតចំណែកព្រះអង្គជាអ្នកមានព្រះទ័យសប្បុរសធម៌បំផុត។

ឱព្រះលោកអើយ! សូមព្រះអង្គប្រទានទិព្វ វិញ្ញាណឱ្យពួកយើង។ ព្រះអង្គជាព្រះប្រកបដោយសព្វានុ ភាព។ព្រះអង្គជាអ្នកប្រទានឱ្យ។ ព្រះអង្គជាព្រះសប្បុរស។

-អង្គពិសិដ្ឋអាប់ឌុលបាហា-

ឱព្រះអង្គដែលជាព្រះមានព្រះទ័យល្អអើយ! អ្នកទាំងអស់គ្នាដែលបានមកជួបជុំគ្នាក្នុងអង្គប្រជុំនេះគឺជាអ្នកបម្រើរបស់ព្រះអង្គពួកគេទាំងអស់គ្នាបានងាកមុខទៅរករាជាណាចក្ររបស់ព្រះអង្គហើយ ហើយពួកគេទាំងនោះក៏កំពុងតែ

ត្រូវការការប្រទានពររបស់ព្រះអង្គដែរ។ ឱព្រះអង្គដែលជាព្រះលោកអើយ! សូមព្រះអង្គបង្ហាញនិងធ្វើឱ្យគេឃើញច្បាស់ពីសញ្ញានៃភាពតែមួយរបស់ព្រះអង្គដែលត្រូវបានគេដាក់បញ្ចូលឱ្យមាននៅក្នុងគ្រប់ធាតុពិតនៃជីវិត។ សូមព្រះអង្គបង្ហាញ និងលាតត្រដាងគុណធម៌ដែលព្រះអង្គបានបង្កប់និងលាក់បំបាំងឱ្យនៅក្នុងធាតុពិតរបស់មនុស្ស។

ឱព្រះលោកអើយ! ពួកយើងប្រៀបដូចជារុក្ខជាតិ ចំណែកឯព្រះអង្គប្រៀបដូចជាទឹកភ្លៀង សូមព្រះអង្គធ្វើឱ្យនិងញ៉ាំងឱ្យរុក្ខជាតិទាំងនេះបានលូតលាស់ និងស្រស់ស្រាយតាមរយៈអំណោយរបស់ព្រះអង្គ។ ពួកយើងជាអ្នកបម្រើរបស់ព្រះអង្គ សូមព្រះអង្គបញ្ចៀសពួកយើងឱ្យបានរួចផុតពីទន្លឹងនៃជីវិតសម្ភារៈនិយម។ ពួកយើងជាមនុស្ស ល្ងង់ខ្លៅ សូមព្រះអង្គធ្វើឱ្យពួកយើងមានគំនិតបញ្ញា។ ពួកយើងគឺជាមនុស្សស្លាប់វិញ្ញាណ សូមព្រះអង្គធ្វើឱ្យវិញ្ញាណរបស់ពួកយើងរស់ឡើងវិញ។ ពួកយើងជាមនុស្សសម្ភារៈ សូមព្រះអង្គប្រទានស្មារតីឱ្យពួកយើង។ពួកយើងជាមនុស្សបង្អត់ខ្លួនឯងសូមព្រះអង្គធ្វើឱ្យពួកយើងស្និទ្ធស្នាលនឹងអាថ៌កំបាំងរបស់ព្រះអង្គ។ ពួកយើងជាមនុស្សខ្វះខាត សូមព្រះ

អង្គប្រទានទ្រព្យ និងពរពីរតនាគារដ៏សម្បូរបែបរបស់ព្រះអង្គឱ្យពួកយើង។ ឱព្រះលោកអើយ! សូមព្រះអង្គធ្វើឱ្យពួកយើងរស់រានមានជីវិតឡើងវិញ។ សូមព្រះអង្គ

ប្រទានចក្ខុឱ្យពួកយើងបានមើលឃើញ សូមព្រះអង្គប្រទាន

សោតឱ្យពួកយើងបានស្តាប់ឮ សូមព្រះអង្គធ្វើឱ្យពួកយើងបានស្គាល់ស្និទ្ធនឹងអាថ៌កំបាំងនៃជីវិត ដើម្បីឱ្យភាពសម្ងាត់នៃរាជាណាចក្ររបស់ព្រះអង្គ អាចត្រូវបានគេលាតត្រដាងឱ្យពួកយើងបានឃើញនៅក្នុងពិភពការងារនេះ និងដើម្បីឱ្យពួកយើងបានទទួលស្គាល់ភាពតែមួយរបស់ព្រះអង្គ។ គ្រប់ការប្រទាននឹងបំភាយចេញពីព្រះអង្គ គ្រប់ការប្រសិទ្ធិពរគឺជារបស់ព្រះអង្គ។

ព្រះអង្គគឺជាព្រះមានឫទ្ធី។ ព្រះអង្គគឺជាព្រះប្រកបដោយសព្វានុភាព។ ព្រះអង្គគឺជាអ្នកប្រទាន ព្រះអង្គគឺជាព្រះប្រកបដោយបុណ្យជាអង្វែង។

-អង្គពិសិដ្ឋអាប់ឌុលបាហា-

ឱព្រះរបស់ទូលបង្គំលោកអើយ! ឱព្រះរបស់ទូល បង្គំលោកអើយ! ពិតណាស់អ្នកបម្រើទាំងនេះកំពុងតែងាក ទៅរកព្រះអង្គកំពុងតែអង្វរសុំមេត្តាធម៌រាជាណាចក្ររបស់ ព្រះអង្គ។ ពិតណាស់ពួកគេកំពុងតែចាប់ចិត្តនឹងភាពពិសិដ្ឋ របស់ព្រះអង្គ កំពុងតែបញ្ចេញពន្លឺដោយភ្លើងនៃក្តីស្រលាញ់ របស់ព្រះអង្គ កំពុងតែស្វែងរកការធានាបញ្ជាក់បន្ថែមពីរា ជាណាចក្រដ៏អស្ចារ្យរបស់ព្រះអង្គ ហើយពួកគេក៏កំពុងតែ សង្ឃឹមថានឹងបានចូលដល់ឋានសួគ៌របស់ព្រះអង្គផងដែរ។ ពិតណាស់ពួកគេចង់ឱ្យអំណោយប្រទានរបស់ព្រះអង្គជ្រាលចុះមក ដល់ពួកគេ ពួកគេចង់ឱ្យព្រះអាទិត្យនៃសច្ចភាពបំភ្លឺ ដល់ពួកគេ។

ឱព្រះលោកអើយ! សូមព្រះអង្គធ្វើឱ្យពួកគេ

បានក្លាយជាចង្កៀងដែលមានពន្លឺភ្លឺថ្លា ក្លាយជាសញ្ញាដែល

ប្រកបដោយមេត្តាធម៌ ក្លាយជាដើមឈើដែលមានផ្កាផ្លែ ស្អេកស្កះ និងក្លាយជាដួងតារាដែលមានពន្លឺយ៉ាងត្រចះត្រ ចង់ផង។ សូមឱ្យពួកគេចូលរួមនៅក្នុងការបម្រើរបស់ព្រះ អង្គ និងសូមឱ្យពួកគេភ្ជាប់ខ្លួនរបស់ពួកគេជាមួយនឹងព្រះ អង្គដោយខ្សែចំណងនៃក្តីស្រលាញ់របស់ព្រះអង្គដែលជាពន្លឺ នៃក្តីអនុគ្រោះរបស់ព្រះអង្គ។ ឱព្រះលោកអើយ! សូមព្រះ អង្គធ្វើឱ្យពួកគេក្លាយជាសញ្ញានៃការដឹកនាំផ្លូវជាខ្នាតគំរូនៃរាជា ណាចក្រជាអមតរបស់ព្រះអង្គ ជារលកនៃមហាសាគរ នៃមេត្តាធម៌របស់ព្រះអង្គ និងជាពន្លឺកញ្ចក់នៃភាពសម្បើម របស់ព្រះអង្គ។ ពិតណាស់ព្រះអង្គ ជាព្រះប្រកបដោយព្រះ ទ័យសប្បុរស ពិតណាស់ព្រះអង្គគឺជាព្រះប្រកបដោយមេត្តា ធម៌។ ពិតណាស់ព្រះអង្គគឺជាព្រះប្រកបដោយជាទីពេញចិត្ត

និងជាទីស្រលាញ់។

-អង្គពិសិដ្ឋអាប់ឌុលបាហា-

ឱព្រះអង្គដែលជាព្រះលើកលែងទោសលោកអើយ!អ្នកបម្រើទាំង នេះ កំពុងតែងាកទៅរករាជាណាចក្ររបស់ ព្រះអង្គនិងកំពុងតែស្វែងរកមនុញ្ញភាពនិងបុណ្យភាពរបស់

ព្រះអង្គ។ ឱព្រះលោកអើយ! សូមព្រះអង្គធ្វើឱ្យបេះដូងរបស់ពួកគេល្អ និងបរិសុទ្ធដើម្បីឱ្យពួកគេបានគាប់ចិត្តនឹងក្តីស្រលាញ់របស់ព្រះអង្គ។ សូមព្រះអង្គធ្វើឱ្យចិត្តវិញ្ញាណរបស់ពួកគេបរិសុទ្ធ និងសន្តភាពដើម្បីពន្លឺនៃព្រះអាទិត្យសច្ចភាពអាចបញ្ចេញរស្មីត្រចះត្រចង់ដល់ពួកគេ។សូមព្រះអង្គធ្វើឱ្យចក្ខុរបស់ពួកគេបរិសុទ្ធ និងពិសិដ្ឋភាពដើម្បីឱ្យពួកគេអាចឃើញពីពន្លឺរបស់ព្រះអង្គ។ សូមព្រះអង្គធ្វើឱ្យសោតារបស់ពួកគេបរិសុទ្ធ និងពិសិដ្ឋភាពដើម្បីឱ្យពួកគេអាចស្តាប់ការស្រែកហៅពីរាជាណាចក្រសួគ៌របស់ព្រះអង្គ។

ឱព្រះលោកអើយ! ពិតណាស់ពួកយើងជាអ្នកទន់ខ្សោយប៉ុន្តែព្រះអង្គជាអ្នកមានឫទ្ធី។ ពិតណាស់ពួកយើងជាអ្នកក្រខ្សត់ ប៉ុន្តែព្រះអង្គជាអ្នកមានភោគទ្រព្យមហាសាល។ ពួកយើងគឺជាអ្នកស្វែងរក ចំណែកព្រះអង្គគឺជាអ្នកដែលគេស្វែងរកនោះហើយ។ ឱព្រះលោកអើយ!សូមព្រះអង្គមេត្តាដល់ពួកយើងនិងលើកលែងទោសឱ្យពួកយើង សូមព្រះអង្គប្រទានសមត្ថភាពនិងគំនិតថ្មីមកដល់ពួកយើង ដើម្បីឱ្យពួកយើងអាចបានដឹងពីតម្លៃនៃការអនុគ្រោះរបស់ព្រះអង្គ ហើយនិងបានក្លាយជាមនុស្សដែលជាប់ចិត្តនឹងរាជាណាចក្ររបស់ព្រះអង្គ និងសូមព្រះអង្គប្រទានសមត្ថភាពនិងគំនិតថ្មីៗដល់ពួកយើងដើម្បីឱ្យពួកយើង

អាចយល់ពីជីវិតបានកាន់តែជ្រៅនិងដើម្បីឱ្យពួកយើងបាន មានភ្លើងនៃក្តីស្រលាញ់របស់ព្រះអង្គនៅក្នុងចិត្ត ព្រមទាំង ដើម្បីឱ្យពួកយើងបានរស់ឡើងវិញតាមរយៈដង្ហើមនៃ វិញ្ញាណបរិសុទ្ធដែលមាននៅក្នុងសតវត្សរ៍ដ៏ចិញ្ចែងចិញ្ចាច នេះផង។

ឱព្រះម្ចាស់ដែលជាព្រះរបស់ទូលបង្គំលោកអើយ! សូមព្រះអង្គទតមើលពីភាពសប្បុរសធម៌ជាទីស្រលាញ់ របស់ព្រះអង្គដល់ការជួបជុំគ្នានេះផង។ សូមព្រះអង្គថែ រក្សាពួកគេម្នាក់ៗនិងពួកគេទាំងអស់គ្នាដែលនៅក្នុងអាណាព្យាបា លរបស់ព្រះអង្គ និងនៅក្រោមកំណារការពាររបស់ ព្រះអង្គឱ្យពួកគេមានសុវត្ថិភាព។ សូមព្រះអង្គបញ្ជូនសព្វ សាធុការពរសួគ៌ដល់អ្នកទាំងនេះ។ សូមព្រះអង្គដាក់ពួក គេត្រាំនៅក្នុងមហាសាគរនៃមេត្តាធម៌របស់ព្រះអង្គ និង ជម្រុញឱ្យពួកគេបានលឿនតាមរយៈដង្ហើមនៃវិញ្ញាណបរិ សុទ្ធ។

ឱព្រះម្ចាស់លោកអើយ! សូមព្រះអង្គប្រទានជំនួយ ឧបត្ថម្ភនិងអំណះអំណាងដែលប្រកបដោយមនុញ្ញភាព របស់ព្រះអង្គមកលើការគ្រប់គ្រងដ៏ត្រឹមត្រូវនេះផង។ ប្រ

ទេសមួយនេះបានស្ថិតនៅក្រោមម្លប់ដែលជាទីជម្រកនៃកំណារការ
ពាររបស់ព្រះអង្គហើយមនុស្សនៅក្នុងប្រទេសនេះ

បាននៅក្នុងការបម្រើរបស់ព្រះអង្គហើយ។ ឱព្រះម្ចាស់
លោកអើយ! សូមព្រះអង្គប្រទានបុណ្យសួគ៌របស់ព្រះអង្គ
និងសូមព្រះអង្គប្រទានទំនោរចិត្តនៃមនុញ្ញភាព និងការអនុ
គ្រោះដ៏បរិបូរណ៍ និងច្រើនក្រាស់ក្រែលរបស់ព្រះអង្គឱ្យបាន
ដល់ពួកគេ។ សូមព្រះអង្គអនុញ្ញាតឱ្យជនជាតិដ៏ជាទីគោរព
នេះបានមានកិត្តិយស និងសូមព្រះអង្គអនុញ្ញាតឱ្យពួកគេ

បានចូលទៅដល់រាជាណាចក្ររបស់ព្រះអង្គផង។

ពិតណាស់ព្រះអង្គគឺជាព្រះប្រកបដោយសញ្ញានុភាព
ជាព្រះប្រកបដោយអំណាច ជាព្រះប្រកបដោយមេត្តាធម៌
និងជាព្រះប្រកបដោយព្រះទ័យសប្បុរសធម៌ជាព្រះប្រព្រឹត្ត
តែអំពើល្អ និងជាព្រះប្រកបដោយមនុញ្ញភាពដ៏ឧត្តម។

-អង្គពិសិដ្ឋអាប់ឌុលបាហា-

ឱព្រះអាទិទេពវិញ្ញាណទិព្វលោកអើយ!សូមព្រះអង្គទតមើលចុះមនុស្សមួយក្រុមនេះត្រូវបានគេចងក្រងជាក្រុម

ឡើងពីមិត្តរបស់ព្រះអង្គដែលជាមនុស្សជាប់ចិត្តនឹងសោភ័ណភាពរបស់ព្រះអង្គ និងជាមនុស្សដែលគេធ្វើឱ្យមានពន្លឺសន្ធោសន្ធៅដោយភ្លើងនៃក្ដីស្រលាញ់របស់ព្រះអង្គ។ សូមព្រះអង្គបំបែរមុខអ្នកទាំងនេះឱ្យទៅកាន់ទេវតាសួគ៌ និងព្រះអង្គធ្វើឱ្យពួកគេរស់ឡើងវិញតាមរយៈដង្ហើមនៃវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គ សូមព្រះអង្គប្រទានអណ្ដាតដែលប្រកបដោយវចីកោសល្យ និងបេះដូងរឹងមាំដល់ពួកគេ សូមព្រះអង្គប្រទានអំណាចសួគ៌ និងអារម្មណ៍មេត្តាធម៌ឱ្យបានដល់ពួកគេ សូមព្រះអង្គញ៉ាំងឱ្យពួកគេបានក្លាយទៅជាអ្នកប្រកាសពីគោលការណ៍នៃភាពតែមួយរបស់មនុស្សជាតិ និងជាអ្នកប្រកាសពីបុព្វហេតុនៃក្ដីស្រលាញ់ និងជាអ្នកស្រុះស្រួលគ្នានៅក្នុងពិភពរបស់មនុស្សជាតិដើម្បីឱ្យភាពងងឹតដែលកើតមកពីការប្រកាន់ជាតិសាសន៍ដ៏ល្ងង់ខ្លៅនេះរលាយសាបសូន្យអស់តាមរយៈពន្លឺនៃព្រះអាទិត្យសច្ចភាព និងដើម្បីឱ្យពិភពដ៏អាប់អួរនេះអាចមានពន្លឺ និងដើម្បីឱ្យកាំរស្មីនៃពិភពស្មារតីអាចជ្រាបចូលដល់ពិភពសម្ភារៈនេះបាន ផងហើយនិងដើម្បីឱ្យពណ៌ដែលខុសគ្នាទាំងនេះអាចលាយបញ្ចូលគ្នាឱ្យទៅជាពណ៌តែមួយព្រមទាំងដើម្បីឱ្យទំនុក

តម្កើងអាចរះឡើងបានទៅដល់រាជាណាចក្រនៃភាពពិសិដ្ឋរបស់ព្រះអង្គបាន។

ពិតណាស់ព្រះអង្គគឺ ជាព្រះប្រកបដោយវិជិតរាជ្យ និងជាព្រះប្រកបដោយមហិទ្ធិឫទ្ធិ!

-អង្គពិសិដ្ឋអាប់ឌុលបាហា-

ឱព្រះអង្គជាអ្នកផ្គត់ផ្គង់ជាទីស្រលាញ់អើយ! អ្នកទាំងនេះបានស្តាប់ទៅនឹងការអំពាវនាវនៃរាជាណាចក្រហើយ ហើយព្រមទាំងបានសម្លឹងទៅលើភាពរុងរឿងនៃព្រះអាទិត្យសច្ចភាពផងដែរ។ ពួកគេបានងើបឡើងធ្វើដំណើរឆ្ពោះទៅកាន់មេឃដ៏ស្រស់បស់នៃក្តីស្រលាញ់ហើយ ហើយពួកគេក៏បានចូលចិត្តនឹងច្បាប់កំណត់ពីធម្មជាតិរបស់ព្រះអង្គ ផងដែរ ហើយពួកគេក៏ព្រមបូជាសក្ការៈដល់សោភ័ណភាពរបស់ព្រះអង្គទៀតផង។ ព្រះអង្គទតមើលចុះពួកគេបានងាកមុខទៅកាន់ព្រះអង្គដោយខ្លួនឯង និយាយពីព្រះអង្គជុំគ្នាដោយខ្លួនឯង ស្វែងរកទីជម្រករបស់ព្រះអង្គដោយខ្លួន ឯង

ហើយនិងកំពុងតែផឹកទឹកស្នឹងពីរាជាណាចក្ររបស់ព្រះ
អង្គដោយខ្លួនឯងទៀតផង។

ព្រះអង្គគឺជាអ្នកប្រទានអ្វីៗគ្រប់យ៉ាង ជាអ្នកផ្តល់ឱ្យ
និងជាព្រះមានក្តីស្រលាញ់ជាអនន្ត។

-អង្គពិសិដ្ឋអាប់ឌុលបាហា-

* * * * *

ធម៌សូត្រព្យាបាលជម្ងឺ

ឱព្រះជាព្រះរបស់ទូលបង្គំលោកអើយ!ទូលបង្គំអង្វរ
សុំឱ្យព្រះអង្គព្យាបាលឱ្យទូលបង្គំតាមរយៈមហាសាគរនៃ
ការព្យាបាលរបស់ព្រះអង្គតាមរយៈភាពរុងរឿងនៃតារាប្រ
ចាំភពនៃមនុញ្ញភាពរបស់ព្រះអង្គ តាមរយៈព្រះនាមរបស់
ព្រះអង្គដែលព្រះអង្គបានបង្ក្រាប តាមរយៈអ្នកបម្រើរបស់ ព្រះអង្គ

តាមរយៈអំណាចដែលបានសាយភាយទូទៅនៃ
បន្ទូលដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះអង្គ តាមរយៈអំណាចនៃប៉ា
កាដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះអង្គ ហើយនិងតាមរយៈមេត្តា
ធម៌របស់ព្រះអង្គដែលព្រះអង្គបានដាក់នៅចំពីមុខមាបន
កម្មគ្រប់គ្នាដែលស្ថិតនៅឋានសួគ៌ ហើយនិងនៅលើផែនដី
ដើម្បីសុំឱ្យព្រះអង្គធ្វើវិសុទ្ធកម្មដល់ទូលបង្គំជាមួយនឹងព្រះ
គង្គានៃបុណ្យរបស់ព្រះអង្គ ដើម្បីឱ្យទូលបង្គំបានគេចផុតពី
គ្រប់ការឈឺចាប់ ហើយនិងគេចផុតពីភាពឥតសណ្ដាប់ធ្នាប់
ព្រមទាំងគេចផុតពីគ្រប់ភាពទន់ខ្សោយ ហើយនិងភាពខ្វះ
កម្លាំងផង។

ឱព្រះរបស់ទូលបង្គំលោកអើយ សូមព្រះអង្គទត
មើលចុះអ្នកអង្វររបស់ព្រះអង្គកំពុងតែឈរចាំនៅឯទ្វារ

នៃបុណ្យរបស់ព្រះអង្គហើយអ្នកអង្វរនោះក៏បានផ្ដោតភ្ជាប់
សេចក្ដីសង្ឃឹមរបស់គាត់ចំពោះព្រះអង្គព្រមទាំងបានចងរឹតភ្ជាប់ខ្លួន
គាត់នឹងខ្សែនៃសប្បុរសធម៌របស់ព្រះអង្គផងដែរ។
ទូលបង្គំសូមអង្វរព្រះអង្គកុំបដិសេធនឹងអ្វីដែលគាត់បាន
ស្វែងរកពីមហាសាគរនៃមនុញ្ញភាពរបស់ព្រះអង្គ និងតារា

ប្រចាំភពនៃព្រះទ័យសប្បុរសធម៌ជាទីស្រលាញ់របស់ព្រះអង្គ។ពិតណាស់ព្រះអង្គជាព្រះមានអំណាចអាចធ្វើអ្វីៗគ្រប់យ៉ាងបានតាមព្រះទ័យប្រាថ្នា។ ក្រៅពីព្រះអង្គគ្មានព្រះឯណាទៀតឡើយ ព្រះអង្គជាព្រះលើកលែងទោសជាអមតជាព្រះប្រកបដោយព្រះទ័យសប្បុរសធម៌។

-ព្រះបាហាអ៊ុលឡាហ៍-

ឱព្រះអាទិទេពលោកអើយ ពិតណាស់ព្រះនាមរបស់ព្រះអង្គគឺជាការព្យាបាលរបស់ទូលបង្គំ ការចងចាំដល់ព្រះអង្គគឺជាឱសថទិព្វរបស់ទូលបង្គំ។ ការនៅជិតព្រះអង្គគឺជាក្ដីសង្ឃឹមរបស់ទូលបង្គំ សេចក្ដីស្រលាញ់ចំពោះព្រះអង្គគឺជាមិត្តរបស់ទូលបង្គំ។ មេត្តាធម៌របស់ព្រះអង្គចំពោះទូលបង្គំគឺជាកាព្យាបាលរបស់ទូលបង្គំនិងការជួយសង្គ្រោះរបស់ទូលបង្គំទាំងនៅក្នុងលោកនេះនិងលោកខាងមុខ។ ពិតណាស់ព្រះអង្គគឺជាព្រះប្រកបដោយបុណ្យគ្រប់យ៉ាង ជាព្រះទ្រង់ញាណគ្រប់យ៉ាង និងជាព្រះប្រកបដោយបញ្ញាញាណគ្រប់

យ៉ាង។

-ព្រះបាហាអ៊ុលឡាហ៍-

ឱព្រះជាព្រះអាទិទេពរបស់ទូលបង្គំអើយ! ពិតណាស់ព្រះអង្គគឺជាព្រះប្រកបដោយភាពរុងរឿង ទូលបង្គំសូមអង្វរព្រះអង្គដោយព្រះនាមរបស់ព្រះអង្គ ដែលតាមរយៈព្រះនាមនោះ ព្រះអង្គបានលើកស្ទួយទង់នៃការដឹកនាំរបស់ព្រះអង្គបានបញ្ចាំងពន្លឺជ្រះថ្លានៃព្រះទ័យសប្បុរសធម៌ជាទីស្រលាញ់របស់ព្រះអង្គ ព្រមទាំងបានបញ្ចេញឱ្យគេឃើញនូវអធិបតេយ្យភាពនៃភាពជាព្រះរបស់ព្រះអង្គ។ ទូលបង្គំសូមអង្វរព្រះអង្គដោយព្រះនាមរបស់ព្រះអង្គដែល

បានធ្វើឱ្យលេចមានពន្លឺឡើងតាមរយៈចង្កៀងដែលជាព្រះនាមរបស់ព្រះអង្គនៅក្នុងអង្គែ(លុងនៅក្នុងជញ្ជាំង)នៃកេតណាភ័ណ្ឌរបស់ព្រះអង្គ ហើយព្រះនាមដែលទូលបង្គំបានអង្វរព្រះអង្គតាមរយៈព្រះនាមនោះ គឺជាទ្រង់ដែលស្ថានទីនមស្សការ(កន្លែងគេគោរពបូជា)នៃសាមគ្គី និងជាព្រះសាស្តារបស់ព្រះអង្គដែលទ្រង់បានបញ្ចេញរស្មីដោយក្តីគ្មានជាប់ជំពាក់។ ទូលបង្គំសូមអង្វរព្រះអង្គដោយព្រះនាមរបស់ព្រះអង្គដែលធ្វើឱ្យគេស្គាល់ព្រះអង្គតាមរយៈមាគ៌ានៃការដឹកនាំ

របស់ព្រះអង្គហើយនិងតាមរយៈមាគ៌ានៃការសប្បាយដែល ត្រូវបានគេគូសចំណាំ។ ទូលបង្គំសូមអង្វរព្រះអង្គដោយព្រះនាមរបស់ព្រះអង្គដែលត្រូវបានគេធ្វើឱ្យញ័ររញ្ជួញតាមរយៈ

គ្រឹះនៃការភាន់ច្រឡំនិងតាមរយៈសញ្ញានៃភាពឃោរឃៅ ត្រូវបានគេបំបាត់ចោលទាំងស្រុង។ ទូលបង្គំសូមអង្វរព្រះអង្គដោយព្រះនាមរបស់ព្រះអង្គ ដែលបានធ្វើឱ្យកើតមានព្រោងព្រាតឡើងតាមរយៈប្រភពនៃគតិបណ្ឌិត ហើយនិងតាមរយៈអាហារសួគ៌ដែលត្រូវបានគេចុះមក។ ទូលបង្គំសូមអង្វរព្រះអង្គដោយព្រះនាមរបស់ព្រះអង្គ ដែលតាមរយៈព្រះនាមនោះ ព្រះអង្គបានការពារអ្នកបម្រើរបស់ព្រះ អង្គនិងបានផ្តល់អភ័យឯកសិទ្ធិដល់ការព្យាបាលរបស់ព្រះអង្គ។ទូលបង្គំសូមអង្វរព្រះអង្គដោយព្រះនាមរបស់ព្រះអង្គដែលតាមរយៈព្រះនាមនោះព្រះអង្គបានបង្ហាញពីមេត្តាធម៌ជាទីស្រលាញ់របស់ព្រះអង្គ ដល់អ្នកបម្រើរបស់ព្រះអង្គហើយនិងបានបង្ហាញឱ្យគេឃើញនូវការលើកលែងទោសរបស់ព្រះអង្គក្នុងចំណោមសត្វលោករបស់ព្រះអង្គ – គឺថាទូលបង្គំអង្វរសុំឱ្យព្រះអង្គថែរក្សាសុវត្ថិភាពដល់នរណាដែលបានប្រញាប់កាន់និងប្រញាប់ងាកទៅរកព្រះអង្គ និងដល់នរណាដែលបានតោងទៅនឹងមេត្តាធម៌របស់ព្រះអង្គហើយនិងដល់នរណាដែលចាប់តោងជាយសម្លៀកបំពាក់នៃទិព្វ

ញាណជាទីស្រលាញ់របស់ព្រះអង្គ។ នៅពេលនេះសូម ព្រះអង្គបញ្ជូនការព្យាបាលរបស់ព្រះអង្គ ឱ្យចុះមកដល់រូប គាត់ ហើយសូមព្រះអង្គធ្វើឱ្យគាត់បានជាសះស្បើយទាំង ស្រុង ព្រមទាំងសូមព្រះអង្គប្រទានឱ្យគាត់នូវចិត្តនឹងធឹង ដែលបានទទួលអភ័យឯកសិទ្ធិពីព្រះអង្គ ហើយព្រមទាំង សូមព្រះអង្គប្រទានភាពស្ងប់ស្ងាត់ពីភាពខ្ពង់ខ្ពស់របស់ព្រះ

អង្គ។

ពិតណាស់ព្រះអង្គគឺជាអ្នកព្យាបាល ជាអ្នកការពារ ជាអ្នកជួយជាអ្នកមានមហិទ្ធិឬទ្ធិ ជាអ្នកមានអំណាចជាអ្នក មានព្រះទ័យសប្បុរសធម៌គ្រប់យ៉ាង និងជាព្រះទ្រង់ញាណ គ្រប់យ៉ាង។

-ព្រះបាហាអ៊ុលឡាហ៍-

ឱព្រះរបស់ទូលបង្គំលោកអើយ!ព្រះអង្គគឺជាព្រះគួរឱ្យគេសរសើរខ្លាំងណាស់ទូលបង្គំសូមអង្វរព្រះអង្គតាមរយៈព្រះនាមដ៏អស្ចារ្យបំផុតរបស់ព្រះអង្គ ដែលតាមរយៈព្រះ

នាមដ៏អស្ចារ្យនេះព្រះអង្គបានធ្វើឱ្យអ្នកបម្រើរបស់ព្រះអង្គ

រឹងមាំឡើងនិងបានស្ថាបនាទីក្រុងរបស់ព្រះអង្គឡើង ទូលបង្គំអង្វរព្រះអង្គ តាមរយៈឋានន្តរសក្តិដ៏ប្រពៃបំផុតរបស់ ព្រះអង្គ និងសូមអង្វរព្រះអង្គតាមរយៈកេតណាភ័ណ្ឌដ៏ខ្ពង់ ខ្ពស់បំផុត ដើម្បីសុំឱ្យព្រះអង្គជួយដល់មនុស្សលោករបស់ ព្រះអង្គ ដើម្បីឱ្យគេបានងាកចូលទៅក្នុងទិសដៅនៃបុណ្យ ផ្សេងៗគ្នារបស់ព្រះអង្គនិងសូមព្រះអង្គដាក់តាំងមុខរបស់

ពួកគេឆ្ពោះទៅរកស្ថានទីនមស្សការនៃគតិបណ្ឌិតរបស់ព្រះ

អង្គផង។ សូមព្រះអង្គជួយព្យាបាលជម្ងឺទាំងឡាយដែល

បានគំរាមកំហែងដល់ពួកគេមកពីគ្រប់ទិសនិងជម្ងឺទាំង

ឡាយដែលបានធ្វើឱ្យពួកគេខ្លាចមិនហ៊ានប្រើភ្នែករបស់ពួកគេដើម្បីសម្លឹងឆ្ពោះទៅកាន់ឋានសួគ៌ដែលបានស្ថិតនៅក្នុងទីជម្រកនៃព្រះនាមដែលជាម្លប់របស់ព្រះអង្គ ដែលតាម

រយៈព្រះនាមនេះព្រះអង្គបានកំណត់ឱ្យធ្វើជាស្ដេចរបស់គ្រប់ឈ្មោះចំពោះអ្នកគ្រប់គ្នាដែលស្ថិតនៅក្នុងឋានសួគ៌ និងគ្រប់អ្នកទាំងឡាយណាដែលនៅលើផែនដី។

ពិតណាស់ព្រះអង្គគឺជាព្រះមានអំណាចអាចធ្វើអ្វីគ្រប់យ៉ាងបានតាមព្រះអង្គសព្វព្រះហឫទ័យ។ រាជាធិរាជណាចក្ររបស់មនុស្សគ្រប់ឈ្មោះគឺស្ថិតនៅក្នុងព្រះហស្ដរបស់ព្រះអង្គ។ ក្រៅពីព្រះអង្គគ្មានព្រះណាទៀតឡើយ ព្រះអង្គគឺជាព្រះមានមហិទ្ធិឫទ្ធិជាព្រះមានបញ្ញាញាណ។

ឱព្រះអាទិទេពរបស់ទូលបង្គំលោកអើយ ទូលបង្គំ

ផ្ទុយពីព្រះអង្គ ព្រោះទូលបង្គំជាសត្វលោកដ៏កំសត់ម្នាក់តែទូលបង្គំបានតោងទៅនឹងជាយនៃសម្លៀកបំពាក់នៃភោគទ្រព្យរបស់ព្រះអង្គហើយ។ ទូលបង្គំជាសត្វលោកមានជម្ងឺ

ម្នាក់តែទូលបង្គំបានប្រញាប់តោងទៅនឹងខ្សែចំណងនៃការ

ព្យាបាលរបស់ព្រះអង្គហើយ។ សូមព្រះអង្គព្យាបាលទូលបង្គំឱ្យបានជាសះស្បើយពីជម្ងឺដែលបានរួបរឹតទូលបង្គំ និងសូមព្រះអង្គលាងជម្រះទូលបង្គំឱ្យបានស្អាតជាមួយនឹងព្រះ

គង្គានៃភាពត្រឹមត្រូវនិងមេត្តាធម៌ព្រមទាំងសូមព្រះអង្គតុបតែងទូលបង្គំជាមួយនឹងសម្លៀកបំពាក់នៃភាពល្អ តាមរយៈការលើកលែងទោស និងព្រះទ័យសប្បុរធម៌របស់ព្រះអង្គផង។ នៅពេលនេះសូមព្រះអង្គដាក់តាំងចក្ខុរបស់ទូលបង្គំឱ្យបានមើលឃើញតែព្រះអង្គ និងសូមព្រះអង្គកំចាត់របស់គ្រប់យ៉ាងដែលតោងស្អិតជាប់នឹងទូលបង្គំលើកលែង

តែរបស់ព្រះអង្គ។ សូមព្រះអង្គជួយទូលបង្គំឱ្យបានធ្វើតែអ្វីដែលព្រះអង្គសព្វព្រះហឫទ័យ និងសូមព្រះអង្គជួយឱ្យទូលបង្គំបានបំពេញតែអ្វីដែលព្រះអង្គសព្វព្រះហឫទ័យ។

ពិតណាស់ព្រះអង្គគឺជាព្រះទាំងនៅក្នុងលោកនេះនិងលោកខាងមុខ។ ពិតណាស់ព្រះអង្គគឺជាព្រះលើកលែងទោសជាអនន្តនិងជាព្រះប្រកបដោយមេត្តាធម៌បំផុត។

-ព្រះបាហាអ៊ុលឡាហ៍-

* * * * *

ធម៌សូត្រសម្រាប់មនុស្សជាតិ

ឱព្រះអាទិទេពដែលទូលបង្គំបូជាសក្ការៈលោកអើយ! ទូលបង្គំសូមធ្វើជាសក្ខីភាពចំពោះសាមគ្គីភាពរបស់ព្រះអង្គ និងចំពោះភាពតែមួយរបស់ព្រះអង្គ ហើយទូលបង្គំក៏សូមទទួលយកអំណោយរបស់ព្រះអង្គទាំងកាលពីអតីតនិងទាំងនាបច្ចុប្បន្ននេះផងដែរ។ ពិតណាស់ព្រះអង្គគឺជាព្រះប្រកបដោយបុណ្យគ្រប់យ៉ាង ព្រះអង្គជាអ្នកបង្ហៀរនូវទឹកភ្លៀងរលឹមនៃមេត្តាធម៌របស់ព្រះអង្គដែលបានបង្អុរចុះមកដល់ទីខ្ពស់និងទីទំនាបស្មើៗគ្នា បន្ថែមពីនោះទៀតព្រះគឺជាអ្នកបង្ហៀរនូវភាពរុងរឿងនៃមនុញ្ញភាពរបស់ព្រះអង្គដែលត្រូវ

បានគេបង្ហូរមកលើទាំងអ្នកស្រេបនិងអ្នកប្រឆាំង។

ឱព្រះអាទិទេពនៃមេត្តាធម៌លោកអើយ ចំណែកមេត្តា

ធម៌ដ៏ប្រសើរបំផុតនោះបានបង្អោនចុះមកនៅចំពីមុខទ្វារ
របស់ព្រះអង្គហើយ ហើយមេត្តាធម៌នោះក៏បានចាក់ចូល
ទៅក្នុងចិត្តវិញ្ញាណរបស់វាកាន់តែជ្រៅនៅជុំវិញនៃបដិ
សរណដ្ឋាននៃបុព្វហេតុសប្បុរសជាទីស្រលាញ់របស់ព្រះអង្គក៏បាន
ព័ទ្ធជុំវិញរួចហើយដែរ ឱព្រះអាទិទេពនៃមេត្តាធម៌ លោកអើយ
ការទទូចអង្វរសុំមនុញ្ញភាពបុរាណរបស់ព្រះ
អង្គនិងការស្វែងរកការអនុគ្រោះរបស់ព្រះអង្គនាបច្ចុប្បន្ន នេះ
ពួកយើងសូមអង្វរព្រះអង្គសូមឱ្យព្រះអង្គប្រទានមេត្តា
ធម៌មកឱ្យពួកេយើងគ្រប់អ្នកទាំងឡាយណាដែលជាអ្នក
បញ្ចេញឱ្យពិភពមនុស្សបានឃើញ ហើយក៏សូមឱ្យព្រះអង្គ
កុំបដិសេធនឹងការទោរទន់ចិត្តរបស់ពួកគេទៅរកមនុញ្ញភាពរបស់
ព្រះអង្គនៅក្នុងយុគសម័យរបស់ព្រះអង្គនេះ។ ពិត ណាស់
ព្រះអង្គគឺជាព្រះមានអ្វីៗគ្រប់យ៉ាង ជាព្រះឈ្នះអស់
គ្រប់ឧបសគ្គនិងជាព្រះប្រកបដោយសព្វានុភាព ចំណែកឯ
ពួកយើងទាំងអស់គ្នាគឺជាអ្នកទន់ខ្សោយនិងជាអ្នកក្រខ្សត់។

-ព្រះបាហាអ៊ុលឡាហ៍-

ឱព្រះលោកអើយ ពិតណាស់ព្រះអង្គជាអ្នកបញ្ចាំងភាពរុងរឿងរបស់ព្រះអង្គមកលើសច្ចភាពដែលជាពន្លឺរបស់មនុស្ស ព្រះអង្គបានបង្ហូរពន្លឺនៃចំណេះដឹងនិងការដឹកនាំយ៉ាងត្រចះត្រចង់មកដល់ពួកគេ ហើយព្រះអង្គក៏បានជ្រើសរើសពួកគេចេញមកពីគ្រប់វត្ថុដែលបានបង្កើតឡើងមកនេះឱ្យកើតជាមនុញ្ញភាពដ៏វិសេស ហើយព្រះអង្គក៏បានញ៉ាំងឱ្យពួកគេមានរបស់គ្រប់យ៉ាង បានញ៉ាំងឱ្យពួកគេយល់ពីខ្លឹមសាររបស់ពួកគេកាន់តែច្រើន ហើយព្រះអង្គក៏បាន

ញ៉ាំងឱ្យពួកគេបង្ហាញពីអាថ៌កំបាំងរបស់ពួកគេដែលនាំឱ្យ

ពួកគេបានចូលទៅកាន់ពិភពដ៏ភ្លឺច្បាស់ប្រាស់ចាកពីភាព ងងឹតនេះ! "ពិតណាស់ មនុស្សដែលព្រះអង្គបានជ្រើសរើសនោះបានបង្ហាញពីមេត្តាធម៌ដ៏ពិសេសរបស់គាត់ទៅកាន់អ្នករាល់គ្នាដែលគាត់សព្វព្រះហឫទ័យ"។

ឱព្រះលោកអើយ សូមព្រះអង្គជួយដល់អ្នកដែលជាទីស្រលាញ់របស់ព្រះអង្គឱ្យបានទទួលនូវចំណេះដឹងបានទទួលនូវវិទ្យាសាស្ត្រ និងការទទួលនូវវិចិត្រសិល្បៈផងហើយក៏សូមព្រះអង្គជួយឱ្យពួកគេបានស្រាយបំភ្លឺនូវអាថ៌កំបាំងដែលត្រូវបានគេចាត់ទុកថាជារតនសម្បត្តិដែលមាន

តម្លៃមហាសាល ដោយពិតប្រាកដរបស់មនុស្សលោកគ្រប់គ្នាដែលបានគេបង្កើតមកនេះ។ សូមព្រះអង្គញ៉ាំងឱ្យគេបានពុតពីសច្ចភាពអាថ៌កំបាំងដែលត្រូវបានគេសរសេរនិងត្រូវ

បានគេបង្កប់នៅក្នុងបេះដូងរបស់មនុស្សគ្រប់គ្នា។ សូមព្រះ

អង្គញ៉ាំងឱ្យពួកគេបានក្លាយទៅជាទង់នៃការដឹកនាំនៅក្នុងចំណោមហ្វូងមនុស្សទាំងអស់ ហើយនិងសូមឱ្យពួកគេបានក្លាយទៅជាកាំរស្មីនៃសតិបញ្ញាដ៏មុតស្រួចដែលកំពុងតែបង្ហូរពន្លឺរបស់ពួកគេឱ្យចូលទៅក្នុង "ជីវិតដំបូង" នេះ។ សូមព្រះអង្គញ៉ាំងឱ្យពួកគេបានក្លាយទៅជាអ្នកនាំផ្លូវចូលទៅកាន់ព្រះអង្គ ជាមេខ្យល់ចូលទៅកាន់មាគ៌ារបស់ព្រះ អង្គ និងបានក្លាយជាអ្នកនាំសារដែលជម្រុញមនុស្សឱ្យបានទៅដល់រាជាណាចក្ររបស់ព្រះអង្គ។

ពិតណាស់ ព្រះអង្គជាព្រះប្រកបដោយសព្វានុភាព ជាអ្នកការពារ ជាអ្នកមានឫទ្ធិអំណាចខ្លាំងពូកែ ជាអ្នកឃុំគ្រងនិងជាព្រះប្រកបដោយព្រះទ័យសប្បុរសធម៌បំផុត។

-អង្គពិសិដ្ឋអាប់ឌុលបាហា-

ធម៌អធិដ្ឋានសំរាប់ផ្សព្វផ្សាយសាសនា

បពិត្រព្រះ! សូមទ្រង់មេត្តាផ្លាស់ស្បៃ ងងឹតនៃភាពស្រមើស្រមៃដែលបាំងបាត់ពីក្រសែចក្ខុរបស់ព្រះអង្គ ដើម្បីអោយគេបានរស់នៅក្រោម ការ គ្រងគ្រាប់តាមច្បាប់ព្រះអង្គ ហើយនិងដើម្បីឱ្យគេ បានបោះជំហាននៅលើដំណើរផ្លូវឆ្ពោះទៅកាន់ភាពសុខសាន្តរបស់ព្រះអង្គនិងត្រាច់ចរតាមគន្លងធម៌នៃ សាសនារបស់ព្រះអង្គផង។

-ព្រះបាហាអ៊ុលឡាហ៍-

ឱព្រះនៃទូលព្រះបង្គំអើយ! សូមព្រះអង្គលើកស្ទួយអ្នកបំរើរបស់ព្រះអង្គម្នាក់នេះ អោយបានបញ្ចេញពាក្យពេចន៍របស់ព្រះអង្គ ហើយសូមព្រះអង្គបញ្ចៀសឱ្យផុតនូវពាក្យពេចន៍ដែលមិនសមរម្យទាំងឡាយ និងសូមអោយពាក្យទាំងអស់ដែល ទូលបង្គំបាននិយាយចេញមកនោះ សុទ្ធតែជាពាក្យពិតដើម្បីផ្សព្វផ្សាយនូវព្រះវចនដ៏ពិសិដ្ឋទាំងនេះ ឱ្យបានទូលំទូលាយនិងបញ្ចេញនូវភាពរុងរឿង និង បណ្ដាលឱ្យរស្មីនៃអរុណោទ័យរះបំភ្លឺក្នុងដួងចិត្តសច្

ធម៌របស់ព្រះអង្គផង។ បពិត្រព្រះអង្គ ទ្រង់ជាអង្គ ដ៏សប្បុរសធម៌ និងមេត្តាករុណាដល់សត្វលោកទាំង ពួង។

-អង្គពិសិដ្ឋអាប់ឌុលបាហា-

ឱព្រះ សូមព្រះអង្គជួយបង្ហាញផ្លូវដល់ ទូលព្រះបង្គំ ហើយសូមព្រះអង្គប្រទានគំនិតនិង ជួយគាំពារគ្រប់កិច្ចការដើម្បីឱ្យទូលព្រះបង្គំបាន ក្លាយជាអ្នកនាំផ្លូវដល់ជនទាំងឡាយដែលត្រៀមខ្លួនទទួលសាស នារបស់ព្រះអង្គផង។

សូមឱ្យទូលព្រះបង្គំយើងខ្ញុំបានជួយត្រួសត្រាយ ផ្លូវដល់ពួកគេផង។ ពិតប្រាកដណាស់ព្រះអង្គទ្រង់ ករុណា ព្រះអង្គទ្រង់សប្បុរសធម៌ ព្រះអង្គមានអានុ ភាពលើវត្ថុទាំងពួង។

-អង្គពិសិដ្ឋអាប់ឌុលបាហា-

* * * * *

ធម៌អាពាហ៍ពិពាហ៍

"អាពាហ៍ពិពាហ៍តាមរបៀបបាហៃគឺជាការសំដែងនូវការរួបរួមនិងស្និទ្ធស្នាលរវាងគូភាគីទាំងសងខាង។ បើទោះជាយ៉ាងនេះក៏ដោយក៏ពួកគេត្រូវតែយកចិត្តទុកដាក់ និងប្រុងប្រយ័ត្នបំផុត ហើយក៏ត្រូវតែប្រកាន់ចរិតលក្ខណៈឱ្យបានស្និទ្ធស្នាលបំផុតជាមួយនឹងពួកគេម្នាក់ៗ។ ចំណងសាមគ្គីភាពជាអមតៈដែលកើតមកពីអាពាហ៍ពិពាហ៍នេះ នឹងត្រូវបានគេធ្វើឱ្យមានភាពសុខដុមរម្យនាដោយមានកិច្ចព្រមព្រៀងរឹងមាំ ហើយគោលបំណងនៃអាពាហ៍ពិពាហ៍នោះនឹងត្រូវបានគេជម្រុញឱ្យមានភាពត្រូវរូវគ្នា មានមិត្តភាពរវាគ្នា នឹងគ្នាមានសាមគ្គីភាពដើម្បីឱ្យបានទទួលនូវជីវិតអស់កាល ជាយូរអង្វែង"។

-អង្គពិសិដ្ឋអាប់ឌុលបាហា-

*ឃ្លាដែលត្រូវបានគេពោលពាក្យសច្ចារួមគ្នាដោយកូនកំលោះនិងកូនក្រមុំ ដែលមានសាក្សីដែលជាអ្នកតំណាងឱ្យ*

*ធម្មសភាចិត្តកម្ពលដ្ឋានមួយនាក់ និងសាក្សីដែលជាអ្នកតំណាងឱ្យខាងកូនកំលោះមួយនាក់ និងសាក្សីដែលជាអ្នកតំណាងឱ្យខាងកូនក្រមុំមួយនាក់។ពាក្យសច្ចាប្រណិធានដែលត្រូវពោលដោយកូនក្រមុំនិងកូនកំលោះនោះ គឺជាឃ្លាដែលមានចែងនៅក្នុងគម្ពីរគីតាប-អ៊ី-អាកដាស ដែលជាគម្ពីរសក្តិសិទ្ធិបំផុត ហើយពាក្យដែលត្រូវពោលសច្ចាប្រណិធាននៅក្នុងពិធីអាពាហ៍ពិពាហ៍នោះមានដូចតទៅ:* "ពិតណាស់យើងទាំងអស់គ្នានឹងគោរពតាមឆន្ទៈរបស់ព្រះ"។ ទ្រង់គឺជាព្រះអ្នកប្រទាន ទ្រង់គឺជាព្រះប្រកបដោយព្រះទ័យសប្បុរស! ទ្រង់គឺជាព្រះគួរឱ្យសរសើរ ជាព្រះពីបុរាណមកជាព្រះគង់នៅជាអមតៈ ជាព្រះតែមួយអង្គឥតផ្លាស់ប្តូរនិងជាព្រះ ជាអនន្ត! ទ្រង់គឺជាអ្នកដែលបានធ្វើជាសាក្សីដោយមនុស្ស អាទិទេព(ព្រះសាស្តា)ផ្ទាល់របស់ទ្រង់ថា ព្រះអង្គគឺពិតជាព្រះតែមួយអង្គឯកជាព្រះគ្មានពីរ ជាព្រះប្រកបដោយភាពសុខសាន្ត ជាព្រះគួរឱ្យសរសើរបំផុត។ ពិតណាស់យើងទាំងអស់គ្នាសូមធ្វើជាសក្ខីភាពថាក្រៅពីទ្រង់គ្មានព្រះណាទៀតឡើយហើយយើងក៏សូមទទួលស្គាល់ភាពតែមួយរបស់ទ្រង់ព្រមទាំងសូមទទួលស្គាល់ដល់ភាពស្មោះរបស់ទ្រង់ផងដែរ។ព្រះអង្គបានគង់នៅជាអចិន្ត្រៃយ៍ក្នុងទីដ៏ខ្ពង់ខ្ពស់ដែលមិនអាចនឹងពិពណ៌នាបាននៅលើកំពូលនៃភាពខ្ពង់ខ្ពស់របស់

ទ្រង់ជាអចិន្ត្រៃយ៍ គ្មាននរណាអាចធ្វើឱ្យព្រះអង្គបរិសុទ្ធពីរបស់សព្វយ៉ាងបានទេក្រៅពីព្រះអង្គខ្លួនអង្គឯង ក្រៅពីព្រះអង្គគ្មាននរណាពិពណ៌នាពីរបស់គ្រប់យ៉ាងបានឡើយ។ ហើយនៅពេលណាទ្រង់ប្រាថ្នាចង់បង្ហាញពីមនុញ្ញភាព ហើយនិងកុសលកម្មចំពោះមនុស្ស ហើយនិងចង់បង្កើតឱ្យពិភពលោកមានសណ្តាប់ធ្នាប់នោះទ្រង់បានបង្ហាញឱ្យឃើញពីបញ្ញត្តិនិងបង្កើតច្បាប់ឡើង ហើយនៅក្នុងចំណោមច្បាប់ដែលព្រះអង្គបានបង្កើតនោះមានច្បាប់អាពាហ៍ពិពាហ៍ដែលបង្កើតវាឡើងទុកជាបន្ទាយសម្រាប់សុខុមាលភាព និងសំរាប់ការពារពួកយើង ហើយព្រះអង្គបានបញ្ជូនច្បាប់នោះចេញមកពីឋានសួគ៌នៃសន្តភាពឱ្យនៅក្នុងគម្ពីរពិសិដ្ឋបំផុតរបស់ព្រះអង្គមកឱ្យពួកយើង។ ព្រះអង្គមានព្រះបន្ទូលថា "ឱមនុស្សលោកអើយ ចូរអ្នកចងមេត្រីជាប្តីប្រពន្ធឡើង ដើម្បីឱ្យអ្នកអាចមានមនុស្សនឹងនិយាយពីតថាគតនៅក្នុង

ចំណោមអ្នកបម្រើរបស់តថាគត ព្រោះភាពរុងរឿងរបស់ព្រះអង្គអស្ចារ្យណាស់។ នេះគឺជាបញ្ញត្តិរបស់តថាគតចំ ពោះអ្នក ចូរអ្នកប្រញាប់ចាប់យកពួកវាទុកជាជំនួយចំពោះ

ខ្លួនអ្នកចុះ"។

-ព្រះបាហាអ៊ុលឡាហ៍-

ទ្រង់គឺជាព្រះ! ឱព្រះដ៏ខ្ពង់ខ្ពស់គ្មានគូប្រៀបលោកអើយ!ដើម្បីឱ្យកំណើតរបស់មនុស្សអាចស្អងគ្នាបាននៅក្នុងពិភពដែលពឹងពាក់គ្នានេះ ព្រះអង្គបានបង្កើតឱ្យមានចំណងអាពាហ៍ពិពាហ៍ ឱ្យមនុស្សគ្រប់សាសន៍ដែលមាននៅក្នុងគតិបណ្ឌិត ដែលប្រកបដោយឫទ្ធិអំណាចដ៏អស្ចារ្យរបស់ព្រះ អង្គ ហើយតាមរយៈអាពាហ៍ពិពាហ៍នោះពួកគេអាចសម្តែងខ្លួនរបស់ពួកគេនៅឯធរណីទ្វារ(ច្រកចូល)នៃភាពតែមួយរបស់ព្រះអង្គដែលមានការបម្រើនិងការគោរពបូជាដែលមានការការពារ ការគោរពស្រលាញ់ ហើយនិងការ

លើកតម្កើងជារៀងរហូតដរាបណាពិភពនេះនឹងនៅមាន។ "ខ្ញុំ(ចំណងអាពាពិពាហ៍)មិនមែនជាអ្នកបង្កើតវិញ្ញាណ និង មនុស្សឡើយ ប៉ុន្តែមនុស្សគួរតែគោរពខ្ញុំ"។ ដូច្នេះសូមព្រះអង្គរៀបអាពាហ៍ពិពាហ៍ឱ្យបក្សាបក្សីដែលមានសម្បុកនៃក្តីស្រលាញ់របស់ព្រះអង្គមួយគូនេះនៅក្នុងឋានសួគ៌នៃមេត្តាធម៌របស់ព្រះអង្គហើយក៏សូមព្រះអង្គធ្វើឱ្យពួកគេបានក្លាយជាធនធាននៃការទាក់ចិត្តជិតអារម្មណ៍ដល់មនុញ្ញភាពជា និច្ចផង

លេកនៃភាពទន់ភ្លន់ដែលកើតចេញមកពីភាពរួបរួម
គ្នានៃមហាសាគរនៃក្តីស្រលាញ់ទាំងពីរនេះនឹងអាចខ្ទោល ឡើង
ហើយនិងអាចបញ្ចាំងពីរតនវត្ថុនៃភាពល្អនិងបរិសុទ្ធ
នៅលើឆ្នេរនៃឆាកជីវិតនេះ។ "ដើម្បីឱ្យពួកគេបានជួបគ្នា
នោះព្រះអង្គបានប្រកាសពីមហាសាគរទាំងពីរនេះថា នៅ
ចន្លោះពួកគេគឺជារនាំងមួយដែលពួកគេមិនអាចឆ្លងកាត់
បានឡើយ។ អ៊ីចឹងតើសប្បុរសធម៌របស់ព្រះរបស់អ្នកមួយ
ណាដែលអ្នកនឹងមិនទទួលស្គាល់នោះ។ ទ្រង់បានយករតន
វត្ថុនោះមានច្រើនមានតិចពីពួកគេម្នាក់ៗនោះ"។

ឱព្រះអង្គដែលជាព្រះមានព្រះទ័យល្អលោកអើយ!
សូមព្រះអង្គធ្វើឱ្យអាពាហ៍ពិពាហ៍នេះមានផ្កាផ្លែថ្លៃថ្លាដូច
ផ្កាថ្មនិងគុជខ្យងផង។ ពិតណាស់ព្រះអង្គគឺជាព្រះមានអំ
ណាចគ្រប់យ៉ាង ជាព្រះដ៏អស្ចារ្យបំផុតនិងជាព្រះលើកលែង
ទោសឱ្យជាអានន្ត។

-អង្គពិសិដ្ឋអាប់ឌុលបាហា-

ឱព្រះអាទិទេពជាម្ចាស់លោកអើយ ព្រះអង្គគឺជា
ព្រះប្រកបដោយភាពរុងរឿង! ពិតណាស់ទាសៈរបស់ព្រះ

អង្គម្នាក់នេះនិងទាសីរបស់ព្រះអង្គម្នាក់នេះបានមកប្រមូលផ្តុំជួបជុំគ្នានៅក្រោមម្លប់នៃមេត្តាធម៌របស់ព្រះអង្គ ហើយពួកគេក៏ត្រូវបានគេបង្រួបបង្រួមគ្នាតាមរយៈការអនុគ្រោះ ហើយនិងភាពសប្បុរសរបស់ព្រះអង្គ។ ឱព្រះម្ចាស់លោក អើយ! សូមព្រះអង្គជួយប្រដុងប្រជាពួកគេឱ្យបាននៅក្នុងពិភពរបស់ព្រះអង្គនេះ និងបាននៅក្នុងរាជាណាចក្ររបស់ព្រះអង្គផងហើយក៏សូមព្រះអង្គទំនុកបម្រុងគ្រប់អំពើល្អឱ្យពួកគេតាមរយៈបុណ្យ និងតាមរយៈមនុញ្ញភាពរបស់ព្រះ អង្គផង។ ឱព្រះម្ចាស់លោកអើយ! សូមព្រះអង្គយល់ព្រមឱ្យពួកគេបានស្ថិតនៅក្នុងសេវគតិភាពរបស់ព្រះអង្គហើយក៏សូមព្រះអង្គជួយប្រដុងប្រជាឱ្យពួកគេបាននៅក្នុងមាគ៌ាការបម្រើរបស់ព្រះអង្គផង។ សូមព្រះអង្គអនុញ្ញាតឱ្យពួកគេបានក្លាយជាសញ្ញានៃព្រះនាមរបស់ព្រះអង្គនៅក្នុងពិភពរបស់ព្រះអង្គ ហើយក៏សូមព្រះអង្គការពារពួកគេតាម

រយៈអំណោយរបស់ព្រះអង្គដែលជាអំណោយមិនចេះចប់នៅក្នុងពិភពនេះនិងពិភពបន្ទាប់ផង។ ឱព្រះម្ចាស់លោក អើយ! ឥឡូវនេះពួកគេកំពុងតែអង្វររករាជាណាចក្រនៃមេត្តាធម៌របស់ព្រះអង្គ ហើយក៏កំពុងតែបួងសួងសំបូងសម្រូងដល់រាជាណាចក្រនៃភាពស្មោះត្រង់របស់ព្រះអង្គ ផងដែរ។ ពិតណាស់ពួកគេបានរៀបការនឹងគ្នាដោយគោរព

តាមបញ្ញត្តិរបស់ព្រះអង្គ។ ដូច្នោះសូមព្រះអង្គញ៉ាំងឱ្យពួកគេបានក្លាយជាសញ្ញានៃភាពត្រូវរូវគ្នា និងជាសញ្ញានៃភាពរួបរួមគ្នារហូតដល់អស់កាលផង។ ពិតណាស់ព្រះអង្គគឺជាព្រះប្រកបដោយសព្វានុភាព ជាព្រះមានវត្តមានគ្រប់ទីកន្លែងនិងជាព្រះប្រកបដោយមហិទ្ធិឫទ្ធិ!

-អង្គពិសិដ្ឋអាប់ឌុលបាហា-

ឱព្រះរបស់ទូលបង្គំលោកអើយ ឱព្រះម្ចាស់របស់ទូលបង្គំលោកអើយ! តាពារិថីដ៏ភ្លឺថ្លាមួយគូនេះត្រូវបានគេរៀបការឱ្យដោយក្តីស្រលាញ់របស់ព្រះអង្គ ត្រូវបានគេចងស្ពានមេត្រីភាពជាមួយគ្នាដោយសេវគតិភាពទៅនឹងធរណី

ទ្វារស័ក្តសិទ្ធិរបស់ព្រះអង្គនិងត្រូវបានគេបង្រួបបង្រួមគ្នានៅក្នុងការជួយបម្រើដល់បុព្វហេតុសាសនារបស់ព្រះអង្គ។ ឱព្រះម្ចាស់របស់ទូលបង្គំលោកអើយ សូមព្រះអង្គធ្វើឱ្យ

អាពាហ៍ពិពាហ៍នេះបានក្លាយជាពន្លឺដែលជាសរសៃអំបោះនៃមនុញ្ញភាពដ៏ឧត្តមរបស់ព្រះអង្គ បពិត្រព្រះអង្គជាព្រះសប្បុរសធម៌ ជាព្រះមានមេត្តាធម៌គ្រប់យ៉ាងនិងជាព្រះអ្នកបញ្ចេញពន្លឺកាំរស្មីនៃអំណោយរបស់ព្រះអង្គ ជាព្រះអ្នកប្រទានឱ្យជានិច្ចដើម្បីឱ្យមែកធាងអាចចេញពីដើមដែលជា

មែកដ៏សំខាន់អស្ចារ្យនេះនឹងមានភាពខៀវខ្ចី ហើយនិងដើម្បីឱ្យវាបានចម្រើនតាមរយៈអំណោយដែលជាទឹកភ្លៀងស្រក់ចុះមកពីពពកនៃមនុញ្ញភាពរបស់ព្រះអង្គផង។ ពិតណាស់ព្រះអង្គគឺជាព្រះប្រកបដោយសប្បុរសធម៌។ ពិតណាស់ព្រះអង្គជាព្រះប្រកបដោយមហិទ្ធិឫទ្ធិ។ ពិតណាស់ព្រះអង្គគឺជាព្រះប្រកបដោយក្ដីករុណា និងជាព្រះប្រកបដោយមេត្តាធម៌គ្រប់យ៉ាង។

-អង្គពិសិដ្ឋអាប់ឌុលបាហា-

* * * * *

ធម៌សូត្រសម្រាប់ការបម្រើ

ឱព្រះអាទិទេពដែលជាព្រះនៃនាមគ្រប់យ៉ាង និងជាអ្នកបង្កើតឋានសួគ៌អើយ! ទូលបង្គំសូមអង្វរព្រះអង្គដោយព្រះនាមរបស់ព្រះអង្គ ព្រះនាមរបស់ព្រះអង្គនោះគឺជាព្រះសាស្តាដែលជាប្រភពរីករាយនៃមហិទ្ធិឫទ្ធិរបស់ព្រះអង្គ ហើយនិងជាទីកន្លែងអរុណ្ណោភាសដែលត្រូវបានគេបញ្ចេញឱ្យឃើញពីអំណាចរបស់ព្រះអង្គ ព្រះនាមនោះគឺជាព្រះនាមដែលធ្វើឱ្យវត្ថុរឹងគ្រប់យ៉ាងបានក្លាយជាវត្ថុរាវអាចហូរបាន ព្រះនាមនោះគឺជាព្រះនាមដែលអាចធ្វើឱ្យគ្រប់រូបកាយដែលអស់សង្ឃឹមអាចមានសង្ឃឹមឡើងវិញ និងជាព្រះនាមដែលធ្វើឱ្យគ្រប់ស្មារតីដែលកំពុងធ្វើចលនាទុកចិត្តឡើង-នៅពេលនេះទូលបង្គំអង្វរព្រះអង្គសូមឱ្យទូលបង្គំបានកំចាត់

ចោលដោយខ្លួនឯងនូវគ្រប់ការជំពាក់ចិត្តទៅនឹងនរណា

ម្នាក់ក្រៅពីព្រះអង្គ សូមឱ្យទូលបង្គំបានបម្រើដល់បុព្វហេតុ

សាសនារបស់ព្រះអង្គ សូមឱ្យទូលបង្គំមានបំណងប្រាថ្នាស្របតាមបំណងប្រាថ្នាដែលព្រះអង្គមានតាមរយៈអំណាចនៃអធិបតេយ្យភាពរបស់ព្រះអង្គ ហើយនិងសូមឱ្យទូលបង្គំបានធ្វើអ្វីដែលជាអំពើគាប់ប្រសើរ ស្របតាមឆន្ទៈរបស់ព្រះអង្គផង។

ឱព្រះម្ចាស់របស់ទូលបង្គំលោកអើយ ទូលបង្គំអង្វរព្រះអង្គសូមទ្រង់ប្រទានឱ្យទូលបង្គំបន្ថែមទៀតនូវអ្វីដែលនឹងធ្វើឱ្យទូលបង្គំមានគ្រប់គ្រាន់ ដើម្បីកុំឱ្យទូលបង្គំត្រូវការអ្នកផ្សេងក្រៅពីព្រះអង្គ។ ឱព្រះម្ចាស់របស់ទូលបង្គំលោក អើយ ព្រះអង្គទតឃើញទូលបង្គំនិងមុខរបស់ទូលបង្គំបាន

ងាកឆ្ពោះទៅកាន់ព្រះអង្គ ហើយហត្ថារបស់ទូលបង្គំកំពុងតែរឹតជាប់ទៅនឹងខ្សែនៃមនុញ្ញភាពរបស់ព្រះអង្គហើយ។ សូមព្រះអង្គបញ្ជូនមេត្តាធម៌របស់ព្រះអង្គឱ្យបានមកដល់ទូលបង្គំនិងសូមព្រះអង្គកត់ត្រាឱ្យទូលបង្គំនូវអ្វីដែលព្រះអង្គបានកត់ត្រាឱ្យអ្នកដែលជាជម្រើសរបស់ព្រះអង្គផង។

ព្រះអង្គគឺជាព្រះប្រកបដោយសព្វានុភាពដែលអាចធ្វើអ្វីៗបានតាមព្រះហឫទ័យ។គ្មានព្រះឯណាក្រៅពីព្រះអង្គឡើយ ព្រះអង្គគឺជាព្រះលើកលែងទោសជានិច្ចជាព្រះប្រកបដោយព្រះទ័យមេត្តា។

-ព្រះបាហាអ៊ុលឡាហ៍-

* * * * *

ធម៌សូត្រសម្រាប់ការលូតលាស់ផ្នែកខាងស្មារតី

ឱព្រះម្ចាស់របស់ទូលបង្គំលោកអើយ សូមព្រះអង្គប្រទានឱ្យទូលបង្គំបានផឹកទឹកអម្រឹតពីស្ទឹងដែលមានក្លិនដ៏ក្រអូបពីអនន្តភាពរបស់ព្រះអង្គ ហើយក៏សូមព្រះអង្គប្រទានឱ្យទូលបង្គំបានភ្លក់រសជាតិនៃផ្លែឈើនៃជីវិតរស់របស់ព្រះអង្គផង ឱព្រះអង្គដែលជាទីពឹងរបស់ទូលបង្គំលោកអើយ!ឱព្រះដែលជាភាពរុងរឿងដ៏ខ្ពង់ខ្ពស់លោកអើយសូមព្រះអង្គអនុញ្ញាតឱ្យទូលបង្គំបានផឹកទឹកពីប្រភពទឹកដ៏ថ្លានៃកែវគ្រីស្តាល់នៃក្តីស្រលាញ់របស់ព្រះអង្គ ហើយក៏សូមព្រះអង្គអនុញ្ញាតឱ្យទូលបង្គំបានរស់នៅក្រោមម្លប់នៃទិព្វវិញ្ញាណជាអនន្តផង ឱព្រះអង្គដែលជាពន្លឺរបស់ទូលបង្គំលោកអើយ! ឱព្រះដ៏ជាទីស្រលាញ់របស់ទូលបង្គំលោក អើយ សូមព្រះអង្គញ៉ាំងឱ្យទូលបង្គំបានត្រាច់ចរនៅក្នុងវាល

ស្មៅនៃការនៅជិតព្រះអង្គចំពីមុខព្រះវត្តមានរបស់ព្រះអង្គ

ហើយក៏សូមព្រះអង្គអនុញ្ញាតឱ្យទូលបង្គំបាននៅអង្គុយនៅ

ខាងស្តាំព្រះហស្តនៃរាជបល្ល័ង្កនៃមេត្តាធម៌របស់ព្រះអង្គផង ឱព្រះអង្គដែលជាទីប្រាថ្នារបស់ទូលបង្គំលោកអើយ! ឱព្រះអង្គដែលជាគោលដៅរបស់ទូលបង្គំលោកអើយ សូមព្រះអង្គញ៉ាំងឱ្យដង្ហើមបានឆ្លងកាត់មកលើទូលបង្គំពីវាយោដ៏ក្រអូបនៃភាពរីករាយរបស់ព្រះអង្គ ហើយក៏សូមព្រះអង្គញ៉ាំងឱ្យទូលបង្គំមានការអនុញ្ញាតបានចូលទៅកាន់ទីឋានសួគ៌ដ៏ខ្ពង់ខ្ពស់នៃភាពពិតរបស់ព្រះអង្គផង ឱព្រះឯកដែលជាទីស្រលាញ់របស់ទូលបង្គំលោកអើយ! ឱព្រះអង្គឯកដ៏មានភាពត្រចះត្រចង់អើយ សូមព្រះអង្គអនុញ្ញាតឱ្យទូលបង្គំបានស្តាប់ទៅនឹងបទភ្លេងរបស់អ្នកស្វែងរកនៃភាពតែមួយរបស់ព្រះអង្គ ហើយក៏សូមព្រះអង្គធ្វើឱ្យទូលបង្គំកើតមានស្មារតី ឡើងតាមរយៈស្មារតីនៃអំណាចរបស់ព្រះអង្គ ហើយនិងមហិទ្ធិឫទ្ធិរបស់ព្រះអង្គផង ឱព្រះអង្គដែលជាអ្នកផ្តល់ឱ្យរបស់ទូលបង្គំលោកអើយ! ឱអ្នកសង្គ្រោះរបស់ទូលបង្គំ លោកអើយ សូមព្រះអង្គរក្សាការពារទូលបង្គំឱ្យមានភាព រឹងមាំនៅក្នុងចិត្តវិញ្ញាណនៃក្តីស្រលាញ់របស់ព្រះអង្គ ហើយក៏សូមព្រះអង្គបង្កើតជំហានរបស់ទូលបង្គំឱ្យបានរឹងមាំនៅ

ក្នុងមាគ៌ានៃភាពសប្បាយរីករាយរបស់ព្រះអង្គផង ឱអ្នកបង្កើតរបស់ទូលបង្គំលោកអើយ!ឱព្រះអង្គដែលជាព្រះមានមេត្តាចំពោះទូលបង្គំអើយ សូមព្រះអង្គញ៉ាំងឱ្យទូលបង្គំបានរស់នៅក្នុងសួនឧទ្យាននៃអមតភាពរបស់ព្រះអង្គចំពោះព្រះភក្ត្ររបស់ព្រះអង្គជារៀងរហូតហើយក៏សូមព្រះអង្គធ្វើ

ឱ្យទូលបង្គំមានស្ថិរភាពនៅលើកៅអីនៃភាពរុងរឿងដ៏ខ្ពង់ខ្ពស់របស់ព្រះអង្គផង ឱព្រះអង្គដែលជាម្ចាស់ភោគទ្រព្យ

របស់ទូលបង្គំលោកអើយ! ឱអ្នកដែលជាទីសង្ឃឹមរបស់

ទូលបង្គំលោកអើយ សូមព្រះអង្គលើកឱ្យទូលបង្គំបានខ្ពស់

ទៅដល់ឋានសួគ៌នៃព្រះទ័យសប្បុរសធម៌ជាទីស្រលាញ់

របស់ព្រះអង្គ ហើយក៏សូមព្រះអង្គនាំទូលព្រះបង្គំឱ្យបាន

ទៅកាន់តារាប្រចាំភព(ព្រះបាហាអ៊ុលឡាហ៍)នៃការដឹកនាំបង្ហាញផ្លូវរបស់ព្រះអង្គផង ឱព្រះអង្គដែលជាអ្នកទាក់ចិត្តដិតអារម្មណ៍របស់ទូលបង្គំលោកអើយ! ឱព្រះអង្គដែលជាប្រភពកំណើតរបស់ទូលព្រះបង្គំ ហើយនិងជាទីប្រាថ្នាដ៏ខ្ពស់បំផុតរបស់ទូលបង្គំលោកអើយ សូមព្រះអង្គគាស់ហៅឱ្យ

ទូលបង្គំបានមានវត្តមាននៅចំពីមុខនៃការបង្ហាញឱ្យឃើញពីចិត្តវិញ្ញាណដ៏អាថ៌កំបាំងរបស់ព្រះអង្គ ហើយក៏សូមព្រះអង្គញ៉ាំងឱ្យទូលព្រះបង្គំបានឯាកមកកាន់ភាពសំខាន់នៃក្លិនពិដោរនៃសោភ័ណភាពរបស់ព្រះអង្គដែលព្រះអង្គនឹងបង្ហាញឱ្យឃើញនាពេលអនាគតនេះផង ឱព្រះអង្គដែលជាព្រះម្ចាស់របស់ទូលបង្គំលោកអើយ! ព្រះអង្គគឺជាព្រះដែលប្រកបដោយសញ្ញានុភាពអាចធ្វើអ្វីៗបានទៅតាមព្រះទ័យរបស់ព្រះអង្គ។ ពិតណាស់ព្រះអង្គគឺជាព្រះដ៏ខ្ពង់ខ្ពស់បំផុតជាព្រះដែលប្រកបដោយភាពរុងរឿងគ្រប់យ៉ាងនិងជាព្រះដ៏ខ្ពង់ខ្ពស់អស់សត្វមនុស្សទាំងពួង។

-ព្រះបាហាអ៊ុលឡាហ៍-

* * * * *

ធម៌សូត្រសំរាប់អង្គប្រជុំរបស់សភា

នៅពេលណាក៏ដោយតែអ្នកចូលទៅកាន់សភាអង្គប្រជុំក្រុមប្រឹក្សានោះ ចូរអ្នកសូត្រធម៌នេះដោយបេះដូងមានក្តីស្រលាញ់របស់ព្រះ ហើយនិងដោយបន្សុទ្ធអណ្តាតឱ្យបរិសុទ្ធពីវត្ថុគ្រប់យ៉ាងលើកលែងតែការចងចាំដល់ព្រះដែលជាព្រះប្រកបដោយសព្វានុភាពគ្រប់យ៉ាងសុំឱ្យព្រះអង្គជួយដល់អ្នកបានទទួលជ័យជំនះដ៏ឧត្តមឡើង។

ឱព្រះដែលជាព្រះរបស់ទូលបង្គំលោកអើយ! យើងទាំងអស់គ្នាគឺជាអ្នកបម្រើរបស់ព្រះអង្គដែលបានងាកទៅរកព្រះភក្រ្តដ៏ពិសិដ្ឋរបស់ព្រះអង្គដោយចិត្តភក្តីហើយក៏ជាអ្នកបម្រើដែលបានលះបង់ខ្លួនពីវត្ថុគ្រប់យ៉ាងលើកលែងតែព្រះអង្គដែលជាព្រះប្រកបដោយភាពរុងរឿងនៅក្នុង

សម័យនេះផងដែរ។ នៅពេលនេះយើងបានជួបជុំគ្នានៅ

ក្នុងអង្គប្រជុំសភា ហើយក៏បានរួបរួមសាមគ្គីគ្នាជាទស្សនៈ និងគំនិតរបស់ពួកយើងដែលប្រកបដោយបំណងត្រូវរ៉ូវគ្នា របស់ពួកយើងដើម្បីលើកតម្កើងបន្ទូលរបស់ព្រះអង្គឱ្យខ្ពង់ខ្ពស់ក្នុង ចំណោមហ្វូងមនុស្សផងដែរ។ ឱព្រះដែលជាម្ចាស់ របស់ទូលបង្គំលោកអើយ!ឱព្រះអង្គដែលជាព្រះម្ចាស់ដ៏ខ្ពង់ខ្ពស់រប ស់ទូលបង្គំយើងខ្ញុំទាំងអស់គ្នាអើយ សូមព្រះអង្គធ្វើ ឱ្យទូលបង្គំយើងខ្ញុំទាំងអស់គ្នាបានក្លាយជាសញ្ញានៃការដឹកនាំបង្ហា ញផ្លូវដ៏ល្អឥតខ្ចោះរបស់ព្រះអង្គ ក្លាយជាស្តង់ដារនៃ ជំនឿដ៏ខ្ពង់ខ្ពស់របស់ព្រះអង្គនៅក្នុងចំណោមហ្វូងមនុស្ស ក្លាយជាអ្នកបម្រើទៅនឹងកិច្ចព្រមព្រៀងដែលប្រកបដោយ ឫទ្ធានុភាពរបស់ព្រះអង្គ ក្លាយជាអ្នកបង្ហាញពីសាមគ្គីធម៌ដ៏ ឥតខ្ចោះរបស់ព្រះអង្គដែលមាននៅក្នុងរាជាណាចក្ររុង រឿងរបស់ព្រះអង្គ ហើយនិងសូមឱ្យទូលបង្គំយើងខ្ញុំទាំង អស់គ្នាបានក្លាយជាតារាដែលបញ្ចេញរស្មីប្រកបដោយភាព រុងរឿងដល់គ្រប់តំបន់ភូមិភាគទាំងអស់ផង។

ឱព្រះសមត្ថិទេពលោកអើយ! សូមព្រះអង្គជួយឱ្យ ទូលបង្គំយើងខ្ញុំបានក្លាយជាមហាសាគរដែលកំពុងតែខ្ទោល ឡើងដោយរលកនៃមនុញ្ញភាពដ៏អស្ចារ្យរបស់ព្រះអង្គ បាន

ក្លាយជាស្នឹងដែលកំពុងតែហូរចេញពីគ្រប់ទីដ៏ខ្ពង់ខ្ពស់ដែលប្រកបដោយភាពរុងរឿងរបស់ព្រះអង្គបានក្លាយជាផល្លានុផលដ៏ល្អពិតដែលនៅលើដើមនៃបុព្វហេតុសាសនាស្នូគិរបស់ព្រះអង្គហើយនិងបានក្លាយជាដើមឈើដែលកំពុងតែបក់រវិចៗដោយវាយោរំភើយៗនៃសោភ័ណភាពរបស់ព្រះអង្គដែលមាននៅក្នុងសួនទំពាំងបាយជូរទិព្វរបស់ព្រះអង្គផង។ ឱសមត្ថទិទេពម្ចាស់លោកអើយ! ដើម្បីឱ្យពួកយើងបានរួមសាមគ្គីគ្នាជារលកនៃមហាសាគរតែមួយនិងបានរួមចូលគ្នាជាកាំរស្មីនៃពន្លឺប្រិមប្រិយរបស់ព្រះអង្គ ហើយនិងដើម្បីឱ្យគំនិតរបស់យើង ទស្សនៈរបស់យើង អារម្មណ៍របស់យើងបានក្លាយជាសច្ចភាពតែមួយដែលស្តែងចេញឱ្យឃើញនូវស្មារតីនៃការរួបរួមគ្នាពាសពេញពិភពលោកនោះ សូមព្រះអង្គធ្វើឱ្យស្មារតីរបស់ពួកយើងស្របតាមកំណាព្យនៃសាមគ្គីភាពដ៏ល្អឥតខ្ចោះរបស់ព្រះអង្គ និងសូមព្រះអង្គធ្វើឱ្យដួងចិត្តរបស់ពួកយើងបានអបអរនឹងដំណឹងនៃមនុញ្ញភាពរបស់

ព្រះអង្គផង។ ព្រះអង្គគឺជាព្រះប្រកបដោយមនុញ្ញភាពជាព្រះប្រកបដោយបុណ្យ ជាព្រះអ្នកប្រទានអ្វីៗគ្រប់យ៉ាងជាព្រះប្រកបដោយឫទ្ធិអំណាច ជាព្រះប្រកបដោយមេត្តាធមិនិងជាព្រះប្រកបដោយក្តីករុណា។

-អង្គពិសិដ្ឋអាប់ឌុលបាហា-

ធម៌សាមគ្គីភាព

ឱសមត្ថទិទេពម្ចាស់លោកអើយ! ឱព្រះរបស់ទូលបង្គំលោកអើយ! សូមព្រះអង្គបង្រួបបង្រួមចិត្តគំនិតនៃអ្នកបម្រើរបស់ព្រះអង្គ និងសូមព្រះអង្គស្តែងអោយពួកគេបានឃើញនូវព្រះរាជដ៏អស្ចារ្យរបស់ព្រះអង្គផង។ សូមអោយពួកគេបានធ្វើតាមបញ្ញានិងបញ្ញត្តិដែលមាននៅក្នុងច្បាប់វិន័យរបស់ព្រះអង្គ។ ឱព្រះអាទិទេពលោកអើយសូមព្រះអង្គជួយឲ្យពួកគេមានការខំប្រឹងប្រែង ហើយនិងសូមព្រះអង្គផ្តល់កម្លាំងឲ្យពួកគេបានបម្រើព្រះអង្គផង។ ឱព្រះលោកអើយ! សូមព្រះអង្គកុំទុកឲ្យពួកគេនៅតែលតោលតែម្នាក់ឯង សូមព្រះអង្គនាំជំហានរបស់ពួកគេដោយពន្លឺនៃចំណេះដឹងរបស់ព្រះអង្គ ហើយសូមទ្រង់ញ៉ាំងឲ្យបេះដូងរបស់ពួកគេបានរីករាយដោយក្តីស្រលាញ់របស់ព្រះអង្គផង។ ពិតណាស់ព្រះអង្គគឺជាអ្នកទ្រទ្រង់ពួកគេនិងជាព្រះម្ចាស់របស់ពួកគេ។

ព្រះបាហាអ៊ុលឡាហ៍

* * * * *

*១.ឱ!ព្រះអង្គអើយ សូមជួយផ្សះផ្សា បេះដូងប្រេះ ឆា នៃអ្នកបម្រើ សូមបង្ហាញផ្លូវ ទៅកាន់ព្រះអង្គ ត្រចះត្រចង់ នៃព្រះអង្គម្ចាស់ ដើម្បីឱ្យគេ បានប្រ តិបត្ត តាមធម្មបញ្ញត្តិ ក្នុងធម៌ព្រះអង្គ ។*

*២.ឱ!ព្រះអង្គអើយ សូមជួយទ្រទ្រង់ ឱ្យគេស្ថិតក្នុង ស្ថានភាពប្រឹងប្រែង សូមមានកម្លាំង ពលំខ្លាំងក្លា យើងខ្ញុំករុណា បានប្រកាន់ខ្ជាប់ សូមឱ្យយើងខ្ញុំ បានស្នាក់អាស្រ័យ ក្រោមម្លប់បារមី របស់ព្រះអង្គ។*

*៣.ឱ!ព្រះអង្គអើយ សូមទ្រង់កុំឱ្យយើងខ្ញុំទន់ខ្សោយ តែម្នាក់ឯងឡើយ សូមព្រះអង្គជួយ នាំជើងទាំងទ្វេ របស់ពួកគេ ដោយព្រះបញ្ញា ទ្រង់ជួយបំភ្លឺ ក្នុង ដួងចិន្តា ដោយក្ដីករុណា របស់ព្រះអង្គ ។*

*ពិតណាស់ព្រះអង្គ ទ្រង់ជាអ្នកជួយ ជាអង្គតែមួយ របស់យើងខ្ញុំ ។*

-

ព្រះបាហាអ៊ុលឡាហ៍-

ធម៌សូត្រតមអាហារ

*នៅក្នុងគម្ពីរគីតាបអ៊ីអាកដាសពោលថា: "យើងបាន បញ្ញត្តិឱ្យអ្នកសូត្រធម៌ហើយនិងតមអាហារចាប់ពីអាយុបក្ក*

*ភាពដែលមានអាយុចាប់ពី១៥ឆ្នាំឡើងទៅ។បញ្ញត្តិនេះត្រូវ បានគេកំណត់ឡើងដោយព្រះដែលជាម្ចាស់របស់អ្នក ហើយ និងជាព្រះរបស់បុព្វបុរសរបស់អ្នក......ច្បាប់តមអាហារនេះ មានការលើកលែងចំពោះអ្នកធ្វើដំណើរផ្លូវឆ្ងាយ អ្នកមាន កូនខ្ចី*

*អ្នកបំបៅដោះកូន ជនចាស់ជរាហើយនិងអ្នកមិនទាន់គ្រប់អាយុដូចបានរៀបរាប់ខាងលើ........ចំណែកឯអ្នកដែលត្រូវតមគឺត្រូវចាប់ផ្តើមតមមិនញ៉ាំមិនផឹកចាប់ពីថ្ងៃរះហើយអ្នកដែលចាប់ផ្តើមតមនោះត្រូវយកចិត្តទុកដាក់កុំឱ្យអារម្មណ៍របស់អ្នកអូសទាញអ្នកឱ្យប្រាស់ចាកពីបញ្ញត្តិដែល*

*មាននៅក្នុងគម្ពីរនោះ”។*

*ការតមអាហារនេះគឺចាប់ផ្តើមឡើងពីថ្ងៃទី២ខែមិនារហូតដល់ថ្ងៃទី២០ខែមិនាជារៀងរាល់ឆ្នាំ។*

ឱព្រះម្ចាស់របស់ទូលបង្គំលោកអើយថ្ងៃនេះគឺជាថ្ងៃទីមួយក្នុងចំណោមថ្ងៃដែលព្រះអង្គបានបញ្ញត្តិឱ្យអ្នកដែលជាទីស្រលាញ់របស់ព្រះអង្គប្រតិបត្តិច្បាប់តមអាហារនេះ។ ទូលបង្គំសូមបួងសួងសុំព្រះអង្គសូមទ្រង់បន្សុទ្ធអ្នកបម្រើរបស់ព្រះអង្គ និងអ្នកដែលបានតមអាហារដោយសារតែក្តីស្រលាញ់ចំពោះព្រះអង្គនិងដោយសារតែក្តីស្រលាញ់ចំពោះមេត្តារបស់ព្រះអង្គគឺថាមិនមែនដោយសារតែខ្លួនឯង និងមិនមែនដោយសារតែចំណងនោះឡើយ ហើយក៏មិនមែនដោយសារតែខ្លាចមានកំហឹងពីព្រះអង្គដែរ-គឺថាគេតមអា

ហារដោយសារតែនាមនិងកេតណាភ័ណ្ឌដ៏ខ្ពង់ខ្ពស់ជាទីប្រណីតបំផុតរបស់ព្រះអង្គ សូមព្រះអង្គបន្សុទ្ធអ្នកបម្រើរបស់ព្រះអង្គដោយអង្គឯងផ្ទាល់ពីការទាក់ចិត្តជិតអារម្មណ៍នឹងវត្ថុទាំងពួងលើកលែងតែព្រះអង្គ ហើយសូមព្រះអង្គអូសទាញពួកគេឱ្យបានចូលដល់ទីកន្លែងអរុណ្ណោភាសដែលជាពន្លឺនៃការលើកទឹកចិត្តរបស់ព្រះអង្គ ហើយនិងកៅអីរាជបល្ល័ង្កនៃភាពតែមួយរបស់ព្រះអង្គ។ ឱព្រះម្ចាស់របស់ទូលបង្គំលោកអើយ សូមព្រះអង្គបំភ្លឺដួងចិត្តរបស់ពួកគេដោយពន្លឺនៃចំណេះដឹងរបស់ព្រះអង្គនិងសូមព្រះអង្គបញ្ចេញឱ្យមុខរបស់ពួកគេមានរស្មីដោយកាំរស្មីនៃតារាប្រចាំភពដែលបានបញ្ចេញពីនភាបាទនៃឆន្ទៈរបស់ព្រះអង្គ។ ព្រះអង្គគឺជាព្រះប្រកបដោយអំណាចធ្វើអ្វីៗបានតាមព្រះទ័យព្រះ អង្គ។ ក្រៅពីព្រះអង្គគ្មានព្រះឯណាទៀតឡើយ ព្រះអង្គគឺជាព្រះប្រកបដោយមនុញ្ញភាពគ្រប់យ៉ាង មនុស្សគ្រប់គ្នាអង្វរសុំជំនួយពីព្រះអង្គ។

ឱព្រះម្ចាស់របស់ទូលបង្គំលោកអើយ សូមព្រះអង្គជួយប្រដុងប្រជាពួកគេឱ្យបានទៅដល់ព្រះអង្គនិងបានលើកតម្កើងបន្ទូលរបស់ព្រះអង្គ។ នៅពេលនេះសូមព្រះអង្គអនុញ្ញាតឱ្យពួកគេបានក្លាយមនុស្សគ្រប់គ្នាអង្វរសុំជំនួយពីព្រះអង្គ។ ឱព្រះម្ចាស់របស់ទូលបង្គំលោកអើយ សូមព្រះអង្គ

ជួយប្រដុងប្រជាពួកគេឱ្យបានទៅដល់ព្រះអង្គនិងបានលើកតម្កើង បន្ទូលរបស់ព្រះអង្គ។ នៅពេលនេះសូមព្រះអង្គអនុញ្ញាតឱ្យពួកគេបានក្លាយជាព្រះហស្តនៃបុព្វហេតុសាសនារបស់ព្រះអង្គនៅក្នុងហ្វូងអ្នកបម្រើរបស់ព្រះអង្គហើយសូមព្រះអង្គធ្វើឱ្យពួកគេបានក្លាយជាអ្នកបញ្ចេញឱ្យឃើញពីសាសនារបស់ព្រះអង្គនិងជាអ្នកបញ្ចេញឱ្យឃើញពីសញ្ញារបស់ព្រះអង្គនៅក្នុងចំណោមមនុស្សជាតិធ្វើដូច្នោះដើម្បីឱ្យពិភពលោកទាំងមូលនឹងអាចត្រូវបានគេបំពេញដោយការចងចាំនិងការលើកតម្កើងរបស់ព្រះអង្គ ហើយនិងត្រូវបានគេបំពេញដោយភស្តុតាងនិងសក្ខីភាពរបស់ព្រះអង្គ។ ពិតណាស់ព្រះអង្គគឺជាព្រះប្រកបដោយបុណ្យគ្រប់យ៉ាងជាព្រះដ៏ខ្ពង់ខ្ពស់បំផុត ជាព្រះប្រកបដោយសព្វានុភាព ជាព្រះមានឫទ្ធីអំណាចនិងជាព្រះប្រកបដោយមេត្តាធម៌។

-ព្រះបាហាអ៊ុលឡាហ៍-

ព្រះអង្គគឺជាព្រះគួរឱ្យសរសើរណាស់ ឱព្រះម្ចាស់របស់ទូលបង្គំលោកអើយ! នៅពេលនេះទូលបង្គំយើងខ្ញុំទាំងអស់គ្នាបានប្រតិបត្តិតមអាហារតាមការបញ្ញត្តិរបស់ព្រះអង្គ

ហើយនិងស្រាយវានាពេលបន្តិចទៀតនេះតាមរយៈក្ដីស្រ
លាញ់របស់ព្រះអង្គនិងតាមរយៈមេត្តាធម៌របស់ព្រះអង្គ។
ឱព្រះម្ចាស់របស់ទូលបង្គំលោកអើយ សូមព្រះអង្គទទួល

យកទង្វើដែលទូលបង្គំយើងខ្ញុំទាំងអស់គ្នាបានប្រព្រឹត្តតាម

មាគ៌ារបស់ព្រះអង្គទាំងស្រុងដើម្បីសោភ័ណភាពរបស់ព្រះអង្គព្រះ
អង្គនិងនាំឱ្យពួកយើងបានចៀសផុតពីការទាក់ចិត្ត
ជិតអារម្មណ៍នឹងវត្ថុផ្សេងៗទាំងពួងលើកលែងតែព្រះអង្គ។
នៅពេលនេះសូមព្រះអង្គប្រទានការលើកលែងទោសរបស់

ព្រះអង្គឱ្យពួកយើង ឱ្យបុព្វបុរសរបស់ពួកយើង ហើយនិង
ឱ្យអ្នកទាំងអស់គ្នាដែលបានជឿចំពោះព្រះអង្គនិងជឿចំ
ពោះសញ្ញាដែលប្រកបដោយឫទ្ធិអំណាចរបស់ព្រះអង្គដែលមាន
នៅក្នុងការត្រាស់ដឹងដែលប្រកបដោយភាពអស្ចារ្យ
និងប្រកបដោយភាពរុងរឿងបំផុតនេះ។ ព្រះអង្គគឺជាព្រះ
ប្រកបដោយសក្តានុពលអាចធ្វើអ្វីៗបានតាមជម្រើសរបស់
ព្រះអង្គ។ ពិតណាស់ព្រះអង្គគឺជាព្រះប្រកបដោយភាពខ្ពង់ ខ្ពស់
ជាព្រះប្រកបដោយសព្វានុភាព និងមានព្រះទ័យទូលំ ទូលាយ។

-ព្រះបាហាអ៊ុលឡាហ៍-

* * * * *

ធម៌សូត្រសំរាប់ថ្ងៃបុណ្យអាយាំអ៊ីហា

(បុណ្យនៃថ្ងៃបង្គ្រប់ឆ្នាំ)

*បុណ្យអាយ៉ាំអ៊ីហាត្រូវបានគេប្រារព្ធធ្វើឡើងចាប់ពីថ្ងៃទី២៦ ខែកុម្ភៈដល់ថ្ងៃទី១មីនា ហើយបុណ្យនេះគេអាចហៅផ្សេងមួយទៀតថាជាថ្ងៃត្រៀមខ្លួនចូលទៅកាន់ថ្ងៃតមអាហារឬក៏ថាជាថ្ងៃសប្បុរសធម៌ក៏បាន។*

ឱព្រះម្ចាស់របស់ទូលបង្គំដែលជាភ្លើងនិងជាពន្លឺរបស់ទូលបង្គំលោកអើយ! ឱព្រះអង្គដែលជាស្តេចនៃគ្រប់នាមអើយ ថ្ងៃដែលព្រះអង្គបានឲ្យ ឈ្មោះថាអាយ៉ាំអ៊ីហានៅក្នុងគម្ពីររបស់ព្រះអង្គនោះបានចាប់ផ្តើមហើយ ហើយថ្ងៃតមអាហារដែលប៉ាកាដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះអង្គបានបង្គប់ឲ្យដល់មនុស្សគ្រប់គ្នាដែលនៅក្នុងរាជាណាចក្រនៃមាបន កម្មរបស់ព្រះអង្គធ្វើតាមនោះ ក៏ជិតមកដល់ហើយដែរ។ ឱព្រះម្ចាស់របស់ទូលបង្គំលោកអើយ នៅគ្រានេះអ្នកទាំងអស់គ្នាបានតោងទៅនឹងខ្សែព្ទរនៃបទបញ្ញត្តិរបស់ព្រះអង្គ ហើយព្រមទាំងបានប្រកាន់យកតាមឱវាទរបស់ព្រះអង្គ ដូចកាលពីគ្រាមុនអញ្ចឹងដែរ ទូលបង្គំសូមអង្វរព្រះអង្គ សូមទ្រង់អនុញ្ញាតឲ្យអ្នករាល់គ្នាបានស្ថិតនៅក្នុងមណ្ឌលនៃព្រះរាជវាំងរបស់ព្រះអង្គ ហើយនិងបានស្ថិតនៅក្នុង

មណ្ឌលនៃអាសនៈដែលជាទីកន្លែងបញ្ចេញឲ្យ
ឃើញពីភាពរុងរឿងដែលជាពន្លឺនៃភាពខ្ពង់ខ្ពស់របស់ព្រះអង្គផង។

ឱព្រះសមត្ថទិទេពរបស់ទូលបង្គំលោកអើយ
អ្នកទាំងនេះគឺជាអ្នកបម្រើរបស់ព្រះអង្គដែលគ្មាន
ចិត្តថោកទាបបញ្ឈប់ពួកគេមិនឲ្យទទួលបាននូវអ្វី
ដែលព្រះអង្គបានបញ្ជូនមកតាមគម្ពីររបស់ព្រះអង្គឡើយ
។ពួកគេខ្លួនឯងបានបន្ទាបខ្លួនឱនលំទោន
នៅចំពោះមុខបុព្វហេតុរបស់ព្រះអង្គ ហើយពួកគេ
ក៏បានទទួលគម្ពីររបស់ព្រះអង្គដែលមានការពន្យល់ពីព្រះអង្គ
ហើយពួកគេក៏បានប្រតិបត្តិតាម
នូវអ្វីដែលព្រះអង្គបានបញ្ញត្តិចំពោះពួកគេ ហើយ
ពួកគេក៏បានជ្រើសរើសធ្វើតាមអ្វីដែលត្រូវបានគេ
បញ្ជូនមកដោយព្រះអង្គ។

ឱសមត្ថទិទេពរបស់ទូលបង្គំលោកអើយ ព្រះ
អង្គបានទតឃើញហើយពីរបៀបដែលពួកគេបាន
ទទួលស្គាល់ហើយនិងបានទទួលកំហុសគ្រប់យ៉ាង

ដែលព្រះអង្គបានបញ្ចេញឲ្យឃើញតាមគម្ពីររបស់ព្រះអង្គ។
 ឱព្រះសមត្ថទិទេពរបស់ទូលបង្គំលោក
អើយ សូមព្រះអង្គប្រទានឲ្យពួកគេបានក្រេបទឹក
មនុញ្ញភាពដែលជាអនន្តភាពរបស់ព្រះអង្គពីព្រះ
ហស្តរបស់ព្រះអង្គផង។ នៅពេលនេះសូមព្រះអង្គ
ព្រះរាជចំណារឲ្យពួកគេនូវសំណាងដែលបាន
កំណត់ឲ្យម្នាក់ៗដែលបានត្រាំខ្លួនឯងនៅក្នុងមហា
សាគរនៃព្រះវត្តមានរបស់ព្រះអង្គ ហើយនិងបាន
ចូលដល់ទឹកអម្រឹតនៃការជួបជុំរបស់ព្រះអង្គផង។

ឱព្រះអង្គដែលជាស្ដេចនៃស្ដេចនិងជាអ្នក
មានក្ដីអាណិតដល់អ្នកដែលគេសង្កត់សង្កិនអើយ
ទូលបង្គំសូមអង្វរព្រះអង្គសូមទ្រង់កំណត់ឲ្យពួកគេ
នូវអំពើល្អដល់ពិភពនេះនិងពិភពបន្ទាប់ផង។ ម្យ៉ាង
វិញទៀតសូមព្រះអង្គព្រះរាជចំណារឲ្យពួកគេនូវអ្វី
ដែលគ្មានសត្វលោកណាមួយរបស់ព្រះអង្គធ្លាប់បានយល់ពីមុនមក
 ហើយនិងសូមព្រះអង្គដាក់
លេខរៀងពួកគេជាមួយនឹងអ្នកទាំងឡាយណា
ដែលបានឆ្វេលក្រឡឹងជុំវិញព្រះអង្គ ហើយនិងអ្នក

ទាំងឡាយណាដែលឆ្វែលជុំវិញរាជបល្ល័ង្ករបស់ព្រះអង្គគ្រប់ពិភព
នៃពិភពរបស់ព្រះអង្គ។

ពិតណាស់ព្រះអង្គគឺជាព្រះប្រកបដោយឫទ្ធានុភាព
ជាព្រះទ្រង់ញាណគ្រប់យ៉ាងនិងជាព្រះប្រ
កបដោយញាណយល់ជ្រាបគ្រប់យ៉ាង។

ព្រះបាហាអ៊ុលឡាហ៍

* * * * *

ធម៌សូត្រនាឱកាសបុណ្យចូលឆ្នាំថ្មី

*បុណ្យចូលឆ្នាំថ្មីតាមរបៀបសាសនាបាហៃ*
*ប្រារព្ធធ្វើឡើងនៅថ្ងៃទី២១ខែមិនាដែលជាថ្ងៃដំបូងនៃឆ្នាំបាហៃ*
*(បុណ្យចូលឆ្នាំបាហៃមានឈ្មោះថាណូរូស)។*

ឱព្រះសមត្ថទិទេពរបស់ទូលបង្គំលោកអើយ ព្រះអង្គជាព្រះគឺជាព្រះគួរឲ្យសរសើរខ្លាំងណាស់ ព្រះអង្គបានកំណត់ឲ្យមានការចូលឆ្នាំថ្មីដែលចាត់ទុកជាកម្មវិធីបុណ្យមួយដល់អ្នកទាំងឡាយដែលបានប្រតិបត្តិតាមច្បាប់បរិសុទ្ធអាហារ(ច្បាប់តមអាហារ)ដោយសារការស្រលាញ់ដល់ព្រះអង្គ ហើយពួកគេក៏បានជៀសវាងពីរបស់គ្រប់យ៉ាងដែលព្រះអង្គស្អប់ខ្ពើមផងដែរ។ ឱសមត្ថទិទេពម្ចាស់របស់

ទូលបង្គំលោកអើយ សូមព្រះអង្គអនុញ្ញាតឲ្យភ្លើងនៃក្តីស្រលាញ់និងកំដៅរបស់ព្រះអង្គដែលបានបង្កើតឡើងដោយច្បាប់បរិសុទ្ធអាហារដែលបានបញ្ញត្តិដោយព្រះអង្គនោះអាចដុតពួកគេនៅក្នុងបុព្វហេតុសាសនារបស់ព្រះអង្គ ហើយក៏សូមព្រះអង្គ

ញ៉ាំងឲ្យពួកគេបាននៅជាមួយនឹងភាពខ្ពង់ខ្ពស់
របស់ព្រះអង្គហើយនិងបានចងចាំដល់ព្រះអង្គផង។

ឱព្រះសមត្ថទិទេពរបស់ទូលបង្គំលោកអើយ
ព្រះអង្គបានតែងលំអពួកគេជាមួយនឹងសម្លៀកបំ
ពាក់នៃច្បាប់បរិសុទ្ធអាហារដែលបានបញ្ញត្តិដោយ
ព្រះអង្គតាមរយៈមនុញ្ញភាព ហើយនិងការអនុ
គ្រោះដែលប្រកបដោយព្រះទ័យសប្បុរសរបស់ព្រះ
អង្គរួចហើយ អ៊ីចឹងសូមព្រះអង្គតុបតែងកាយពួកគេ
ជាមួយនឹងសម្លៀកបំពាក់ដែលជាសម្លៀកបំពាក់នៃការអត់ធ្មត់
របស់ព្រះអង្គផង។ ព្រោះទង្វើរបស់
មនុស្សគ្រប់គ្នាសុទ្ធតែពឹងលើព្រះទ័យរីករាយរបស់
ព្រះអង្គហើយសុទ្ធតែត្រូវបានគេដាក់កំហិតដោយ
បន្ទូលបណ្តាំរបស់ព្រះអង្គទាំងអស់។ សូមព្រះអង្គ
ចាត់ទុកគាត់ម្នាក់នេះថាជាអ្នកដែលបានស្រាយបរិ
សុទ្ធអាហារ(ដល់ថ្ងៃកំណត់ឬឈប់តមអាហារ) ដូច
គ្នានឹងម្នាក់ទៀតដែលបានប្រតិបត្តិតាមការបរិសុទ្ធអាហារអ៊ីចឹងដែរ
ហើយសូមឲ្យបុរសម្នាក់នេះត្រូវ
បានគេរួមគ្នាជាមួយនឹងពួកគេទាំងអស់គ្នាដែល

កំពុងតែបានបន្តរក្សាការបរិសុទ្ធអាហារពីអនន្តភាពផង។
នរណាដែលបានប្រតិបត្តិការបរិសុទ្ធអាហារ
រហូតដល់ការស្រោយវានោះសូមព្រះអង្គកំណត់ឲ្យ
អ្នកនោះបាននៅតាមលំដាប់លេខរៀងជាមួយនឹងអ្នកដែលបានធ្វើ
ឲ្យសម្លៀកបំពាក់នៃការត្រាស់ដឹង
របស់ព្រះអង្គត្រូវបានប្រឡាក់ដោយធូលី ហើយត្រូវបានគេលាងជ
ម្រះយ៉ាងស្អាតដោយទឹកដ៏ថ្លាយង់ពីប្រភពទឹករស់អមតនេះផង។

"គេសរសើរព្រះអង្គគ្រប់គ្នាតាមរយៈព្រះរាជកិច្ចរបស់ព្រះអង្គ" ព្រះអង្គគឺជាទ្រង់ដែលត្រូវបានគេលើក " គេស្តាប់បង្គាប់ព្រះតាមរយៈព្រះរាជ បណ្តាំរបស់ព្រះអង្គ " ព្រះអង្គគឺជាខ្នាតគំរូដែលគេ
លាតត្រដាង។ ឱព្រះសមត្ថទិទេពរបស់ទូលបង្គំលោកអើយ សូមព្រះអង្គធ្វើឲ្យឋានៈរបស់ព្រះអង្គនេះត្រូវបានគេដឹងឮដល់អ្នកបម្រើរបស់ព្រះអង្គដើម្បីឲ្យពួកគេបានដឹងថាភាពប្រណីតដែលកើតមកពីវត្ថុគ្រប់យ៉ាងគឺអាស្រ័យលើបទបញ្ញត្តិរបស់ព្រះអង្គ និងបន្ទូលរបស់ព្រះអង្គហើយគុណធម៌ ដែលកើតមកពីគ្រប់អំពើនោះគឺត្រូវបានគេដាក់កំហិតដោយការអនុញ្ញាត្តិរបស់ព្រះអង្គនិងដោយការពេញព្រះទ័យពី

ឆន្ទៈរបស់ព្រះអង្គ ហើយនិងដើម្បីឲ្យគេបានទទួលស្គាល់ថាគ្រប់ខ្សែបង្ហៀរនៃទង្វើ
របស់មនុស្សគឺស្ថិតនៅក្នុងអំណាចនៃការយល់ព្រមរបស់ព្រះអង្គ និងបទបញ្ញត្តិរបស់ព្រះអង្គ។ សូមព្រះ
អង្គធ្វើឲ្យឋានៈរបស់ព្រះអង្គនេះត្រូវបានគេដឹងឮ
ដល់អ្នកបម្រើរបស់ព្រះអង្គថារបស់គ្រប់យ៉ាងគ្មាន
របស់ណាមួយអាចបិទបាំងពីសោភ័ណភាពរបស់ព្រះ
អង្គបានឡើយ ហើយនៅក្នុងសម័យនេះ នា កាល
មួយនោះព្រះយេស៊ូវបានឧទានថា ″ឱព្រះអង្គ ដែល
ជាអ្នកបង្កើតចិត្តវិញ្ញាណអើយ(ព្រះយេស៊ូវ)អំ
ណាចគ្រប់យ៉ាងគឺជារបស់ព្រះអង្គ" ហើយព្រះ
មហាម៉ាត់បានស្រែកទ្រហោថាៈ "ឱព្រះអង្គដែលជាទីស្រឡាញ់បំផុតអើយ ព្រះអង្គគឺជាព្រះប្រកប ដោយ
ភាពខ្ពង់ខ្ពស់ព្រោះព្រះអង្គបានបង្ហាញសោ
ភ័ណភាពរបស់ព្រះអង្គឲ្យគេឃើញហើយព្រះអង្គក៏បានរាជនិពន្ធឲ្យអ្នកដែលជាជម្រើសរបស់ព្រះអង្គនូវអ្វីដែលនឹងនាំឲ្យពួកគេបានទៅដល់អាសនៈនៃការបង្ហាញឲ្យឃើញពីព្រះនាមដ៏អស្ចារ្យបំផុតរបស់ព្រះអង្គ ហើយព្រះនាមដ៏អស្ចារ្យបំផុតនោះ មនុស្ស
គ្រប់គ្នាសោកស្តាយខ្លាំងណាស់លើកលែងតែអ្នក
ដែលបានលះបង់ខ្លួនគេពីវត្ថុគ្រប់យ៉ាងក្រៅពីព្រះអង្គ

ហើយនិងលើកលែងតែអ្នកដែលបានភ្ជាប់ខ្លួន
ពួកគេឆ្ពោះទៅរកទ្រង់ដែលជាអ្នកបង្ហាញពីព្រះអង្គផ្ទាល់
ហើយនិងពីព្រះសាស្តាដែលជាកេតណាភ័ណរបស់ព្រះអង្គ″។

ឱព្រះសមត្ថទិទេពរបស់ទូលបង្គំលោកអើយ
ទ្រង់ដែលជាមេកដ៏សំខាន់របស់ព្រះអង្គហើយអ្នក
ទាំងអស់គ្នាដែលជាបរិស័ទរបស់ព្រះអង្គនោះ នៅ
ពេលនេះពួកគេបានស្រាយការបរិសុទ្ធអាហារ
របស់ពួកគេនៅថ្ងៃនេះហើយ ដោយក្រោយពីពួកគេ
បានប្រតិបត្តិតាមការបរិសុទ្ធអាហារ ដែលនៅក្នុង
មណ្ឌលនៃព្រះរាជវាំងរបស់ព្រះអង្គ ហើយនិងដោយ
ចំណង់របស់ពួកគេដើម្បីបំពេញព្រះទ័យរបស់ព្រះអង្គរួចមក។
សូមព្រះអង្គកំណត់ឲ្យទ្រង់
ហើយនិងឲ្យពួកគេនិងអ្នកទាំងអស់គ្នាដែលបាន
ចូលគាល់ព្រះវត្តមានរបស់ព្រះអង្គនៅក្នុងគ្រានេះ
សូមឲ្យពួកគេបានទទួលនូវសម្បត្តិសុខសម្បត្តិសួគ៌
ដែលព្រះអង្គបានទំនុកបំរុងនៅក្នុងគម្ពីររបស់ព្រះអង្គផង។
នៅគ្រានេះសូមព្រះអង្គប្រទានឲ្យពួកគេ

នូវអ្វីដែលនឹងជាប្រយោជន៍ដល់ពួកគេទាំងនៅជាតិ
នេះនិងទៅបរលោកផង។

ពិតណាស់ព្រះអង្គគឺជាព្រះប្រកបដោយ

ញាណដឹងគ្រប់យ៉ាងនិងជាព្រះប្រកបដោយគតិបណ្ឌិតគ្រប់យ៉ាង។

ព្រះបាហាអ៊ុលឡាហ៍

-

ធ

ធ

x

កថាខណ្ឌរបស់អាម៉ាត់

*kfaxNÐenHRtUv)anTTYlsÁal;edayRBH)ahaG‘ul*

*Lah_EdlRbkbeTAedaykMlaMgnigKtieBcn_Biess .*

RBHGgÁKWCaesþcelIGs;mnusSTaMgBYg

RBHGgÁKWCaRBH RTg;jaN

RBHGgÁKWCaRBHRbkbedaybBaØajaN¡

emIln+¡RBHGgÁKWCabkSazansYK´Edl)anERskeRcog

sMenogd¾BieraHenAelIEmkeQIénGnnþPaBEdlRbkb

edaybTd¾Bisidæ ehIynigBieraHrNþMEdl)anRbkasnUv

dMNwgrIkraydl;GñkEdlesµaHs[)anenACit RBHCa m©as;

RBmTaMg)anGMBavnavdl;GñkCMenOEdlenAkñúg

samKÁIPaBrbs;RBHGaTieTB [cUleTAkan;RBHbrm

raCvaMgedIm,IbgÁMKal;dl;RBHCam©as; EdlRbkbeday

RBHT½ysb,úrsFm´ehIyRBmTaMg)anR)ab;dl;GñkTaMg Lay

EdlekøóvkøanUvsarEdl)anRtas;beBa©jeday

RBHGaTieTBCam©as; EdlCaesþcénEpndInigzansYK´

EdlCaRBHRbkbedayRBHT½ysb,úrsFm´ EdlCaRBH

KµanKUeRbob

RBHGgÁKWCaGñknaMpøÚvdl;GñkEdlmankþIRs

laj;eTAkan;Gasn³énsnþPaB ehIynigeTAkan;esa P½NPaBd¾RtcHRtcg;pgEdr .

BitR)akdNas; enHKWCaesaP½NPaBd¾Gs©arü bMputEdl)anTayTukCamunenAkñúgtRma¬Km<Ir¦ rbs; GñknaMsartamry³esaP½NPaBd¾Gs©arüenH sc©Fm´ nwgRtUv)aneKeFVI[dwgBIkMhusTaMgGs;cMENÉKtibNÐit EdlekItecjmkBIRKb;bBaØtþienaH k¾nwgRtUv)aneKeFVI BiesaFnkmµeLIgpgEdr . BitNas; RBHGgÁKWCaedIm eQIénCIvitEdlCaGñknaMmknUvEpøpáarbs;RBHGaTieTBCam ©as;EdlCaRBHKYr[sresIr EdlCaRBHRbkbeday sBVanuPaB ehIyk¾CaRBHd¾Gs©arübMputpgEdr .

»Gam:at;eGIy¡ cUrGñkeFVICasakSIeLIgfaRBHGgÁ KWBitCaRBHm©as; ehIyeRkABIRBHGgÁk¾KµanRBHCam©as; dé TNaeToteLIy RBHGgÁenHehIyk¾CaesþcénEpndI nigzansYK´KWCaGñkkarBar KWCaGñkKµanKUeRbobehIyk¾ CaGñkEdlRbkbedaysBVanuPaBpgEdr . cMENkÉ

RBHGgÁEdlCaRBHCam©as; RTg;)anbBa¢Únmkedayman RBHnamfaGall¬RBHbb¦enaH KWCaRBHsasþamYyGgÁ BitEdlecjmkBIRBHGaTieTBCam©as; EdlRKb;bBaØtþi rbs;RBHGgÁeyIgTaMgGs;KñaRtUvEtRbtibtþitam .

cUrniyaysresIreLIg³»mnusSEdlCaGñksþab; »vaTbBaØtþirbs;RBHGaTieTBCam©as;eGIy cUrniyaynUv GVIEdleK)andak;bBa¢aenAkñúgKm<IrEdlmaneQµaHfa**{)a y:an;}** edayRBHEdlRbkbedayPaBrugerOg ehIynig edayKtibNÐiteLIg . BitNas;RBHGgÁKWCaesþcrbs; GñknaMsar cMENkÉKm<Irrbs;RTg;KWCaKm<Ird¾sMxan;Edl GñkRtUvdwgehIynigeFVItam .

bkSazansYK´)anbnøWsUrsMenogGMBavnavrbs;RTg; [dl;GñkBIBn§naKarenHehIycUrGñkeFVItamRTg;eLIg. RBHGgÁ)anGMBavnavenH KWedIm,IEføgbBa¢ak;sarenH[ )anc,as; . GIucwgnrNaEdlR)afñacg;)anenaH cUrjaMug [Kat;gakeTArk»vaTenH ehIynrNaEdlR)afñacg; )anenaH cUrjaMug[Kat;eRCIserIsmaK´aeTAkan;RBHCa

m©as;rbs;Kat;cuH .

»mnusSRKb;Catisasn_eGIy ebIGñkRcanecal minsþab;nUvkMNaBüTaMgenH etIPsþútagkEnøgNaEdl faGñkeCOcMeBaHRBHCam©as;enaH? »RkumCMnMuGñkEdl mankMhuseGIy cUrGñkbgð¶ajvamkemIl .

ebIeyageTAtamRBHGaTieTBCam©as;EdlRBHhsß rbs;RTg;CaviBaØaNrbs;GgÁGjenaHfa BYkeKminGac bgð¶ajPsþútagenH)aneLIy ehIyk¾minGaceFVIdUecñaH )anEdr ebIeTaHbICaBYkeKTaMgGs;rYmKñaedIm,Ibgð¶ajBI Psþútagena Hk¾eday .

»Gam:at;eGIy¡ cUrkMubMePøcnUvsb,úrsFm´rbs;

GgÁGjenAeBlNaGgÁGjGvtþmanBImuxGñk . cUrcg

caMsm½ykalrbs;GgÁGj enAkñúgsm½ykalrbs;Gñk ehIycUrGñkcgcaMesckþITukçRBYy ehIynigkarbMbrbg;

rbs;GgÁGj enAkñúgBn§naKard¾Esndac;RsyalenH pg . ehIycUrGñknwgFwgenAkñúgesckþIRslaj;rbs; GgÁGjeLIgedIm,IkMu[ebHdUgrbs;Gñkrn§t;jab;j½r ebI eTaHbICadavrbs;sRtUvvaysRmukmkrkGñk ehIyebI eTaHbICaRKb;zansYK´ ehIynigEpndIegIbeLIgRbqaMg nwgGñkk¾eday .

cUrGñkeFVICaGNþatePøIgedIm,IbMPøWdl;sRtUvrbs;Gg ÁGj[)anPøWpg ehIycUrGñkeFVICasÞwgEdlmanCIvit CaGnnþdl;GñkEdlCaTIRslaj;rbs;GgÁGjedIm,I[

GñkTaMgenaHGs;cm¶l; . ehIyebIenAeBlNaGñkCYb RbTHnUvesckþIQWcab;enAkñúgmaK´arbs;GgÁGj b¤k¾CYb RbTHnUvesckþIefakTabedIm,ICaRbeyaCn_rbs;GgÁGj cUrGñkkMuGn;citþnwgkarQWcab;b¤PaBefakTabenaH eLIy .

cUrGñkTukcitþcMeBaHRBHCam©as;EdlCaRBHrbs;Gñk ehIyk¾CaRBHGaTieTB CaRBHvraCbitarbs;GñkcuH . eRBaH\LÚvenHmnusSmñakMBugEtrevIrvayenAkñúgmaK´aénk arPan;RcLM kMBugEtrevIrvaykñúgmaKa´énkar)at;bg;

ElgemIleXIjRBHedayEPñkpÞal;rbs;BYkeK ehIyk¾ Elgsþab;B¤bTcMerogrbs;RTg;edayRtecokpÞal;rbs; BYkeKehIy . dUecñHmanEteyIg¬RBHsasþa¦eTEdl yl;dl;BYkeK GIucwgcUrGñkeFVICasakSIpg .

BitNas;CMenOeqVgrbs;BYkeKKWCaés,]bsKÁEdl

)aMgBYkeKehIynigebHdUgrbs;BYkeKRBmTaMgraraMgBYk

eKmin[edIrcUlkñúgmaK´aRBHCam©as; EdlCaRBHKYr[ sresIr ehIynigCaRBHd¾Gs©arüeTotpg .

BitNas; cUrGñkR)akdenAkñúgcitþrbs;Gñkfaebl nrNagakecjBIesaP½NPaBenHenaHmann½yfaKat;k¾ )angakecjBIGñknaMsarBIGtItkalehIyEdr ehIy Kat;enaHk¾kMBugEtbgðajnUvPaBRkGWtRkTm GYtGagcM eBaHRBHPRkþrbs;RBHCam©as;EdlCaRBHelcecjmkBIRKb;G nnþPaBmYyeTAkan;GnnþPaBmYyeTotpgEdr .

»Gam:at;eGIy¡ cUrGñkeronkfaxNÐenH[)anl¥. rYcehIycUrGñksµÚtvanasm½ykalrbs;Gñk ehIycUr GñkkMudkxøÜnrbs;GñkecjBIkfaxNÐenaH[esaH.eRBaH vaCaerOgBit RBHCam©as;)ankMNt;[GñkCaGñksµÚtva CargVan;rbs;GñkTukárbuKÁlrab;ryGñkehIyk¾CakarbMerI mYydl;PBTaMgBIrpgEdr . PaBGnueRKaHEdleyIg ¬RBHsasþa¦)anRbTan[dl;GñkenH KWCaPaBsm,ÚN´ EdlsßitenAelImaK´arbs;eyIg¬RBHsasþa¦ ehIyk¾Ca emtþaFm´EdlecjmkBIvtþmanrbs;eyIg ¬RBHsasþa¦ edIm,I[GñkGackøayCamnusSmñak;kñúgcMeNamGñkEdleKsE mþgnUvktBaØÚtaFm´pgEdr .

tamry³RBHCam©as;¡ ebInrNamñak;manesckþI TukçevTnab¤k¾manesckþIesakseRggenaH cUrGankfa xNÐenHedayesckþIesµaHbMputenaH RBHCam©as;R)akd CanwgkMcat;ecalnUvesckþIesakseRggrbs;Kat; edaH RsaynUvesckþIvibtþirbs;Kat; ehIyRBmTaMgkMcat;

ecalnUvTukçevTnarbs;Kat;[RCHRsLHBIxøÜnrbs;Kat;
)anCaminxaneLIy .

BitNas; RBHGgÁKWCaRBHEdlRbkbedayemtþa Fm´ ehIyk¾CaRBHRbkbedaykþIGaNitGasUrdl;eyIg pgEdr . cUrelIktemáIgdl;RBHCam©as;EdlCaRBHGaTi eTBdl;RKb;BiPBcuH .

-RBH)ahaG`ulLah_-

* * * * *

កថាខណ្ឌសំរាប់ការចូលគាល់ព្រះបាហាអ៊ុលឡាហ៍

សេចក្តីសរសើរដែលបានរះចេញឡើងពីព្រះកាយដ៏អស្ចារ្យរបស់ព្រះ ហើយនិងភាពរុងរឿងដែលបានកើតឡើងពីសោភ័ណភាពដ៏ត្រចះត្រចង់របស់ទ្រង់ ដែលជាអ្នកត្រាស់ដឹងនូវភាពខ្ពង់ខ្ពស់ ហើយនិងជាម្ចាស់នៃអនន្តភាពនិងជាព្រះអាទិទេពរបស់អ្នកដែលនៅឋានសួគ៌ និងនៅលើលោកិយនេះ។

ទូលបង្គំសូមធ្វើជាសក្ខីភាពថា តាមរយៈព្រះសាស្តារបស់ព្រះអធិបតេយ្យភាពរបស់ព្រះ ហើយ និងវិជិតរាជ្យរបស់ទ្រង់ ភាពខ្ពង់ខ្ពស់របស់ទ្រង់ ព្រមទាំងភាពរុងរឿងរបស់ព្រះអង្គគឺត្រូវបានបញ្ចេញឱ្យឃើញហើយ តារាពេលថ្ងៃពីបុរុមបុរាណបានបង្ហូរភាពដ៏ត្រចះត្រចង់នៃព្រះបន្ទូលរបស់ព្រះ ដែលមិនអាចផ្លាស់ប្តូរបាន ហើយនិងកេតណាភ័ណ្ឌារបស់ព្រះដែលបានបញ្ចេញឱ្យឃើញនូវគ្រប់ការបង្កើតរបស់ទ្រង់។

ទូលបង្គំសូមធ្វើជាសាក្សីផងដែរថា តាមរយៈការត្រាស់ដឹងរបស់ព្រះដែលមានព្រះបន្ទូលថា អ្វីៗនឹងកើតឡើងហើយត្រូវបានគេប្រតិបត្តិ ព្រមទាំងអាថ៌កំបាំងរបស់ព្រះដែលបានលាក់ទុកត្រូវបានគេបញ្ចេញឱ្យ ដឹងហើយនិងគ្រប់ការបង្កើតទាំងឡាយត្រូវបានគេបញ្ចេញ ឱ្យឃើញព្រមទាំងការត្រាស់ដឹងទាំងអស់របស់ព្រះដែលបានបញ្ជូនមកទៀតផង។

ទូលបង្គំសូមធ្វើជាសក្ខីភាពថាតាមរយៈកេតណាភ័ណ្ឌរបស់ព្រះសាស្តារបស់ព្រះ យើងបានឃើញកេតណាភ័ណ្ឌរបស់ព្រះដ៏ជាទីស្រឡាញ់របស់យើង ហើយនិងតាមរយៈព្រះភ័ក្ររបស់ព្រះសាស្តា យើងបានឃើញព្រះភ័ក្ររបស់ព្រះ ដែលជាសេចក្តីប្រាថ្នារបស់យើងនិងតាមរយៈព្រះបន្ទូលរបស់ព្រះសាស្តា ព្រះអង្គបានបែងចែកនូវការបង្កើតរបស់ទ្រង់ចំពោះអ្នកដែលមានការជឿជាក់ចំពោះព្រះនឹងបានឡើងទៅដល់ឋានសួគ៌នៃភាពរុងរឿងទិព្វហើយចំពោះអ្នកដែលមិនទទួលស្គាល់ទ្រង់នឹងធ្លាក់ចូលទៅកាន់ទីរហោដ្ឋាន។

ទូលបង្គំសូមធ្វើជាសាក្សីថាចំពោះនរណាដែលទទួលស្គាល់ព្រះសាស្តានោះមានន័យថា គាត់ក៏ទទួលស្គាល់ព្រះជាម្ចាស់ដែរ នរណាដែលបានគោរពតាមព្រះសាស្តានោះមានន័យថាគាត់ក៏គោរពតាមព្រះដែរ។ ដូច្នេះសព្វសាធុការពរដ៏អស្ចារ្យរបស់ព្រះនឹងកើតមានដល់នរណាដែលជឿជាក់ចំពោះទ្រង់ ហើយជាមួយនឹងសញ្ញាណរបស់ ទ្រង់ ហើយនរណាដែលបានលំអោនកាយរបស់គាត់ចំពោះ ព្រះ ហើយនិងអ្នកដែលត្រូវបានគេផ្តល់កិត្តិយសឱ្យដោយសារកពជួបជាមួយព្រះអង្គនិងអ្នកដែលបានប្រតិបត្តិតាមឆន្ទៈរបស់ព្រះ និងអ្នកដែលបានឆ្វៃលក្រឡឹង ជុំវិញទ្រង់ ហើយនិងនរណាដែលបានឈរនៅចំពោះព្រះរាជបល្ល័ង្គរបស់ព្រះ។

ចំពោះអ្នកទាំងឡាយណាដែលប្រឆាំង, បដិសេធន៍, បំផ្លិចបំផ្លាញកិត្តិនាមរបស់ព្រះ និងអ្នកទាំងឡាយណាដែលនិយាយអាក្រក់អំពីអធិបតេយ្យភាពរបស់ទ្រង់ អ្នកទាំងឡាយនោះនឹងទទួលនូវការវិនាសហិនហោចដោយខ្លួនឯង

។ ចំពោះនរណាដែលក្រោកឡើងប្រឆាំងនឹងទ្រង់ ហើយបង្ហាញនូវភាពអំនួតអួតអាងចំពោះព្រះភ័ក្រព្រះជា ម្ចាស់ ហើយនិងចំពោះនរណាដែលជំទាស់នឹងព្រះរាជបន្ទូល របស់ព្រះអង្គ ចំពោះអ្នកដែលឃ្លាតឆ្ងាយពីច្បាប់ហើយនិង វិជិតរាជ្យរបស់ទ្រង់ ហើយនិងអ្នកដែលត្រូវបានគេចាត់ទុក ថាជាអ្នកគ្មានជំនឿចំពោះព្រះហើយឈ្មោះរបស់គេ ត្រូវបានកត់ត្រាចូលទៅក្នុងផែនចារឹកសក្តិសិទ្ធិរបស់ព្រះ។

ឱព្រះនៃទូលព្រះបង្គំអើយ! តាមរយៈសេចក្តីមេត្តាធម៌របស់ព្រះអង្គ ហើយនិងសប្បុរសធម៌នៃសេចក្តីស្រឡាញ់របស់ទ្រង់ សូមព្រះអង្គមេត្តាប្រទាននូវដង្ហើមនៃសេចក្តីអនុគ្រោះរបស់ទ្រង់ដើម្បីឱ្យទូលបង្គំឃ្លាតឆ្ងាយពីវត្ថុលោកិយនេះ ហើយសូមព្រះអង្គនាំទូលព្រះបង្គំទៅកាន់ព្រះរាជាណាចក្ររបស់ព្រះអង្គផង។ ព្រះអង្គពោរពេញទៅដោយពលានុភាពក្នុងការធ្វើអ្វីៗគ្រប់បែបយ៉ាង។ពិតណាស់ ព្រះអង្គគឺជាអ្នកដែលខ្ពង់ខ្ពស់អស់លើវត្ថុទាំងពួង។ការរំឭកដល់ព្រះហើយនិងសេចក្តីសរសើរដល់ទ្រង់ព្រមទាំង ភាពរុងរឿងរបស់ព្រះ និងភាពត្រចះត្រចង់របស់

ទ្រង់ត្រូវបានគេផ្តល់ឱ្យតាមរយៈព្រះសាស្តាដែលជាសោ
ភ័ណភាពរបស់ព្រះអង្គ។

ទូលព្រះបង្គំសូមធ្វើជាសក្ខីភាពថាមនុស្សលោកទាំង
អស់មិនដែលសំលឹងមើលទៅព្រះអង្គ ដែលពួកមនុស្សមួយ
ចំនួនគិតថាទ្រង់ជាអ្នកខុសនោះទេ។ ក្នុងមួយជីវិតរបស់ ព្រះអង្គ
ទ្រង់ទទួលយកនូវសេចក្តីរងទុក្ខវេទនាគ្រប់បែប យ៉ាង។
នៅពេលមួយទ្រង់ត្រូវបានគេដាក់នឹងច្រវ៉ាក់ ហើយ
និងហាមឃាត់ទ្រង់គ្រប់បែបយ៉ាង ពេលមួយទៀតនោះ
ព្រះអង្គត្រូវគេគំរាមកំហែងដោយព្រះខណ្ឌាពីអ្នកដែលប្រ
ឆាំងនឹងទ្រង់។ ទោះបីជាស្ថិតនៅក្នុងស្ថានភាពបែបនេះក៏
ដោយក៏ទ្រង់នៅតែបន្តការបង្ហាត់បង្រៀនទៅមនុស្សលោក
ដើម្បីឱ្យគេប្រតិបត្តិតាមនូវអ្វីដែលត្រូវបានគេចារឹកនៅក្នុង
គម្ពីររបស់ទ្រង់ ដែលជាព្រះទ្រង់ញាណនូវអ្វីៗគ្រប់បែប
យ៉ាងនិងប្រសើរអស់លើវត្ថុទាំងពួង។

សូមព្រះធ្វើឱ្យព្រលឹងវិញ្ញាណរបស់ទូលព្រះបង្គំក្លាយជាការ
លះបង់ដើម្បីជំនួសនូវសេចក្តីរងទុក្ខវេទនា របស់ព្រះអង្គ

និងសូមឱ្យស្មារតីរបស់ទូលបង្គំបានតបស្នងនូវសេចក្តីរងទុក្ខវេទនារបស់ព្រះអង្គផង។ ទូលបង្គំសូមអង្វរករចំពោះព្រះតាមរយៈព្រះសាស្តា ហើយនិងសាវក ទាំងអស់ដែលបានទទួលភាពរុងរឿងរបស់ព្រះ ហើយនិងនរណាដែលមានសេចក្តីស្រឡាញ់ចំពោះទ្រង់ ដែលពួកគាត់បានប្រតិបត្តិតាមបន្ទូលរបស់ព្រះអង្គ សូមព្រះជាម្ចាស់មេត្តាពាំងនូវឧបសគ្គទាំងឡាយដែលក្លាយជា

រនាំងនៃការជឿជាក់របស់ទូលបង្គំចំពោះព្រះអង្គផង។

សូមព្រះប្រទានដល់ទូលព្រះបង្គំនូវអ្វីៗដែលល្អប្រសើរទាំងក្នុងលោកនេះនិងទៅបរលោក។ ពិតប្រាកដ ណាស់ ព្រះអង្គប្រកបដោយពលានុភាព ហើយនិងខ្ពង់ខ្ពស់អស់លើវត្ថុទាំងពួង ទ្រង់ពោរពេញដោយភាពរុងរឿង និងសេចក្តីអនុគ្រោះព្រះអង្គពោរពេញដោយព្រះទ័យមេត្តាករុណា។

ឱព្រះអាទិទេពនៃទូលបង្គំអើយ សូមទ្រង់បង្ហូរសព្ទសាធុការពរ ចំពោះស្លឹកឈើនៃដើមឈើរបស់ព្រះអាទិទេព

ហើយនិងមែកធំនិងមែកតូចរបស់ព្រះអាទិទេព ហើយនិងដើមឈើព្រមទាំងពូជនៃដើមឈើរបស់ព្រះអាទិទេព សូមព្រះអង្គជួយដល់ពួកគេឱ្យគេប្រតិបត្តិតាមបន្ទូលរបស់ទ្រង់ផង។ សូមការពារពួកគេឱ្យពួកគេឃ្លាតឆ្ងាយពីការបង្កជម្លោះនៃភាពឈ្លានពាននិងភាពជាទាសករ។ ពិតណាស់ព្រះអង្គប្រកបដោយឫទ្ធានុភាព និងពោរពេញដោយពលា នុភាព។

ឱព្រះនៃទូលបង្គំអើយ សូមឱ្យសព្ទសាធុការពរមានដល់អ្នកបម្រើទាំងស្រីទាំងប្រុសរបស់ព្រះអង្គ ដែលបានគោរពតាមធម្មវិន័យរបស់ទ្រង់។ ពិតណាស់ព្រះអង្គទ្រង់ពោរពេញទៅដោយសព្ទសាធុការពរ និងពរជ័យរបស់ព្រះអង្គមានជាអនន្ត។ ពុំមានព្រះដទៃណាទៀតឡើយក្រៅពីព្រះអង្គ ព្រះអង្គទ្រង់ករុណា ព្រះអង្គទ្រង់សប្បុរសធម៌។ -ព្រះបាហាអ៊ុលឡាហ៍-

* * * * *